កួច សឿង

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

# បាត់ដំបង សម័យលោកម្ចាស់





បោះពុម្ពផ្សាយក្រោមការឧបត្ថម្ភនៃ
មជ្ឈមណ្ឌលបូព៌ា-បស្ចិម ក្រុងហូណូលូលូ រដ្ឋហាវ៉ៃ

www.budinst.gov.kh www.elibraryofcambodia.org

**ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh**    **www.elibraryofcambodia.org**

www.budinst.gov.kh    www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# ព្រះគម្ពីរ

## សម័យលោកម្ចាស់

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

គួច ឈួន

# ច្បាប់ជំនុំ

## សម័យលោកម្ចាស់

មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
១៩៩៤

www.budinst.gov.kh www.elibraryofcambodia.org

TAUCH CHHUONG

# BATTAMBANG

## DURING THE TME OF THE LORD GOVERNOR

Publications funded by
EAST-WEST CENTER
Honolulu : Hawaii (U.S.A)

www.budinst.gov.kh www.elibraryofcambodia.org

៥១៣.៨

តូច ឈួង

# បាត់ដំបង

## សម័យលោកម្ចាស់

បោះពុម្ពផ្សាយក្រោមការឧបត្ថម្ភនៃ
*EAST-WEST CENTER*
*HONOLULU HAWAII*

ពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ LIBRARY BUDDHIST INSTITUTE
៣២១៣/៩៧

មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
១៩៩៤

www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា

សៀវភៅ "**បាត់ដំបងសម័យលោកម្ចាស់**" ត្រូវបានបោះពុម្ពផ្សាយកាលពីឆ្នាំ ១៩៧៤ ជាការសាកល្បងក្នុងការស្រាវជ្រាវដើម្បីឲ្យខេត្តបាត់ដំបង ទឹកដីកំណើតរបស់ខ្ញុំ មានប្រវត្តិសាស្ត្រមួយសំរាប់យុវជនជំនាន់ក្រោយ ដូចភូមិភាគដទៃខ្លះនៃប្រទេសចំរើនលូតលាស់ ។

គោលបំណងនៃការបោះពុម្ពផ្សាយលើកទី ១ គឺម្យ៉ាងដើម្បីស្តាប់មតិអ្នកអានខ្មែរ អំពីប្រវត្តិសាស្ត្ររបស់ខ្លួន ម្យ៉ាងទៀតដើម្បីបំផុសគំនិតស្រាវជ្រាវ កត់ត្រាចងចាំឯកសារគ្រប់បែបយ៉ាងទាក់ទិនដល់ទឹកដីរបស់ខ្លួន ។ ហេតុនេះហើយបានជាខ្ញុំផ្សព្វផ្សាយភាគច្រើនបំផុតតែអ្វីដែលលោកតាលោកយាយ ចាស់ៗបានផ្តល់ពីអ្វីដែលគាត់បានដឹងនិងបានឮតៗមក ។ ខ្ញុំបានគ្រោងទុកមួយអន្លើ នូវឯកសារសសេររបស់អ្នកប្រាជ្ញ ភាគច្រើនជាបរទេស រង់ចាំពេលណាការស្រាវជ្រាវក្នុងស្រុកបានចប់សព្វគ្រប់ ទើបបញ្ចូលគ្នាបោះពុម្ពម្តងទៀត ជាកិច្ចបញ្ចប់ ។

ក្រោយពេលបោះពុម្ពលើកទី ១ អ្នកអានគ្រប់មជ្ឈដ្ឋាន ជាពិសេស

www.budinst.gov.kh www.elibraryofcambodia.org

"**សមាគម អ្នកនិពន្ធខ្មែរ** "បានផ្ញើសំបុត្រមកសរសើរ លើកទឹកចិត្ត និងផ្តល់ពត៌មានបន្ថែម ។ ខ្ញុំសូមថ្លែងអំណរ គុណអស់លោក ទាំងអស់ ដែលបានឧបត្ថម្ភគាំទ្រការនិពន្ធ សៀវភៅ "**បាត់ដំបងសម័យលោកម្ចាស់** "នេះដោយពេញចិត្តពេញថ្លើម ។

មកទល់ពេលនេះ អ្វីៗត្រូវបាត់បង់អស់ហើយ ក៏ប៉ុន្តែដោយ ឥតបានស្មានទុក នៅចុងទសវត្សទី៨០កន្លងទៅនេះ ខ្ញុំបានទទួល ដំណឹងតាមសំបុត្រថា មានអ្នកយកចិត្តទុកដាក់ច្រើនពីសៀវភៅ របស់ខ្ញុំនៅសហរដ្ឋអាមេរិក និងនៅប្រទេសបារាំង ។ ខ្ញុំមិនបាន ស្មានសោះថាសៀវភៅរបស់ខ្ញុំបានឆ្លងទ្វីប ឆ្លងសមុទ្រ ទៅដល់ទី នោះ ។

នៅសហរដ្ឋអាមេរិក លោក ហ៊ុន ស៊ីថាន និងបណ្ឌិត ការ៉ុល ម៉រឡិន ដោយមានការគាំទ្រពីបណ្ឌិត ជូឌី ឡេដជ័រវូដ និង អស់លោកដទៃទៀតបានបកប្រែ និង រចនាគាក់តែងសៀវភៅ **បាត់ដំបងសម័យលោកម្ចាស់** "ជាភាសាអង់គ្លេស ។

នៅប្រទេសបារាំង លោក ឡូច ឆានឆាយ បានសុំដកស្រង់ គំនិតក្នុងសៀវភៅ "**បាត់ដំបងសម័យលោកម្ចាស់** "ធ្វើនិក្ខេបបទ ប្រឡងអនុបណ្ឌិតខាងអក្សរសាស្ត្រ ។

នៅពេលនេះទៀត ដោយការលើកទឹកចិត្តនិងឧបត្ថម្ភពី

www.budinst.gov.kh www.elibraryofcambodia.org

បណ្ឌិតជូឌី ឡេដជ័រវូដ ខ្ញុំសំរេចចិត្តរៀបចំសៀវភៅនេះជាថ្មីដើម្បីបោះពុម្ពជាលើកទី ២ ទុកជាមរតកដល់អ្នកសិក្សាបច្ចុប្បន្ន និងអនាគត ទោះបីខ្ញុំយល់ថា ដើម្បីឲ្យបានសព្វគ្រប់ពេញលេញ ខ្ញុំត្រូវការពេលវេលា សម្ភារៈ និងការប្រឹងប្រែងច្រើនណាស់ ពីព្រោះខ្ញុំត្រូវបានគេបង្ខំឲ្យបោះបង់ការងារនេះ អស់ពេល២១សវត្សទៅហើយ ។

ដោយមានការឧបត្ថម្ភដ៏សប្បុរសខាងមូលនិធិពីមជ្ឈមណ្ឌលបូព៌ា បស្ចិម ក្រុងហូណូលូលូ រដ្ឋហាវ៉ៃ ការបោះពុម្ពលើ ទី ២ នេះ និងធ្វើជាពីរភាសា គឺខ្មែរនិងអង់គ្លេស ដែលនឹងផ្តល់លក្ខណៈងាយស្រួលដល់យុវជនយើង ដែលនឹងអាចយល់ភាសាបរទេសតាមរយៈនៃការអានប្រវត្តិសាស្ត្ររបស់ខ្លួន និងដល់ជនបរទេសដែលត្រូវការចង់ដឹង និងសិក្សាប្រវត្តិសាស្ត្រនៃខេត្តបាត់ដំបងយើងផង ។

តូច ឈួង

www.budinst.gov.kh www.elibraryofcambodia.org

# ចៅហ៊្វាមែន

## មូលហេតុដែលនាំឲ្យសៀមត្រួតបាត់ដំបង អស់មួយសតវត្ស

នៅរវាងឆ្នាំ ១៧៦៤ នៅប្រទេសសៀម មានជនជាតិចិនម្នាក់ ត្រូវបានតែងតាំងឲ្យត្រួតត្រាខេត្តមួយនៅតាមព្រំដែនភូមា ឈ្មោះ ខេត្ត តាក ។ គេហៅចៅហ្វាយខេត្តនេះថា "**ផ្យាតាកសិន**" ព្រោះគាត់មានឈ្មោះសិន ។ នៅឆ្នាំ ១៧៦៦ ភូមាបានលើកទ័ព យ៉ាងគគ្រឹកគគ្រេងមកវាយកំទេចក្រុងស្រីអយុធ្យា ជារាជធានី សៀម ធ្វើឲ្យសៀមធ្លាក់ចុះក្នុងអនាធិបតេយ្យយ៉ាងធ្ងន់ ។ រាជវង្សា នុវង្សស្តេចសៀមបាក់បែកខ្ចាត់ខ្ចាយ ។ ប្រទេសសៀមត្រូវចែក ជារដ្ឋតូចៗឯករាជ្យរៀងៗខ្លួន ។ ក្សត្រសៀមពីរអង្គ នាម **ចៅចុល និង ចៅស៊ីសាំង** បានរត់មកសុំជ្រកកោននៅប្រទេស កម្ពុជា ជាមួយព្រះបាទនរាយណ៍រាជាអង្គតន់ ។ នៅពេលនោះ ចៅពញាតាកសិនឬ ផ្យាតាកសិន បានប្រមូលបក្ខពួកវាយកំទេចទ័ព បរទេសឈ្លានពាន ហើយបង្ក្រាបអំពើបះបោរក្នុងស្រុក ហើយប្រ កាសខ្លួនជាមហាក្សត្រនៃប្រទេសសៀម ។ គេហៅថា **ព្រះចៅ**

www.budinst.gov.kh www.elibraryofcambodia.org

.ក្រសិន ទៅតាមខេត្តដើមនិងឈ្មោះដើម ។ ព្រះចៅតាកសិន បានលើករាជធានីទៅតាំងនៅចំងាយប្រមាណ ៧០ គ.ម ខាងត្បូងក្រុងស្រីអយុធ្យា នៅតាមដងទន្លេមេណាមចៅផ្រះយ៉ា នាត្រើយខាងលិច ។ រាជាធានីថ្មីនេះមានឈ្មោះថា ធនបុរី ។

នៅឆ្នាំ ១៧៦៨ ព្រះចៅតាកបានផ្ញើសារមកព្រះបាទនរាយណ៍រាជាអង្គតន់សុំឲ្យទទួលស្គាល់ព្រះអង្គជាស្តេចសៀមថ្មី តែព្រះអង្គតន់បានបដិសេធ ។ ព្រះចៅតាកអាក់អន់ព្រះទ័យយ៉ាងខ្លាំង ក៏លើកទ័ពមកវាយលុកប្រទេសខ្មែរ ដោយអាងលេសថាយកព្រះអង្គនន់រាមា ដែលភៀសខ្លួនទៅនៅស្រុកសៀមយូរហើយនោះ ឲ្យមកសោយរាជ្យនៅប្រទេសកម្ពុជាវិញ ។ ព្រះចៅតាក បានចាត់ចៅពញាចក្រីដួងឲ្យនាំទ័ពជើងគោក ឯព្រះអង្គបញ្ជាកងទ័ពជើងទឹកតាមសមុទ្រមកឡើងនៅកំពត ដោយនាំព្រះអង្គនន់រាមាមកជាមួយផង ។ ទ័ពសៀមបានវាយលុកប្រទេសកម្ពុជា រហូតដល់ឧដុង្គមានជ័យ ។ ព្រះនរាយណ៍រាជាទប់ទល់មិនបាន ក៏រត់ទៅស្រុកយួនសុំពឹងស្តេចយួន ។ ព្រះចៅតាកក៏លើកព្រះអង្គនន់រាមា ឲ្យឡើងសោយរាជ្យនៅឧដុង្គមានជ័យ ។

ព្រះនរាយណ៍រាជាអង្គតន់ ដោយមានជំនួយពីទ័ពយួនក៏វាយរុញច្រានព្រះអង្គនន់រាមាឲ្យចេញពីឧដុង្គទៅតាំងនៅកំពតវិញ ត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

ត្រាតែខេត្តភាគខាងត្បូង ។ ចាប់ពីពេលនោះមក ប្រទេសខ្មែរ បែកជាពីរ មានស្តេចមួយនៅឧដុង្គ ស្តេចមួយនៅកំពត ។

គឺនៅពេលនេះហើយ ដែលមន្ត្រីម្នាក់ឈ្មោះ បែន បានចូលទៅសុំបំរើព្រះអង្គនន់រាមា ។ ពញា បែន នេះមានកំណើតនៅខេត្តទ្រាំង គឺក្នុងខែត្រតាកែវសព្វថ្ងៃ ។

នៅឯឧដុង្គមានជ័យ ព្រះនរាយណ៍រាជាអង្គតន់បានចាត់រាជទូត ឲ្យនាំរាជសារទៅថ្វាយព្រះចៅតាក ដោយសុខចិត្តទទួលស្គាល់ព្រះចៅតាកជាស្តេចសៀម ។ ព្រះចៅតាកឈប់រករឿងរកហេតុនិងព្រះនរាយណ៍រាជាអង្គតន់ទៀតហើយ ។ តែដោយមានការនឿយណាយនិងសង្គ្រាម ព្រះនរាយណ៍រាជាអង្គតន់ក៏សុខចិត្តដាក់រាជសម្បត្តិថ្វាយទៅព្រះអង្គនន់រាមាវិញ នៅឆ្នាំ ១៧៧៥ ។ ព្រះអង្គតន់ សុខចិត្តទទួលព្រះឋានៈទាបជាព្រះមហាឧភយោរាជវិញ ព្រះអង្គតន់សុគតនៅឆ្នាំ ១៧៧៧ ដោយមានព្រះរាជបុត្រាតែមួយអង្គ គឺ ព្រះអង្គអេង ដែលនៅជាកុមារនៅឡើយ ។

ព្រះអង្គនន់រាមា មានគំនិតចង់បំបាត់ចោលឥទ្ធិពលយួន លើប្រទេសខ្មែរ ដោយលើកទ័ពទៅច្បាំងនឹងយួន នៅពេលដែលមានការបះបោរនៃពួកតៃសឺន នៅប្រទេសយួន ។ អំពើនេះធ្វើឲ្យមន្ត្រីចាស់ ដែលនិយមព្រះអង្គតន់អាក់អន់ចិត្តយ៉ាងខ្លាំង ។ មិនតែ

www.budinst.gov.kh www.elibraryofcambodia.org

ប៉ុណ្ណោះ ដើម្បីសងគុណសៀម ព្រះអង្គបានកេណ្ឌទ័ពនិងស្បៀងទៅជួយសៀម ច្បាំងជាមួយលាវទៀត ។ កំណែននេះបាននាំឲ្យមានការបះបោរ នៅខេត្តកំពង់ស្វាយ បារាយណ៍ និងគោកសេះដោយមានការរួមគំនិតនៃមន្ត្រីបីរូប ដែលជាបងប្អូនបង្កើត គឺឧកញ៉ាតេជោ ទែន ឧកញ៉ាសែនខាងហ្វា ពាង និង ឧកញ៉ាមន្ត្រី ស្នេហាសួរ ។ ឧកញ៉ាមន្ត្រីស្នេហាសួរបានត្រូវព្រះអង្គនន់រាមាកាត់ទោសប្រហារជីវិត ។ មិនតែប៉ុណ្ណោះព្រះអង្គនន់រាមាយល់ច្រឡំ ទៅចាត់ចៅហ៊្វា ម៉ូ ដែលជាបងនៃមន្ត្រីទាំង ៣ រូបនោះឲ្យទៅបង្ក្រាបឧកញ៉ាតេជោ ទែន និងឧកញ៉ាសែនខាងហ្វា ពាង ។ សម្តេចចៅហ៊្វា ម៉ូ ក៏ចូលដៃជាមួយប្អូនហើយបែរទ័ពប្រឆាំងនឹងព្រះអង្គនន់រាមាទៅវិញទៀត ។

នៅពេលនោះ ព្រះអង្គនន់រាមាបានតែងតាំង *ឧកញ៉ាវង្សាអគ្គរាជបែនឲ្យឡើងឋានៈជា ឧកញ៉ាយមរាជ* ហើយចាត់ឲ្យនៅថែរក្សារាជធានី ជាមួយនិងឧកញ៉ាវិបុលរាជ ស៊ូ ។ ព្រះអង្គនន់រាមាក៏លើកទ័ពទៅកំពង់ស្វាយបង្ក្រាបអំពើក្បត់របស់សម្តេចចៅហ៊្វា ម៉ូ ព្រមទាំងប្អូននិងបក្សពួក ។

ឧកញ៉ាវិបុលរាជ ស៊ូ ដែលជាបក្សពួករបស់ចៅហ៊្វា ម៉ូ ក៏ចាត់ភ្នាក់ងារឲ្យទៅពឹងយួនមកជួយសម្តេចចៅហ៊្វា ម៉ូ ។ ទ័ពយួន ចូល

www.budinst.gov.kh www.elibraryofcambodia.org

មកជួយហើយបានចាប់ព្រះអង្គនន់រាមា និងព្រះរាជវង្សានុវង្សធ្វើគត់ទាំងអស់ទៅ ។ មន្ត្រីសេនាបតីទាំងអស់បានលើករាជសម្បត្តិថ្វាយទៅព្រះអង្គអេងដែលទើបនឹងមានជន្មាយុ ៧ វស្សាឲ្យឡើងសោយរាជ្យ ។ ប៉ុន្តែ រដ្ឋអំណាចពិតប្រាកដត្រូវចៅហ្វា ម៉ូ កាន់កាប់ទាំងអស់ ក្នុងឋានៈជា សម្តេចចៅហ្វាមហារាជ ។ សម្តេចចៅហ្វាម៉ូ បានលើកប្អូនឈ្មោះ ពាង ឲ្យឡើងជាឧកញ៉ាចក្រី ហើយលើកឧកញ៉ាវិបុលរាជ ស៊ូ ឲ្យឡើងជាឧកញ៉ាក្រឡាហោម ។ ព្រះធម្មបិតារបស់ព្រះអង្គអេង ក៏បានឡើងទីជា ឧកញ៉ាវាំង ។

សម្តេចចៅហ្វា ម៉ូ មិនទុកចិត្តឧកញ៉ាយមរាជបែនទេព្រោះជាមនុស្សរបស់ព្រះអង្គនន់រាមា ក៏ចាត់យមរាជបែនឲ្យទៅនៅកំពង់ស្វាយ ជាមួយនឹងឧកញ៉ាតេជោ ទែន ។

នៅឯក្រុងធនបុរី ព្រះចៅតាកព្រួយព្រះទ័យណាស់និងអំពើក្បត់របស់សម្តេចចៅហ្វា ម៉ូ ក៏បានចាត់ឲ្យគេមកហៅ ឧកញ៉ាយមរាជបែន ទៅស្រុកសៀម ។ លុះបានដល់ហើយ ព្រះចៅតាកស្តីបន្ទោសឧកញ៉ាយមរាជបែនយ៉ាងខ្លាំង ថាត្រចៀកស្រាលបណ្តោយឲ្យគេសំលាប់ស្តេចបានហើយចាត់ឲ្យគេវាយយមរាជបែន ១០០រំពាត់ចៀរស្លឹកត្រចៀកនិងដាក់គុកនៅស្រុកសៀមរហូតទៅ[1]។

---

[1] ព្រោះតែរឿងដែលព្រះចៅសៀមវាយ និងចៀរស្លឹកត្រចៀកយមរាជបែននេះ

www.budinst.gov.kh www.elibraryofcambodia.org

ក្រោយមក ព្រះចៅតាកចាត់ឲ្យដោះលែងឧកញ៉ាយមរាជ បែន ចេញពីគុកឲ្យត្រឡប់មកកាន់ប្រទេសខ្មែរ ជាមួយនិងចៅពញា ចក្រី ឌួង ដែលលើកទ័ពយ៉ាងធំមកវាយបង្ក្រាបពួកសម្ដេចចៅហ្វ៊ា ម៉ូ រហូតដល់ឧដុង្គ ។ ចៅហ៊្វា ម៉ូ ក៏ចាត់ឲ្យទៅសុំជំនួយទ័ពពីស្ដេច យួន ។ ស្ដេចយួនឈ្មោះ ផៀង ទី ក៏ចាត់សេនាទាហានឲ្យមកជួយ សម្ដេចចៅហ៊្វាមហារាជ ម៉ូ ។

នៅពេលដែលពញាចក្រីឌួង កំពុងតែធ្វើសង្គ្រាមនៅប្រទេស ខ្មែរ ព្រះចៅតាកសិនដែលគង់ឯក្រុងធនបុរី បានចំរើនព្រះកម្មដ្ឋាន តាមព្រះពុទ្ធសាសនាក៏បែកផ្លូវឆ្វេងធ្លាក់ខ្លួនទៅជាវិកលចរិតដែលជា ហេតុនាំឲ្យកើតចលាចលនិងអនាធិបតេយ្យពេញព្រះនគរ ។

ចៅពញាចក្រី ឌួង ដែលកំពុងធ្វើចំបាំងនៅប្រទេសខ្មែរ បាន ដឹងរឿងចលាចលដែលកើតនៅឯក្រុងធនបុរី ក៏នាំទ័ពត្រឡប់ទៅ ស្រុកសៀមវិញ ។ ចៅពញាចក្រី ឌួង បានវាយបង្ក្រាបអំពើក្បត់និង ចលាចលក្នុងព្រះនគរ រួចហើយក៏ឡើងកាន់អំណាចជាមហាក្សត្រ

---

បានជាគ្រួសារចៅហ៊្វាបែនមិនចូលចិត្ត និងមិនស្រឡាញ់មនុស្សដែលមានស្លឹក ត្រចៀកធំទេ ។ ពួកគេស្អប់អ្នកណាមានស្លឹកត្រចៀកធំរហូត ។ មកដល់ឆ្នាំ ១៩០៧ ហើយក៏ពូជពង្សចៅហ៊្វាបែន ដែលគេហៅថាត្រកូលអភ័យវង្សនៅតែ និយាយថាស្អប់មនុស្សស្លឹកត្រចៀកធំដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

នៃប្រទេសសៀម ក្នុងព្រះនាមថា ព្រះពុទ្ធយ៉តហ្វាចុឡាលោក [1] ។

---

[1] តាមពត៌មានខ្លះនិយាយថា ចៅពញាចក្រីដួងនេះ មានកំណើតជា ខ្មែរ កើតនៅត្រាំសសរ ឃុំសំរោង ស្រុកទូកមាស ខេត្តកំពត ។ គាត់និងគ្រួសារគាត់ត្រូវសៀមកៀរយកទៅតាំងពីពេលដែលគាត់នៅតូចៗនៅឡើយ ។ គាត់ឡើងសោយរាជ្យបន្តពីព្រះចៅតាកមក ។ ព្រះមហាក្សត្រសៀមសព្វថ្ងៃនេះជាអ្នកតំណាងវង្សចក្រី ដួងទាំងអស់ ។ ហេតុនេះហើយបានគេហៅរាជវង្សស្តេចសៀមសព្វថ្ងៃថា "រាជវង្សចក្រី"។ តែអ្នកខ្លះហៅរាជវង្សនេះថា "រាជវង្សរតនៈកោសិន" ។

ចាប់ពីឆ្នាំ ១៩១០ មក ព្រះចៅវជីរាវុធបានបញ្ញត្តិឲ្យហៅស្តេចទាំងឡាយនៃរាជវង្សចក្រី ដួងនេះថាព្រះ "ព្រះរាមាធិបតី"។ ចាប់ពីឆ្នាំ ១៧៨២ មកដល់សព្វថ្ងៃ រាជវង្សចក្រីមានស្តេច ៩ ហើយ ។ គេហៅស្តេចសៀមថា ព្រះរាមាធិបតីទី១-ទី២ ឬព្រះរាមាទី ១ ទី២ ឬគេហៅថារជ្ជកាលទី១ ទី២ រហូតដល់ទី៩ សព្វថ្ងៃ ។

ព្រះចៅសៀមនៃរាជវង្សចក្រី ឬរាជវង្សរតនៈកោសិន ទាំង ៩ដែលសោយរាជ្យតាំងពីឆ្នាំ ១៧៨២មក គឺ :

- ព្រះពុទ្ធយ៉តហ្វាចុឡាលោក ឬ ព្រះរាមាទី ១ ឬ រជ្ជកាលទី ១
- ព្រះពុទ្ធឡឺតឡានភាល័យ ឬ ព្រះរាមាទី ២ ឬ រជ្ជកាលទី ២
- ព្រះណាងក្លាវ ឬ ព្រះរាមាទី ៣ ឬ រជ្ជកាលទី ៣
- ព្រះមង្គុតក្លាវ ឬចមក្លាវ ឬ ព្រះរាមាទី ៤ ឬ រជ្ជកាលទី ៤

www.budinst.gov.kh www.elibraryofcambodia.org

ព្រះចៅពុទ្ធឃ័តហា្វចុឡាលោកនេះ បានលើករាជធានី ពីធនបុរី ដែលនៅត្រើយខាងលិច មកតាំងនៅត្រើយខាងកើតទល់មុខក្រុងចាស់វិញ មានឈ្មោះថា ក្រុងទេពមហានគរ ។

នៅពេលនេះ ឧកញ៉ាយមរាជ បែន បានចូលមកប្រទេសខ្មែរវិញដោយមានការសមគំនិតជាមួយឧកញ៉ាក្រឡាហោម ស៊ូ ដែលទើបនឹងបានឡើងសក្តិជា សម្តេចចៅពញា ស៊ូ ។ ឧកញ៉ាយមរាជ បែន និងសម្តេចពញា ស៊ូ បាននាំគ្នាសំលាប់សម្តេចចៅហ្វ៊ាមហារាជ មូ និងគ្រួសារទាំងអស់ ។ សម្តេចចៅពញា ស៊ូ ក៏ឡើងកាន់អំណាចជាសម្តេចចៅហ្វ៊ា ស៊ូ តមកទៀត ។ ថ្ងៃក្រោយមក សម្តេចចៅហ្វ៊ា ស៊ូ ចង់កាន់អំណាចតែម្នាក់ឯង ក៏រកឧបាយសំលាប់ ឧកញ៉ាយមរាជ បែន ទៀត ។ តែឧកញ៉ាយមរាជបែនដឹងខ្លួនទាន់ ក៏នាំបក្ខពួកទៅសំលាប់ចៅហ្វ៊ា ស៊ូ ទៅទៀត ។ ឧកញ៉ាយមរាជ បែន ក៏ឡើងកាន់នាទីជាសម្តេចចៅហ្វ៊ាទល្ហៈ កាន់កាប់ការរដ្ឋតមក ។

---

| | | |
|---|---|---|
| - ព្រះវជីរ៉ាវុធ | ឬ ព្រះរាមាទី ៦ | ឬ រជ្ជកាលទី ៦ |
| - ព្រះប្រជាធីប៉ុក | ឬ ព្រះរាមាទី ៧ | ឬ រជ្ជកាលទី ៧ |
| - ព្រះអនន្ទ មហិដុន | ឬ ព្រះរាមាទី ៨ | ឬ រជ្ជកាលទី ៨ |
| - ព្រះភូមិពល អតុល្យ តេជ | ឬ អានថា | ភូមិដុនអដុន្យដេត |
| | ឬ ព្រះរាមាទី ៩ | ឬ រជ្ជកាលទី ៩ |

www.budinst.gov.kh www.elibraryofcambodia.org

ដោយមិនអាចបង្ក្រាបគូសត្រូវបានទាំងអស់នោះ សម្ដេចចៅហ៊្វា បែន ក៏ចាត់បញ្ជូនព្រះអង្គអេងនិងរាជវង្សានុវង្សទាំងអស់ទៅស្រុកសៀម ។ ព្រះចៅសៀមបានទទួលព្រះអង្គអេងយ៉ាងរាក់ទាក់ហើយចាត់ទុកជាបុត្រចិញ្ចឹម ។ នៅពេលដែលចៅហ៊្វា បែន នាំទ័ពទៅស្រុកសៀមនោះ បក្សពួកខាងចៅហ៊្វា មូ បាននាំគ្នាចូលមកក្រុងឧដុង្គ ហើយលើកឧកញ៉ាតេជោ ទែន ឲ្យឡើងជាសម្ដេចចៅហ៊្វាទែន ។

ព្រះចៅសៀមទ្រង់តែងតាំងចៅហ៊្វា បែន ជា**ចៅពញ្ញាអភ័យ ធិបេស វិសេសសង្គ្រាមរាមនរិន្ទ ឥន្ទជ័យ អភ័យភេរី បរាក្រមពាហុ** ហើយ បានចាត់ឲ្យនាំទ័ពមកការពារស្រុកបាត់ដំបងនិងវាយកំចាត់ចៅហ៊្វា ទែន ចេញពីឧដុង្គមានជ័យដែលជាហេតុនាំឲ្យមានចំបាំងរវាងខ្មែរម្ខាងដែលពឹងយួន និងខ្មែរម្ខាងទៀតដែលពឹងសៀម ។ ទ័ពចៅហ៊្វា ទែន បានវាយរុញច្រានទ័ពចៅពញ្ញាអភ័យធិបេស បែន រហូតដល់បាត់ដំបង ។ តែចៅពញ្ញាអភ័យធិបបេស បែន បានវាយតបមកវិញយ៉ាងខ្លាំង ធ្វើឲ្យទ័ពចៅហ៊្វា ទែន បរាជ័យយ៉ាងធ្ងន់នៅត្រង់ព្រែកដូនទាវ ។ ទ័ពចៅហ៊្វា ទែន បាក់រត់ខ្ចាត់ខ្ចាយរហូតដល់ភ្នំពេញ ។ ចៅពញ្ញាអភ័យធិបេស បែន ដេញតាមរហូតដល់ឧដុង្គ ហើយចាប់បាន

www.budinst.gov.kh www.elibraryofcambodia.org

សម្តេចចៅហ្វា ទែន នាំទៅថ្វាយស្តេចសៀម ។ ស្តេចសៀមបែរជាប្រណីលើកលែងទោសឲ្យសម្តេចចៅហ្វា ទែន ទៅវិញ ។

ចៅពញាអភ័យធិបេស បែន ឡើងកាន់អំណាចនៅឧដុង្គ គ្រួតត្រាប្រជារាស្ត្រដោយវិធីឃោរឃៅកាប់សំលាប់ឥតត្រាប្រណីធ្វើឲ្យប្រជារាស្ត្រក្តៅក្រហាយយ៉ាងខ្លាំង ។ (នៅសម័យចៅហ្វា បែន ប្រុសៗភាគច្រើនស្លាប់អស់ នៅសល់តែស្រីមេម៉ាយនិងក្មេងកំព្រា ទើបមានដំណាលថា ៖ "សម័យចៅហ្វាបែន មេម៉ាយ១០ថ្លៃមួយស្លឹងសំផឹង ១០ស្មើស្លាពុកមួយ"។)

ព្រះចៅសៀមដឹងអំពើឃោរឃៅរបស់ចៅពញាអភ័យធិបេស បែន ក៏សុខចិត្តបញ្ជូនព្រះអង្គអេង ឲ្យមកសោយរាជ្យវិញ ។ ព្រះអង្គអេងមានព្រះជន្ម ២២ ឆ្នាំ ក៏យាងមកសោយរាជ្យនៅប្រទេសខ្មែរនៅឆ្នាំ ១៧៩៤ ។

នៅពេលនេះ ចៅពញាអភ័យធិបេស បែន សុំព្រះអង្គអេងមកធ្វើជាចៅហ្វាយខេត្តបាត់ដំបងនិងសៀមរាបវិញ ព្រោះខ្លួនមិនអាចធ្វើការនៅឧដុង្គបានទេ ព្រោះខ្លួនមានទំនាស់ជាមួយសម្តេចចៅហ្វា ប៉ុក ដែលជាព្រះធម្មបិតា ជាមួយនឹងព្រះអង្គកែវដួងហើយនិងឧកញ៉ាតេជោ ទែន ។ព្រះអង្គអេងក៏សុខចិត្តយល់ព្រម ។ តែក្រោយមក ចៅពញាអភ័យធិបេស បែន បានចូលទៅក្រាបបង្គំ

www.budinst.gov.kh www.elibraryofcambodia.org

គាល់ព្រះចៅសៀមសុំមិនស្ដាប់រាជការក្រុងឧដុង្គទេ ព្រោះខ្លួនមានទំនាស់នឹងមន្ត្រីជាន់ខ្ពស់នៅឧដុង្គ ដោយខ្លួនសុំឡើងសួយសារអាករមកខាងព្រះចៅសៀមវិញ ។

ព្រះចៅសៀមមានព្រះទ័យអំណរក្រៃពេក ក៏ផ្ញើព្រះរាជសារមកថ្វាយព្រះអង្គអេងសុំខេត្តបាត់ដំបងនិងសៀមរាប ព្រះអង្គអេងមិនព្រម តែក្រោយមកដឹងថា ចៅពញាបែនក្បត់ចូលដៃជាមួយស្ដេចសៀមរួចទៅហើយ ក៏សុខចិត្តថ្វាយខេត្តបាត់ដំបងនិងសៀមរាបទៅព្រះចៅសៀមក្នុងមួយរជ្ជកាលព្រះពុទ្ធយ៉តហ្វាចុឡាលោក ។ ផុតពីរជ្ជកាលនេះទៅ ព្រះអង្គអេងសុំយកខេត្តទាំងពីរនេះមកវិញ ដោយហេតុនេះហើយបានជាចាប់តាំងពីឆ្នាំ១៧៩៤មក ខេត្តបាត់ដំបងសៀមរាប សំណាត់ ចុងកាល់ បានក្លាយជាខេត្តសៀម ដោយមានចៅពញាអភ័យធិបេសបែននិងគ្រួសារកាន់អំណាចត្រួតត្រាជាស្ដេចត្រាញ់លើទឹកដីដ៏ល្វឹងល្វើយនេះរហូតដល់ឆ្នាំ ១៩០៧ ។

ព្រះអង្គអេងសុខចិត្តថ្វាយខេត្តបាត់ដំបង និង សៀមរាបទៅព្រះចៅសៀម តែក្នុងមួយរជ្ជកាលព្រះពុទ្ធយ៉តហ្វាប៉ុណ្ណោះ ។ ព្រះអង្គអេងនឹងសុំយកមកវិញនៅរជ្ជកាលស្ដេចក្រោយ ។ តែនៅឆ្នាំ ១៨០៦ ព្រះអង្គអេងក៏សុគតមុនព្រះពុទ្ធយ៉តហ្វាទៅទៀត ។ ព្រះមហាក្សត្រក្រោយព្រះអង្គអេងមានកង្វល់ផ្សេងៗ ក៏មិនបានទាម

www.budinst.gov.kh www.elibraryofcambodia.org




ខេត្តភាគខាងលិចនៃប្រទេសកម្ពុជា

www.budinst.gov.kh www.elibraryofcambodia.org

ទារយកខេត្តទាំងនេះពីសៀមមកវិញទេ ។ គ្រួសារចៅហ៊្វាបែនក៏កាន់កាប់ខេត្តនេះ រហូតទៅដល់ ៦ តំណ រួមទាំងចៅពញាអភ័យធិបេសបែនរហូតដល់លោកកថាថន ឈុំ គឺពីឆ្នាំ ១៧៩៤ ដល់ ១៩០៧ ។

www.budinst.gov.kh www.elibraryofcambodia.org

# មួយសតវត្ស
# ក្រោមអំណាចគ្រួសារ ចៅហ៊្វាបែន

ចាប់ពីឆ្នាំ ១៧៩៤មក ចៅពញាអភ័យធិបេស បែន បានឡើងឋានៈជាស្តេចត្រាញ់ ឈប់ស្តាប់បង្គាប់ព្រះមហាក្សត្រខ្មែរនៅឧដុង្គទៀតហើយ ។ គាត់កាន់ការខេត្តបាត់ដំបង ដោយមានជំនួយពីកងទ័ពសៀម ហើយត្រូវលើកសួយសារអាកររាល់ឆ្នាំទៅថ្វាយព្រះចៅសៀម ។ ក្រោយដែលគាត់ស្លាប់ទៅ គ្រួសារគាត់ទទួលមរតកត្រួតត្រាខេត្តបាត់ដំបងអស់៤តំណ រហូតដល់ឆ្នាំ១៩០៧ ទើបខេត្តបាត់ដំបងបានវិលមកប្រទេសខ្មែរវិញ ។

យើងនិយមហៅចៅពញាអភ័យធិបេសនេះថា **ចៅហ៊្វាបែន** តាមងារដែលគាត់តាំងខ្លួនឯងជាធំត្រួតត្រាប្រទេសខ្មែរនៅឧដុង្គ ។ ពាក្យថា ចៅហ៊្វាត្រូវបាត់បង់ទៅហើយតាំងពីពេលដែលស្តេចសៀមតាំងជា "ចៅពញាអភ័យធិបេស វិសេសសង្គ្រាម រាមនរិន្ទ ឥន្ទជ័យ អភ័យភេរី បរាពាហុ"

យើងមិនមានឯកសារច្បាស់លាស់អំពីកូនចៅ ចៅហ៊្វាបែននេះទេ ព្រោះឯកសារនិយាយមិនអាចសល់គង់វង់កើត ។ យើងដឹង

www.budinst.gov.kh www.elibraryofcambodia.org

បានតែលោកកថាថន ឈុំ ដែលជាស្តេចត្រាញ់ចុងក្រោយបង្អស់នៃត្រកូលចៅហ៊្វាបែន ដែលគេហៅថា ត្រកូល "**អភ័យវង្ស**"។ ក្រោយដែលគាត់បានឡើងជាស្តេចត្រាញ់ ចៅហ៊្វាបែន បានចាត់រាស្ត្រខ្មែរ១សែននាក់ឲ្យទៅជួយជុតអិដ្ឋ ជីកព្រែកនៅឯរាជធានីសៀម ធ្វើឲ្យខ្មែរព្រាត់ប្រាសប្រពន្ធកូន ទៅរស់នៅស្រុកគេរហូតដល់សព្វថ្ងៃ កើតជាសង្កាត់មួយហៅថា "បាងសែន"។

នៅក្រោយពេលដែលព្រះអង្គអេងសុគតនៅឆ្នាំ ១៨០៦ ចៅពញាអភ័យធិបេស បែន បានយកបុត្រីនាម នាងទេព មកថ្វាយព្រះអង្គចន្ទដែលទើបនឹងឡើងសោយរាជ្យនៅឧដុង្គ ។ អ្នកម្នាងទេពនេះមានបុត្រីមួយអង្គនាម ព្រះអង្គហែន ដែលក្រោយមកយួនបានចាប់យកទៅជ្រមុជទឹកសំលាប់នៅឯលង់ហោ ។ ចៅពញាអភ័យ ធិបេស បែន ទទួលអនិច្ចកម្មនៅឆ្នាំ១៨០៩ ប៉ុន្មានខែក្រោយដែលព្រះចៅសៀមព្រះពុទ្ធយ៉តហ្វាចុឡាំលោកសុគត ។ ព្រះចៅថ្មីនៃប្រទេសសៀមគឺ ព្រះពុទ្ធឡឺតឡានភាល័យ បានតែងតាំងលោកវិបុលរាជ ប៉ែន ដែលត្រូវជាកូនលោកអភ័យធិបេសបែន ឲ្យឡើងកាន់អំណាចនៅខេត្តបាត់ដំបង ដោយមាននាទីជាចៅពញាអភ័យធិបេស តមកទៀត ។ លោកវិបុលរាជប៉ែនកាន់អំណាចបាន ៧ ឆ្នាំ ក៏ធ្វើមរណកាលទៅ ។ លោករស់ ដែលត្រូវជា

www.budinst.gov.kh www.elibraryofcambodia.org

កូនលោកវិបុលរាជ ប៉ែន ត្រូវបានស្តេចសៀមតែងតាំងជា ចៅពញាអភ័យធិបេស តមកទៀត ។ ចាប់ពីឆ្នាំ ១៨១៦ លោកអភ័យធិបេសរស់ កាន់អំណាចបាន២០ឆ្នាំ ក៏ធ្វើមរណកាលទៅទៀតនៅឆ្នាំ ១៨៣៤ ។

នៅពេលនេះ នៅឯរាជធានីឧដុង្គមានវិបត្តិរាជវង្សយ៉ាងខ្លាំង យួនបានលើក **ក្សត្រីអង្គម៉ី** ឲ្យសោយរាជ្យ ។ ព្រះអង្គឌួងនិងព្រះអង្គអិម ដែលជាព្រះអនុជព្រះអង្គចន្ទ បានរត់ទៅស្រុកសៀម ។ សៀមបានឧបត្ថម្ភព្រះអង្គអិម និងព្រះអង្គឌួង ដោយចាត់ឲ្យព្រះអង្គអិម មកគង់នៅបណ្តោះអាសន្នឯបាត់ដំបង ។ ព្រះអង្គឌួងយាងមកគង់នៅមង្គលបុរី ត្រង់វត្តពោធិល្វង ។ នៅពេលមកដល់បាត់ដំបង ព្រះអង្គអិមបានកសាងប៉មបន្ទាយមួយ តែជាប៉មបន្ទាយធ្វើអំពើឈើច្រុះក្តារចាក់ដី បន្តែទឹកលិចនៅរដូវវស្សា ។

នៅពេលនោះស្តេចសៀម ព្រះណាងក្លាវ ហាក់ដូចជាចង់ឈប់ឲ្យត្រកូលសារ ចៅហ៊្វាបែន កាន់អំណាចនៅបាត់ដំបងទៀតហើយ បានជាប្រគល់ខេត្តបាត់ដំបងឲ្យទៅព្រះអង្គអិមត្រួតត្រាវិញ ។ ព្រះអង្គអិម មិនពេញចិត្តនឹងធ្វើត្រឹមតែស្តេចត្រាញ់ ត្រួតខេត្តមួយទេ ចង់តែមកសោយរាជ្យនៅឧដុង្គតែម្តង ។ គាប់ជួនពេលនោះ យួនដឹងថាព្រះអង្គអិមមកគង់នៅបាត់ដំបង ក៏ចាត់ភ្នាក់ងារសំងាត់ដែល

www.budinst.gov.kh www.elibraryofcambodia.org

គេហៅថា "អុងផរ "ឲ្យចូលមកប្រលោមព្រះអង្គអិមដោយបោកប្រាសថា យួនប្រគល់រាជសម្បត្តិថ្វាយ ។ ព្រះអង្គអិមត្រេកអរណាស់ព្រោះត្រូវនឹងចំណុចចិត្តក៏សរសេរសំបុត្រសំងាត់មួយទៅថ្វាយស្តេចសៀមថា ព្រះអង្គដួងដែលគង់នៅមង្គលបុរី មានទាក់ទងសមគំនិតជាមួយយួន ។ កលល្បិចនេះមានគោលបំណងបំបែកព្រះអង្គដួង កុំឲ្យមកសោយរាជ្យនៅឧដុង្គ ប្រជែងនឹងព្រះអង្គ ។ ស្តេចសៀមទទួលដំណឹងនេះភ្លាម ក៏ចាត់ឲ្យគេមកយាងព្រះអង្គដួង ទៅឯក្រុងបាងកក ។

នៅពេលមានឱកាសល្អ ព្រះអង្គអិមក៏លួចធ្វើដំណើរដោយស្ងាត់ជាមួយភ្នាក់ងារយួនទៅឧដុង្គ ។ ព្រះអង្គអិមមិនយាងទៅម្នាក់ឯងទេ ថែមទាំងបានចាប់លោកបាឡាត់ រស់ ក្រមការខេត្តបាត់ដំបង ព្រមទាំងកៀរគ្រួសារខ្មែរនៅតាមដងផ្លូវយកទៅផង ។ តែនៅពេលទៅដល់ពោធិសាត់ យួនក៏ចាប់ទាំងព្រះអង្គអិម ព្រមទាំងលោកបាឡាត់ ទាំងគ្រួសារខ្មែរយកទៅឃុំទុកឯក្រុងវេ នាប្រទេសអាណ្ណាម ។ យួនឃុំគ្រួសារខ្មែរទុកនៅស្រុកវាអស់ពេលជាង ១០ ឆ្នាំ ។ នៅក្រុងវេនេះ លោកបាឡាត់រស់បានបន់ស្រន់ព្រះរតនត្រ័យ សុំឲ្យជួយគាត់និងគ្រួសារឲ្យបានត្រឡប់មកស្រុកទេសវិញ ។ លោកបាឡាត់បានបន់ស្រន់ថានឹងសាងវត្តមួយតបស្នង

www.budinst.gov.kh www.elibraryofcambodia.org

សងគុណព្រះរតនត្រ័យ ។ ហេតុនេះហើយបានជាក្រោយពេលដែលគាត់បានមកស្រុកវិញ លោកបាឡាត់បានសាងវត្តមួយដែលគេហៅថា **វត្តបាឡាត់** សព្វថ្ងៃ ។

សៀមព្រួយបារម្ភណាស់ ពីជំរឿតជំរែកយួន នៅបាត់ដំបងដែលជាទ្វារនៃប្រទេសគេ ។ សៀមក៏ចាត់**ចៅពញាបតិន្ទ្រ**គេជាហៅថា **ចៅពញាបឌិន** ឬ **លោកចៅឃុន** ឲ្យរៀបចំខេត្តបាត់ដំបង ទប់ទល់នឹងការរាតត្បាតនៃទ័ពយួនជាយថាហេតុ ក្នុងរវាងឆ្នាំ ១៨៣៨ ។ ក្នុងការរៀបចំស្រុកបាត់ដំបងនេះ សៀមបានចូលមក សាងបន្ទាយប្រាការមួយធ្វើអំពីឥដ្ឋបូកបាយអរ មានបណ្ដោយ ១៨ សិន ទទឹង ១២សិន ។ អ្នកស្រុកហៅបន្ទាយប្រាការនេះតាមសៀម ថា **កំផែងខ្ពស់** ឬ **កំផែង**ដែលប្រែថា កំពែង ។ គេបានបញ្ជាទិញកាំភ្លើងធំជាច្រើនពីប្រទេសអង់គ្លេស ដើម្បីការពារកំផែងនេះ ។ មួយចំណែកទៀត គេបានទប់ស្ទឹងចាស់ គឺអូរដំបងឲ្យទឹកហូរតែមួយផ្លូវ មករកស្ទឹងសង្កែដែលហូរកាត់ទីប្រជុំជនបាត់ដំបងនេះ ។ គេបានបញ្ចុះអាគមគាថាក្នុងស្ទឹង ត្រង់កំពង់សីមានៅខាងលើនិងពាមសីមានៅខាងក្រោម ។ គេដាំថ្មគោលធំៗនៅជុំវិញទីក្រុងដើម្បីការពារសត្វសាហាវនិងសឹកសត្រូវផ្សេងៗ ។ ក្នុងការរៀបចំស្រុកនេះ សៀមបានកេណ្ឌទ័ពតាំងពីខ្ពង់រាបនគររាជ

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំង ទី ២



ចៅពញា បឌិន មេទ័ពសៀម (អ.ជ)

www.budinst.gov.kh www.elibraryofcambodia.org

សីមាមក ។ ទ័ពសៀមនៅពេលនោះកាចសាហាវណាស់ ដើរកាប់សំលាប់ប្លន់ទ្រព្យសម្បត្តិអ្នកស្រុក ធ្វើឲ្យរាស្ត្រខ្មែរខ្លាចរអាយ៉ាងខ្លាំង ។

នៅឆ្នាំ ១៨៤២ ព្រះចៅសៀមព្រះណាងក្លាវបានចាត់ចៅពញាបឌិនឲ្យនាំទ័ពជូនព្រះអង្គដួង មកសោយរាជ្យនៅឧដុង្គ ។ ប្រជារាស្ត្របាត់ដំបងបានចូលរួមមួយផ្នែកក្នុងកងទ័ពនេះ ក្រោមបញ្ជារបស់ព្រះអង្គកែវម៉ា និងព្រះនរិន្ទយោធា ។ ព្រះអង្គកែវម៉ានេះជា កូនចៅហ្វាបែនដែលបាននាំទ័ពរុញច្រានយួនរហូតដល់មាត់ជ្រូក ពាមនាវ ។

យួនសុំចុះចាញ់ថយចេញពីប្រទេសខ្មែរ ព្រះង្គដួងក៏បានឡើងសោយរាជ្យនៅឧដុង្គមានជ័យ ។ ចៅពញាបឌិន បានថ្វាយបង្គំលាព្រះអង្គដួង ត្រឡប់មកតាំងនៅបាត់ដំបង ។ ចៅពញាបឌិនបានចាត់ចែងបែងចែកដែនដីស្តេចត្រាញ់នៅបាត់ដំបង នៅរវាងឆ្នាំ ១៨៤៤ ជាខេត្តតូចៗដាច់ៗពីគ្នា ដូចជាខេត្តបាត់ដំបង សៀមរាប សិរីសោភ័ណ ចុងកាល់ ព្រះស្រុក ។ ការបំបែកខេត្តនេះមានន័យថាបន្ថយអំណាចស្តេចត្រាញ់នៅបាត់ដំបង ។ ខេត្តបាត់ដំបងនៅសល់តែស្រុកបួនទេគឺ មោងឬស្សី បាត់ដំបង មង្គលបុរី និងស្រែអន្ទាក់ ។ សៀមបានលើកកូនរបស់លោកអភ័យធិបេសរស់

www.budinst.gov.kh www.elibraryofcambodia.org

ម្នាក់ឈ្មោះ នង ឲ្យត្រួតត្រាខេត្តបាត់ដំបងដោយមានងារជា អភ័យធិបេស ដដែល ។

គេមិនបានដឹងថា ចៅពញាអភ័យធិបេស នង នេះបានធ្វើអ្វីខ្លះ ហើយទទួលអនិច្ចកម្មនៅឆ្នាំណាទេ តែនៅឆ្នាំ១៨៩៦លោកបានចាត់មន្ត្រីឲ្យទៅជាវគម្ពីរព្រះត្រ័យបិដកនិងទូមួយ ពីប្រទេសសៀមយកមកតំកល់នៅវត្តពោធិវាល ។

ក្រោយដែលលោកអភ័យធិបេស នង ធ្វើមរណកាលទៅ ព្រះចៅសៀមបានជ្រើសរើសកូនលោក នង ម្នាក់ឈ្មោះ យារ ហៅ ញ៉ុញ ឲ្យធ្វើជាស្ដេចត្រាញ់ មានងារថា **ចៅពញាគទាធរធរណិន្ទ្រ រាមនរិន្ទឥន្ទ្រាធិបតី អភ័យភេរី ពាហុ** ។ ពាក្យថា គទាវធរ នេះអានតាមសៀមថា កថាថន ប្រែថា អ្នករក្សាដំបង ។

ការផ្លាស់គោរម្យងារស្ដេចត្រាញ់នេះ ពិតជាមានន័យថា គ្រួសារចៅហ្វាបែន ត្រូវគេបន្ថយទឹកដីនិងអំណាចខ្លះ ។

គឺលោកយារ ហៅ ញ៉ុញ នេះហើយ ដែលបានស្ថាបនាព្រះវិហារវត្តសង្កែសព្វថ្ងៃ ដែលមានចេតិយពីរនៅខាងមុខ មួយសំរាប់តំកល់អដ្ឋិលោកកថាថន ញ៉ុញ មួយទៀតសំរាប់អដ្ឋិលោកជំទាវឈ្មោះ ធិម ។ លោកជំទាវ ធិម នេះ បានស្ថាបនាវត្តមួយនៅក្នុងកំផែង ដែលគេហៅថាវត្តកំផែង ដែលកាលនោះនៅត្រង់

www.budinst.gov.kh www.elibraryofcambodia.org



លោកម្ចាស់ គថាថន ញ៉ុញ (ន.ណ)



អ្នកម្ចាស់ឃ្លិប (អ.ជ)

www.budinst.gov.kh www.elibraryofcambodia.org

ទក្ខិណសាលាបឋមសិក្សាសព្វថ្ងៃ ។

នៅឆ្នាំ ១៨៦៣ ប្រទេសកម្ពុជាបានធ្លាក់ក្នុងអាណាព្យាបាលបារាំង ។ នៅឆ្នាំ ១៨៧២ ចៅពញាគទាធរ ញ៉ុញ បានទៅគាល់ព្រះបាទនរោត្តម នៅពេលដែលព្រះអង្គយាងមកធ្វើទស្សនកិច្ចនៅពោធិសាត់ ។ ព្រះបាទនរោត្តម បានប្រទានប្រអប់មាស១ កន្ថោរមាស ១ ជើងពានមាស១ ដល់លោកកថាថន ញ៉ុញ ។ គេមិនយល់ថាហេតុអ្វីបានជាព្រះបាទនរោត្តម ប្រទានរបស់ដ៏មានតំលៃយ៉ាងនេះដល់លោកញ៉ុញ ដែលគ្រាន់តែជាស្តេចត្រាញ់ប៉ុណ្ណោះ ឬមួយក៏ជាតង្វាយ ផ្ញើទៅស្តេចសៀម ។

នៅពេលនេះដែរ គេសង្កេតឃើញព្រះរាជបុត្រ នៃព្រះអង្គដួង ព្រះនាម ព្រះអង្គម្ចាស់កែវមនោហរ បានរត់មកជ្រកកោនជាមួយ លោកកថាថន ញ៉ុញ ដោយមិនដឹងមូលហេតុច្បាស់លាស់ ។ ព្រះអង្គម្ចាស់កែវមនោហរនេះបានសង់ដំណាក់មួយនៅខាងត្បូងវត្តតាមិម ប្រមាណ១០០ម៉ែត្រ ដោយបានយកដំរីនិងសេះជាច្រើនមកជាមួយផង ។ កន្លែងនេះ នៅពេលនោះ គេហៅថា កំពង់លួង ។

នៅពេលនេះ ទំនាស់រវាងសៀមនិងបារាំង ចេះតែកើតមានខ្លាំងឡើងៗ ។ នៅឆ្នាំ ១៨៩៣ បារាំងបានបង្ខំសៀមឲ្យដាក់ខេត្ត

www.budinst.gov.kh www.elibraryofcambodia.org

បាត់ដំបងជាតំបន់គ្មានកងទ័ព ដូច្នេះ សៀមគ្មានអំណាចតាំងទ័ពឬសង់បន្ទាយនៅបាត់ដំបងទេ ។

នៅក្នុងសម័យលោកកថាថន ញ៉ុញ នេះខេត្តបាត់ដំបងមានការលូតលាស់បន្តិចខាងគមនាគមន៍ ។ គេបើកឲ្យមានប្រៃសណីយ៍ទូរសព្ទនិងទូរលេខ ទាក់ទងជាមួយបាងកក ភ្នំពេញ ព្រៃនគរ ។ នៅជាមួយនេះ កប៉ាល់ក៏បានចូលមកដឹកទំនិញ និងអ្នកដំណើរ ពីបាត់ដំបងទៅបាក់ព្រា ពីបាក់ព្រាទៅមង្គលបុរី ពីបាក់ព្រាទៅភ្នំពេញដែរ ។

លោកកថាថន ញ៉ុញ នេះរាប់អានលោកចៅឃុនបឌិនណាស់ ។ គាត់បានរៀបការកូនស្រី ឈ្មោះ អ្នកម្ចាស់ ឃ្លិប ហៅ ម៉ុំ ជាមួយកូនលោកចៅឃុនបឌិនឈ្មោះ អែម សិង្ហសេនីយ៍ ។ នៅពេលដែលលោក ញ៉ុញ ចូលក្នុងវ័យចាស់ជរា អ្នកម្ចាស់ ឃ្លិប ចាត់ចែងកិច្ចការទាំងអស់ជំនួសឪពុក ។ ព្រះចៅសៀមពេញចិត្តណាស់ ហើយមានបំណងលើកប្ដីអ្នកម្ចាស់ ឃ្លិប នេះឲ្យកាន់តំណែងជាចៅហ្វាយខេត្តបាត់ដំបង ។ តែនៅពេលនោះ លោកឈុំ ដែលជាប្អូនអ្នកម្ចាស់ឃ្លិប មានការច្រណែននិន្ទា ក៏ចាត់ឲ្យគេលួចកាប់សំលាប់ប្ដីអ្នកម្ចាស់ឃ្លិបនេះចោលទៅ ។

លោកកថាថន ញ៉ុញនេះធ្វើមរណកាលនៅរវាងឆ្នាំ១៨៩៤ ។

www.budinst.gov.kh www.elibraryofcambodia.org

គេហៅលោក ញ៉ុញ ថាលោកម្ចាស់ព្រះកោដ្ឋ ព្រោះគេដាក់សព លោក ញ៉ុញ ក្នុងកោដ្ឋធ្វើបុណ្យ មុននឹងបូជា ។

ស្ដេចសៀមទាល់ព្រះតំរិះ ក៏លើកលោកឈុំនេះ ដែលជាកូនប្រុសតែមួយរបស់លោកជំទាវធិម ឲ្យធ្វើជាស្ដេចត្រាញ់តទៅដោយមានងារថា ចៅពញាគទាធរ ធរណិន្ទ្រ រាមនរិន្ទ ឥន្ទ្រាធិបតីអភ័យភេរី ពាហុ ។

លោក ឈុំ កាន់អំណាចបានជាង ១០ឆ្នាំ សៀមក៏ប្រគល់ខេត្តបាត់ដំបងមកឲ្យខ្មែរវិញ ។ លោកឈុំនេះ ត្រូវទៅរស់នៅឯបស្ចិមបុរី នាប្រទេសសៀម ។

ក្នុងរយៈជាង១ សតវត្ស គឺពីឆ្នាំ១៧៩៥ដល់ ១៩០៧ គ្រួសារចៅហ្វាបែន ត្រួតត្រាខេត្តបាត់ដំបងរហូតមក ។ អ្នកស្រុកនាំគ្នាហៅស្ដេចត្រាញ់របស់ខ្លួនថាលោកម្ចាស់ ។ តែដើម្បីកុំឲ្យច្រឡំរវាងលោកម្ចាស់ញ៉ុញ និងលោកម្ចាស់ឈុំនេះ គេហៅលោកញ៉ុញថាលោកម្ចាស់ព្រះកោដ្ឋ ឯលោកឈុំ គេហៅថា លោកម្ចាស់បស្ចិម ។

www.budinst.gov.kh www.elibraryofcambodia.org

# ចំបាំងតាកែ
# នៅតំបន់ភ្នំក្រវាញ

នៅសម័យដើម របបសក្តិភូមិតម្រូវឲ្យប្រជារាស្ត្របង់ពន្ធដារជាផលិតផលដែលខ្លួនធ្វើបាន តែក្រោយមកមានការផ្លាស់ប្តូរបន្តិចដោយគេឲ្យអ្នកស្រុកដែលជាផលិតករ បង់ពន្ធជាលុយកាក់វិញ ។ រាជការបាត់ដំបងបានតាំងព្រះវិចិត្តគិរី ជាភ្នាក់ងារទារពន្ធក្រវាញដែលគេហៅថាសួយក្រវាញ ។ រាស្ត្រប្រជាដែលប្រកបរបរបេះក្រវាញនេះគេហៅថា ពួកសួយក្រវាញ ។

នៅរវាងឆ្នាំ ១៨៩៨ ពួកសួយក្រវាញ នៅត្រង់សង្កាត់ក្រញូងបានបះបោរប្រឆាំងនឹងការសង្កត់សង្កិនឥតត្រាប្រណី ពីសំណាក់ព្រះវិចិត្តគិរីដែលជាភ្នាក់ងាររបស់លោកម្ចាស់ ។ ចាស់ៗនៅបាត់ដំបងសុទ្ធតែបានដឹងអំពីការបះបោរនេះ ហើយនិងការបង្ក្រាបយ៉ាងខ្លាំងអំពីអាជ្ញាធរសម័យនោះ ។ អ្នកស្រុកបានហៅ ការបះបោរ និងការបង្ក្រាបនេះថាចំបាំងតាកែ ។ លោកឧកញ៉ាសុត្តន្តប្រីជា ឥន្ទបានចងក្រងព្រឹត្តិការណ៍ដែលកើតនៅសម័យនោះ ជាកំណាព្យ ដែលយើងសូមសង្ខេបនិងដកស្រង់ខ្លះដូចតទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅរវាងឆ្នាំ ១៨៩៨ ពួកស្ទួយក្រវាញប្រមាណ ៥០០នាក់ ក្រោមដឹកនាំរបស់តាកែ បានក្រោកឡើងបះបោរ ប្រឆាំងនឹងការសង្កត់សង្កិនទារពន្ធក្រវាញយ៉ាងធ្ងន់ ។ តាកែនេះជាមនុស្សអង់អាចក្លាហានស្ទិតស្ទាញហើយខ្លាំងពូកែ ។ (លោកតាញ៉ុក ហួត បាននិយាយតៗតាមចាស់ៗថា តាកែនេះមានកាយសម្បទាពិសេស ។ តាកែអាចពាំដូងមួយធ្លាយចុះពីដើម ដោយយកក្បាលមកក្រោមមុនបានដោយងាយ) ។ តាកែមានលោកសង្ឃយួនមួយអង្គឈ្មោះយួនសៅ ជាទីប្រឹក្សា ។ យួនសៅនេះ ក៏ពូកែខាងមន្តអាគមវិជ្ជាការរអួមអាមស្តោះព្រួស ពទ្ធសីមាស្រោចទឹក ។ ពួកស្ទួយក្រវាញប្រមាណ ៥០០នាក់ ដោយមាន តាកែជាមេដឹកនាំក៏បះបោរឈប់បង់ពន្ធក្រវាញ ហើយប្រដាប់អាវុធច្បាំងតតាំងនឹងលោកម្ចាស់ ។ ពួកបះបោរបានដេញកំចាត់ព្រះវិចិត្តគិរីពីតំបន់របស់គេ ។ ព្រះវិចិត្តគិរីក៏យករឿងនេះទៅជំរាបប្តឹងលោកម្ចាស់ ។

លោកម្ចាស់ជ្រាបការណ៍ហើយ ក៏និយាយទូរសព្ទទៅហ្លួងកំភោតដែលជាចៅហ្វាយស្រុកមោងឫស្សី ឲ្យចាត់ចែងនាំទ័ពទៅបង្ក្រាបនៅតំបន់ភ្នំក្រវាញ ។ ហ្លួងកំភោតទទួលបញ្ជាតាមទូរសព្ទហើយ ក៏ចាត់ចែងនាំទ័ពលើកសំដៅទៅតំបន់ភ្នំក្រវាញតែម្តង ។

ក្រោយពីចេញដំណើរបានពីរបីថ្ងៃ ហ្លួងកំភោតក៏បោះទ័ព

www.budinst.gov.kh www.elibraryofcambodia.org

សំរាកនៅបាយរិល រង់ចាំទ័ពព្រះវិចិត្តគិរី ដែលចេញពីបាត់ដំបងមក ។ នៅពេលព្រះវិចិត្តគិរីលើកទ័ពទៅដល់ ហ្លួងកំភោតជំនុំរកមធ្យោបាយចាប់តាកែ ។ ហ្លួងកំភោតក៏សំរេចចាត់ភ្នាក់ងារឲ្យនាំសារទៅល្បួងលោមតាកែឲ្យចុះចូល ។ វគ្គមួយនៃលិខិតនោះមានថែងថា :

*«ឥឡូវលោកម្ចាស់ប្រើយើងមក ជំរះលៃលកក្នុងរឿងតា*
*តើតាជាខឹងនឹងអ្នកណា បានជាអហង្ការយ៉ាងនេះហោង*
*ឬមួយខឹងនិងព្រះវិចិត្ត ដែលគេរឹងរឹតទារស្វយសង*
*ឲ្យក្តៅក្រហាយអស់រាស្ត្រផង បានជាគិតប៉ងអាឃាតក្រោយ »។*

នាយលាញក៏នាំសារចេញទៅ ។ បក្ខពួកតាកែឃើញ ក៏ចាប់អ្នកនាំសារទាំងបីនាក់យកទៅជូនតាកែ ។ តាកែក្តៅណាស់ ក៏ចាត់ឲ្យគេយកនាយលាញនិងមិត្តទាំងពីរទៅសំលាប់ចោល ។ តែគាប់ជួនពេលនោះ យួនសៅ បានឃើញ ក៏មកសាកសួរ ហើយសុំបិណ្ឌបាតយកអ្នកទាំងបីយកទៅកន្លែងខ្លួន ។ តែថ្ងៃក្រោយនាយលាញនិងមិត្តបានបោកប្រាស យួនសៅ ត្រឡប់មកជំរាបហ្លួងកំភោតអំពីចរិតឥតកែប្រែរបស់តាកែ ។ ហ្លួងកំភោតដឹងថាមិនអាចសំរុះសំរួលបាន ក៏ទន្រ្ទាំជើងចាត់សេនាទាហាន ឲ្យប្រុងប្រៀបខ្លួនលើកទ័ពនៅថ្ងៃស្អែកបំរុង

www.budinst.gov.kh www.elibraryofcambodia.org

«ចោរមចាប់អាកែជាមេក្បត់ សីលាប់ឲ្យម័ត់ទាំងយោធី
កាប់ក្បាលវាដោតប្រចាំទី ឲ្យក្អែកត្មាត ស៊ី ជាភក្សា ។ »

នៅពេលនាំទ័ពចេញទៅ លោករាមសរជិតនិងសេនាប្រាក់ជាមេទ័ពមុខ ត្រូវដើរតាមផ្លូវតូចចង្អៀតក្បែរមាត់ជ្រោះ ។

ពួកល្បាតខាងតាកែ ឃើញទ័ពហ្លួងកំភោតហើយ ក៏បាញ់កាំភ្លើងជាសញ្ញាដល់បក្សពួកខ្លួន ។ តាកែក៏នាំទ័ពចេញមកភ្លាមដែរ ហើយបាញ់គ្នាទៅវិញទៅមកយ៉ាងកោលាហល ។ បន្ទាប់មកតាកែទាញដាវដេញកាប់ពលទាហានសេនាប្រាក់ ហើយប្រយុទ្ធគ្នាដាវនឹងដាវជាមួយសេនាប្រាក់ ដែលលោកសុត្តន្តប្រីជា ឥន្ទ បានចងជាកំណាព្យថា :

«អាកែលោតចាក់អាប្រាក់ចាប់ អាកែបែរកាប់អាប្រាក់គេច
ស្ទុះរត់ហក់វិលដូចគេវិច ពលបែកថយគេចរត់បរា ។
អាកែមានជ័យដេញកាប់ចាក់ ពួកទ័ពអាប្រាក់រត់ឆ្វេឆ្វា
រត់ជ្រួលពពាក់ពពួនគ្នា ខ្លះដួលខ្លះពារវារពួនជ្រក ។
ខ្លះស្ទូន់រត់ពួនប៉ះដើមឈើ ទល់ផ្អកងីងើដូចគេហក
អាកែដេញដល់កាត់ក្បាលយក នាំមកដោតឆ្កាងខាងផ្លូវថ្លា ។
អាផាក់អាក្រោយដេញប្រឈម កាប់ដៃអាអោមដាក់ពីស្មា
អាអោមរត់ប៉ះជាន់សិលា ដួលផ្ងារលើព្រៃក្ស័យជីវិត» ។

www.budinst.gov.kh www.elibraryofcambodia.org

ឃើញទ័ពសេនាប្រាក់ដកថយហើយ តាកែក៏ប្រមូលគ្នាឲ្យត្រឡប់ក្រោយវិញ ។ ទ័ពខាងហ្លួងកំភោតភ័យស្លន់ស្លោរត់ប្រសេចប្រសាចទៅប្ដឹងហ្លួងកំភោតៗ ក៏ភ័យភាំងទៀត បង្កើតជាវិការដ្ឋានមួយគួរឲ្យអស់សំណើច ដូចមានកំណាព្យថា ៖

«ឯរាមតេជោ ជាទ័ពល្អូន ឃើញក្បួនទ័ពបែកទៅទីទៃ
ស្រែកប្រាប់ទៅថាបរាជ័យ ចាញ់ដៃអាកែវាដេញហើយ ។
ទ័ពរាមតេជោរាមសរជិត ភ័យភិត មិតរត់មិនមើលឡើយ
ខ្លះស្រែកថាឆាប់វាកាប់ហើយ ខ្លះស្បៀយកំលាំងគាំងបាទា ។
ខ្លះធ្លាក់អាវុធ អំពីដៃ អ្នកខ្លះធ្លាក់ទៃអំពីស្មា
ខ្លះធ្លាក់ខ្នុកគ្រូពីកេសា ខ្លះហបខ្លះហាមាត់រត់ទៅ ។
ថ្លែងពីអាយ៉ោកបាវឃុនហ្លួង ឃើញទ័ពទាំងពួងបែកខ្ទួលខ្មៅ
ទើបស្ទុះរត់ចេញមកខាងក្រៅ ចូលទៅប្ដឹងហ្លួងកំភោតថា ។
លោកនាយអញ្ជើញរត់ឲ្យឆាប់ អាកែដេញកាប់មកហើយណា
ឃុនហ្លួងឮហើយរត់ឆ្លេឆ្លា ថាមែនឬអា-ឯណាទ័ព ។
អាយ៉ោកថាហ្នឹងនោះលោកនាយ ពលយើងរត់រាយបែកក្រឡាប់
ឃុនហ្លួងថាច្នោះឯងឆាប់ៗ ទៅចាប់យកសេះមកឲ្យអញ ។
ឯទ័ពហ្លួងផុនឃុំស្បៀងចែក ឮថាទ័ពបែកអាកែដេញ
ភិតភ័យស្លន់ស្លូតរត់ពាសពេញ ខ្លះដេញគោមកទីមរទេះ ។

ផ្ទាំង ទី ៤



ហ្លួងកំភោត (ញ.ឡ)

www.budinst.gov.kh www.elibraryofcambodia.org

ខ្លះស្ទួនទឹមគោយកក្បាលចូល អាគោកញ្ច្រោលដោលរបេះ
ខ្លះចាប់ច្រឡំយកឯសេះ មកទឹមរទេះថាជាគោ ។
ខ្លះទឹមគោពីររទេះពីរ ឡើងបរវក់វីរវាយពារលោ
ដល់នឹមធ្លាក់ផែតស្រែកពុទ្ធោ ស្ទុះដោះគោទឹមសារជាថ្មី ។
ខ្លះទឹមកណ្ដាលខ្លួនគោភ្លាម ដល់ដាក់ខ្សែទាមថាខ្សែតី
ខ្លះស្ទួនរត់ព័ន្ធគោក្របី ខ្លះចាប់ដុំដីថាទៃត្រូ ។
ខ្លះស្ទួនរត់ជាន់ហិបប្រអប់ ដួលចុះកំពុបធ្លាក់ស្លាម្ជូ
ខ្លះប៉ះដើមឈើធ្វើមុខជូរ ខ្លះរកគុណគ្រូឪពុកម្ដាយ ។
ខ្លះដួលអាក្រាតស្រាតចេញក្រៅ កន្ត្រាក់យកអាវមកបិទកាយ
ខ្លះរត់ប៉ះព័ន្ធនាយចៅហ្វាយ នាយប្រាយបាវប្រាសគាស់ដៃគ្នា ។
នាយដួលបាវដេកទៅលើខ្នង នាយធាក់បាវផងគេចពានពារ
នាយទះបាវតប់ប្រសប់គ្នា ស្ទុះពារពួន លួនរត់ទៅ ។
ឯហ្លួងកំភោតលោតឡើងសេះ ក្រោយគិតថាអេះឈប់សិននៅ
ចាំមើលឲ្យដឹងកិច្ចភាក់ជ្រៅ នឹងទៅក្រែងពលផ្អើលខ្ចាត់ខ្ចាយ ។»

នៅពេលនោះលោកវិសេសយ៉ាកន នូវ ដែលបាក់ទ័ពដែរនោះ មិនព្រមទៅជួបហ្លួងកំភោតទេព្រោះ «ខ្លាចប្រើទៀតចង្អៀតចិត្ត» ។ គាត់ក៏មកស្រុកបាត់ដំបង ដេកពុតធ្វើជាគ្រុនចាញ់ស្រុកលើ ។ ហ្លួងកំភោតក្ដៅក្រហាយនឹងបរាជ័យរបស់ទ័ពខ្លួន ក៏ដាច់ចិត្ត

www.budinst.gov.kh www.elibraryofcambodia.org

បកសំបុត្រប្ដឹងដល់លោកម្ចាស់ ដើម្បីសុំទ័ពជំនួយ ។ ហ្លួងកំភោត ក៏ចាត់នាយវេននាំសំបុត្រទៅជូនលោកម្ចាស់នៅឯកំផែង ។ ដោយនៅពេលនោះលោកម្ចាស់នៅឯភាស នាយវេនក៏ឡើងសេះបន្តដំណើរទៅភាសទៀត ។ លោកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ បានពិពណ៌នាអំពីទំនៀបលោកម្ចាស់នៅភាសថា ៖

*«ដល់ហើយដល់ភាសទីទំនៀប ចៅឃុនលោករៀបជាទីភាក់*
*មានល្វែងខ្វាត់ខ្វែងតែងច្រើនថ្នាក់ មុខក្រោយលាយចក្រសឹងជាលេខ ។*
*ជញ្ជាំងបង្អួចសឹងស្លឹករឹត ឫស្សីរិចិត្រជាជើងក្អែក*
*ខ្លះជាដកចន្ទកាន់យុងយែក មើលឯកលើសអស់ទីនានា ។*
*ទីទួលស្រួលស្រស់អស់ទឹកលិច គោកនៅជានិច្ចដូចបព្វតា*
*មានឈើដុះបាំងព្រះសុរិយា វាតារំភើយស្បើយក្ដីក្ដៅ ។*
*ស្ពានវាលព្រៃវែងតាមផ្លូវស្មឹង ទឹកនឹងគ្មានហូរគ្មានហែងទៅ*
*មច្ឆាអាស្រ័យជាលំនៅ ត្រង់ជ្រៅត្រីជ្រកច្រើនក្រាស់ក្រៃ ។*
*ខាងលើធ្វើស្ពានជាស្ពានឆ្លង អស់រាស្ត្រទាសផងបានអាស្រ័យ*
*ដើរឆ្លងទៅមកទាំងយប់ថ្ងៃ ក្សេមក្សាន្តឥតភ័យផងពាធា ។»*

លោកម្ចាស់បានទទួលសំបុត្រពីនាយវេនមើលដឹងអំពីបរាជ័យរបស់ទ័ពហ្លួងកំភោត ក៏លាន់មាត់ថា ៖

www.budinst.gov.kh www.elibraryofcambodia.org

«គួរប្ដូរធ្វើការបរាជ័យ ឲ្យអាអ្នកព្រៃមើលងាយបាន
គ្នាវានោះតើមានប៉ុន្មាន បានជាមិនហ៊ានចូលយុទ្ធនា ។
បង់ជាតិកំណើតកើតជាប្រុស ធ្វើឲ្យអាប់យសប្រុសដូចគ្នា
ទ័ពតូចប៉ុណ្ណោះបកគេចវា ចំណង់បើជាទ័ពធំដុំ ។
ទៅលេងនឹងគេឯណាបាន សមអន្តរធានទាំងតូចធំ
តែទ័ពអាព្រៃរត់កន្ទុំ មកនៅសំងំបាយរវិល ។ »

លោកម្ចាស់ប្រាប់នាយ វេន ឲ្យត្រឡប់មកវិញ ចាំពីរបីថ្ងៃទៀតលោកនឹងចាត់ការ ។ ក្រោយនោះលោកម្ចាស់វិលមកកាន់កំផែងវិញ ហើយហៅស្មៀនត្រាឲ្យវាយទូរលេខទៅបាងកក សុំអាវុធពីរដ្ឋាភិបាលសៀម ។ កំណាព្យមានឃ្លាដូចតទៅ ÷

«ស្មៀនត្រាទទួលប្រសាសន៍ថ្វាត់ លើកហត្ថលាថយមករៀបកាយ
ទៅដល់រោងលួសហើយនិយាយ នឹងនាយមីស្មើរអាត្យាស្រ័យ ។
ថាលោកជាម្ចាស់មានការក្ដៅ សូមវាយលួសទៅ ឯក្រុងក្រៃ
ចំពោះក្រសួងក្រុមមហាផ្ទៃ អញ្ជើញនាយវ៉ៃឥឡូវណា ។
ថាហើយស្មៀនត្រាកត់ពាក្យប្រាប់ ជាអក្សរសព្ទតាមភាសា
មីស្មើរទទួលមូលនាឡិកា ខារសួរ ឆឹងៗដឹងដល់ហោង ។»

ព្រះចៅសៀមទទួលដំណឹងហើយ ក៏យល់ព្រមតាមសុំ ។ លោកម្ចាស់ទទួលទូរលេខពីបាងកកហើយ ក៏ចាត់រទេះឲ្យទៅដឹក

www.budinst.gov.kh www.elibraryofcambodia.org

កាំភ្លើងធុនថ្មីយ៉ាងទំនើប គឺកាំភ្លើងមីលីឈើចំនួនមួយរយដើមពីសិរីសោភ័ណ ។ លុះបានអាវុធទំនើបថ្មីនេះហើយ លោកម្ចាស់ក៏ចាត់ការឲ្យរៀបទ័ពទៅបង្រ្កាបតាកែ ឯភ្នំក្រវាញ ។ កងទ័ពថ្មើរជើង ទ័ពសេះ រទេះ និងដំរី ចេញដំណើរកាត់តាមភូមិស្ទឹង ភូមិបឹងក្រសាល រួចទៅដល់ភូមិកញ្ចាំងបោះទ័ពនៅទីនោះ ។ ក្រោយមកលោកម្ចាស់ចាត់បំបែកទ័ពជាបីផ្នែក មួយផ្នែកទៅតាមចំលងរមាំង មួយផ្នែកទៅតាមកំពង់រពៅ និងមួយផ្នែកទៀតទៅតាមភូមិត្រដោក ។ ពលទាហានសុទ្ធតែមានចងកំណាត់ពណ៌ក្រហម សខ្មៅ ទៅតាមកង ជាសញ្ញា ។

តាំងពីពេលបាក់ទ័ពមក ព្រះវិចិត្តគិរីពួនក្នុងព្រៃជានិច្ច ។ ទើបតែពេលនេះ ដាច់ចិត្តចេញមកសុំទោសលោកម្ចាស់ៗបានស្ដីបន្ទោស ដូចមានកំណាព្យថា ÷

*«បន្ទោសតែព្រះវិចិត្ត គំនិតសោតដូចស្រីសំផឹង*
*បានតែអាណាគ្មានឹងៗ គ្មានលោះមួយស្លឹងអំពីគ្នា ។*
*លុះទៅត្រូវផៃយ៉ាងអាកែ ភ្នែកសល្អក់បែរបស់វា*
*ម្ល៉េះមិនខ្មាសគេផងនានា នៅអួតថាជាមេកងសួយ ។*
*បើបានឆីៗមិនរើសមុខ បានទុក្ខៗមករកគេជួយ*
*ប្រើមកគ្មានបានការតូចមួយ ឲ្យពួកអាសួយមាក់ងាយបាន ។»*

www.budinst.gov.kh www.elibraryofcambodia.org

លោកម្ចាស់បញ្ជាទ័ពឲ្យលើកទៅបោះនៅខាងមុខទៀត ។ នៅពេលយប់មានកូឡាម្នាក់ចូលមកសុំយកអាសារលោកម្ចាស់ ទៅយកក្បាលតាកែ ដោយសុំឲ្យលោកម្ចាស់អនុគ្រោះឲ្យខ្លួន បានរៀបការជាមួយកូនក្រមុំតាដារ៉ា ដែលជាបក្សពួកតាកែ ។ លោកម្ចាស់មានការសង្ស័យក៏បដិសេធពាក្យសុំរបស់កូឡានេះ ។ តាមពិតកូឡានេះជាភ្នាក់ងាររបស់តាកែមែន ។ កូឡានេះចូលមកស៊ើបការណ៍ពីស្ថានភាពទ័ពលោកម្ចាស់ទៅប្រាប់តាកែ ។

តាកែបានប្រមូលបក្សពួកហើយ ក៏បាញ់កាំភ្លើងយកជ័យ ។ យួនសៅ ក៏សេពមន្តវិជ្ជាអាគមគាថាការពារពលទាហាន ។ តាកែចាត់គ្នាប្រាំនាក់ឲ្យមកយាមតាមច្រកចូលទៅកាន់ភូមិ ។

ព្រឹកស្អែកឡើង លោកម្ចាស់ក៏ដាស់ពលទាហានឲ្យដាំបាយហើយចេញដំណើរទៅ ។ លុះដល់ផ្លូវចូលទៅភូមិអង្គជុំ ពួកល្បាតតាកែក៏នាំដំណឹងទៅប្រាប់មេកើយខ្លួន ។ តាកែដឹងហើយក៏បញ្ជាឲ្យពលទាហានបាញ់ពលលោកម្ចាស់ដោយឥតសំចៃដៃ ។ ពួកខាងលោកម្ចាស់បាញ់តាកែដួលខ្លាក់ តាកែស្ទុះក្រោកតដៃទៀត តែទ្រាំមិនបានក៏ដួលដេកស្លាប់ទៅ ។ ពួកពលតាកែក៏ស្លាប់ដេរដាសហើយខ្លះក៏រត់យករួចខ្លួនទៅពួនក្នុងព្រៃ ។

នៅពេលនោះ សេនាប្រាក់ក៏នាំពួកពលចូលទៅរកលោក

www.budinst.gov.kh www.elibraryofcambodia.org

សង្ឃយួន ដែលនៅឯភូមិ ។ តាប្រាក់ក៏ចូលទៅចាប់យួនឲ្យចេញមកក្រៅ ។ លោកសង្ឃយួននេះក៏អង្វរតាប្រាក់ថាសុំឆាន់បាយសិន តែតាប្រាក់មិនសុខចិត្ត ក៏បណ្ដាលឲ្យកើតមានការវាយតប់គ្នាយ៉ាងខ្លាំង ដូចមានចែងជាកំណាព្យថា :

«តាប្រាក់ឃើញថ្មោះស្ទុះចូលទៅ ថាពះវានៅទីនោះណា ។
ថាហើយក៏ចាប់កន្ត្រាក់ចុះ ចៅយួនថាឱះលោកមេត្តា
ចាំអាចក្តីឆាន់បាយសិនវ៉ា តាប្រាក់ស្រែកថាហ៊ឹះអាដែង ។
អាឯងមេខ្លាំងតាំងជាធំ បញ្ចូលអ្នកភ្នំឲ្យកាចកោង
បានដៃឱ ហើយអាតាយហោង ឆាន់អី អាផងចុះឆាប់វ៉ា ។
យួនសៅជំងើចក្រាញរបឹង ខ្មែរខឹងស្ទុះស្រូបរូបហត្ថា
ខ្មែរទាញយួនគោងតាំងរំពា ខ្មែរធាក់យួនថាអនិច្ចាចាះ ។
ខ្មែររឹតយួនរើលើជញ្ជាំង ខ្មែររុកយួនរាំងតាំងបំរះ
ខ្មែរដាល់យួនដោលកញ្ច្រោលផ្ដាស់ ខ្មែរប្រាយយួនប្រាស់គាស់តែដៃ ។
តាប្រាក់ទំលាក់ចៅយួនខ្ទី ដល់ដីក៏ចាប់អង្រែវៃ
ងុបចុះងើបឡើងស្រែកយ៉ៃៗ ចេតវ៉ាយបន្លែក្ស័យជន្មា ។»

យួនសៅក៏ដល់នូវសេចក្ដីស្លាប់ក្នុងពេលនោះទៅ ។ តាប្រាក់ក៏កាត់ក្បាលយួនសៅយកមកជូនលោកម្ចាស់ ។លោកម្ចាស់ស្រងាក

www.budinst.gov.kh www.elibraryofcambodia.org

ចិត្តក៏បន្ទោសតាប្រាក់ថាមិនគួរសំលាប់ទេ គួរតែចាប់ទាំង រស់ ។

នៅទីបញ្ចប់ លោកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ បានសរសើរសិរីភាពរបស់តាកែដូចមានឃ្លាថា :

*«តាកែបើមើលតាមដំណើរ　　គួរកោតសសើរចិត្តវាជា*
*គួរឬកាំភ្លើងយើងបាញ់វា　　គ្រាប់ជាលាជផ្ទុះហ៊ានស៊ូះយុទ្ធ។*
*ត្រូវផ្លូលចុះប្រឹងក្រោកត្រដរ　　ដៃម្ខាងបាញ់តទាល់តែផុត*
*ចិត្តរឹងមានះគ្មានរន្ធត់　　ឥតស្លុតក្តីស្លាប់វិនាសប្រាណ ។*
*អើនេះសមពេញជាមេទ័ព　　គួររាប់ហៅថាជាទាហាន*
*មនុស្សយ៉ាងនេះកប្រមាន　　ច្រើនតែទៅពាន កំសាកញី"* ។

លោកម្ចាស់ ចាត់ចែងឲ្យគេត្រួតពិនិត្យទ្រព្យសម្បត្តិរបស់តាកែនិងបក្ខពួកប្រមូលយកមកដាក់ឃ្លាំង ។ គេយកក្បាលតាកែនិងយួនសៅមកដោតនៅដើមផ្លូវ ។

តុល្យការនៃការប្រយុទ្ធនេះគឺ ខាងតាកែមានស្លាប់ ២៦នាក់ ឯខាងលោកម្ចាស់មានស្លាប់តែពីរនាក់ទេ ។ យើងមិនអាចដឹងអំពីជំរៀតជំរែកពីខាងក្រៅក្នុងរឿងបះបោរនេះទេ តែគួរឆ្ងល់ពីវត្តមាននៃយួនសៅនៅក្នុងទីនេះ ។ ឬមួយក៏បារាំងមកបង្ករឿងនៅទីនេះ ?

មានពាក្យឃ្លោងប្រជាប្រិយ៍មួយឃ្លាពោលថា "*អាកែអាកាំង អាកែចេញច្បាំង បារាំងចូលស្រុក* ។

www.budinst.gov.kh　www.elibraryofcambodia.org

# ទឹកដី និងមនុស្ស
# មុនឆ្នាំ ១៩០៧

ចាប់ពីឆ្នាំ ១៧៩៤ គ្រួសារចៅហ្វាបែន ដែលក្រោយមកគេដាក់ឈ្មោះថា "**ត្រកូលអភ័យវង្ស** "នោះត្រួតត្រាខេត្តបាត់ដំបងនិងសៀមរាបទាំងមូល ។ តែក្រោយមក គេកាត់ដែនដីខ្លះ ហើយប្ដូរផ្លាស់ច្រើនលើកច្រើនសារ ។ នៅពេលចុងក្រោយនេះត្រកូលអភ័យវង្សត្រួតត្រាតែដែនដីតូចមួយប៉ុណ្ណោះ ។ នៅដំណាច់សតវត្សនេះ ខេត្តបាត់ដំបងមានទំហំប្រហាក់ប្រហែលសព្វថ្ងៃ តែត្រូវមានការផ្លូវដេញខ្លះ ។ ខេត្តបាត់ដំបងពេលនោះ មានស្រុកតែ៤ទេគឺ **ស្រុកបាត់ដំបង ស្រុកមោងឫស្សី ស្រុកមង្គលបុរី និងស្រុកស្រែអន្ទាក់** ។ កាលដើមស្រុកស្រែអន្ទាក់ ជាស្រុកមួយលាតសន្ធឹងនៅតំបន់ខាងលើនៃដងស្ទឹងមង្គលបុរី និងតំបន់ប៉ៃលិនសព្វថ្ងៃគ្រាន់តែជាភូមិតូចមួយ ។ នៅពេលនោះស្រុកសិរីសោភ័ណអូរជ្រៅនិងព្រះនេត្រព្រះ មិននៅក្រោមអំណាចខេត្តបាត់ដំបងទេ។

ខេត្តបាត់ដំបងជាទំនាបល្បាប់ ប្រកបដោយជីវជាតិ លាតសន្ធឹងពីទិសអាគ្នេយ៍ទៅពាយព្យ ។ នៅខាងនិរតីមានជួរភ្នំខ្ពស់ៗ

www.budinst.gov.kh www.elibraryofcambodia.org

ដែលគេហៅថាជួរភ្នំក្រវាញ មានឈ្មោះល្បី ដោយសារមានដុះក្រវាញដែលគេត្រូវការទិញយកទៅធ្វើថ្នាំកែររោគផ្សេងៗ ។ អ្នកស្រុកនៅទីនោះប្រកបរបរតែម្យ៉ាង គឺបេះក្រវាញលក់ គេហៅ ថាពួកស្លួយក្រវាញ ។ នៅតំបន់ភ្នំក្រវាញប៉ែកខាងបាត់ដំបងនេះមានកំពូលភ្នំខ្ពស់ៗ ដូចជាភ្នំមូស(១៣៣៧ម) ភ្នំទឹកព្រិល (១១២៣ម) ភ្នំតាដិត (១១១៤ម)។ ជួរភ្នំក្រវាញនេះ មានបន្តទៅខាងកើតទៀត ជាកូនភ្នំរដាច់រដោច រហូតដល់ក្បែរៗទីប្រជុំជនបាត់ដំបងដូច ជាភ្នំសំពៅ ភ្នំក្រពើ ភ្នំក្ដោង ភ្នំរំសាយសក់ ភ្នំបាណន់ ។ល។ ភ្នំរដាច់រដោចទាំងនេះមាននិទានក្នុងរឿងព្រេងចៅរាជកុល និងនាងរំសាយសក់ ដែលលោកតាលោកយាយយើងឧស្សាហ៍និទានដោយមានជំនឿមុតមាំ ។

## ១- ស្ទឹងសង្កែ

ស្ទឹងសង្កែជាស្ទឹងសំខាន់ហូរកាត់ទីប្រជុំជនបាត់ដំបង ។ ស្ទឹងសង្កែមានប្រភពនៅភ្នំទឹកព្រិល ដែលជាភ្នំខ្ពស់មួយនៅត្រង់តំបន់ប៉ៃលិន ដែលគេហៅថា ស្រុកឈើ មានស្ទឹងអូរតូចៗជាច្រើនហូរចាក់មក ដូចជាអូរក្បាលក្របី អូរគគីរ ស្ទឹងក្រញូង អូរស្ពានអូរត្រែង អូរអណ្ដូង ស្ទឹងកំពង់គល់ ។ល។

www.budinst.gov.kh www.elibraryofcambodia.org

កាលដើមឡើយ នៅប្រមាណ ៣ គ.ម. ខាងត្បូងទីប្រជុំជនបាត់ដំបង ស្ទឹងសង្កែហូរបែកជាពីរ គឺអូរដំបង និង អូរសង្កែ ។ តែក្រោយមក គេបានចាត់ចែងទប់ស្ទឹងអូរដំបងនេះ ដើម្បីឲ្យទឹកហូរមកតែមួយផ្លូវ តាមស្ទឹងដែលហូរកាត់ទីប្រជុំជនបាត់ដំបង ។

ឯកសារសរសេរដៃរបស់ព្រះគ្រូសិរីសត្ថា កែវ សាង អនុគណ ស្រុកបាត់ដំបងបានពិពណ៌នាអំពីស្ទឹងសង្កែកាលជំនាន់ដើមថា :

«តាមសេចក្ដីដំណាលរបស់ចាស់ទុំមុនៗមក និយាយថា ស្ទឹងបាត់ដំបងកាលពីដើមជាស្ទឹងតូចមួយមានទទឹងប្រហែល ៩ម ត្រង់មុខវត្តសង្កែ ហើយមានដើមសង្កែមួយដុះទេរទៅត្រើយម្ខាង ។ គេដើរលើដើមសង្កែនោះឆ្លងស្ទឹងបាន បានជាដីត្រង់នោះគេហៅថា គុម្ពសង្កែៗ ។ តមកគេបានសាងវត្តនេះឡើងហៅថា *វត្តសង្កែ* ។ ឯក្បាលស្ទឹងធំសំរាប់ខេត្តបាត់ដំបង គឺស្ទឹងនៅត្រង់ភូមិអូរដំបងសព្វថ្ងៃនេះបានជានៅខាងចុងស្ទឹងនេះ គេហៅថា **ស្ទឹងចាស់** គឺនៅត្រង់ភូមិស្ទឹងចាស់ »។

ឯកសារបានអធិប្បាយអំពីការទប់ស្ទឹងចាស់ដូចតទៅ :

«ក្នុងឱកាសដែលទប់ស្ទឹងនេះ គេធ្វើទំនប់ត្រង់ស្ទឹងបែកក្បែរវត្តខ្វែង ប៉ុន្តែទប់មិនជាប់ចេះតែបាក់ច្រើនដងច្រើនគ្រា ។ ទើប

www.budinst.gov.kh www.elibraryofcambodia.org

ពេលក្រោយ គេយកទូកថ្ងៃធំមួយមកដាក់ទទឹងព្រែក ហើយ ដាក់ដីធ្វើជាទំនប់ ។ មានចាស់ៗភាគច្រើន ដែលបានចាំរឿងរ៉ាវនិយាយតៗគ្នាមកថា គេធ្វើពិធីបួងសួង ដោយសំពាប់ស្ត្រីមានគភ៌បូជាវត្ថុសក្តិសិទ្ធិដែលរក្សាទំនប់នេះផង ។ ត្រង់នោះ ហៅថាព្រែកពណ្ណរាយ ។

មានចាស់ទុំមួយពួកទៀតនិយាយថា គេបានធ្វើកូនសាលាតំកល់បដិមាបីអង្គ គឺព្រះពុទ្ធរាព្រះហស្ត ១អង្គ ព្រះពុទ្ធប្រក់នាគ ១អង្គ និងព្រះនារាយណ៍១អង្គ នៅក្បែរទំនប់នោះ ។

តាំងពីថ្ងៃនោះមក ទំនប់ក៏លែងបាក់ ទឹកក៏ហូរតាមស្ទឹងបាត់ដំបងបណ្តាលឲ្យស្ទឹងនេះកាន់តែរីកធំឡើងៗ ។ ស្ទឹងដែលហូរតាមអូរដំបងក៏កាន់តែរាក់តូចទៅៗបន្តិចម្តងៗ ។ »

ឯកសារដដែលនេះ បានចែងអំពីកូនសាលាដែលតំកល់បដិមានោះថា ៖ «...បានសួរចាស់ទុំ ដែលនៅជិតភូមិខ្វែងនេះមានលោក ជាងភៀន ជាដើម និយាយថាកាលនៅក្មេង គាត់ឃើញមានសាលាតូចមួយរបៀបជារោងអ្នកតា ។ មនុស្សចាស់ៗនិយាយថា សាលានោះគេធ្វើដោយឈើតាត្រាវ ស្ថិតនៅក្បាលជ្រោយខាងកើត ខាងមុខវត្តខ្វែង ជិតនិងមាត់ទឹក ។....តែដល់គាត់ធំឡើង ស្រាប់តែឃើញ ដីបាក់ច្រាំងធ្លាក់មកក្នុងស្ទឹងដោយបាត់ទាំង

www.budinst.gov.kh www.elibraryofcambodia.org

រោងអ្នកតានោះផង ។»

ចំណែកឯបដិមាទាំង៣អង្គវិញនោះ ឯកសារដដែលនេះ និយាយថា : «កាលពីសម័យសៀមគ្រប់គ្រងខេត្តបាត់ដំបង ពីឆ្នាំ ១៩៤១ ដល់ ១៩៤៦ គេរើសបានព្រះពុទ្ធរូបប្រក់នាគធ្វើអំពីថ្មបុរាណ នៅក្នុងស្ទឹង ជិតទំនប់នេះ............គឺជាព្រះដែលតំកល់ក្នុងពិធីបួងសួង ពេលដែលទប់ទឹកនោះ ។

.....បានពិនិត្យឃើញ ព្រះនរាយណ៍ ដែលគេតំកល់ទុកគោរពបូជានៅក្នុងព្រៃខាងកើតវត្តខ្វែងសព្វថ្ងៃនេះ ប្រហែលជាគេនិមន្តយកព្រះនរាយណ៍ទៅទុកធ្វើសក្ការបូជាមុនពេលច្រាំងបាក់ ។ ឯព្រះរាព្រះហស្តវិញប្រហែលជាគេបានយកចេញពីកន្លែងនេះដែរ ។»

ឯកសារនេះ បានសន្និដ្ឋានថាទំនប់នេះប្រហែលជាស្ថាបនាតាំងពីមុនចៅហ្វា បែន ចូលមកកាន់កាប់ខេត្តបាត់ដំបងម្ល៉េះ គឺមុនឆ្នាំ ១៧៩៤ ទៅទៀត ។ ចំពោះរឿងនេះលោកតា រស់ ប៊ុត បាន បរិយាយថា : «នៅពេលមួយនោះ យួនបានចូលមកចាប់លោកបាឡាត់ស្ដីទីខេត្តបាត់ដំបង យកទៅឃុំទុកឯស្រុកវាអស់ពេលច្រើនឆ្នាំ ។ លោកចៅឃុនបាននាំទ័ពពីស្រុកសៀម លើកតាមវាយយកបានលោកបាឡាត់មកវិញ ។ ចាប់ពីពេលនោះមក គេក៏ទប់ស្ទឹងចាស់នេះ កុំឲ្យយួនចូលមកលឿនពេកព្រោះស្ទឹងចាស់នេះត្រង់

www.budinst.gov.kh www.elibraryofcambodia.org

ណាស់ ។» ឯវិធីទប់ស្ទឹងមាននិយាយដូចឯកសារមុនដែរ ។ «នៅពេលទប់ចុងក្រោយ គេយកដើមឈើទាំងដើមៗមកច្រុះតំរៀបគ្នាទទឹងស្ទឹង ដោយមានដាក់ទូកថ្ងៃមួយ ដែលមានស្បៀងអាហារនិងភស្តុភារផ្សេងៗ ។ គេរៀបចំពិធីបួងសួង ហើយគេហាមដាច់ខាតមិនឲ្យស្ត្រីមានផ្ទៃពោះ ដើរកាត់មុខរោងពិធី ។ នៅពេលដែលគេបួងសួងឆាកហ៊ោរឡើង ស្រាប់តែមានស្ត្រីមានផ្ទៃពោះម្នាក់ដើរកាត់មុខរោងពិធី ។ គេក៏ចាប់ស្ត្រីនោះសំលាប់ដាក់ក្នុងទូកឲ្យចាំបាតទំនប់ហើយគេក៏លុបដីចាក់បំពេញទៅ ។ លុះធ្វើទំនប់រួចហើយ គេដេញហ្វូងដំរីឲ្យដើរចុះដើរឡើងតាមអូរសង្កែ ឲ្យរបេះរបើកដីកើតជាផ្លូវទឹកធំសំរាប់ជំនន់ឆ្នាំក្រោយ ហើយកុំឲ្យទឹកហូរខ្លាំងធាក់លើទំនប់ ។»

បើយើងគិតរឿងលោកបាឡាត់ និងលោកចៅឃុននោះរឿងនេះកើតនៅពាក់កណ្តាលសតវត្សទី ១៩ ទេ មិនមែនមុនលោកចៅហ៊្វាបែននៅចុងសតវត្សទី ១៨ទេ ។ម្យ៉ាងទៀតប្រវត្តិវត្តបាឡាត់ក៏បានចែងដែរថា យួនបានមកចាប់លោកបាឡាត់រស់ នៅឆ្នាំ ១៨៣៧ យកទៅឃុំទុកស្រុកវាអស់ពេលដប់ឆ្នាំ ។

បើនិយាយពីដើមឈើដែលគេច្រុះធ្វើទំនប់នោះវិញ ដើមឈើធំៗទាំងនោះទើបតែនឹងរបេះធ្លាក់អណ្តែតទឹកអស់ ប្រហែលជា

www.budinst.gov.kh www.elibraryofcambodia.org

២០ ឆ្នាំមុននេះទេ ។

ចំពោះរឿងទំនប់នេះទៀត លោក ញ៉ិក ហួត បានប្រាប់ថា ជីដូនគាត់បានកើតទាន់ការទប់ស្ទឹងចាស់នេះ ។ នៅពេលដែលសៀមចូលមករៀបស្រុក លើកទំនប់សង់បន្ទាយ បងប្អូនខ្មែរបាននាំគ្នារត់ចូលព្រៃលាក់ខ្លួនពួនអាត្មា មិនឲ្យពួកសៀមយាយីឆក់ប្លន់ទ្រព្យសម្បត្តិ ។ លោកតាហួតបានប្រាប់ទៀតថាឲ្យតែឮមាត់សៀមចូលភូមិម្តងៗ សូម្បីតែឆ្កែក៏រត់ពួនដែរ ។

បើគិតត្រឹមជីដូនលោកតា ញ៉ិក ហួត យើងឃើញថាមានប្រហែលបីតំណមនុស្សប៉ុណ្ណោះមកទល់នឹងឆ្នាំ ១៩០៧ មិនអាចលើសពី ១០០ឆ្នាំបានឡើយ ។

ម្យ៉ាងទៀត អ្នកធម្មជាតិវិទ្យាបារាំងឈ្មោះលោក មូហូ ដែលបានមកធ្វើទស្សនកិច្ចនៅបាត់ដំបង នៅពាក់កណ្តាលសតវត្សទី ១៩ បានសរសេរថា ស្ទឹងសង្កែនៅពេលនោះ មានទទឹងប្រហែល ១២ ម៉ែត្រទេ នៅកន្លែងខ្លះ ។

មានមតិខ្លះនិយាយថា ស្ទឹងចាស់ គឺស្ទឹងអូរដំបង ជាផ្លូវទឹកត្រង់ទៅទន្លេសាប អាចឲ្យសឹកសត្រូវលើកទ័ពមកវាយបានដោយងាយ ទើបគេទប់ស្ទឹងនេះឡើង ។ តែតាមពិតបើយើងមើលផែនទីយើងនឹងឃើញថា ស្ទឹងចាស់បត់បែនក្ងិកក្ងក់ជាងស្ទឹងសង្កែ

www.budinst.gov.kh www.elibraryofcambodia.org

ឆ្ងាយណាស់ ។

បើនិយាយពីយុទ្ធសាស្ត្រវិញ ស្ទឹងសង្កែក៏មិនមែនជាចំណុចមាំជៀតចូលមិនបាននោះទេ ព្រោះតាំងពីមុនចៅហ្វាបែនមកកាន់កាប់បាត់ដំបង ទ័ពតៃជោវទែនបានវាយរុញច្រានទ័ពចៅហ្វាបែន រហូតដល់មានការប្រយុទ្ធគ្នាយ៉ាងសាហាវនៅត្រង់តំបន់ដូនទាវ ។

(ឯពាក្យថា ដូនទាវ នេះទៀត ក៏មានទាក់ទងនិងចៅហ្វាបែនដែរ ។ ឯកសាររបស់ព្រះគ្រូសិរីសត្ថា កែវ សាង យោងតាមព្រះថេរដីការរបស់សម្តេចព្រះវនរ័ត អ៊ុំ ទូត បាននិយាយថា «កាលចៅហ្វាបែនរត់ពីស្រុកខ្មែរមកបាត់ដំបង មានភរិយាម្នាក់ ឈ្មោះនាងទាវ ។ ក្រោយមក នាងទាវនឹករលឹកស្រុកកំណើតពេកក៏សុំលាចៅហ្វាបែនត្រឡប់ទៅស្រុកវិញ តែចៅហ្វាបែនមិនព្រមអនុញ្ញាតឲ្យទៅសោះ ។ នាងទាវក៏លួចរត់ធ្វើដំណើរតាមទូក តាមស្ទឹងសង្កែត្រឡប់ទៅស្រុកវិញ ។ នៅពេលនោះ ចៅហ្វាបែនដឹងទាន់ក៏ចាត់បាវបំរើឲ្យតាមនាងទាវ ដោយបញ្ញត្តិថា បើទាន់ត្រង់ណាឲ្យសំលាប់ចោលត្រង់នោះ ។ ពួកបាវបំរើតាមទាន់នាងទាវ ក៏សំលាប់នាងទាវកប់ត្រង់ក្បាលជ្រោយដូនទាវសព្វថ្ងៃ ។ ខ្មោចនាងទាវនោះ ក៏ក្លាយជាបីសាចសំរាប់ទទួលក្រយាបូជាពីអ្នកដំណើរចុះឡើងតាមផ្លូវទឹក ។ ហេតុទាំងនេះហើយដែលនាំឲ្យមានពាក្យ ថា

www.budinst.gov.kh www.elibraryofcambodia.org

ផ្លូវទាវ រហូតដល់សព្វថ្ងៃ ។) •

ជាមួយគ្នានឹងការទប់ស្ទឹងនិងសាងកំផែងនេះ គេបានបញ្ចុះសីមា អំពីថ្មភក់ មានចារអក្សរអាគមគាថា ដាក់នៅបាតស្ទឹងសង្កែត្រង់វត្តកំពង់សីមាមួយកន្លែង នៅពាមសីមាដែលជាទីប្រសព្វមុខនៃស្ទឹងស្រែងនិងស្ទឹងសង្កែមួយកន្លែង ។ គេដាក់សីមាក្នុងស្ទឹងនេះ ដើម្បីការពារសឹកសត្រូវនិងសត្វសាហាវផ្សេងៗ ។ ចាស់ៗនិយាយថា កាលដើម សម្បូរក្រពើណាស់ ហើយក្រពើតែងមកខាំមនុស្សរាល់ៗឆ្នាំ ។ តែចាប់តាំងពីមានបញ្ចុះអាគមគាថានៅក្នុងស្ទឹងមក ក្រពើដែលមុជទឹកហែលមកនោះ ត្រូវផុសងើបពីកំពង់សីមារហូតដល់ពាមសីមា ដោយសារតែបារមីនៃសីមានេះ ។ គេអាចស្ដាប់សីមានេះបាន នៅរដូវទឹកស្រក នៅកំពង់សីមា ។ ដោយសារក្រពើមុជទឹកមិនលិចនេះ អ្នកស្រុកអាចដឹងខ្លួនទាន់មុនពេលមកដល់នៃក្រពើ ហើយគ្រោះថ្នាក់ដោយក្រពើខាំ ក៏បាត់ទៅដែរ ។

ក្នុងគោលបំណងដដែល គេបានបញ្ចុះថ្មគោលនៅជុំវិញទីក្រុងដែលយើងអាចប្រទះឃើញថ្មនេះត្រង់នេះមួយត្រង់នោះមួយ រហូតដល់សព្វថ្ងៃនេះ គឺជាថ្មធំៗដែលគេកប់ស្មើដី មានច្រើននៅជុំវិញវត្តកំពង់សីមា ។

www.budinst.gov.kh www.elibraryofcambodia.org

## ២- អំពីប្រជាជនបាត់ដំបង

**ក- ចំនួនប្រជាជន** ៖ ខេត្តបាត់ដំបង កាលជំនាន់ដើមមិនសូវមានមនុស្សម្នាប៉ុន្មានទេ ។ ដីមួយភាគធំជា ព្រៃ ព្រៃរបោះឬជាវាលស្មៅវាលស្មោង ។ យើងឃើញស្រាប់ហើយលោកម្ចាស់ទៅបរបាញ់សត្វនៅ អូរស្រឡៅ នៅរាំងកេសី ដែលជាវាលស្បូវដ៏ធំធេង ។

កាលពីរវាងឆ្នាំ ១៩០០ មនុស្សមានច្រើនតែនៅតាមដងស្ទឹងពីកំពង់អំពិលរហូតទៅដល់បាក់ព្រា នៅតាមដងស្ទឹងមោងខ្លះ តាមដងស្ទឹងមង្គលបុរីខ្លះ ។ ឯភូមិដែលនៅឆ្ងាយពីដងស្ទឹងមានតិចតួចណាស់ ដូចជាកំពង់ព្រះនិងគាស់ក្រឡ ។ល។

អ្នកប្រាជ្ញបារាំងឈ្មោះ ប្រឺយ៉ាង ដែលបានមកដល់បាត់ដំបងកាលពីឆ្នាំ ១៨៨៤ បានសន្និដ្ឋានប្រជាជននៅបាត់ដំបងសម័យលោកម្ចាស់ថា មានប្រហែល ១០០.០០០នាក់ ហើយមានបែងចែកដូចតទៅ ៖

| | មនុស្សប្រុសអាយុច្រើនជាង ១៨ឆ្នាំ | ស្រីនិងកូនក្មេង |
|---|---|---|
| ខ្មែរ | ១៥.០០០ នាក់ | ៤៥.០០០ នាក់ |
| ខ្មែរដែលប្រកាស ខ្លួនថាសៀម | ៤ ០០០នាក់ | ១៥.០០០ នាក់ |
| សៀម | ២ ០០ នាក់ | ៦ ០០ នាក់ |

www.budinst.gov.kh www.elibraryofcambodia.org

| | | |
|---|---|---|
| លាវ | ១.៤០០ នាក់ | ៤.៤០០ នាក់ |
| ថៃ | ១០០ នាក់ | ៣ ០០ នាក់ |
| យួន | ២.០០០ នាក់ | ៣.០០០ នាក់ |
| ចិន | ៣.០០០ នាក់ | ៣.០០០ នាក់ |
| កូឡា | ៣.០០០ នាក់ | ៣.០០០ នាក់ |
| **ចូករួម** | **២៩.៨០០ នាក់** | **៧៤.៤០០នាក់** |
| **រួមទាំងអស់** | | **១០៤.២០០ នាក់** |

យើងសង្កេតឃើញថា ទោះបីខេត្តបាត់ដំបង នៅក្រោមអំណាចសៀមក៏ដោយ ក៏ជនជាតិសៀមមិនអាចមករស់នៅបានងាយនៅបាត់ដំបងដែលមានដីសំបូរជីរជាតិនិងត្រីសាច់នោះទេ ។ យើងឃើញមានសៀមតែ ៨០០ នាក់ប៉ុណ្ណោះ ដោយរាប់ទាំងស្រីនិង កូនក្មេងផង ។

តែការប៉ាន់ប្រមាណប្រជាជនបាត់ដំបងដោយលោក ប្រ៊ីយាងនេះមិនច្បាស់លាស់ទេ ព្រោះមិនមែនជាការជំរឿនតាមលក្ខណៈបច្ចេកទេស គេអាចសន្និដ្ឋានបានថា ប្រជាជនមិនមែនតិចដូចនេះពេកទេ ព្រោះនៅឆ្នាំ ១៩២១ គឺ ៣៧ឆ្នាំក្រោយ គេបានធ្វើជំរឿនប្រជាជន ឃើញថា បាត់ដំបងមានប្រជាជន ៣០៧.០០០នាក់ ។

www.budinst.gov.kh www.elibraryofcambodia.org

គេពិបាកជឿ ណាស់ថា នៅចន្លោះ ៣៧ឆ្នាំ ពីឆ្នាំ ១៨៨៤ ដល់ ១៩២១ ប្រជាជន បាត់ដំបង អាចកើនរហូតទៅបីដង ។

## ខ- សង្គមប្រជាជន-

នៅសម័យលោកម្ចាស់ ប្រជាជនចែកជាវណ្ណៈច្រើនតែមិនច្រើនដល់នៅប្រទេសឥណ្ឌា ឬ ប្រទេសដទៃខ្លះទៀតទេ ។ ការដែលចំឡែកចំពោះយុវជនជាន់ក្រោយ គឺទាសភាព ដែលបារាំងបានបង្ខំឲ្យលោកម្ចាស់បំបាត់ចោល តែមិនបានសំរេច ។ នៅសម័យនោះ ប្រជាជនចែកជា ៣ វណ្ណៈ ៖

### ១- វណ្ណៈអភិជន-

គឺជាវណ្ណៈខ្ពង់ខ្ពស់ មានវង្សត្រកូលលោកម្ចាស់នេះជាអាទិ ហើយនិងវង្សត្រកូលពួកមន្ត្រីធំៗតមក ដូចជាលោកព្រះឃ្លាំង លោកមន្ត្រីនាយកជាដើម ។ ពួកអភិជនមានដីស្រែតាមដងស្ទឹងសឹងតែទាំងអស់ជាកម្មសិទ្ធិរបស់គេ ។ ពួកអភិជនមិនមែនជាត្រកូលក្សត្រទេ មិនប្រើរាជសព្ទទេ តែមានភាសាខ្ពស់ សំរាប់អ្នកតូចតាចនិយាយជាមួយគេ ។ នៅផ្ទះ គេមានបាវបំរើស្ដាំ ឆ្វេង ហើយមានពិធីការផ្សេងៗបង្ខំដាក់សុជីវធម៌ ពិសេសលើរាស្ត្រតូចតាច ។ អ្នកណាដើរកាត់មុខផ្ទះអភិជន ដោយមិនយកក្រមា

www.budinst.gov.kh www.elibraryofcambodia.org

ក្រវាត់ចង្កេះ ឬដើរហូចច្រៀងគេចាត់ទុកជាព្រហើន ហើយគេអាចចាប់អ្នកនោះយកទៅវាយប្រដៅ ឬជូនកាលមានយកទៅសំលាប់ចោលបើរឹងទទឹង ។ ផ្ទុយទៅវិញ កូនពួកអភិជនអាចព្រហើនកោងកាចដាក់រាស្រ្តប្រជាវិញបាន ។

ពួកអភិជនច្រើនតែមានគោរម្យងារសំរាប់ហៅ គេមិនសូវហៅចំឈ្មោះទេ ។ គេមានលំដាប់សក្តិទៀតផង ដូចជា ចៅហ្វ្រះយ៉ា-ហ្វ្រះយ៉ា-ហ្វ្រះឬព្រះ-ហ្លួង-ឃុន-ម៉ឺន ។ លំដាប់សក្តិនោះមានគោរម្យងារពីក្រោយដូចជា ចៅហ្វ្រះយ៉ាកថាថនហ្វ្រះយ៉ាអធ័យ ហ្វ្រះយ៉ាព្រះឃ្លាំង ហ្វ្រះយ៉ាមនោមេត្រី ហ្លួងកំភោតហ្លួងរិទ្ធិពលសែន ព្រះភិនិត្យសម្បត្តិ ឃុនពិនិត្យអក្សរ ឃុនសារកិ្តកិច្ច ។ល។

តែយើងពិបាកដឹងលំដាប់សក្តិណាស់ ព្រោះអ្នកស្រុកច្រើនហៅតែងារ ដូចជាលោកព្រះឃ្លាំង លោកស្រីពិភត្តិ លោកស្នេហាប្រទេស លោកស្រីអញ្ចិត ។ល។

វណ្ណៈអភិជននេះជាវណ្ណៈតពូជពង្ស ខ្លះជាឋានៈបានដោយសារសមត្ថភាព ខ្លះជាឋានៈបានដោយការផ្គាប់ផ្គុនសូកប៉ាន់ ។ អ្នកមានឋានៈជាចៅហ្វ្រះយ៉ា មានតែម្នាក់ទេគឺ **លោកម្ចាស់** ។ វណ្ណៈលោកម្ចាស់នេះ ជាវណ្ណៈតពូជតពង្ស ។ គេត្រូវហៅកូនលោក

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំង ទី ៤



ជីវភាពរាស្ត្រសាមញ្ញ (ម.ម)

www.budinst.gov.kh www.elibraryofcambodia.org

ម្ចាស់ថា ឃុន ដូចជាឃុនឈឿម ឃុនហ៊ឹង ឃុនឃួង ។ តែបើមាន សមត្ថភាពនៅពេលពេញវ័យ គេអាចតំឡើងសក្តិពី ឃុន ទៅហ្លួង ទៅផ្រះយ៉ាបានដូចជា ឃុន ឈឿម ឡើងជាផ្រះយ៉ាអផ័យ ឃុន ឃួង ឡើងជាហ្លួងកោវិទ ។ល។ ចៅលោកម្ចាស់ គេច្រើនហៅថា នាយ ដូចជា នាយជា ។

## ២- វណ្ណៈរាស្ត្រសាមញ្ញ :

គឺជាវណ្ណៈប្រជារាស្ត្រធម្មតា ប្រកបរបរកសិកម្ម សិប្បកម្ម នេសាទ ពាណិជ្ជកម្ម ។ គឺជាវណ្ណៈដែលគេហៅថា អ្នកជា (មិនខ្ញុំគេ) ។ វណ្ណៈរាស្ត្រសមញ្ញត្រូវបង់ពន្ធដារជូនលោកម្ចាស់ ហើយ អាចលោកម្ចាស់កេណ្ឌឲ្យធ្វើការផ្សេងៗ ដូចជានៅពេល មានបុណ្យទាន ឬ ទៅបាញ់សត្វជាដើម ។

## - វណ្ណៈទាសករ-

គឺជាវណ្ណៈខ្ញុំកញ្ជះគេ ។ ឈ្លើយសង្គ្រាម អ្នកមានទោស អ្នក ជំពាក់ប្រាក់គេ ត្រូវធ្លាក់ខ្លួនជាខ្ញុំកញ្ជះគេ ធ្វើការឲ្យគេដោយឥត យកកំរៃ ដោយគ្រាន់តែបានបាយមួយចំអែត និងខោអាវមួយ ចង្កេះ ។ ទាសករប្រភេទខ្លះ អាចរំដោះខ្លួនបានដោយសារការ យកលុយទៅលោះ ។ យើងជំពាក់ប្រាក់គេ ១០០បាត យើងត្រូវ

BUDDHIST INSTITUTE LIBRARY

www.budinst.gov.kh www.elibraryofcambodia.org

ធ្វើខ្ញុំកញ្ចះគេ រហូតដល់ថ្ងៃដែលយើងយកប្រាក់ទៅលោះមកវិញ ។

ទាសករដែលគេហៅថា "ខ្ញុំ" នោះ មានច្រើនសណ្ឋានដូចជា **ខ្ញុំរបិប ឬ ខ្ញុំក្នុង** ត្រូវរស់នៅបំរើគេរហូតខួបប្រាំងខួបវស្សា ។ បើមានកូនកើត កូននោះត្រូវធ្លាក់ខ្លួនជាខ្ញុំគេទៀត គេហៅថា **កូនក្រោល** ។ "**ខ្ញុំក្រៅ**" អាចនៅផ្ទះសំបែងបានក្រោយដែលធ្វើស្រែរួចហើយៗ អាចរកលុយកាក់មកលោះខ្លួនបាន ។

បើនិយាយពីទាសភាពនេះ យើងឃើញថាក្រៅពីអភិជនសឹងតែគ្មានអ្នកណារួចខ្លួនជាអ្នកជាពិតប្រាកដទេ ។ រាស្ត្រសាមញ្ញត្រូវមានកំណែនដោយឥតឲ្យកំរៃ ទៅបរបាញ់សត្វ ជួយផ្តល់សម្ភារៈ និងភស្តុភារផ្សេងៗជូនលោកម្ចាស់ឬ អភិជនណាដែលខ្លួនស្ម័គ្រ ។ ដូចនេះរាស្ត្រសាមញ្ញក៏មានជំពាក់បំណុលនឹងអភិជនដែរ ។ គ្រប់គ្នា ត្រូវរើសលោកធំណាម្នាក់ធ្វើជាចៅហ្វាយ ហើយបំរើគេគ្រប់ពេល ដែលគេមានធុរៈ ។ គេហៅយើងថា *«ពាវកំលាំង»* ។

## គ- ជនបរទេស-

គេអាចចាត់ទុកជាជនបរទេសគឺចិននិង យួន ។ ឯសៀម លាវ និងកូឡា គេចាត់ទុកជាជាតិជាមួយគ្នា ព្រោះប្រទេសសៀមមានជនជាតិទាំងនេះជាម្ចាស់ស្រុក តាំងពីយូរណាស់មកហើយ ។ សៀមបោកប្រាសជនជាតិខ្មែរ លាវ មន ថាជាបងប្អូនគ្នាមាន

www.budinst.gov.kh www.elibraryofcambodia.org

សាច់ឈាមកំណើតជាមួយគ្នា ។

ជនជាតិចិនមកតាំងនៅបាត់ដំបង តាំងពីយូរណាស់មក ហើយ ។ ព្រះវិហារចិននៅផ្លូវលេខ ១ ឬនៅចុងស្ពានដែក មាន តាំងពីមុនលោកម្ចាស់ទៅទៀត ។ តាំងពីពេលនោះមកដល់ពេល នេះ ចិនប្រកបរបរតែម្យ៉ាងគឺពាណិជ្ជកម្ម ។ ចិនបាននាំគ្រឿង ឧបភោគបរិភោគពីស្រុកក្រៅមកលក់នៅបាត់ដំបង ។ ជនជាតិចិន ច្រើនរស់នៅតែក្នុងទីប្រជុំជន ។

ចិនខ្លះបានក្លាយទៅជាអ្នកមាន ហើយទទួលការរាប់អានពី លោកម្ចាស់ៗក៏ឲ្យឋានន្តរសក្តិ ដូចជាលោកភក្តីពាណិជ្ជ យ៉ាង លោកស្រី ពិភក្តិ តាំង ស៊ា លោកស្នេហាប្រទេស ។ល។ ក្រោយ ដែលបានបណ្តាសក្តិនេះហើយ អភិជនថ្មីនេះត្រូវស្លៀកពាក់ឯក សណ្ឋានសំពត់ចងក្បិន អាវកត្រង់ ពាក់សក្តិយស ដូចមន្ត្រីដទៃ ទៀតដែរ ។ តែដំបូង គាត់មិនព្រមកាត់កំប៉ោយដែលជាទំលាប់ ចិនទេ ។ អ្នកស្រុកតែងឡកឡឺយឲ្យអភិជនថ្មីនេះថា«*កំប៉ោយចិន ក្បិនខ្មែរ*» ។ អស់លោកចិនទាំងនេះ ទ្រាំមិនបានក៏សុខចិត្តកាត់ កំប៉ោយទៅ ទើបមានពាក្យថា «*ចិនដាច់កំប៉ោយ*» ។

តាមធម្មតា នៅពេលនោះ ចិនតែងទុកសក់វែងហើយចងជា កំប៉ោយដោយមានបន្តអំបោះសូត្រ មូរជុំវិញកំប៉ោយនោះ ។ ពួក

www.budinst.gov.kh www.elibraryofcambodia.org

ចិនៗខ្លាចតំរូតភូថនណាស់ ។ ចិនមកស្រុកខ្មែរមិនសូវយកប្រពន្ធមកទេ ច្រើនតែមករៀបការជាមួយខ្មែរ ។

ជនជាតិយួនរស់នៅតាមដងស្ទឹង មានមុខរបរនេសាទនិងសិប្បកម្ម ។ យួនមានច្រើននៅភូមិខ្សាច់ពោយ ហើយច្រើនកាន់សាសនាកាតូលិក ។ យួនច្រើនប្រើសំពត់ព្រៃរលោងៗជាសំលៀកបំពាក់ បានជាមានពាក្យថា ព្រៃយួន ។ ម្យ៉ាងទៀតយួនចូលចិត្តស្លៀកខោឡាញ់ ។ មានពាក្យឃ្លោងបុរាណថា«*ដីរីយោល ដៃស្រីថ្លៃយោលខ្លួន សក់យោលក្រមួនយួនយោលខោឡាញ់ ។*»

យួនច្រើនរស់នៅជាសហគមន៍ដាច់ដោយឡែក មិនសូវរៀបការជាមួយ ខ្មែរដូចចិនទេ ។

## ឃ- សុខុមាលភាពប្រជារាស្ត្រ-

នៅសម័យលោកម្ចាស់ ប្រជារាស្ត្ររស់នៅត្រដាបត្រដួសពិបាកជំនះនឹងធម្មជាតិណាស់ ។ ជំងឺរាត្បាតផ្សេងៗ បានធ្វើឲ្យមនុស្សស្លាប់អស់សឹងតែពាក់កណ្តាលក្នុងមួយឆ្នាំៗ ហើយជាពិសេសច្រើនតែស្លាប់កូនក្មេង ។

លោកម្ចាស់ មិនដែលមានគំនិតកសាងមន្ទីរពេទ្យសំរាប់ជួយសង្គ្រោះប្រជារាស្ត្រទេ ។ ពេលមានជំងឺ អ្នកស្រុកប្រើតែសំបកឈើបើមឈើ ធ្វើជាថ្នាំកែរោគ ។ មន្តអាគមគាថារបស់គ្រូស្តោះព្រួស

www.budinst.gov.kh www.elibraryofcambodia.org

អាចសង្គ្រោះបានតែអ្នកមាននិស្ស័យ ។ គេឮថា កាលដើមនៅវត្តកណ្ដឹងមានលោកគ្រូស្ដោះព្រួសពូកែមួយអង្គព្រះនាម ចាន់ ត្រុស ពូកែខាងរោគបាក់ដៃបាក់ជើងនិងមើលរោគផ្សេងៗ ។ លោកគ្រូ ចាន់ ត្រុស ពូកែហួសពីកាស្មាន ។ គេថា នៅពេលនោះ បើមានអ្នកណាកើតអាសន្នរោគ ឲ្យតែបានសែងចូលក្នុងវត្តកណ្ដឹងមុខតែជាសះស្បើយ មិនបាច់ផឹកថ្នាំទេ ។ នៅសម័យលោកម្ចាស់ឃុំ លោកគ្រូ រស់ នៅវត្តកណ្ដឹងដដែលនេះក៏ពូកែសក្ដិសិទ្ធិដែរ ។

តែការព្យាបាលរោគតាមរបៀបទាន់សម័យមិនទាន់មានទេ ។ នៅក្នុងក្រុង មានហាងចិនសែពីរកន្លែងលក់ថ្នាំមកពីស្រុកចិន តែខ្មែរមិនសូវប្រើថ្នាំចិនសែតែមួយមុខទេ ។ អ្នកមាន ឬអ្នកធំមាន អាស្ពីរីន ពីរ៉ាមីដុង ប្រើដែរ តែថ្នាំទាំងនេះទិញមកពីភ្នំពេញ ឬពីបាងកក ។

លោក អុង ប៉ាង តឹក បានប្រាប់ថា នៅហាងរូសិល មានលក់ថ្នាំបារាំងមួយមុខដែរគឺ អែយ៉ូដាយ ដែលក្រោយមកហៅតាមបារាំងថា អ៊ីយ៉ូឌីន គឺថ្នាំក្រហមសំរាប់លាបដំបៅ ។ លោកតា ឥន្ទ សុន្ទរ៍ បានប្រាប់បន្ថែមថា កាលគាត់នៅពីតូចៗ ឪពុកគាត់បាននាំគាត់ទៅបណ្ដុះអុតនៅហាងរូសិលជាមួយនឹងកុមារដទៃទៀត ។ តែការនាំឲ្យពិបាកចិត្តនោះ គឺនៅស្ថានកុងស៊ុលបារាំង មានគិលានុប្ប

www.budinst.gov.kh www.elibraryofcambodia.org

ដ្ឋានមួយដែរ តែលោកម្ចាស់ហាមដាច់ខាតមិនឲ្យរាស្ត្រប្រជាទាក់ទងជាមួយកុងស៊ុលបារាំងនេះទេ ។ លោកម្ចាស់បាញ់ចោលអ្នកណាហ៊ានរឹងទទឹងទៅទាក់ទងជាមួយបារាំង ។

ម្យ៉ាងទៀត នៅឆ្នាំ ១៩០៤ ខាងសាសនាកាតូលិក មានបើកមន្ទីរពេទ្យតូចមួយដែរ តែរាស្ត្រខ្មែរកាន់ពុទ្ធសាសនា មិនទៅជួបមុខពួកអសេយ្យសាសន៍ទាំងនោះទេ ។ នៅពេលជាមួយនេះ គេក៏មានបើកមន្ទីររក្សាក្មេងកំព្រាមួយដែរ ។

## ច- សំលៀកបំពាក់និងការតុបតែងកាយ.-

កាលពី៧០ឆ្នាំមុន ដោយសារសង្គមខ្មែរនៅបាត់ដំបងចែកជាវណ្ណៈច្បាស់លាស់ សំលៀកបំពាក់និងការតុបតែងកាយក៏មានភាពខុសគ្នាពីវណ្ណៈមួយទៅវណ្ណៈមួយដែរ ។ ទាសកររកតែខោស្លៀកគ្មាន ច្រើនតែស្លៀកសំពតអាវដែលគេឈប់ប្រើហើយៗយកមកប៉ះច្រើនជាន់ច្រើនត្រួត ។ រាស្ត្រសាមញ្ញមិនសូវសម្បូរខោអាវណាស់ដែរទេ ស្លៀកខោអាវដាច់រយ៉ៃប៉ះមុខប៉ះក្រោយ ។ តែពួកអភិជននិងអ្នកមានធំស្លៀកពាក់និងតុបតែងកាយតាមរបៀបទំនើបបើយើងមិនបានគិត មុខតែស្មានខុសហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

## ផ្ទាំង ទី ៦



សំលៀកបំពាក់បុរស (ប.ម)



សំលៀកបំពាក់ស្ត្រី



កុមារ (ប.ម)

www.budinst.gov.kh www.elibraryofcambodia.org

- សំលៀកបំពាក់ប្រុស.-

នៅពេលធ្វើស្រែចំការឬលីសែង គេនិយមស្លៀកខោខ្លីត្រឹមក្បាលជង្គង់ពាក់អាវកមូលដៃខ្លី មានពុះទ្រូង ដាក់ឡេវពីរ ដែលគេហៅថា "អាវប៉ែក "។ អ្នកក្រត្រូវមានសំលៀកបំពាក់បំរុងទុកនៅពេលមានបុណ្យទាន ។ ពេលបុណ្យ អ្នកក្រនិយមស្លៀកសំពត់ចងក្បិន ឬ ខៀន ពាក់អាវប៉ែក ហើយមានក្រមាចងក្រវាត់ពីក្រៅអាវ ។ អ្នកមានច្រើនពាក់អាវកត្រង់ ហៅថា "អាវកត " ស្លៀកសំពត់ចងក្បិន ពាក់ស្បែកជើងឃ្លុប ពាក់ស្រោមជើងវែង ។ នៅពេលមានបុណ្យ ឬពិធីផ្សេងៗ ទាំងនាម៉ឺនទាំងអ្នកមានធនធានមធ្យមនិយមពាក់អាវផាយ ។ អាវផាយជាអាវធំ មានដៃវែងរលុងហើយស្រុងដល់ក្បាលជង្គង់ធ្វើអំពីសំពត់ព្រែស្តើង មានប៉ាក់ផ្កាសំរាប់ពាក់ក្រៅអាវ ។ នៅពេលធម្មតា មនុស្សតិចណាស់ចេះពាក់ស្បែកជើង ។ មានតែ មន្ត្រីទេដែលពាក់ស្បែកជើងទៅតាមឯកសណ្ឋានដែលគេបញ្ញត្តិ ។ ពេលដើរធម្មតា គេឃើញមានអ្នកខ្លះពាក់ស្បែកជើងផ្ទាត់ មានខ្សែជំពាមធ្វើពីស្បែកគោទាំងកំរោលដែលគេហៅថា ស្បែកជើង កូឡា ព្រោះគេនាំយកមកពីតំបន់ប៉ៃលិន ។

www.budinst.gov.kh www.elibraryofcambodia.org

- សំលៀកបំពាក់ស្ត្រី.-

ដូចសព្វថ្ងៃដែរ ម៉ូតសំលៀកបំពាក់ស្ត្រីផ្លាស់ប្តូរញឹកញាប់ណាស់ ។ តាមធម្មតាគេនិយមប្រើអាវបំពង់ជាមួយសំពត់ចងក្បិន។ ពេលចេញដើរ គេច្រើនពាក់អាវនាងណយ ដែលមានដៃវែង ។

នៅពេលធ្វើដំណើរតាមរទេះគោ គេមានអាវម្យ៉ាងគ្មានដៃមានក មានដាក់ខ្សែរសំរាប់ពាក់ក្រៅអាវ កុំឲ្យធូលីប្រឡាក់អាវហៅថា អាវបេប្វូរ (ប្រែថាអាវស្លឹកឈូក)។ គេច្រើនប្រើខ្សែរម្យ៉ាងហៅថាខ្សែរកាឌុម ។ ស្រីតិចណាស់ចេះពាក់ស្បែកជើង ។ ស្រីអភិជនច្រើនពាក់ស្បែកជើងឃ្លុប និងពាក់ស្រោមជើងដូចប្រុសដែរនៅពេលមានបុណ្យទាន ឬគេប្រើស្បែកជើងផ្ទាត់មានឃ្លុបមុខឬមានប៉ាក់ឌិន ។ ស្បែកជើងទាំងស្រីទាំងប្រុស ច្រើនទិញមកពីបរទេស ។

- សក់ក្បាល.-

ទាំងស្រីទាំងប្រុសនិយមកាត់សក់ខ្លី ហៅថា*សក់ផ្កាថ្កូវ* តែស្រីច្រើនទុកឲ្យមានជើងសក់វែង ដែលគេហៅថា ទុករៃ ។ កាលពីជំនាន់លោកកថាថន ញ៉ុញ ពួកស្រីល្ខោនត្រូវតែដកសក់ជុំវិញផុកដោយលាបខ្លាញ់ដំរីមិនឲ្យដុះរហូត ។

គេនិយមកោរសក់ឲ្យក្មេង ទាំងស្រីទាំងប្រុសដោយមានទុក

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំង ទី ៧




បាត់ដំបងនៅឆ្នាំ ១៩០៧

www.budinst.gov.kh www.elibraryofcambodia.org

ផ្កាក ។ ផុកនៅលើហៅថា កំប៉ោយ ផុកនៅខាងក្រោយហៅថា កន្ទុតអួង ។ បើមានផុកពីរនៅសងខាង គេហៅថា ផុកទីទុយ ។ ក្មេងខ្លះទុកផុកពីរ ឬ បួនកន្លែង ។ គេបួងផុក ដោយមានដាក់ ស្មៀតសក់ជូនកាលធ្វើអំពីមាសឬដាំពេជ្រ ។

នៅពេលអាយុបាន ១៣ ឬ ១៤ឆ្នាំ គេប្រារព្ធពិធីកោរសក់ គឺ កោរផុកចោលហើយកាត់សក់ដូចចាស់ៗ ។ អ្នកមាន ឬអ្នកធំធ្វើ បុណ្យយ៉ាងអ៊ឹកធឹកនៅពេលកោរសក់ឲ្យកូននេះ ។ តែ អ្នកក្រ រង់ចាំតែថ្ងៃខែរាហ៍ទើបនាំគ្នាទៅវត្តឲ្យលោកសង្ឃស្រោចទឹកបង្គ្រប់ កិច្ច ហើយកោរផុកចោលទៅ ។ នេះជាពិធីសាមញ្ញបំផុត បង្ហាញ ឋានៈទាបតូចរបស់ខ្លួន ។

## ៣- ទីប្រជុំជនបាត់ដំបងនៅឆ្នាំ ១៩០៧

តាំងពីយូរយារណាស់មកហើយ ក្រុងបាត់ដំបងមានទីតាំងនៅ ត្រង់ដដែលគ្រាន់តែផ្លាស់ប្តូរបន្តិចបន្តួចប៉ុណ្ណោះ គឺលាតសន្ធឹងតាម ត្រើយខាងឆ្វេងនៃស្ទឹងសង្កែ តាំងពីភាសុីស្រាខាងត្បូងកំផែងរហូត ដល់ព្រៃកមហាទេព ។ កាលនៅឆ្នាំ១៩០៧ បាត់ដំបងជាទីប្រជុំជន តូច មានផ្លូវថ្នល់តែមួយស្របតាមដងស្ទឹង ។ អ្នកស្រុកសង់ទីលំនៅ រកេតរកូតសងខាងផ្លូវថ្នល់នេះ ។ អ្នកប្រាជ្ញបារាំងឈ្មោះ ដឺឡាប៉ក បានមកធ្វើទស្សនកិច្ចនៅបាត់ដំបងកាលពីឆ្នាំ ១៨៨០ បានសន្និដ្ឋាន

www.budinst.gov.kh www.elibraryofcambodia.org

ថាទីប្រជុំជនបាត់ដំបង មានប្រជាជនប្រហែល ២៥.០០០នាក់ ។ គេអាចចែកទីក្រុងបាត់ដំបង នៅពេលនោះជាពីរសង្កាត់គឺ :

- សង្កាត់ មុខកំផែង
- សង្កាត់ ផ្សារស្វាយប៉ោ

## ក/ សង្កាត់មុខកំផែង

នៅត្រើយខាងលិចនៃដងស្ទឹងសង្កែ ខាងត្បូងទីប្រជុំជនមានកំផែង ធ្វើអំពីអិដ្ឋបូកបាយអរ បណ្តោយ ៧២០ម៉ែត្រ គឺពីត្រង់ផ្លូវបំបែកទៅប៉ៃលិន មកទល់និងមន្ទីរប្រៃសណីយ៍សព្វថ្ងៃ ហើយមានទទឹង ៤៨០ម៉ែត្រ គឺពីផ្លូវលេខ១ ដល់ក្រោយពន្ធនាគារសព្វថ្ងៃ ។

នៅខាងចុងនៃឯកសារនេះ នឹងមានរៀបរាប់អំពីកំផែងនេះដែលគេរុះរើចោល តាំងពីឆ្នាំ ១៩១០ ។

នៅខាងត្បូងកំផែង ត្រង់ផ្សារលើសព្វថ្ងៃ មានរោងបិតស្រារបស់លោកស្រីពិភត្តិ ។ តាមដងស្ទឹង ហូរហែទៅទិសខាងជើងមានផ្លូវថ្នល់មួយ កាត់មុខកំផែង និងកាត់ទីប្រជុំជន ។

មកដល់ត្រង់ជ្រុងអាគ្នេយ៍នៃកំផែង ផ្លូវថ្នល់បែកជាពីរ គឺមួយស្របតាមជើងកំផែង មួយទៀតបែកទៅមាត់ស្ទឹងទៅជួបផ្លូវទី១ជាផ្លូវធំ នៅអូរតាគាំ ។ នៅមុខក្លោងទ្វារទាំងពីរខាងកើតនៃកំផែង មានផ្លូវពីរកាត់ទទឹង ភ្ជាប់ផ្លូវស្របកំផែងនិងផ្លូវមាត់ស្ទឹង ។

www.budinst.gov.kh www.elibraryofcambodia.org

មុខកំផែង ជាសង្កាត់លំនៅឋានរបស់អភិជន មានផ្ទះថ្មនិងផ្ទះឈើ សង់លាយចំរុះគ្នារកេតរកូត ឥតសណ្ដាប់ធ្នាប់ ប្រជ្រៀតគ្នានៅក្បែរថ្នល់ ហើយផ្ទះភាគច្រើនសង់ចុះជ្រៅទៅក្នុងស្ទឹង គឺជើងសសរក្រោយ នៅក្នុងទឹកតែម្ដង ។ នៅតាមមុខកំផែងមិនមានផ្ទះនៅខាងលិចផ្លូវទេ ពីព្រោះផ្លូវនេះស្របកៀកនិងកំផែងណាស់ ។ នៅជាប់និងផ្លូវស្របកំផែង ពីត្បូងទៅជើង អ្នកដំណើរអាចសង្កេតឃើញផ្ទះសំខាន់ៗដូចជាផ្ទះលោកមហាថៃ ផ្ទះផ្សារអភ័យលឿម និងផ្ទះថ្ម ៣ ជាន់មួយខ្នង សំរាប់ទទួលភ្ញៀវកិត្តិយស ដែលអ្នកស្រុកសម័យនោះនិយមហៅថា "តឹកខ្ពស់ "។ មកដល់មុខក្លោងទ្វារខាងជើង ខាងកើតមានទីធ្លាស្រឡះដែលអ្នកស្រុកតែងនាំគ្នាយកផលិតផលរបស់ខ្លួនមកលក់ដូរ ហើយនិយមហៅថា "ផ្សារមុខកំផែង "។ នៅខាងកើតផ្សារនេះ នៅតាមមាត់ស្ទឹងមានតៀមចិនលក់ទំនិញផ្សេងៗ ។ ផុតពីទីផ្សារនេះទៅគឺជាសង្កាត់រដ្ឋបាល ដែលមានសាលាអំភើ (សាលស្រុក) សាលាខ្ទង (តុលាការ) និងប្រៃសណីយ៍ទូរលេខ ។ នៅមុខវត្តសង្កែ ត្រើយខាងលិចមានផ្ទះបណ្ដែតទឹកដែលគេហៅថា "ផែ "ជាទីសំរាប់ស្ត្រីក្នុងកំផែងចុះមកងូតទឹករាល់ពេលល្ងាច ។

សូមបញ្ជាក់ថា នៅមុខកំផែង ត្រង់ក្លោងទ្វារទាំងពីរទាំងខាង

www.budinst.gov.kh www.elibraryofcambodia.org

លិចស្ទឹង ទាំងខាងកើតស្ទឹង អ្នកស្រុកមិនហ៊ានសង់ផ្ទះទេ ពីព្រោះវាចំមុខកាំភ្លើងធំដែលតាំងនៅក្នុងកំផែង ។

សង្កាត់មុខកំផែង ចប់ត្រឹមអូរមួយនៅចន្លោះកំផែងនិងវត្តដំរីស ដែលហូរពីវាលស្រែទៅស្ទឹងសង្កែ ហៅថា "អូរតាគាំ"។ តាគាំជាឈ្មោះចៅហ្វាយស្រុកស្រែអន្ទាក់ តាំងពីមុនឃុនធិនទៅទៀត ។ គាត់បានយកដំរីមកបញ្ជាន់ដីឲ្យទឹកហូរ កុំឲ្យលិចលង់ស្រែគាត់ ។ ក៏ប៉ុន្តែអ្នកខ្លះនិយាយថា កាលគាត់ធ្វើចៅហ្វាយស្រុកគាត់បាននាំកូនស្រុករបស់គាត់មកជួយជីកអូរនេះធ្វើជាគូទឹកពទ្ធ័ជុំវិញកំផែង ។ ក៏ប៉ុន្តែបើតាមយើងដឹង អូរតាគាំនេះជាប់ហូរហែរ ទៅអូរសន្ទែ (ច្រាបក្រសាំង) រហូតដល់បឹងខ្នារ (ឈើទាល) ។

## ខ/- សង្កាត់ផ្សារស្វាយប៉ោ.-

យើងឆ្លងស្ពានឈើមួយ កាត់អូរតាគាំតាមផ្លូវតែមួយនៃទីក្រុង ។ ចាប់ពិនេះទៅ ផ្ទះច្រើនតែសង់ខាងកើតថ្នល់តាមលក្ខណៈដដែល គឺ ដាក់ផ្ទះបាយទៅក្នុងស្ទឹងដែលជាទំលាប់មួយខុសក្បួនអនាម័យ ។ ផ្ទះមានច្រើនណាស់ តែយើងអាចសង្កេតឃើញនៅខាងមុខវត្តដំរីស ខាងលិចថ្នល់ផ្ទះលោកភក្តីពាណិជ្ជ យ៉ាង ។ នៅខាងកើតមាន ផ្ទះចឹកជុយដែលជាធនាគារិករបស់លោកម្ចាស់ជាអ្នកបោះប្រាក់ ប៉ៃ សំរាប់ចាយនៅបាត់ដំបង ។ហួសពីនេះបន្តិច

www.budinst.gov.kh www.elibraryofcambodia.org

ទៅ ត្រង់ផ្នែកសាធារណការ មានផ្ទះលោកអតីតព្រះឃ្លាំងប៉ុកដែល ជាចៅហ្វាយស្រុកមង្គលបុរី ។ នៅក្បែរស្ពានដែក ខាងកើតផ្ទល់ មុខរោងកុនសង្កែសព្វថ្ងៃ មានគ្រឹះស្ថានពាណិជ្ជកម្មសំខាន់មួយ ដែលអ្នកស្រុកហៅថា **ហាងវូសិល** ។ កាលដើម វូសិល លក់តែ គ្រឿងកំប៉ិកកំប៉ុកទេ តែថ្ងៃក្រោយមក ក្លាយជា ហាងធំលក់តាំង ពីសំពត់អាវ ចានក្បានរហូតដល់កាំភ្លើង គ្រាប់រំសេវ ។ វូសិលនេះ ជាជាតិអាឡឺម៉ង់ មានកូនប្រុសម្នាក់ឈ្មោះ សៀសង់ "ដែលអ្នកស្រុក និយមហៅថា ស៊ីសងៗ ។ មកដល់ត្រង់សណ្ឋាគារអង្គរសព្វថ្ងៃ មានអ្នកតាចិនមួយនៅមាត់ស្ទឹង ហើយមានផ្លូវមួយមកពីវាលស្រែ សំរាប់អ្នកស្រុកនាំក្របីមកផឹកទឹក ។ គេហៅកន្លែងនេះថា "កំពង់ ក្របី "។ នៅកំពង់ក្របីនៅខាងក្រោយបន្តិចមានបនស្រីពេស្យាមួយ កន្លែង។

ហួសពីកំពង់ក្របីទៅ មានតៀមចិនលក់ទំនិញ តៗរហូតដល់ ទីផ្សារសព្វថ្ងៃ ដែលកាលនោះគ្រាន់ជាវាលស្រឡះសំរាប់អ្នកស្រុក លក់ផលិតផលរបស់ខ្លួន ។ នៅក្បែរនេះ នៅក្រោមម្លប់ស្វាយមួយ យ៉ាងធំ មានរោងបៀ ដែលជាល្បែងស៊ីសងម្យ៉ាង ទើបមានពាក្យថា **ស្វាយបៀ** "រហូតដល់សព្វថ្ងៃនេះ ។ សូមបញ្ជាក់ថានៅសម័យ លោកម្ចាស់ គេអាចជក់អាភៀន ឬ លេងល្បែងស៊ីសងបានតាម

www.budinst.gov.kh www.elibraryofcambodia.org

ចិត្ត នៅតាមរោងល្បែងដែលមានបង់ភាស៊ីជូនលោកម្ចាស់ ។

បើយើងដើរហួសផ្សារស្វាយប៉ៅទៅជើង ចំនួនផ្ទះថយចុះបន្តិចម្តងៗ ។ នៅមុខវត្តពិភិទ្ធ គេឃើញមានផ្ទះខាហ្លួងសៀមដែលជាផ្ទះឈើប្រក់ស្បូវ ។ នៅត្រង់ទីប្រសព្វមុខព្រែកមហាទេពនិងស្ទឹងសង្កែ មានទីសំចតកប៉ាល់ដែលមកពីបាក់ព្រា ។ យើងឆ្លងព្រែកមហាទេព តាមស្ពានតូចមួយដែលរទេះគោមិនអាចបរកាត់បានទេ ។ នៅខាងជើងព្រែក មានស្ពានកុងស៊ុលបារាំង ដែលគេសំគាល់បានពីចំងាយ ដោយសារដងកើយ៉ាងខ្ពស់ បង្ហូតទង់ជាតិបារាំងពណ៌ខៀវ ស ក្រហម ។ ហួសពីស្ពានកុងស៊ុលបារាំងនេះទៅគឺភូមិអ្នកស្រុកធម្មតា ។ នៅខាងកើតស្ទឹងក៏ជាភូមិអ្នកស្រុកមិនមានទីប្រជុំជនធំដុំទេ ។

**គ- អំពីការលក់ដូរ-** នៅសម័យលោកម្ចាស់ សកម្មភាពពាណិជ្ជកម្មក្នុងខេត្តមានលក្ខណៈទន់ខ្សោយណាស់ ។ នៅទីផ្សារអ្នកស្រុកនាំផលិតផលរបស់ខ្លួនមកលក់ដូរដោយដាក់សំដិលផ្ទាល់ដី ឬមានរានតូចៗ សំរាប់លក់បបរ នំនែកផ្សេងៗ ។ នៅទីផ្សារមិនដែលមានលក់សាច់គោទាល់តែសោះ ។ គេច្រើនតែបេះផ្លែឈើស្លឹកឈើយកមកលក់ ។ បន្លែដែលដាំមានតែតាមរដូវ ។ គេលក់សាច់ក្រពើជាអចិន្ត្រៃយ៍ជាមួយត្រី ។ នៅតាមផ្ទះចិនមានលក់

www.budinst.gov.kh www.elibraryofcambodia.org

គ្រឿងឧបភោគបរិភោគផ្សេងៗ តែគេមិនឃើញមានហាងលក់គុណទាវ កាហ្វេទេ ។ ទឹកកកក៏មិនទាន់មានលក់ដែរ តែលោកយាយអ៊ិចដែលម្ដាយគាត់ជាអតីតស្រីរបាំ គាត់អាចចូលក្នុងកំផែងបាននោះ បានអះអាងថា នៅផ្ទះលោកម្ចាស់មានម៉ាស៊ីនធ្វើទឹកកកដែលមានយួនប្រុសម្នាក់ជាអ្នកកាន់កាប់ ។ គេធ្វើទឹកកកសំរាប់តែគ្រួសារលោកម្ចាស់និងចែកញាតិមិត្តខ្លះ ។

នៅតាមភៀមចិនមិនទាន់មានហាងកាត់ដេរខោអាវ ឬហាងកាត់សក់ទេ ។ គេឃើញមានផ្ទះ២ លក់ថ្នាំចិនសែ ។ នៅពេលនោះគេមានថតរូបដែរហើយ ។ តែដោយមិនមានអគ្គិសនី គេថតតែនៅខាងក្រៅផ្ទះ ។ អ្នកស្រុកអាចជួលចិនឲ្យទៅថតដល់ផ្ទះតែប្រដាប់ថតពេលនោះធំហើយពិបាកលើកចុះឡើងណាស់ ។ មានតែអ្នកធំ អ្នកមានទេ ដែលបានថតរូប ព្រោះគេយកឈ្នួលថ្លៃពេក។ អ្នកស្រុកមិនសូវហ៊ានថតទេ ព្រោះយល់ថា ម៉ាស៊ីនថត អាចស្រូបយកឈាមមនុស្ស ធ្វើឲ្យមនុស្សមានអាយុខ្លី ហើយគេអះអាងថាអ្នកដែលបានថត ច្រើនតែស្លាប់ប៉ុន្មានខែក្រោយ គ្រប់គ្នា ៗ ។

## ឃ- អំពីផ្ទះសំបែង

លំនៅស្ថាននៅសម័យលោកម្ចាស់ ប្លែកពីយើងសព្វថ្ងៃច្រើនដែរ ។ គំរូផ្ទះដែលមានសម័យនោះច្រើនតែបាត់អស់ទៅហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទះដែលជាលក្ខណៈសំគាល់នៅពេលនោះគឺផ្ទះម្យ៉ាងដែលមានដំបូលខ្ពស់ស្រួច ហៅថា "**ផ្ទះខ្មែរ** "។ ផ្ទះខ្មែរគឺជាផ្ទះរាស្ត្រសាមញ្ញ ។ ផ្ទះខ្មែរមានដំបូលចោតយ៉ាងខ្លាំង ហើយមានហប់មុខហប់ក្រោយ និងហប់នៅចុងជើង ។ ខាងក្បាលដំណេក គ្មានហប់ទេ ។ ផ្ទះខ្មែរមានរនាបក្រាលពីរថ្នាក់ ។ សព្វថ្ងៃ ផ្ទះខ្មែរបាត់អស់រលីងទៅហើយ ។ ក្រៅពីផ្ទះខ្មែរ ដែលជាលក្ខណៈពិសេសជំនាន់ដើមគេមានគំរូផ្ទះផ្សេងៗដូចជា ៖

- **ផ្ទះរោងដោល** គឺជាផ្ទះមានសសរ៣ជួរ ហើយដំបូលមានហោជាងតូចមួយ ។ បើគ្មានហោជាង ហៅថា**ផ្ទះគ្រដោម** ។ អ្នកស្រុកមិនសូវធ្វើផ្ទះគ្រដោមទេ ព្រោះគេថាសក្តិមិនដល់ ។

- **ផ្ទះរង់ដៀង** ខុសប្លែកពីផ្ទះរោងដោលត្រង់ដែលមានសសរ ៤ ជួរ ហើយមានហោជាងធំជាង ។ ម្យ៉ាងទៀត ផ្ទះរបៀបរង់ដៀងដែរ តែមានដំបូលពីរថ្នាក់របៀបដូចដំបូលព្រះវិហារ គេហៅថា ផ្ទះខសង ។ គេច្រើនតែធ្វើកុដិ ឬសាលាជាផ្ទះ**ខសង**។

នៅបាត់ដំបងពេលនោះ មានផ្ទះថ្មតិចតួចណាស់ ។ គេអាចក្រឡៃផ្ទះថ្មតាមបែបសម័យ តែគេធ្វើផ្ទះឈើដោយមានក្បូនខ្នាតទៀងទាត់ពីបុរាណ ។ គេមិនដែលបំភ្លៃម៉ូតផ្ទះ ដូចសព្វថ្ងៃទេ ។

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំង ទី ៨




(ម.ម)




(ម.ម)

www.budinst.gov.kh www.elibraryofcambodia.org

ខ្មែរធ្វើផ្ទះផុតពីដី មានសសរជាជន្ទល់ តែនៅពេលនោះមិនមានសសរតំកល់អិដ្ឋទាល់តែសោះ ។

ចិនច្រើនរស់នៅក្នុងផ្ទះតៀមផ្ទាល់ដី ។ យួនចូលចិត្តធ្វើផ្ទះមានដំបូលកាត់ ហៅថា **ផ្ទះកន្តាំង** ។

www.budinst.gov.kh www.elibraryofcambodia.org

# របបគ្រប់គ្រង

## ក- កិច្ចការរដ្ឋបាល :

កាលដើម គ្រួសារចៅហ៊្វាបែនត្រួតត្រាទឹកដីធំទូលាយតាំងពីបាត់ដំបង រហូតដល់សៀមរាប សំរោងចុងកាល់ ។ តែក្រោយមកនៅរវាងឆ្នាំ ១៨៤៨ សៀមបានផ្ដាច់ទឹកដីខ្លះចេញពីអំណាចរបស់គ្រួសារចៅហ៊្វាបែន ដោយមានបង្កើតខេត្តសិរីសោភ័ណ ភ្នំស្រុកព្រះស្រុក សៀមរាប សំរោងចុងកាល់ ។ ចៅហ្វាយខេត្តថ្មីទាំងនេះមិនស្ដាប់បង្គាប់ស្ដេចត្រាញ់នៅបាត់ដំបងទេ តែទទួលបញ្ជាផ្ទាល់ពីរដ្ឋាភិបាលបាងកក ។

នៅសម័យដែលគ្រួសារចៅហ៊្វាបែនត្រួតត្រារស់ពេលមួយសតវត្សនោះ ខេត្តបាត់ដំបងមានឈ្មោះជាផ្លូវការថា "ព្រះតំបង"។ ខេត្តបាត់ដំបងនៅពេលនោះចែកជាស្រុកតែបួនទេគឺស្រុកបាត់ដំបង ស្រុកមោងឫស្សី ស្រុកមង្គលបុរី និងស្រុកស្រែអន្ទាក់ ។ ស្រុកនីមួយៗមាននាយអំភើម្នាក់ជាអ្នកត្រួតត្រា ។ ស្រុកចែកជាសង្កាត់ហៅថា កំណាន់ ត្រួតត្រាដោយនាយកំណាន់ ។

លុះដល់ឆ្នាំ ១៨៩៤ ប្រទេសថៃទាំងមូលបានធ្វើកំណែទំរង់រដ្ឋបាល ដោយចែកប្រទេសជា ១៨មណ្ឌល ហៅថា *មន់ថុន* ។

www.budinst.gov.kh www.elibraryofcambodia.org

មន់ថុនចែកជាចង្វាត់ ។ ចង្វាត់ចែកជាអំភើ ។ អំភើចែកជាតំបន់។ តំបន់មាន ១០ភូមិ ហៅថា បាន ។ កំណែទំរង់នេះមានបំណង បំបាត់ដែនដីស្ដេចត្រាញ់ដូចជា បាត់ដំបង ឆៀងម៉ៃ ចំប៉ាសក្ដិ ជាដើម ។ ខេត្តបាត់ដំបងបានរួមជាមួយខេត្តសិរីសោភ័ណ ភ្នំស្រុក និងសៀមរាប កើតជាមន់ថុនមួយហៅថា **មន់ថុនបូរផា** ប្រែថា មណ្ឌលបូពា៌ ។ ដើម្បីជាទីលើកទឹកចិត្តគេបានចាត់តាំងឲ្យលោក កថាថនដែលជាស្ដេចត្រាញ់នៅបាត់ដំបងធ្វើជា*សមុហទេសាភិបាល មន់ថុនបូរផា* នេះ ដែលជាមួយនោះសៀមបានតាំង *ខាហ្លួង* ម្នាក់នៅអមលោកម្ចាស់ កថាថន ។ ខាហ្លួងមាននាទីជាទីប្រឹក្សា ឬជាអធិការ ឬមានអំណាចប្រហែលនិងរេស៊ីដង់បារាំង នៅខាង ប្រទេសកម្ពុជាដែរ ។ ខាហ្លួង ត្រួតពិនិត្យតាំងពីកិច្ចការរដ្ឋបាល តុលាការ រហូតដល់ពន្ធដារ ។

ក្នុងការត្រួតត្រាស្រុកនានាក្នុងខេត្ត លោកម្ចាស់មានអំណាច ដាក់គ្រួសារគាត់ឲ្យធ្វើចៅហ្វាយស្រុកបានតាមចិត្ត ។

លោកម្ចាស់បានតាំងហ្លួងកំភោតឈ្មោះ ឈើយ ឬ ខែក ដែលជាប្អូន គឺកូនលោកកថាថានញ៉ុញដែរ តែមានម្ដាយផ្សេងគ្នា ឲ្យធ្វើចៅហ្វាយស្រុមោងឫស្សី ។

លោកម្ចាស់បានដាក់កូនម្នាក់ឈ្មោះ ឃុនធិន ឲ្យធ្វើចៅ

www.budinst.gov.kh www.elibraryofcambodia.org

ហ្វាយស្រុកស្រែអន្ទាក់ ។ ឃុនធិនធ្វើចៅហ្វាយស្រុកស្រែអន្ទាក់មិនបានប៉ុន្មានឆ្នាំផង ក៏កើតរោគគ្រុនចាញ់ស្លាប់នៅទីនោះទៅ ។ គេដឹកខ្មោចឃុនធិនតាមដំរី យកមកធ្វើបុណ្យយ៉ាងអធិកអធម នៅបាត់ដំបង ។

នៅមង្គលបុរី លោកម្ចាស់បានដាក់លោកព្រះឃ្លាំងប៉ុក ឲ្យធ្វើចៅហ្វាយស្រុក ព្រោះគាត់ជាមនុស្សអង់អាច ហើយនៅពេលនោះនៅមង្គលបុរីមានមេចោរកាចសាហាវដើររាតត្បាតយ៉ាងខ្លាំង ។ លោកប៉ុក ចៅហ្វាយស្រុកមង្គលបុរី កាលដើមជាព្រះឃ្លាំងនៅបាត់ដំបងអមលោកម្ចាស់ តែក្រោយពេលដែល លោកស្រីអ៊ឹងបានឡើងឋានៈជាលោកជំទាវ លោកម្ចាស់ក៏លើកឪពុកក្មេកឲ្យឡើងជាព្រះឃ្លាំង គឺ *ព្រះឃ្លាំងម៉ៅ* ។ តែអ្នកស្រុកមង្គលបុរី នៅតែហៅលោក ប៉ុក ដែលជាចៅហ្វាយស្រុកនេះថា ព្រះឃ្លាំងដដែល ។

នៅមង្គលបុរី លោកព្រះឃ្លាំង ប៉ុក នេះ មានអំណាចខ្លាំងក្លាណាស់អាចកាប់សំលាប់រាស្ត្រប្រជាបាន ។ គាត់បានតាំងបន្ទាយមន្ទីរនៅត្រង់សាលាស្រុកសព្វថ្ងៃ ។ នៅផ្ទះគាត់មានឈ្លោនស្រី ឈ្លោនប្រុស ដូចនៅក្នុងកំផែងបាត់ដំបងដែរ ។

សូមបញ្ជាក់ថា កាលដើម ខ្មែរក៏ដូចជាសៀម មានឈ្មោះតែ

www.budinst.gov.kh www.elibraryofcambodia.org

មួយម៉ាត់ៗ តែចាប់តាំងពីរជ្ជកាលទី ៤ គឺព្រះចៅចុឡាឡុងកនមក គេក៏ចាប់ផ្ដើមដាក់ឈ្មោះត្រកូល ទើបគេឃើញមានឈ្មោះថា ឈុំ អភ័យវង្ស ។ លោកព្រះឃ្លាំង ប៉ុក ក៏មានឈ្មោះថា ប៉ុក ពោសៃឃុប ។ ឯគ្រួសារចៅពញាបឌិន ក៏មានឈ្មោះត្រកូលថា សង្ហិហសេនីយ៍ ដែរ ។

ដើម្បីជាជំនួយដល់កិច្ចការរដ្ឋបាល គេមានប៉ូលីស ដែលមានឈ្មោះថា "តំរួតភូថន "ប្រែថាតំរួតព្រះភូធរ ។ តំរួតភូថននេះមានបុគ្គលិក ប្រមាណជា ១០ ឬ ២០នាក់យ៉ាងច្រើន ។ ភ្នាក់ងារតំរួតភូថន នេះត្រូវបានជ្រើសរើសក្នុងចំណោមអ្នកមានកំណើតនៅបាត់ដំបង ហើយឲ្យទៅហាត់ហ្វឹកហ្វឺន នៅឯបាងកក តែក្រោយមកអំណាចប៉ូលីសនៅបាត់ដំបង ត្រូវបានប្រគល់ដោយសម្ងាត់ទៅឲ្យបារាំងកាន់កាប់វិញ ។

## ខ- អំពើពន្ធដារ និង សួយសារអាករ.-

លោកម្ចាស់ជាស្ដេចត្រាញ់ មានអំណាចទារពន្ធដារគ្រប់បែបយ៉ាង ពីប្រជារាស្ត្រក្នុងខេត្ត ។ ពន្ធដារដែលសង្កត់ធ្ងន់លើប្រជារាស្ត្រផ្ទាល់គឺ **ពន្ធស្រូវ និង ពន្ធខ្លួន** ។ តែនៅមានពន្ធមិនចំពោះមួយចំនួនទៀតជាភាសី ដូចជាភាសីស្រា ភាសីអាភៀន ភាសីល្បែងស៊ីសង ភាសីនេសាទត្រី ភាសីឃ្មុំ ។ ប្រាក់ពន្ធដារនិងការហូតភាសី

www.budinst.gov.kh www.elibraryofcambodia.org

ទាំងនេះ ជាសម្បត្តិផ្ទាល់របស់លោកម្ចាស់សំរាប់ចាយវាយតាមចិត្ត ទិញមាសទិញពេជ្រចែកកូនចែកចៅ ។ គេមិនដែលឃើញលោកម្ចាស់យកប្រាក់ពន្ធទៅចាយជាប្រយោជន៍សាធារណៈដូចជាស្ពានថ្នល់ ឬមន្ទីរពេទ្យឡើយ ។ នៅដំណាច់ឆ្នាំ លោកម្ចាស់ តែងយកប្រាក់ពន្ធដាររមួយភាគទៅថ្វាយព្រះចៅសៀម ជាសួយសារអាករ ។ តាមអ្នកប្រាជ្ញបារាំងឈ្មោះ ប្រ៊ីយាង បានមកធ្វើអង្កេតនៅបាត់ដំបង បានកត់ក្នុងឯកសារលោកថា ចំណូលខាងពន្ធដាររបស់លោកម្ចាស់ បានប្រហែល ៩១.០០០រៀលក្នុងមួយឆ្នាំ ។

ដីស្រែទាំងអស់ក្នុងខេត្ត ជាសម្បត្តិរបស់លោកម្ចាស់ ។ លោកម្ចាស់ហូត ១០ ភាគរយនៃផលិតផលដែលកសិករធ្វើបានក្នុង ១ឆ្នាំ ៗ ។ នៅពេលធ្វើស្រែរួច មេកងពន្ធ ដោយមានបាឡាត់កង និង ស្មៀនពីរនាក់ បានចេញដើរពីភូមិមួយទៅភូមិមួយ ទារពន្ធស្រូវ ។ គេដើរវាស់ស្រូវដែលមានក្នុងជង្រុកដោយមានវិធីទៀងទាត់ដើម្បីវាស់វែងប៉ាន់ប្រមាណ ។ គេមិនទារពន្ធស្រូវដែលហាលបំរុងបុកកិនបរិភោគទេ ។ ដោយហេតុនេះហើយ បានជានៅពេលដែលមេកងពន្ធចូលភូមិម្តងៗ អ្នកស្រុកនាំគ្នាខ្ចីកន្ទេលគេយកមកហាលស្រូវ ។ អ្នកខ្លះហាលស្រូវក្រាស់ៗ ដើម្បីឲ្យស្រាលពន្ធបន្តិច ។ ជួនកាល គេដឹកស្រូវដែលទារពន្ធបានយកទៅដាក់ឃ្លាំងក្នុងកំផែង

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំង ទី ៩



ព្រះឃ្លាំង ម៉ៅ (ម.១)

www.budinst.gov.kh www.elibraryofcambodia.org

តែជូនកាលគេយកជាប្រាក់តាមតំលៃស្រូវ ពីម្ចាស់ស្រូវតែម្តង ។

ថែមលើពន្ធស្រូវ ប្រជារាស្ត្រភេទប្រុសទាំងអស់ ដែលមានអាយុពី ២០ឆ្នាំឡើងទៅត្រូវបង់ប្រាក់ ៤បាតក្នុងម្នាក់ៗ ក្នុង ១ឆ្នាំ ។ ប្រាក់ពន្ធនេះគេហៅថាពន្ធខ្លួន ។

ពន្ធមិនចំពោះ មានភាសុីផ្សេងៗដែលលោកព្រះឃ្លាំង ម៉ៅ ចាត់ចែងដេញថ្លៃរាល់ឆ្នាំ ។ អ្នកចង់ប្រកបអាជីវកម្មត្រូវទៅសុំលោកព្រះឃ្លាំងផ្ទាល់ ដោយគ្រាន់តែជូនសំណូកខ្លះល្មមគាត់ពេញចិត្ត ។ អ្នកដេញភាសុីបាន ច្រើនតែជាជនជាតិចិន ។ លោកស្រីពិភក្តិឈ្មោះតាំង ស៊ា ជាឪពុកអ្នកឃ្លោយ កាន់កាប់ភាសុីស្រាហូតមក មិនដែលមានផ្លាស់ប្តូរអ្វីទេ ។

បន្ទាប់ពីប្រមូលប្រាក់ពន្ធដារពីប្រជារាស្ត្របានហើយ លោកម្ចាស់ត្រូវយកពន្ធដារមួយភាគ ជាសួយសារអាករទៅថ្វាយស្តេចសៀម ។ កាលដើម គេដឹកផលិតផលក្នុងស្រុកគ្រប់មុខតាំងពីមាស ពេជ្រ ប្រាក់ ស្រូវ អង្ករ ភ្លុកដំរី ក្រមួន ក្រវាញ ជ័រឈើ ។ល។ ទៅ ថ្វាយស្តេចសៀម ។ តែថ្ងៃក្រោយមក ដើម្បីសំរួលការដឹកនាំ គេឈប់ដឹកផលិតផលទាំងអស់ទៅទៀតហើយ គេយកតែមាស ប្រាក់ លុយកាក់ទៅថ្វាយស្តេចតែម្តង ។

លោក ម៉ៅ រិន អតីតមគ្គុទ្ទេសទេសចរណ៍បាត់ដំបងបានបក

www.budinst.gov.kh www.elibraryofcambodia.org

ប្រែឯកសារសៀមមួយចំនួនចេញពីសៀវភៅឈ្មោះ "ប្រជុំចុតហ្មាយទាក់ទងថៃ-យួនក្នុងរជ្ជកាលទី៣"។ តែនៅពេលនេះ យើងអាចស្រង់យកតែវគ្គខ្លី ស្តីអំពីការដឹកនាំក្រវាញទៅថ្វាយព្រះចៅសៀម ព្រះណាងក្លាវត្រង់ទំព័រទី ១៤២ មានសេចក្តីថា :

«..........ហ្លួងអភ័យពិទក្ស ចាងហ្វាង នាយកង បាឡាត់កង ស្វយក្រវាញយកផលក្រវាញ ៩០ រទេះបញ្ជូនចូលមក ។ នឹងយករទេះក្របីទៅវិញទទេ ឃើញថាខូចការ ទើបប្រោសអនុញ្ញាតឲ្យព្រះរាជទានអំបិល ៦០០ ថាំងដល់ពួកព្រះ ឃុន ហ្លួង ម៉ឺន ពល ខ្ញុំ ស្វយក្រវាញនឹងបានចែកចាយគ្នាព្រះរាជទានជាកំលាំងរាជការ ។...

ចំនួនមនុស្សនិងរបស់អនុញ្ញាតិឲ្យហ្លួងអភ័យពិទក្ស ចាងហ្វាង នាយកង បាឡាត់កង ស្វយក្រវាញត្រឡប់ទៅស្រុកបាត់ដំបង មានព្រះសង្ឃ ៧អង្គ សាមណេរ ៥អង្គ ត្រូវជា ១២អង្គ ។ នាយកង ៣៥ ។ ពលខ្មែរ ៣៣ ពលចិន ៥ ត្រូវជា ៣៨ រួមទាំងអស់ត្រូវជា ៧៣ ។ ស្រី៥ រួមជា ៧៨ ។ កាំភ្លើងថ្មជំនាន់ដើម ៣ បំពង់ ចាត់ទិញ១ បំពង់ត្រូវជា ៤បំពង់ ។ សំណព្រះរាជទាន ២ហាប ៥០នាឡិ សំណចាត់ទិញ២ហាប៥០នាឡិ ។ ពុម្ពសិតបល្លង្កព្រះពុទ្ធរូប ៥ហាប ខ្ទះដែកព្រះរាជទាន ១០ ចាត់ទិញ ១០ ត្រូវជា ២០ ។ ដួង ៥០០ផ្លែ ទូក១៤គ្រឿង...»

www.budinst.gov.kh www.elibraryofcambodia.org

តាមរយៈចុតហ្មាយដែលបកប្រែដោយលោក ម៉ៅ រិន នេះ យើងឃើញថាស្តេចក៏បានប្រោសព្រះរាជទានសម្ភារៈខ្លះដល់មន្ត្រីរាជការ កងស្វយដែលនាំស្វយសារអាករទៅថ្វាយដែរ តែយើងមានការលំបាកក្នុងការប៉ាន់ប្រមាណរបស់ដែលយកទៅថ្វាយ និងរបស់ដែលព្រះរាជទាននេះណាស់ ។

## គ- អំពីតុលាការ និង ការផ្តន្ទាទោស.-

នៅពេលនេះមិនទាន់មានឯកសារសរសេរ ដើម្បីបានដឹងអំពីរបបតុលាការនៅសម័យលោកម្ចាស់ទេ ។ តែតាមពត៌មាន គឺអាជ្ញាធររដ្ឋបាលជាអង្គការតុលាការផង ។ មន្ត្រីរដ្ឋបាល ជាចៅក្រម ។ ក្នុងស្រុកពុំមានច្បាប់ច្បាស់លាស់ទេ មានតែបញ្ញត្តិឬបំរាមដែលលោកម្ចាស់ដាក់ឲ្យគោរពតាមទំនើងចិត្ត ។ តុលាការនៅតែជាមួយសាលាស្រុក សាលាខេត្ត ដែលមានពីរថ្នាក់ គឺ **សាលាខ្មែរ** ដែលជាអង្គការតុលាការជាន់ទាប សំរាប់ស្រុកនីមួយៗ ហើយនិង **សាលាក្លាង** ដែលជាសាលាជនុំជំរះក្តីខ្ពស់ជាងគេនៅក្នុងខេត្តបាត់ដំបង ។ អ្នកស្រុកតែងហៅសាលាកាត់ក្តីទាំងពីរនេះថា សានខ្មែរ និងសានក្លាង ។

សាលាក្លាង តាំងនៅក្នុងកំផែង នៅខាងមុខ កំផែងកែវ តែម្តង ។ លោកស្រីសាទេព ជាចៅក្រមធំនៅសាលា ក្លាង ។

www.budinst.gov.kh www.elibraryofcambodia.org

នៅសម័យលោកម្ចាស់ ការចាប់ចងសួរចំលើយ និងផ្ដន្ទាទោសមានលក្ខណៈជាទារុណកម្ម យ៉ាងសាហាវយង់ឃ្នង ។

- ***ការដាក់ឃ្នាង និងខ្នោក*** បើជនណាម្នាក់ត្រូវជាប់ចោទ ហើយត្រូវគេនាំបណ្ដើរទៅកាន់សាលា ជននោះនឹងត្រូវជាប់ឃ្នាង ឬ ខ្នោក មិនខានឡើយ ។ ឃ្នាង ជាឫស្សីពីរដើមមានកាំដូចជណ្ដើរ ជួនកាលមានប្រវែងជាងពីរម៉ែត្រ ។ គេដាក់ក្បាលអ្នកជាប់ចោទចូលក្នុង ហើយគេដាក់កាំបញ្ចូលដោយបោះស្នៀតយ៉ាងណែនឲ្យជាប់អ្នកជាប់ចោទ ។ អ្នកជាប់ឃ្នាងត្រូវតែពឹងគេអ្នកក្រៅទើបដោះរួច ។ ឃ្នាងមួយអាចដាក់មនុស្សបានពីរនាក់ ។ ឃ្នាងតែងមានកាំគត់គូរ ។ ចាស់ៗមានទំលាប់ធ្វើជណ្ដើរឲ្យមានកាំគត់គូរទេ កុំឲ្យមើលទៅហាក់ដូច ឃ្នាង ។

ឯខ្នោក គ្រាន់តែជាឈើជំពាមមួយដែលគេច្រកក្បាលអ្នកជាប់ចោទ ឲ្យចូលក្នុងជំពាមហើយគេស៊ៀតកាំយ៉ាងជាប់ពីក្រោយឲ្យជាប់កនៅក្នុងនោះ ។ ខ្នោកមួយដាក់មនុស្សបានតែម្នាក់ទេ ។

ការដាក់ឃ្នាងឬខ្នោកនេះ ជាការផ្ចាញ់ផ្ចាលមនុស្សឲ្យរាងចាលម្យ៉ាង ហើយរំខានកុំឲ្យរត់គេចបានដោយងាយនេះម្យ៉ាង ។

- ***ទារុណកម្មនៅពេលសួរចំលើយ*** ៖ គេមានវិធី ២យ៉ាង ដើម្បីជំរិតអ្នកជាប់ចោទឲ្យសារភាពទាន់ចិត្ត ។ ក្នុងករណីធម្មតា

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំង ទី ១០

ការវាយធ្វើបាប



(ម.ម)



(ម.ម)



(ម.ម)

www.budinst.gov.kh www.elibraryofcambodia.org

បើអ្នកជាប់ចោទរឹងទទឹង គេប្រើ បែ៉ន ដើម្បីទះកំភ្លៀង ។ បែ៉នគឺជាឈើមូលធំជាងគ្រាប់អង្គុញបន្តិច មានដងសំរាប់កាន់ដូចរ៉ាកែត។ នៅតាមកន្លែងសួរចំលើយ គេតែងសង្កេតឃើញមានបែ៉នដែលគេខាត់យ៉ាងរលោងជានិច្ច ។ ការទះកំភ្លៀងដោយបែ៉ននេះ ជួនកាល អាចបណ្តាលឲ្យបាក់ធ្មេញ បី-បួន ។

តែបើអ្នកចុងចោទរឹងទទឹងខ្លាំង ឬគ្មានវិធីសារភាព គេប្រើ **គំនាបស្លាស្លឹង** ដែលមានលក្ខណៈដូចគំនាបគាបត្នោត ។ គេយកស្លាស្លឹង គឺគ្រាប់ស្លាស្ងួតទាំងមូល យកមកដាក់ត្រង់សៀតផ្កា មួយម្ខាងហើយគេដាក់គំនាបពីលើស្លានោះ ។ គេគាបបន្តិចម្តងៗ ពីតិចទៅខ្លាំង ។ អ្នកស្លូតត្រង់ដែលមិនអាចឆ្លើយសារភាពបាន មុខជាត្រូវគេគាបរហូតដល់លៀនគ្រាប់ភ្នែក ឬសន្លប់មិនខានឡើយ ។ តែអ្នកដែលស្គាល់មហិទ្ធិរិទ្ធនៃគំនាបនេះប្រាកដជាឆ្លើយដាក់គេដាក់ឯងយករួចតែខ្លួនមិនខានឡើយ ។

- ***ការផ្តន្ទាទោស*** : បើកាលណាយើងត្រូវជាប់ពិរុទ្ធហើយ គេមានមធ្យោបាយច្រើនយ៉ាងសំរាប់ធ្វើឲ្យយើងរាងចាល ចាប់តាំងពីការវាយរ៉ាវ ការដាក់ច្រវាក់និងការប្រហារជីវិត ។

- ***ការវាយរ៉ាវ*** ជាទារុណកម្មមួយគួរឲ្យរន្ធត់ ។ គេឲ្យអ្នកទោសអង្គុយលើកំណល់មួយ ។ គេចាប់ចងជើងចងដៃភ្ជាប់និង

www.budinst.gov.kh www.elibraryofcambodia.org

បង្គោលមួយ តាមធម្មតា គេច្រើនតែចងមេដៃនិងមេជើង ។ បន្ទាប់មកគេចងចង្កេះ ដោយខ្សែវែងឬដោយច្រវាក់ភ្ជាប់ទៅបង្គោលមួយទៀត នៅខាងក្រោយ ។ គេដកកំណល់អង្គុយចេញធ្វើឲ្យអ្នកទោសអណ្តែតប៉ែលប៉ាលៗ ។ គ្រាន់តែប៉ុណ្ណោះ បែបពីបាកណាស់ទៅហើយ ។ គេវាយអ្នកទោសយ៉ាងខ្លាំងៗ ឲ្យស្នាមរំពាត់ស្របៗគ្នាជានិច្ច ។ បើកាលណាវាយឲ្យមានស្នាមរំពាត់ខ្វែងគ្នា អ្នកវាយត្រូវមានទោសយកទៅវាយម្តងវិញ ។ ក្នុង ការវាយនេះ បើវាយ ៣០ រំពាត់ គេថាមួយ យក់ អ្នកខ្លះត្រូវទោសមួយយក់ ពីរយក់ ឬកន្លះយក់ ។ នៅពេលវាយ អ្នកទោសអាចរើបានតែក្បាលនិងកបន្តិចទេ ។ បីថ្ងៃក្រោយមក គេចាប់អ្នកទោសដដែលមកវាយម្តងទៀត គេហៅថា «**វាយបកក្រមរ**»

ការដាក់ច្រវាក់មានច្រើនសណ្ឋានណាស់ ។ ជួនកាលគេដាក់ច្រវាក់ហៅថា **ខ្នងក** ។ គេធ្វើកងដែកដាក់កអ្នកទោសដោយមិនឲ្យដោះបាន ។ គេយកច្រវាក់មួយខ្សែល្មមភ្ជាប់កងកអ្នកទោសម្នាក់ទៅកងកអ្នកទោសម្នាក់ទៀត ។ អ្នកទាំងពីរត្រូវទៅណាមកណាទាំងពីរនាក់ទោះបីត្រូវទៅបន្ទោរបង់លាមកក៏ដោយ ។ គេប្រើអ្នកទោសរបៀបនេះឲ្យសែងឈើ រែកទឹក ពុះអុស ។ តែជួនកាលយើងត្រូវទោសតែគ្មានគូ គេដាក់ច្រវាក់ម្ខាងឲ្យជាប់កយើង តែ

www.budinst.gov.kh www.elibraryofcambodia.org

ចុងម្ខាងទៀតគេភ្ជាប់ដុំដែកមួយមានទំងន់ ៧គីឡូ ដែលពេលទៅណាមកណា យើងត្រូវលើកដុំដែកនោះកាន់ឡើង ។

ម្យ៉ាងទៀត គេដាក់ច្រវាក់ហៅថា ជង្គង់ត្រដក់ ។ គេដាក់កងដែកនៅកជើងយើងទាំងពីរ ដោយមិនឲ្យដោះបាន ។ គេយកដែកប៉ុនមេដៃប្រវែងជិតមួយម៉ែត្រមកភ្ជាប់កងជើងយើងទាំងពីរ ។ ពេលទៅណាមកណា យើងត្រូវតែដើរទីងទាងៗទើបទៅមុខបាន ។ គេច្រើនប្រើអ្នកដែលជាប់ជង្គង់ត្រដក់ ឲ្យកិនស្រូវបុកអង្ករ ឬឈូសឈើ ។ តែបើយើងមានកំហុសស្រាលបន្តិច គេអនុគ្រោះឲ្យដែកដែលភ្ជាប់កងជើងនោះ មានពីរកំណាត់អាចឲ្យយើងធ្វើចលនាបានស្រួលបន្តិច ។ នៅពេលដើរយើងអាចយកខ្សែមួយមកចងត្រង់មុខតំណដែក ហើយលើកដែកនោះបន្តិចឡើង មិនសូវពិបាកជើងពេក ។

នៅពេលយប់ អ្នកទោសមានកន្លែងសំរាកពីរកន្លែង មួយនៅវត្តកំផែង មួយទៀតនៅត្រង់ជ្រុងល្បសានកំផែង ។ អ្នកទោសត្រូវដាំបាយបរិភោគដោយខ្លួនឯង ។ លោកព្រះឃ្លាំងមានភារៈបើកអំបិល ត្រីងៀត ត្រីឆ្អើរ ឲ្យអ្នកទោស ។ នៅតាមផ្សារ គេសង្កេតឃើញអ្នកទោសដើរសុំទានចំណីគេបរិភោគ តែអ្នកទោសមិនអាចឆ្លៀតពេលដើរស៊ីឈ្នួលរែកទឹកពុះអុស ឲ្យអ្នកស្រុកក្រៅពីគ្រួសារ

www.budinst.gov.kh www.elibraryofcambodia.org

លោកម្ចាស់បានទេ ។ អ្នកត្រូតត្រាមនុស្សទោស គឺលោកសន្ទួន អៀមនិងលោកអង្គទរាជ ។

- ***ទោសប្រហារជីវិត*** : បើមានមនុស្សមានទោសដល់ប្រហារជីវិត គេនិយមវិធីសំលាប់ដោយកាត់កនឹងដាវ ជួនកាលគេចាប់មនុស្សយកទៅសំលាប់ស្ងាត់ៗ ។ គេចាប់អ្នកទោសឲ្យអង្គុយសំពះនៅមាត់រណ្តៅ ។ គេចងអ្នកទោសនោះពីរឬបីចំណង ។ ពេជ្ឈឃាដធ្វើពិធីរាំវែកជុំវិញមនុស្សទោស ហើយគេបញ្ចប់ពិធីដោយកាត់កអ្នកទោស ហើយច្រានទំលាក់ក្នុងរណ្តៅកប់ចោលទៅ។ លោកតាលិម ស៊ុត នៅភូមិវត្តកណ្តឹង បានប្រាប់ថា លោកម្ចាស់មានដាវពិសេសមួយមានឈ្មោះ *ស្រីខ្មៅ* ។ ដាវស្រីខ្មៅនេះមុតណាស់អាចកាប់ទៀនដែលដោតបញ្ឈរឲ្យដាច់ តែមិនដួលទៀនទេ បើយើងមិនប៉ះពាល់ទៀននោះ ។ គេមានតំណមម្យ៉ាង គឺមិនឲ្យប្រើដាវនេះកាប់មនុស្សតែម្នាក់ ។ ពេលដកដាវស្រីខ្មៅចេញពីស្រោមគេត្រូវតែកាប់មនុស្សពីរនាក់យ៉ាងតិច ទើបគេច្រកដាវនេះក្នុងស្រោមវិញ ។ មានគេតំណាលថា នៅពេលមួយ មានមនុស្សម្នាក់ នៅកំពង់ឆ្លង មានទោសដល់ប្រហារជីវិត តែដោយរកគូមិនទាន់បានអស់ពេលដ៏យូរនោះ គេក៏អនុញ្ញាតឲ្យមនុស្សនោះទៅរង់ចាំនៅផ្ទះសិន ទំរាំគេរកគូបាន ។ ដោយហេតុស្លូតត្រង់ មនុស្សនេះ

www.budinst.gov.kh www.elibraryofcambodia.org

ក៏សុខចិត្តរស់នៅធម្មតាជាមួយគ្រួសាររហូតមក ។ នៅពេលមួយដែលមនុស្សនេះកំពុងប្រក់ផ្ទះ ស្រាប់តែមានភ្នាក់ងារគេមកហៅថាដល់គួហើយ ។ មនុស្សកំសត់នេះក៏ស្លន់ស្លោរធ្លាក់ពីលើដំបូលផ្ទះមក ។ គេក៏ចាប់យកមកកាប់ចោលនៅត្រង់ផ្លូវរទេះភ្លើងខាងកើតស្ទឹងសព្វថ្ងៃ ។ នៅពេលកាប់ គេមានពិធីម្យ៉ាងទៀត គឺគេមិនចងដៃជើងទេ តែគេចងភ្នែកដោយសំពត់ខ្មៅ ។ នៅត្រចៀកអ្នកទោសគេសៀតផ្កាច្បារពណ៌ក្រហម ។ (ហេតុនេះហើយបានជាចាស់ៗតែងហាមក្មេងៗ មិនឲ្យសៀតផ្កាច្បារនៅត្រចៀកទេព្រោះមើលទៅហាក់ដូចអ្នកទោសដែលគេយកទៅកាប់ចោល ។ ) គេឲ្យអ្នកទោសអង្គុយលុតជង្គង់លើកដៃប្រណម្យ ។ គេរេរាំតាមក្បាច់ស្រងៃពែនជុំវិញអ្នកទោស ។ ពេជ្ឈឃាដម្នាក់ទៀតនៅខាងមុខលើកដាវជន្ល ធ្វើហាក់ដូចកាប់ តែពេជ្ឈឃាដម្នាក់ទៀតនៅខាងក្រោយជាអ្នកកាប់មែនទែន ។

គេកាត់ក្បាលយកទៅដោត ផ្ដាលនៅតាមផ្លូវដើរ ។

ទោះបីមានការវាយដំដាក់ច្រវាក់កាប់សំលាប់ យ៉ាងនេះក៏ដោយ ក៏នៅតែមានមនុស្សប្រព្រឹត្តបទល្មើសមិនលោះពេលដែរ ។ តែការស៊ីសំណូកសូកប៉ាន់ក៏នៅតែមាន ។ សូមអានសៀវភៅគតិលោក របស់ឧកញ៉ាសុត្តន្តប្រីជាឥន្ទ ។

www.budinst.gov.kh www.elibraryofcambodia.org

# ជីវភាពសេដ្ឋកិច្ច

របបសក្តិភូមិ និង របបទាសភាពទ្រទ្រង់ឲ្យសេដ្ឋកិច្ចទន់ខ្សោយជានិច្ច ជាពិសេសខាងកសិកម្ម ដែលជាសកម្មភាពតែមួយដែលសំខាន់ជាងគេនៅបាត់ដំបង ។ កសិកម្មពឹងផ្អែកលើដំណាំស្រូវតែមួយមុខគត់ ។ កង្វះគមនាគមន៍ ធ្វើឲ្យប្រជារាស្ត្របាត់ដំបង ក្នុងសម័យលោកម្ចាស់នេះរស់នៅសឹងតែដាច់ស្រឡះពីពិភពដែលមានអរិយធម៌លូតលាស់ ពោលគឺរស់នៅតែដោយសារមធ្យោបាយប្រពៃណីរបស់ខ្លួន ។ សិប្បកម្មអាចបង្គ្រប់សេចក្តីត្រូវការបានខ្លះ ខាងសម្ភារៈ ។ អ្នកបាត់ដំបងសម័យនោះរស់នៅតែដោយសារខ្លួនឯង គឺរស់តាមរបៀប សេដ្ឋកិច្ចចិញ្ចឹមពោះ ។

**ក- កសិកម្មចិញ្ចឹមពោះ :**

កសិកម្មនៅបាត់ដំបងមុនឆ្នាំ ១៩០៧ ធ្វើតាមរបៀបឯកវប្បកម្មគឺធ្វើតែដំណាំស្រូវមួយមុខ ។ ដីស្រែល្អៗ មានជីវជាតិ ត្រូវបានពួកអភិជន ពោលគឺពួក ឃុន ហ្លួង ផ្យា គេប្រមូលដណ្តើមយកអស់ ។ ពួកអភិជនប្រើទាសករឲ្យធ្វើស្រែចំការដោយឥតត្រួតត្រាពិនិត្យដិតដល់ទេ ព្រោះទំហំការដែលគេក្រសោបនោះធំពេក ។ម្យ៉ាងទៀត ពួកអភិជនពុំសូវអើពើនឹងការបង្កបង្កើនផលទេ រវល់

www.budinst.gov.kh www.elibraryofcambodia.org

សប្បាយនឹងល្បែងផ្សេងៗទៅវិញ ។ ទាសករដែលជាបាវបំរើ ធ្វើដោយឥតបានកំរៃអ្វីសោះ បានតែខោអាវមួយចង្កេះបាយមួយចំអែត រស់ទាំងត្រដាបត្រដួសដោយឥតសង្ឃឹមថាខ្លួននឹងបានទទួលផលពីការងាររបស់ខ្លួន ។ ទាសករមានប្រយោជន៍អ្វីនឹងខំយកចិត្តទុកដាក់ក្នុងការបង្កបង្កើនផល ។ ម្ល៉ោះហើយ ទាសករធ្វើការកុំឲ្យតែចៅហ្វាយនាយស្តីបន្ទោស ឬវាយដំច្រំផាក់ប៉ុណ្ណោះ ។ កត្តាទាំងនេះហើយ ដែលនាំឲ្យទិន្នផលស្រូវនៅបាត់ដំបងសម័យនោះ ទាបជានិច្ច ទោះបីដីស្រែនៅបាត់ដំបងល្បីឈ្មោះថាជាដីមានជីវជាតិជាងគេក៏ដោយ ។ ផលិតផលសរុបមានកំរិតខ្ពស់ក៏ដោយសារតែទំហំដីដែលធ្វើស្រែនោះទេ ។

បើនិយាយអំពីបរិក្ខារ និងបច្ចេកទេសក្នុងការបង្កើនផលវិញនោះប្រាកដជាមានកំរិតទាបបំផុត កុំនិយាយពីរឿងនង្គ័ល រនាស់ដែលជាឧបករណ៍យ៉ាងចាស់បុរាណនោះ ។ គេធ្វើស្រែរកតែទីដីស្រឡះ ពុំសូវកាប់ឆ្ការព្រៃទេ ។

ដោយហេតុដីស្រែមានជីវជាតិ ត្រូវពួកអភិជនវាតក្រសោបយកអស់នោះ ប្រជារាស្ត្រសាមញ្ញមានការលំបាកក្នុងការរកដីធ្វើស្រែណាស់ ។ ដោយខ្វះមធ្យោបាយកាប់គាស់រានដីថ្មីគេត្រូវតែជួលដីធ្វើស្រែដោយឲ្យឈ្នួលយ៉ាងខ្ពស់ ។ កម្រមានរាស្ត្រសាមញ្ញដែល

www.budinst.gov.kh www.elibraryofcambodia.org

គេហៅថា *អ្នកជា* មានដីធ្វើស្រែខ្លួនឯងណាស់ ។ កង្វះគមនាគមន៍ និងការកេងប្រវ័ញ្ចសព្វបែបយ៉ាងបានធ្វើឲ្យប្រជាកសិករបាត់បង់ទឹកចិត្តនឹងបង្កើនផល រួមផ្សំនិងផ្នត់គំនិតចុះចាញ់ព្រេងវាសនា ហើយនិងកំរៃណែនគ្រប់យ៉ាងដែលលោកម្ចាស់និងពួកអភិជនបង្ខំដាក់ពីលើ ។

គេធ្វើស្រែសំរាប់តែសេចក្តីត្រូវការខាងអាហារ និងដើម្បីដូរយកសំលៀកបំពាក់និងប្រដាប់ប្រដារប្រើប្រាស់ខ្លះ ។ គេធ្វើស្រែតែមួយដងទេក្នុងឆ្នាំ ។ ដើម្បីចៀសវាងផលិតផលលើសដោយសារខ្វះមធ្យោបាយនាំទៅលក់នៅទីឆ្ងាយ រាស្ត្រសាមញ្ញធ្វើស្រែវៃឲ្យបានផលត្រឹមតែ ៧០ឬ៨០ថាំងប៉ុណ្ណោះក្នុងមួយគ្រួសារ ។ តែ អស់លោក ឃុន ល្វង ដែលមានដីស្រែធំទូលាយ ហើយមានទាសករច្រើន មានជង្រុកស្រូវយ៉ាងធំធាត់ ហើយដឹកស្រូវទៅលក់ឯបរទេសបានលុយកាក់ ទិញមាសប្រាក់ចាយវាយហ៊ឺហា ។ លោកមន្ត្រីនាយកមានជង្រុកស្រូវដែលមានបណ្តោយដល់ទៅ ២០ល្វែង ។

ក្រៅពីដំណាំស្រូវ គេដាំដំណាំផ្សេងៗទៀតចំរុះគ្នា សំរាប់បរិភោគក្នុងគ្រួសារ ឬចែកចាយដល់មិត្តភក្តិ ឬលក់ដូរខ្លះ ។ ក្នុងចំការផ្ទាល់ខ្លួន ជាពិសេសច្រើននៅជុំវិញផ្ទះ គេមានដាំ ដូង ស្លាចេក ស្វាយ ល្មុត ក្រូច អំពៅ ម្នាស់ ។ល។ គេមិនដែលឃើញ

www.budinst.gov.kh www.elibraryofcambodia.org

ចំការដែលមានដាំសុទ្ធតែក្រូច ឬស្វាយតែមួយមុខទេ ។ ចំពោះបន្លែវិញ គេដាំតែតាមរដូវ គេគ្មានបច្ចេកទេសក្នុងការដាំដំណាំខុសរដូវទេ ។ ស្ពៃ ត្រសក់ ត្រឡាច ជាដើម មិនមានដាំនៅរដូវប្រាំងទេ ។ ចាស់ៗដំណាលថា បើនៅសម័យនោះ បើមានអ្នកជំងឺដល់ស្លាប់ហើយត្រូវការ ស្ពៃយកទៅធ្វើថ្នាំនៅរដូវប្រាំង អ្នកនោះប្រាកដជាស្លាប់មិនខានឡើយ ព្រោះគេមិនអាចរកស្ពៃបាន ។

ម្យ៉ាងទៀត បន្លែខ្លះដូចជា ប៉េងប៉ោះ ស្ពៃក្តោប សាឡាត់ខាត់ណា មិនទាន់មានយកមកដាំនៅបាត់ដំបងយើងទេ ។ សម័យនោះគេឃើញមានតែ ប៉េងប៉ោះម្យ៉ាង ផ្លែតូចៗមូលប៉ុនកូនដៃ ។ ឯម្ទេសវិញក៏មានតែពីរបែបទេគឺពូជម្ទេសឥន្ទជិត និងពូជម្ទេសយក្ខកន្ត្រៃដែលសព្វថ្ងៃយើងមិនសូវបរិភោគផងទេ ។

ដើម្បីជាជំនិះ និង កិច្ចការស្រែចំការ គេចិញ្ចឹម គោ ក្របី សេះ ដំរីនៅក្នុងគ្រួសារ ។ អ្នកមាន មានគោក្របីទាំងហ្វូងៗ ហើយមានបាវបំរើឃ្វាល ។ អ្នកក្រមានគោ ឬក្របីតែមួយនឹម ឬក៏គ្មានផង ។ អ្នកក្រខ្សត់ត្រូវជួលគោក្របីគេធ្វើស្រែចំការ ថែមលើការជួលដីស្រែទៀត ។ កសិករប្រភេទនេះច្រើនតែរស់ត្រដាបត្រដួសជួនកាលដោយសារទំងន់មួយទៀនគឺការខ្ចីបុលគេ ។

តាំងពីយូរមកហើយ មានច្បាប់បញ្ញត្តិមួយចែងអំពីរបៀប

www.budinst.gov.kh www.elibraryofcambodia.org

របបក្នុងការចិញ្ចឹមសត្វ ។ ចាប់ពីថ្ងៃ ៣ កើត ខែមាឃ ដល់ថ្ងៃ៣ កើតខែពិសាខ ទាំងអស់គ្នា ទាំងលោកម្ចាស់ ទាំងអភិជនទាំងរាស្ត្រប្រជា អាចលែងគោ ក្របី សេះ ដំរី ឲ្យដើររកស៊ី ដោយឥតព្រួយបារម្ភក្រែងសត្វពាហណៈខ្លួន ដើរបេះបោចស៊ីដំណាំអ្នកដទៃឡើយ ។ គេរង់ចាំតែដល់ថ្ងៃ ៣ កើតខែពិសាខ ទើបនាំគ្នាទៅចាប់គោក្របីយកមកធ្វើស្រែចំការវិញ ។ វិធានការនេះ ផ្តល់ការងាយស្រួលដល់អ្នកមានគោក្របី តែឲ្យផលអាក្រក់ដល់អ្នកដែលមានបំណងដាំដំណាំផ្សេងៗ ដូចជាដាំ ពោត សណ្តែកបាយជាដើម ។ ដូចនេះក្រោយការស្រែចំការ ត្រូវទំនេរទាំងអស់គ្នា គេនាំគ្នាដើរពីស្រុកមួយទៅស្រុកមួយ ដើរស្តាត់សាកសួរសុខទុក្ខញាតិមិត្ត ធ្វើបុណ្យធ្វើទានកំសាន្តសប្បាយ ឬលេងល្បែងស៊ីសងតាមទំនើងចិត្ត ។ គេមិនសូវខ្វល់ខ្វាយនឹងកិច្ចការរកស៊ីអ្វីឡើយ ។ រដូវប្រាំងជារដូវកំសាន្តសប្បាយ ជារដូវបុណ្យទាន ជារដូវចូលឆ្នាំ ។

ក្នុងការចិញ្ចឹមសត្វនេះទៀត គេមានច្បាប់មួយយ៉ាងដែលតឹងរ៉ឹងជាទីបំផុត គឺចោរលួច គោក្របី សេះដំរី ត្រូវតែប្រហារជីវិតចោលនៅពេលចាប់បាន ។ អ្នកមានគោ ក្របីមិនសូវព្រួយបារម្ភខ្លាចចោរលួចសត្វពាហណៈឡើយ ។ ច្បាប់នេះប្រហែលជាមានបំណងការពារទ្រព្យសម្បត្តិលោកម្ចាស់ និងពួកអភិជន ដែលមានគោក្របីទាំង

www.budinst.gov.kh www.elibraryofcambodia.org

ក្រោលៗទេ ។ ដំរី លោកម្ចាស់ដើររាតត្បាតពេញភូមិ ស៊ីចេកស៊ីម្នាស់អ្នកស្រុក ហើយខ្លះដើរបោចរើខ្ទមអ្នកក្រីក្រ តែពុំមានអ្នកណាហ៊ាននិយាយមួយម៉ាត់ឡើយ ។ លោកតា តូច បានយកផ្គខ្វែកទៅបាញ់ដំរីលោកម្ចាស់ ដែលចូលមកស៊ីអំពៅក្នុងចំការគាត់ ។ ដំរីនោះវាច្រឡោតដោយត្រូវគ្រាប់ផ្គខ្វែកក៏ដេញព្រេចគាត់ទាល់តែស្លាប់ ។ ដល់ពេលនេះ ច្បាប់មានន័យផ្សេងៗ គេចោទថាលោកតា តូចធ្វើឲ្យដំរីគេកាច ដែលនាំឲ្យដំរីនោះដើរព្រេចគេព្រចឯងតទៅទៀត ។ គ្រួសារលោកតាតូចត្រូវគេពិន័យជាប្រាក់ ៤ តម្លឹង ។ គ្រួសារគាត់ត្រូវជំពាក់បំណុលគេ ដោយម្យ៉ាងត្រូវរកប្រាក់ធ្វើបុណ្យខ្មោច ម្យ៉ាងទៀតត្រូវរកលុយទៅសងថ្លៃដំរីគេ ដែលសម័យនោះ គេប្រើពាក្យម្យ៉ាងថា "*ហៅព្រលឹងឲ្យដំរី*" ។

នៅសម័យនោះ អ្នកស្រុកមិននិយមបរិភោគសាច់គោទេ ។ នៅទីផ្សារមិនដែលមានលក់សាច់គោទាល់តែសោះ ។ គេបរិភោគតែសាច់សត្វព្រៃដែលគេបរបាញ់ ឬដាក់អន្ទាក់បាន ។ មានតែអ្នកប្រមឹកទេដែលបរិភោគសាច់គោក្របីដោយមិនឲ្យគេដឹងខ្ជរខ្ជាយ ។

មានតែ ចិន យួនទេ ដែលចិញ្ចឹម ជ្រូក មាន់ ទាព្រោះខ្មែរកាន់ព្រះពុទ្ធសាសនាទៀងទាត់ ខ្លាចបាបណាស់ មិនហ៊ានចិញ្ចឹមសត្វ សំលាប់សត្វទេ ។

www.budinst.gov.kh www.elibraryofcambodia.org

ដោយសារមនុស្សតិចនិងផ្ទៃដីលិចទឹកធំ ខេត្តបាត់ដំបង សម័យនោះសម្បូរត្រីហួសពីសេចក្តីត្រូវការឆ្ងាយណាស់ ។ គេបរិភោគតែត្រីធំៗដូចជាត្រីរ៉ស់ ត្រីសណ្តាយ ។ គេនេសាទត្រីបានដោយងាយណាស់ដោយគ្រាន់តែប្រើឧបករណ៍សាមញ្ញៗ ។ នៅបឹងទន្លេសាបលោកម្ចាស់លក់ភាស៊ី គឺឲ្យនេសាទឲ្យពាណិជ្ជករ ដែលភាគច្រើនជាជាតិចិនធ្វើអាជីវកម្ម យកត្រីឆ្អើរ ត្រីងៀតទៅលក់ឯប្រទេសសៀមបានចំណេញយ៉ាងកប់ក្តោង ។

នៅសម័យនោះ គេមិនដែលបរិភោគត្រីតូចៗល្អិតល្អោចដូចត្រីរៀល ត្រីលិញ ត្រីចង្វារទេ ។ អ្នកណាបរិភោគត្រីទាំងនេះ ត្រូវគេមើលងាយសើចចំអកយ៉ាងខ្លាំង ព្រោះត្រីប្រភេទនេះ គេប្រើសំរាប់តែធ្វើខ្លាញ់ ។

នៅខែកត្តិក មិគសិរ ឬពិសាខ ជេស្ឋ នៅពេលដែលនៅបាត់ដំបងសម្បូរត្រី អ្នកស្រុកខេត្តសុរិន្ទ បុរីរម្យ ច្រើននាំគ្នាធ្វើដំណើរ តាមរទេះគោរាប់រយមកធ្វើត្រីឆ្អើរ ប្រហុក ផ្អកយកទៅស្រុកវិញ ។

រឿងមួយចំឡែកគឺនៅពេលនោះ គេបរិភោគសាច់ក្របីគ្រប់គ្នាឥតប្រកែប្រកាន់អ្វីឡើយ ។ ជួនកាលគេប្រើសាច់ក្របីជំនួសសាច់ជ្រូកផងក៏មាន ។ នៅទីផ្សារ មានលក់សាច់ក្របីរាល់ ថ្ងៃ ។

www.budinst.gov.kh www.elibraryofcambodia.org

## ខ- សិប្បកម្ម ៖

ភាពដាច់ស្រយាលដោយសារកង្វះគមនាគមន៍ បានធ្វើឲ្យប្រជាជនបាត់ដំបងចេះរស់ ដោយសារខ្លួនឯង មិនសូវពឹងពាក់បរិក្ខារមកពីបរទេសពេកទេ ។ គេអាចធ្វើឧបករណ៍កសិកម្មបានសឹងតែគ្រប់ជំពូក ។ គេអាចសង់ផ្ទះបានដោយប្រើតែគ្រឿងគ្រៅក្នុងស្រុក ។ គេមានរោងជាងតូចៗត្រង់នេះមួយ ត្រង់នោះមួយធ្វើគ្រឿងបរិក្ខារផ្សេងៗ សំរាប់បំពេញសេចក្តីត្រូវការ ។ គេនិយមដូរផលិតផលគ្នាទៅវិញទៅមក ឬលើកដៃជួយគ្នាទៅវិញទៅមកក្នុងកិច្ចការផ្សេងៗ ។ ការលក់ ឬជួលមិនសូវមានទេ ។

### - សិប្បកម្មសំណង់

នៅគ្រប់វត្តអារាម នៅគ្រប់ភូមិ មនុស្សប្រុសគ្រប់គ្នាសុទ្ធតែចេះឈូសឈើ អារឈើ ធ្វើតុទូ ធ្វើរទេះ ធ្វើទូកឬសង់ផ្ទះ ។ គេមិនសូវជួលជាងសង់ផ្ទះឈើទេ ។ គេច្រើនតែពឹងពាក់គ្នាទៅវិញទៅមក ។ គេសង់ផ្ទះ តាមក្បួនតម្រាយ៉ាងច្បាស់លាស់ ដែលមានចែងទុកតាំងពីបុរាណមក ។ គេមិនដែលបំភ្លៃរាងរៅផ្ទះសំបែងឲ្យប្លែកខុសពីក្បួនបុរាណទេ ។ ជាងសង់ផ្ទះដែលល្បីជាងគេ គឺជាង*អុន* នៅក្បែរវត្តក្តាំងងារដែលប៉ិនប្រសប់ទាំងខាងសំណង់ ទាំងចំលាក់ឈើ និងធ្វើគ្រឿងដែក ។ គាត់ចេះរចនាធ្វើប្រដាប់ស្ទូច

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំង ទី ១១

ចំណាក់វត្តឌីរីស (គ.ច)



វត្តឌីរីស ស្នាដៃ កុងតូ ជាងញ៉ិក
ជាងសៀ នៅឆ្នាំ ១៩០៤ (គ.ច)



www.budinst.gov.kh www.elibraryofcambodia.org

លើកឈើ ឬផ្ទះធំៗ ហៅថា "*កាឡាក់* "។ ជាងអុននេះល្បីឈ្មោះរហូតដល់ពេលក្រោយមកទៀត ។

តែសំណង់ផ្ទះថ្ម ដូចជា វិហារ សាលា ជាដើម ត្រូវការជាងមានបច្ចេកទេស ។ គេមិនសូវឃើញមានប្រើស៊ីម៉ង់ទេ តែគេប្រើកំបោរលាយក្រដាស់ប៉ុយ ស្ករក្អម និងជ័រទឹក ។ គេប្រើឥដ្ឋ ដែលផលិតចេញពីឡឥដ្ឋពីរ គឺឡឥដ្ឋ ចឹកឡុក និងឡឥដ្ឋ ចឹកកា ដែលតាំងនៅចន្លោះ វត្តខ្មែង និងវត្តតាមិម ។ គេច្រើនជួលជាងចិនមករៀបឥដ្ឋធ្វើព្រះវិហារ ឬផ្ទះថ្ម ។ ជាងរៀបឥដ្ឋល្បីឈ្មោះជាងគេ គឺកុងតូ នៅភូមិដូនទាវ និងជាងស្នា នៅមុខកំផែង ។ ក្នុងការរៀបឥដ្ឋនេះ មេជាងយកឈ្នួល ៥កាក់ក្នុងមួយថ្ងៃ កូនជាងយក ៣ កាក់ក្នុងមួយថ្ងៃ ។

ក្នុងសំណង់ផ្ទះ ព្រះវិហារ សាលា ឬការធ្វើទូក រទេះ គេមិនសូវភ្លេចក្បាច់រចនាទេ ។ គេមិនដែលប្រើតុទូ ឬទូករទេះ ដែលឥតក្បាច់រចនា ដែលហៅថា "*កំរោល* "នោះទេ ។ ជាងឆ្លាក់ឈើដែលល្បីឈ្មោះ គឺជាងអុននៅក្បែរវត្តក្តាំងងារ ជាងញ៉ិកនៅព្រែកតាតន់ ។ ជាងសឿប្រហែលនៅចំការសំរោង ប៉ិនប្រសប់ខាងឆ្លាក់រូបស៊ីម៉ង់ ។ រូបគ្រុឌ គោ ស្វា មនុស្ស យក្សនៅព្រះវិហារវត្តកណ្តឹង និងវត្តដំរីស សុទ្ធតែជាស្នាដៃជាងញ៉ិក ជាងសឿទាំងអស់ ។

www.budinst.gov.kh www.elibraryofcambodia.org

ជាងញ៉ីក មានថ្មីដែខាងគំនូរផាត់ពណ៌ទៀត ។ លោកសុត្តន្តប្រីជា ឥន្ទ ក៏ជាជាងគំនូរផាត់ពណ៌ល្បីឈ្មោះម្នាក់ដែរ ។

អ្នកស្រុកបាត់ដំបង មិនសូវប៉ិនប្រសប់ធ្វើរទេះគោប៉ុន្មានទេ ។ រទេះទ្រាយប្រកបដោយក្បាច់រចនាយ៉ាងប្រណិតនោះ ត្រូវគេនាំយកមកពីតំបន់ស្វាយចេក និង កោះក្រឡ ។ គេមិនដែលឃើញមានកន្លែងណាធ្វើទូកច្បាស់លាស់ទេ តែគេច្រើនធ្វើទូកនៅកន្លែងដែលត្រូវការតែម្តង ។

## - ជាងដែក

នៅត្រើយខាងកើតនៃស្ទឹងសង្កែ ចាប់តាំងពីមុខវត្តសំពៅរហូតដល់ភូមិចិន ព្រែកព្រះស្តេច វត្តបាឡាត់មានរោងជាងផលិតបរិក្ខារធ្វើអំពីដែក សំរាប់សេចក្តីត្រូវការក្នុងស្រុក ដូចជា ប្រណាក កណ្តៀវ កាំបិត ពូថៅ ផាល ។ល។ នៅវត្តបាឡាត់ មាន ជាងគង និងជាងស៊ិន ។ នៅភូមិចិន មានជាងម៉ៅ ដែលផលិតផលរស់គាត់ល្បីសុះសាយពេញខេត្តបាត់ដំបង ។ នៅខាងត្បូងវត្តសូរភី មានជាងសិតស្ពាន់ធ្វើអកកំបោរ តែគេមិនដែលឃើញមានជាងសិតព្រះពុទ្ធរូបអំពីស្ពាន់ទេ ។

www.budinst.gov.kh www.elibraryofcambodia.org

- **ជាងមាស- ជាងប្រាក់**

នៅសម័យសក្តិភូមិ ពួកអភិជនដែលមានមធ្យោបាយច្រើន ចូលចិត្តប្រើបរិក្ខារដូចជា អលង្ការ កន្តោរ ផ្តិល ហិបស្លា ជើងពាន ធ្វើអំពីប្រាក់ ឬអំពីមាស ដើម្បីលើកកិត្តិយសរបស់គេ ។ ពួកអភិជនច្រើនជួលជាងឲ្យទៅធ្វើគ្រឿងមាសប្រាក់នៅក្នុងផ្ទះគេរាប់ខែ ។ ពេលខ្លះ លោកម្ចាស់បើកមាសទាំងដុំៗឲ្យជាងធ្វើគ្រឿងអលង្ការ ឬប្រដាប់ប្រដាផ្សេងៗនៅក្នុងកំផែងតែម្តង ។

ជាងមាសដែលល្បីឈ្មោះជាងគេ គឺជាងជានៅភូមិរតនៈ ។ ជាងឈើយ នៅកំពង់សំបួរក្បែរវត្តសំរោង ជាជាងប្រាក់ដ៏ល្បីល្បាញ ជាគ្រូលើជាងប្រាក់ទាំងអស់នៅពេលនោះ ។ គឺជាងឈើយនេះហើយដែលមានទោចក្រយានជិះមុនគេនៅបាត់ដំបង ។

- **សិប្បកម្មតំបាញ និងកាត់ដេរ**

ពួកអភិជនប្រើសំពត់អាវព្រៃសូត្រ ដែលទិញមកពីបរទេស ។ ប្រជាជនសាមញ្ញ ត្រូវចេះលៃលកផលិតសំពត់អាវ មុង ភួយ ក្រមាសារុង សំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន ។ សំពត់ដែលគេត្បាញនៅពេលនោះ ជាសំពត់លាត ឬឆ្នូត ធ្វើអំពីកប្បាស ដែលគេហៅថា *សំពត់ប៉ប៉ក* ។ គេដាំកប្បាសដើមធំៗ ហៅថាកប្បាសទេស ដើម្បីយកសំឡី រវៃជាអំបោះត្បាញជាភួយក្រមា ។

www.budinst.gov.kh www.elibraryofcambodia.org

ភូមិជាច្រើនមានចិញ្ចឹមដង្កូវនាង តែអ្នកបាត់ដំបងមិនសូវល្បីខាងធ្វើសូត្រប៉ុន្មានទេ ។ នៅសឹងតែគ្រប់ផ្ទះ សុទ្ធតែមានកីតំបាញ តែពេលនោះគេប្រើកីតំបាញរបស់ខ្មែរ មិនមែនកីតំបាញបែបសៀមដែលយើងឃើញខ្លះសព្វថ្ងៃនេះទេ ។

នៅឆ្នាំ១៩០៧ ក្រុងបាត់ដំបងដោយមិនទាន់មានជាងកាត់ដេរតាំងយីហោដូចសព្វថ្ងៃ គេជួលកាត់ដេរខោអាវ នៅតាម ផ្ទះជាងដេរកាត់ដែលល្បីឈ្មោះ នៅតាមភូមិ ។ ជាងភាគច្រើនដេរខោអាវដោយដៃ ។ តែពេលនោះ គេឃើញមានម៉ាស៊ីនដេររវៃដោយដៃពុំមែនធាក់ដោយជើងដូចសព្វថ្ងៃនេះទេ ហើយក៏ប្រើ ត្រល់វែងមិនមែនត្រល់មូលដូចសព្វថ្ងៃនេះដែរ ។

## - សិប្បកម្មធ្វើកន្ទេលផ្តៅ :

ខេត្តបាត់ដំបងល្បីឈ្មោះតាំងពីយូរយារណាស់មកហើយខាងធ្វើកន្ទេលផ្តៅ ។ ភូមិស្ទឹង បឹងក្រសាល ជីរក ។ល។ ជាតំបន់ដែលមានមុខជំនាញខាងធ្វើកន្ទេលផ្តៅ ។ គេបោចផ្តៅពីតំបន់ព្រៃភ្នំនៅជិតខាងយកមកច្រៀកជាបន្ទះតូចៗ រួចត្បាញអន្ទងជាមួយសំបកខ្លែងពណ៌ ធ្វើជាកន្ទេល សំរាប់ប្រើប្រាស់ក្នុងគ្រួសារប្រចាំថ្ងៃ ។

កន្ទេលផ្តៅ មានគុណភាពស្វិតមាំ សំរាប់ប្រើនៅគ្រប់កន្លែងអ៊ុកពើន តែមិនមែនជាគ្រឿងប្រណិតខ្ពង់ខ្ពស់ទេ ។

www.budinst.gov.kh www.elibraryofcambodia.org

- រោងបិតស្រា

នៅត្រង់ផ្សារលើសព្វថ្ងៃ មានរោងមួយវែង ដំបូលប្រក់ស្បូវ ដែលអ្នកស្រុកតែងហៅថា ភាស៊ុស្រា គឺជាកន្លែងបិតស្រាតែមួយគត់នៅខេត្តបាត់ដំបង ។ រោងបិតស្រានេះប្រើអង្ករ និងស្ករត្នោតជារូបធាតុដើម ។ ម្ចាស់រោងបិតស្រានេះជាជាតិចិនដែលដេញភាស៊ុបាន មានសិទ្ធិធ្វើស្រាលក់ផ្តាច់មុខតែម្នាក់ឯង ។ លោកម្ចាស់ត្រូវធានាមិនឲ្យមានផលិតករប្រកួតប្រជែងឡើយ ទោះបីលួចលាក់ក៏ដោយ ។ មេភាស៊ុចិននេះមានសិទ្ធិចាប់ចង ពិន័យ ឬធ្វើទោសជនណាដែលបិតស្រាលួចលាក់ ដែលនាំឲ្យខូចប្រយោជន៍គេ ។ ម្ចាស់ភាស៊ុស្រានេះគឺលោកស្រីពិភិត្ត ។

មានតែអ្នកក្រីក្រទេ ដែលផឹកស្រាចេញពីរោងបិតស្រានេះ ។ អ្នកមានប្រើស្រាដែលនាំមកពីបរទេស ជាពិសេសស្រាមកពីប្រទេសបារាំង ដូចជា សំប៉ាញ រ៉ូម អាប់សែន ជាដើម ។

- សិប្បកម្មធ្វើខ្លាញ់ត្រី

គឺជាអាជីវកម្មមួយ ដែលខ្លះខ្ចាយធនធានធម្មជាតិដ៏សម្បូរហូរហៀរក្នុងប្រទេសជាទីបំផុត ។ គេធ្វើខ្លាញ់ត្រីយកទៅលក់ឯប្រទេសសៀម ។ គេស្លខ្លាញ់នៅរដូវប្រាំងនៅតំបន់បឹងទន្លេសាប ។

គេចាប់ត្រី តូចក្តី ធំក្តី យកទៅដាក់ក្នុងខ្ទះត្នោតធំៗហើយដុត

www.budinst.gov.kh www.elibraryofcambodia.org




(ម.ម)

ភ្លើងដាំឲ្យពុះយ៉ាងយូរលុះត្រាតែចេញខ្លាញ់ល្អ ។ គេចាក់ទាំងត្រីទាំងខ្លាញ់ទៅក្នុងស្នឹង ។ កាកត្រី ដែលគេហៅថា "អាចម៍ខ្លាញ់" ក៏លិចទៅក្នុងទឹក ។ ឯខ្លាញ់ដែលស្រាល ក៏អណ្តែតតាមទឹកទៅទើរនឹងផ្ទាំងស្លឹកត្នោតដែលគេច្រុះបាំងនៅខាងមុខ ។ គេដួសខ្លាញ់ដាក់ទូក ហើយយកមកចំរាញ់ម្តងទៀត ។

## - មុខរបរធ្វើផ្អិត

នេះជាវិធីបំផ្លាញធម្មជាតិមួយយ៉ាងចំឡែកនៃអ្នកស្រុកនៅជុំវិញបឹងទន្លេសាប ។

នៅរដូវប្រាំង តំបន់ជុំវិញទន្លេសាបត្រូវគោកស្ងួតនៅសល់តែបឹងខ្លះៗដែលហ៊ុំព័ទ្ធទៅដោយព្រៃយ៉ាងស្មុគ្រស្មាញ ។ សត្វស្លាបមានត្រដក់ រនាល ក្រសារ ។ល។ តែងនាំគ្នាទៅកកកុញរកអាហារនៅតាមបឹងនោះ ។

ព្រានប្រមាញ់តែងនាំគ្នាជាក្រុម រវាង១០នាក់យ៉ាងច្រើន ធ្វើដំណើរលបៗចូលទៅហ៊ុំព័ទ្ធបឹងនោះ ។ គេស្រែកព្រមៗគ្នាឲ្យសត្វស្លាបទាំងនោះផ្អើល ។ សត្វដែលមានចំនួនច្រើនលើសលប់មិនអាចហើរបានទាំងអស់ទេ ។ មួយចំនួនត្រូវរត់ទៅជ្រកក្នុងព្រៃនៅជុំវិញបឹង ។

ព្រានដេញតាមចាប់សត្វទាំងនោះបានហើយ ក៏កាត់យកតែ

www.budinst.gov.kh www.elibraryofcambodia.org

ស្លាបភ្លាម ដោយឥតសំលាប់សត្វទាំងនោះទេ ។

គេនាំគ្នារើសរែកស្វែងស្លាបសត្វទាំងនោះ យកមកកាន់ភូមិ វែង ត្បាញធ្វើផ្លិត ហៅថា "ផ្លិតស្លាប "ដែលជាទីនិយមនៃព្រះសង្ឃ ឬ អ្នកមានខ្ពង់ខ្ពស់ ។

## - សិប្បកម្មធ្វើក្រមួន

គេនិយមប្រើទៀន សំរាប់បំភ្លឺក្នុងផ្ទះសំបែង ឬពេលមាន បុណ្យទាន ។

ឃ្មុំនិយមធ្វើសំបុកនៅតាមដើមឈើខ្ពស់ៗ នៅតំបន់ព្រៃលិច ទឹក ជុំវិញបឹងទន្លេសាប ។

ពេលរដូវប្រាំង គេតែងនាំគ្នាបររទេះទៅកាន់ដើមឈើដែល សម្បូរដោយសំបុកឃ្មុំ ។ មុននឹងឡើងយកឃ្មុំ គេតែងធ្វើពិធីសែន ព្រេនតាមក្បួនប្រពៃណីដោយខានមិនបាន ដើម្បីសុំអ្នកតានៅរក្សា តំបន់ ។ នៅពេលយប់ គេកាន់ភ្លើងគប់ ឡើងទៅលើដើមឈើ ។ គេនិយមយកសរសៃដើមល្ហុងដែលស្ងួតយកមកចងធ្វើជាគប់ភ្លើង ដោយចងជាបាច់យ៉ាងតឹងដុតទៅមិនមានអណ្តាតភ្លើង ។

នៅពេលយប់ ពេលឡើងដល់លើដើមហើយ គេចោលគប់ ភ្លើងនោះអស់មួយទំហឹងដៃទៅកាន់កន្លែងមួយឆ្ងាយពីគល់ឈើ ។ ឃ្មុំឃើញរងើកភ្លើងរសាត់តាមគប់នោះ ក៏ហើរចោលសំបុកទៅ

www.budinst.gov.kh www.elibraryofcambodia.org

រោមភ្លើងនោះ ។

អ្នកឡើងក៏ប្រមូលចៀរយកសំបុកឃ្មុំ និងទឹកឃ្មុំបង្ហូតចុះមកដី ។ តាមពត៌មានថា ក្នុងដើមឈើមួយដើមគេអាចយកទឹកឃ្មុំបានរវាង ២០ក្អមធំៗ សំរាប់លក់ដូរតាមត្រូវការ

គេយកសំបុកឃ្មុំទៅស្ងោរក្នុងខ្ទះត្នោតឲ្យពុះត្រឹមត្រូវ រួចដួសយកទឹកក្រមួន ដាក់ក្នុងឆ្នាំងមួយផ្សេងទៀតដាំស្ងោរ រហូតអស់ជាតិទឹក ។ គេដួសទឹកក្រមួនដាក់ក្នុងចានប៉ុនៗគ្នា ទុកឲ្យកក ល្មមមួយដុំទំងន់មួយនាឡិ ។ ទឹកឃ្មុំនិងក្រមួនឃ្មុំ ជាវត្ថុមានតំលៃមួយនៅសម័យនោះ ។

## - អាជីវកម្មរកត្បូងនៅបរប៉ៃលិន

ពួកកូឡាបានចូលមកជីកត្បូង នៅតំបន់ប៉ៃលិន តាំងពីឆ្នាំ ១៨៧៦ តែឥតមានបង់ពន្ធដារអ្វីដល់លោកម្ចាស់ទេ ។ ពួកនេះទាក់ទងជាមួយចៅហ្វាយខេត្តសៀមនៅចន្ទបុរីទៅវិញ ។ នៅឆ្នាំ១៨៨១ ពួកកូឡាដែលជីកត្បូងកើតវិវាទគ្នា ។ កូឡាម្នាក់បានពឹងពាក់កុងស៊ុលអង់គ្លេសប្រចាំក្រុងបាងកក ឲ្យនាំខ្លួនចូលទៅគាល់ទូលព្រះចៅសៀម ។ រាជការសៀមយល់ឃើញប្រយោជន៍ក៏ចាត់ចែងហូតពន្ធដារលើការជីកត្បូងនេះ ។ មេភាស៊ីត្បូងនៅពេលនោះ គឺ

www.budinst.gov.kh www.elibraryofcambodia.org

*ម៉ង ឃុន ទី* ដែលព្រះចៅសៀមតែងតាំងជា*ហ្លួងមណីយុទ្ធនា* ។ តាមពត៌មានថា លោកម្ចាស់ឥតបានកំរៃ ដោយសារភាស៊ីនេះទេ ព្រោះប្រាក់ពន្ធទាំងអំបាលម៉ាណ ត្រូវបង់ទៅព្រះចៅសៀមផ្ទាល់តែម្តង ។

ពួកកូឡានៅប៉ៃលិនទាំងនេះ ច្រើនទាក់ទងខាងពាណិជ្ជកម្មជាមួយខេត្តចន្ទបូរី ។ តែមានពួកកូឡាមួយពួក ដោយមានលាវចូលរួមផង បានមកដឹកអង្ករនិងប្រេងកាតពីបាត់ដំបងទៅប៉ៃលិន ដោយប្រើ **គោតាង** ជាពាហណៈសំរាប់ដឹកនាំ ។ គេប្រើរទេះគោរមិនកើតទេ ព្រោះផ្លូវទៅប៉ៃលិនជាផ្លូវឡើងភ្នំចុះភ្នំ ហើយគ្មានផ្លូវថ្នល់ស្អាតបាតផង។

**- អំពីការកិនស្រូវ**

នៅសម័យនោះ អ្នកស្រុក ទាំងមានទាំងក្រ បរិភោគអង្ករដែលបុកដោយដៃ ។ គេប្រើត្បាល់កិនដែលធ្វើអំពីឫស្សីត្បាញ ហើយបិទដីសំរាប់កិនស្រូវ ។ គេយកអង្ករសំរូបដែលកិនហើយយកទៅបុកដោយត្បាល់បុក ឬ ត្បាល់ក្តឿង ឲ្យអស់ជាតិកន្ទក់ រួចអុំស្លេ ឲ្យទៅជាអង្ករសំរិត ។ នៅក្នុងកំផែង មានរោងសិប្បកម្មមួយយ៉ាងធំ ដែលមានត្បាល់កិនត្បាល់បុកជាច្រើនគ្រឿង ដែលគេប្រើអ្នកទោសឲ្យកិនស្រូវ បុកអង្ករនៅទីនេះ ។ លោកអង្គទរាជ

www.budinst.gov.kh www.elibraryofcambodia.org

មាននាទីត្រួតត្រាអ្នកទោស កិនស្រូវ បុកអង្ករ ផ្គត់ផ្គង់គ្រួសារលោកម្ចាស់ ស្រីរបាំ ស្រីបំរើទាំងអស់ក្នុងកំផែង ។

នៅខាងជើងវត្តសូរភី អ្នកស្រុកមានបច្ចេកទេសពិសេសតាំងពីយូរយារមកហើយ ខាងធ្វើត្បាល់កិនទើបគេហៅភូមិនេះថាភូមិត្បាល់កិនរហូតដល់សព្វថ្ងៃ ។

## - វិធីស្លក្រាម

ក្រាមជាវត្ថុធាតុដើម សំរាប់ធ្វើរំសេវ ធ្វើថ្នាំព្យាបាលរោគ ឬធ្វើគ្រឿងផ្សំសំរាប់ប្រឡាក់ត្រីសាច់ ។ គេទិញក្រាមមកពីបរទេស ប៉ុន្តែអ្នកស្រុកបាត់ដំបង សម័យនោះ មានទេពកោសល្យម្យ៉ាង អាចផលិតក្រាមបានដោយខ្លួនឯង ។

គេប្រមូលអាចម៍ប្រជៀវ នៅតាមរអាងភ្នំយកមកត្រាំទឹក ក្នុងពាងធំៗអស់ពេលច្រើនថ្ងៃ ។ គេត្រងយកទឹកដែលរងថ្លា ដាក់ក្នុងខ្ទះធ្លោត ដាំឲ្យពុះខះនៅសល់តែ ១ភាគ៣ ។

គេយកល្អីធ្វើពីឫស្សី ក្រាលកំណាត់ផាឱបរួចដាក់ផេះឈើសាំងរាំង រួចក្រាលកំណាត់មួយជាន់ទៀតទើបចាក់ទឹកនោះទៅក្នុងល្អី ។

គេត្រងទឹកនោះដាក់ក្នុងផើង ទុកច្រើនថ្ងៃ ទើបកករដូចអំបិល នៅបាតផើង ។ គេប្រមូលក្រាមនោះដាក់សំដិលឲ្យស្រស់ទឹក

www.budinst.gov.kh www.elibraryofcambodia.org

ទុកប្រើការ ។ ភូមិស្លក្រាម មានល្បីឈ្មោះខាងផលិតក្រាមនេះ ។

## វិធីធ្វើស្ពាន់ធ័រ

ចាស់ៗបានដំណាលថាខ្មែរអាចធ្វើស្ពាន់ធ័របាន ។ គេយកពងមាន់ ពងទាគោះយកតែពងក្រហម ដាក់ចូលក្នុងបំពង់ឫស្សី ចុកចំបើង រួចយកទៅកប់ពាក់កណ្តាលបំពង់ក្នុងដីដែលសើមជានិច្ច ។ ក្នុងរយៈ ២ ឬ ៣ខែ ពងមាន់ ឬពងទា ដែលនៅក្នុងបំពង់អាចក្លាយជាម្សៅ ដែលគេប្រើធ្វើជាឱសថសំរាប់លាបកមរមាស់ ។

ចាស់ៗបានអះអាងទៀតថា ស្ពាន់ធ័រដែលផលិតក្នុងស្រុកនេះ មិនមានគុណភាពគ្រប់គ្រាន់សំរាប់ធ្វើរំសេវបានទេ ។

## គ- គមនាគមន៍

នៅរវាងឆ្នាំ ១៩០៧ នៅពេលដែលក្រុងបាងកកមានរថភ្លើង និងមានរថយន្តបើកបរលើផ្លូវកៅស៊ូខ្លះហើយនោះ ខេត្តបាត់ដំបងនៅតែប្រើផ្លូវគមនាគមន៍និងយានជំនិះបែបបុរាណនៅឡើយ ។ គេមិនឃើញមានសញ្ញាត្រង់ណាថា លោកម្ចាស់មានបំណងរៀបចំផ្លូវគមនាគមន៍ ឲ្យប្រសើរបន្តិចនោះទេ លើកលែងតែផ្លូវមួយប្រវែងប្រមាណ ៧០០ម៉ែត្រនៅមុខកំផែង ដែលលោកម្ចាស់ប្រើអ្នកទោសឲ្យយកអំបែងក្បឿងមកក្រាលហើយបុកឲ្យហាប់ ។

www.budinst.gov.kh www.elibraryofcambodia.org

មួយដែរ គឺការបើកឲ្យមានប្រើប្រៃសណីយ៍ទូរសព្ទនិងទូរលេខ នៅបាត់ដំបង ។ គេអាចផ្ញើទូរលេខ ទៅបាងកក ភ្នំពេញ ព្រៃនគរបានទាន់ចិត្ត ។ គេអាចនិយាយទូរសព្ទទៅមោង មង្គលបុរីបាន ។ មានជនជាតិអង់គ្លេសម្នាក់ជាអ្នកគ្រប់គ្រងប្រៃសណីយ៍នេះ ដែលអ្នកស្រុកហៅថាម៉ីស្ទើរ ។

គេអាចផ្ញើសំបុត្រទៅវិញទៅមក ពីបាត់ដំបងទៅបាងកក ដោយបិទតែម ១ហ្សឿងសំរាប់សំបុត្រធម្មតា ឬ ១០ប៉ៃ សំរាប់សំបុត្រអនុសិទ្ធិ ។ មន្ទីរប្រៃណីយ៍ តាំងនៅមាត់ស្ទឹងខាងកើត រោងចក្រអគ្គិសនីសព្វថ្ងៃ ។

នៅឆ្នាំ ១៩០៤ មានសទ្ធិសញ្ញាបារាំង សៀមមួយគ្រោងស្ថាបនាផ្លូវរថភ្លើងរួមគ្នាមួយពីភ្នំពេញមកបាត់ដំបង តែសទ្ធិសញ្ញានេះពុំបានអនុវត្តទៅវិញទេ ។ ផ្លូវរថភ្លើងនេះក៏ពុំបានស្ថាបនាដែរនៅពេលនោះ ។

## ឃ- យានជំនិះ

ដោយមានការលំបាកខាងផ្លូវគមនាគមន៍ ប្រជាជននៅបាត់ដំបង ប្រើយានជំនិះមិនបានទាន់សម័យដូចនៅភ្នំពេញ ព្រៃនគរបាងកកទេ ។ គេប្រើតែយានជំនិះបុរាណដូចជា ដំរី សេះ រទេះទូក ។ ពិតមែនតែពុំទាន់សម័យ តែយានជំនិះទាំងនោះតែងមាន

www.budinst.gov.kh www.elibraryofcambodia.org

តាំងលម្អរាងដោយសារក្បាច់រចនា ដែលជាស្នាដៃនៃសិល្បករខ្មែរ ដែលល្បីល្បាញតាំងពីយូរមកហើយ ។

- **រទេះគោ-រទេះក្របី**

ពេលដើរកំសាន្តឬមានការប្រញាប់ អ្នកស្រុកនិយមប្រើ **រទេះបំបោល** ដែលនៅតំបន់ខ្លះ គេហៅថារទេះសាលី ។ រទេះបំបោលជារទេះគោធុនស្រាល ផ្ទុកមនុស្សបានពីរឬបីនាក់យ៉ាងច្រើន តែអាចបរបោនលឿនទាន់ចិត្ត ។ អ្នកស្រុកតែងប្រកួតប្រជែងគ្នារចនាតុបតែរទេះបំបោលនេះ ដោយធ្វើយ៉ាងណា ឲ្យបានលឿនជាងគេ បានល្អជាងគេ មានក្បាច់ក្បូរជាងគេ ។

ពួកអភិជនឬគ្រួសារលោកម្ចាស់ ធ្វើដំណើរទៅណាមកណាដោយ**រទេះកឹង** ដែលជារទេះគោមានដំបូលប្រកបដោយក្បាច់រចនាយ៉ាងប្រណិត មានបាំងវាំងននពណ៌ឆើតឆាយ ហើយមានក្រាលពូក ។

ក្នុងការដឹកនាំឥវ៉ាន់ ឬ ទំនិញសព្វសារពើ គេប្រើ**រទេះទ្រាយឬរទេះតាង** ។ រទេះទ្រាយតែងមានជញ្ជាំងរាងបោងបន្តិច។ បើជញ្ជាំងទាបគេហៅថា **មុខឈ្នាង** ។ រទេះទ្រាយច្រើនមានដំបូលនិងជញ្ជាំងបិទជិត អាចចាក់សោរទុកឥវ៉ាន់ក្នុងនោះបាន ដែលគេហៅថា **ផ្ទះ** ។ តាមធម្មតា ផ្ទះគ្រប់បាំងតែឥវ៉ាន់ឬទំនិញទេ

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំង ទី ១៣

រទេះ ស្នូរ



រទេះបំពោល



(ម.ម)



ដំរី (អ.ស.ជ)



គោតាង (អ.ស.ជ)

www.budinst.gov.kh www.elibraryofcambodia.org

គេហៅថា **ផ្ទូរក្លូប** ។ ផ្ទូរខ្លះមានដំបូលគ្របទាំងឥវ៉ាន់ គ្របទាំងអ្នកបរ គ្របទាំងសត្វពាហណៈដែលអូសរទេះនោះផង គេហៅថា **ផ្ទូរអំពាន់** ។ ភាគច្រើន គេប្រើផ្ទូរអំពាន់សំរាប់តែរទេះក្របី ព្រោះក្របីជាសត្វចាញ់កំដៅ ។

**រទេះតាង**មានជញ្ជាំងត្រង់ៗ ហើយមិនសូវមានដំបូល ជាផ្ទូរទេ ។ រទេះតាងមានពីរយ៉ាង គឺតាងជ្រែង និងតាងទ្រុង ។

អ្នកស្រុកដែលមានទីលំនៅក្បែរទីប្រជុំជនបាត់ដំបង មិនសូវល្បីឈ្មោះខាងធ្វើរទេះគោ រទេះក្របីទេ ។ អ្នកបាត់ដំបង ច្រើនធ្វើរទេះតាងព្រោះជាការងាយជាង ។ ឯរទេះទ្រាយ ដែលប្រកបដោយក្បូរក្បាច់រចនានោះ ច្រើនតែនាំមកពីតំបន់ស្វាយចេក និងកោះក្រឡ ។

ក្រៅពីក្បាច់រចនា ជាងធ្វើរទេះមានឯកទេសធ្វើរទេះដោយឲ្យបញ្ចេញសូរសំលេងតែមួយបែបដូចៗគ្នា ។ រទេះគោឬរទេះក្របីនៅសម័យនោះប្រើតែភ្លៅធ្វើអំពីឈើ មិនដែលប្រើភ្លៅដែកដូចសព្វថ្ងៃទេ ។ នៅពេលបរ រទេះភ្លៅឈើនេះបញ្ចេញសូរសំលេងយ៉ាងអ៊ឹងអាប់ ។ ជាងដែលប៉ិនប្រសប់អាចធ្វើរទេះឲ្យបញ្ចេញសំលេង ៣ បែបតាមចិត្តចង់ ដូចជា **សំលេងផ្គោះ សំលេងចាបស្រុក និងសំលេងតឹក្កវីត** ។ សំលេងផ្គោះឮសូរបង្ហួស ង៉ូតៗ

www.budinst.gov.kh www.elibraryofcambodia.org

វែងៗ ។ សំលេងចាបស្រុកឮស្នូរខ្សៀវខ្សារ ឯសំលេងតឹក្ករីត ឮស្នូរខ្ជីកញ្ឆក់ៗ ឮវេតៗវេតៗ ។ សំលេងផ្គោះជាសំលេងគំរូញ លន្លង់លន្លោចពីរោះ ធ្វើឲ្យស្រណោះស្រក់ទឹកភ្នែក ជាពិសេសនៅរដូវប្រាំងពេលរៀបអស្តង្គត ។ គេនិយាយថា មានស្រីៗច្រើនគ្នាអង្គុយសំរក់ទឹកភ្នែក នៅពេលដណ្តាំបាយពេលល្ងាច បើឮស្នូររទេះច្រើនដែលមានសំលេងផ្គោះដូចគ្នាបរកាត់ភូមិ ។

តែបើមានរទេះចំឡែកបញ្ចេញសំលេង ង៉េតៗង៉តៗ នោះគេមិនបាច់ឆ្ងល់ទេ គេថាជាងធ្វើរទេះនោះជាជាងមិនកើត ជាជាងចោលម្សៀត ។ អ្នកបររទេះរបៀបនេះច្បាស់ជាត្រូវគេសើចចំអកពេបជ្រាយឡកឡឺយឲ្យមិនខានឡើយ ។

យើងគួរកត់សំគាល់ដែរថា រទេះគោ ឬ រទេះក្របី ដែលយើងឃើញកសិករយើងប្រើនៅបាត់ដំបងសព្វថ្ងៃនេះ សឹងតែទាំងអស់នោះគេហៅថា **រទេះនាងដា** មានកំណើតនៅកោះក្រឡ ។ រទេះនាងដាក្លាយពីរទេះទ្រាយបន្តិចរទេះតាងបន្តិចមានប្រយោជន៍ខាងសេដ្ឋកិច្ចជាង ។

- **រទេះសេះ**

ដោយថ្នល់មិនសូវស្អាតបាត គេច្រើនប្រើតែរទេះគោ រទេះក្របី តែនៅពេលចុងក្រោយនៃសម័យលោកម្ចាស់ គេឃើញប្រើ

www.budinst.gov.kh www.elibraryofcambodia.org

រទេះសេះខ្លះហើយ ។ តែរទេះសេះច្រើនតែមានប្រើនៅរដូវប្រាំង។ គេច្រើនប្រើរទេះសេះកង់ពីរ អូសដោយសេះមួយ ។ រទេះសេះពេលនោះ មានលក្ខណៈប្រហាក់ប្រហែលនឹងរទេះគោដែរ គឺគ្មានជន្ទាស គ្មានគ្រាប់ ឬបាដាងនៅក្នុងដុំទេ ។ គេឃើញមានរទេះសេះរត់ឈ្នួល ពីផ្សារស្វាយប៉ោទៅដល់កំពង់សីមា ឬពីស្វាយប៉ោទៅដល់ពាមឯក ។ រទេះរបៀបនេះមានឈ្មោះថា **រទេះកាត** ។ រទេះសេះសម័យនោះមានជញ្ជាំងខ្ពស់ អ្នកជិះអង្គុយលិចបាត់ខ្លួន ហើយបញ្ចេញតែក្បាល ។

លោកម្ចាស់មានរទេះសេះប្រហែលពីរ បីដែរ ជួនកាលទឹមសេះពីរជួនកាលទឹមសេះបួន ។ រទេះដែលទឹមដោយសេះបួន ជារទេះកិត្តិយសមានក្បាច់រចនា មានជន្ទោលវែងទៅមុខ ជាក្បាលនាគ ហើយមានចងទង់ជ័យ ។ រទេះនេះធ្វើសំរាប់តែទទួលភ្ញៀវកិត្តយស ។ អ្នកស្រុកហៅរទេះសេះនេះថា **រាជរថ** ។

លោកម្ចាស់ មិនសូវប្រើរទេះសេះ ក្នុងការធ្វើដំណើរទេ ។

- **គោតាង**

ច្រើនតែពួកលាវនិងពួកកូឡាទេដែលប្រើគោតាង ។ គោនីមួយៗត្រូវគេបំពាក់ជាល ឬត្រកម្សៀងនៅលើខ្នង សំរាប់ដាក់ទំនិញ ។ តាងនេះ គេធ្វើអំពីឫស្សីត្បាញ ។ គេប្រើគោតាងសំរាប់

www.budinst.gov.kh www.elibraryofcambodia.org

ដឹកអង្ករ ឬប្រេងកាត ពីបាត់ដំបងទៅប៉ៃលិន ។ ផ្លូវទៅប៉ៃលិន មានការលំបាកច្រើន ដោយត្រូវឡើងភ្នំចុះភ្នំ មិនអាចឲ្យបររទេះបានទេ ទើបគេប្រើគោតាងនេះ ។

នៅសម័យលោកម្ចាស់ មិនទាន់មានផ្លូវទៅប៉ៃលិន តាមភ្នំសំពៅទេ ។ គេធ្វើដំណើរទៅប៉ៃលិន ដោយចេញទៅតាមឈើទាលរហូតដល់ឥន្ទជិតទើបបត់ទៅស្ទឹង ហើយកាត់តាមត្រែង តំរង់ទៅប៉ៃលិន ។ នៅមង្គលបុរី មានសៀម លាវ មកពីភិម័យ សុរិន្ទ សង្កាក់ គោខណ្ឌមកដឹកត្រីសាច់យកទៅលក់ដោយប្រើគោតាងដែរ

## - ដំរី

ដំរីជាសត្វពាហណៈ ចេះអត់ធន់អាចផ្ទុកបានច្រើន ដើរបានលឿន និងធ្វើដំណើរបានឆ្ងាយ ។ គេត្រូវប្រើពេលពីរថ្ងៃ ដោយជិះដំរី ដើម្បីចេញពីបាត់ដំបងទៅដល់បាងកក ។

តាមធម្មតា គេជិះដំរីដោយមានដាក់រានមួយនៅលើខ្នងវា ដើម្បីឲ្យអ្នកដំណើរអង្គុយឬផ្ទុកឥវ៉ាន់ ។ រានដែលគេអង្គុយនេះ ហៅថា **ព្រែង** ។ តែបើមានដំបូលនិងក្បាច់រចនាល្អនោះ គេហៅថា **កូប ឬកូបខ្សង** ។ នៅលើព្រែងឬកូបនេះ គេអាចដាក់មនុស្សបានបី ឬបួននាក់ ។

បើគ្មានកូបឬព្រែងទេ គេជិះដំរីដោយក្រាលសំបកកណ្តោល

www.budinst.gov.kh www.elibraryofcambodia.org

ដែលគេដំឲ្យទក់ ក្រាលលើខ្នងវា ហើយចងខ្សែរផង្គន់ ។

- សេះ

សេះជាជំនិះលឿនទាន់ចិត្ត តែផ្ទុកមិនបានច្រើន ។ មន្ត្រីធំៗ ឬអ្នកមាននិយមប្រើសេះណាស់ ក្នុងការធ្វើដំណើរ ឬ ទៅបរបាញ់សត្វ ។ គេជិះសេះដោយដាក់អាន ដែលជាកែបធ្វើអំពីស្បែកនាំមកពីបរទេស ជាពិសេសនាំមកពីប្រទេសបារាំង ។

- ទោចក្រយាន

រហូតដល់ឆ្នាំ ១៩០៧ នេះហើយ ខេត្តបាត់ដំបងទាំងមូលមិនទាន់មានរថយន្តទេ ។ ឯទោចក្រយានវិញ ក៏មានស្ទួចស្ដើងណាស់។ គេរាប់ឃើញមានទោចក្រយានប្រហែលតែ ៤ គ្រឿងទេនៅសម័យលោកម្ចាស់ ។ ទោចក្រយានសម័យនោះ មានរាងខ្ពស់ៗ មានខ្នងកង់ឈើ មានកៅស៊ូតាន់មិនពិបាកសប់ទេ ហើយក៏មិនមានរលីបទៀត ។ កាលណាឡើងជិះហើយ យើងត្រូវធាក់ដោយឥតសំរាក បើមិនដូចនោះទេ មុខជាឈ្លាន់វាត់បាក់ជើងមិនខានឡើយ

លោកម្ចាស់ខ្លួនឯង ដែលជាស្ដេចត្រាញ់នោះ មិនទាន់មានទោចក្រយានជិះទេ ។ កូនចៅលោកម្ចាស់ក៏គ្មានដែរ ។ អ្នកដែលមានទោចក្រយានជិះមុនគេ គឺជាងឈើយ នៅភូមិកំពង់សំបួរ

www.budinst.gov.kh www.elibraryofcambodia.org



ទូកង (អ.ស.ឌ)



ទូកមួង (អ.ស.ឌ)



ទូកកិង (ម.ម)



www.budinst.gov.kh www.elibraryofcambodia.org

ឈ្មោះ យិបនៅផ្សារស្វាយប៉ោ កុងតូដែលជាជាងកំបោរនៅភូមិ ដូនទាវ ហើយនិងជនជាតិអាឡឺម៉ង់ម្នាក់ឈ្មោះ ស៊ីសង ជាកូនម្ចាស់ ហាងធំមួយឈ្មោះរូសិល ។

នៅពេលមកដល់ដំបូង ឬក៏នៅឆ្នាំ ១៩១២ នេះហើយ អ្នក ស្រុកបាត់ដំបង នៅតែផ្អើលឈូរឆរតាមមើលគេជិះទោចក្រយាន យ៉ាងភ្ញាក់ទឹកភ្ញាក់ដី ។

- **ទូក កញ្ចាល់**

នៅតាមព្រែក ស្ទឹង គេប្រើទូកជាយានជំនិះ ។ ពេលមាន ការប្រញាប់ គេប្រើ **ទូកង** ។ ពេលទៅណាម្តងៗ លោកម្ចាស់ចូល ចិត្តប្រើទូករបស់វត្តសំពៅឈ្មោះរថណាម ឬរបស់វត្តកណ្តឹងឈ្មោះ សព្រហ្មមាស ។ ទូកងជាទូកអុំ ឯទូកម៉ួងជាទូកចែវ ។ ក្នុងការ ដឹកនាំទំនិញតិចតួច គេប្រើ **ទូកកំរោល**ឬទូកដំបូល ដែលមានចែវ ពីរឬចែវបួន ។ គេដឹកស្រូវពីបាត់ដំបងទៅព្រៃនគរដោយ **ទូកថ្ងៃ** **ទូកប៉ុកចាយ** ឬ **ទូកកាណែវ** ។ ទូកថ្ងៃមានដំបូលជិតសល់ទំនេរ តែកន្លែងអ្នកចែវ ខាងមុខនិងខាងក្រោយ ។ ទូកប៉ុកចាយមាន លក្ខណៈប្រហាក់ប្រហែលនិងទូកថ្ងៃដែរ តែធំជាងហើយអាចផ្ទុក បានច្រើនជាង ។ ទូកថ្ងៃអាចផ្ទុកស្រូវបាន ៥០ថាំង ឯទូកប៉ុកចាយ អាចផ្ទុកបាន ១០០ឬ ២០០ថាំង ។ ឯ**ទូកកាណែវ** ជាទូកដឹកទំនិញ

www.budinst.gov.kh www.elibraryofcambodia.org

មានក្បាលស្រួច មានដំបូលគ្របតាំងពីក្បាលរហូតដល់កន្លែងដែលអ្នកចែវត្រូវឈរលើដំបូលតែម្តង ។

តាមដងស្ទឹងសង្កែ ពីបាត់ដំបងដល់បាក់ព្រា មានកប៉ាល់ដែលប្រើអុសជាថាមពល បើកបរចុះឡើងដឹកអ្នកដំណើរ ។ កប៉ាល់នេះច្រើនចេញចូលនៅរដូវទឹកឡើង ។ តាមពត៌មានមិនសូវច្បាស់ថាកប៉ាល់នេះជាកម្មសិទ្ធិរបស់លោកស្រីពិភក្តិនៅមុខកំផែង ។

នៅសម័យនោះ បាក់ព្រាជាកំពង់ផែយ៉ាងសំខាន់នៃខេត្តបាត់ដំបង ហើយមានសកម្មភាពខាងនាវាចរណ៍ជាងសព្វថ្ងៃនេះទៅទៀត ។ កប៉ាល់ធំៗ ដែលអាចផ្ទុកអ្នកដំណើរបានជាង ១០០នាក់ ព្រមនិងទំនិញសព្វសារពើផង ចូលមកដឹកអ្នកដំណើរពីបាក់ព្រាទៅភ្នំពេញ ស៊ឹងតែរាល់ថ្ងៃ ។ កប៉ាល់ដែលគេស្គាល់ជាងគេ មានឈ្មោះថា **ដំរី ណាំយ៉ាង មេគង្គ បាត់ដំបង** ។ល។

នៅសម័យនោះ កំពង់ផែបាក់ព្រាមានសារៈសំខាន់យ៉ាងសកម្មនៅពេលដែលខេត្តបាក់ដំបងមិនទាន់មានផ្លូវថ្នល់ និងផ្លូវរទេះភ្លើង ។

តាំងពីយូណាស់មកហើយ ធានាគារឥណ្ឌូចិន (Banque de l'Indochine) បានមកតាំងសាខារបស់ខ្លួននៅទីនោះ ដើម្បីកិច្ចប្រតិបត្តិការខាងហិរញ្ញវត្ថុ ។

www.budinst.gov.kh www.elibraryofcambodia.org

## ង- រូបិយវត្ថុ

នៅដំណាច់សតវត្សទី១៩នេះ រូបិយវត្ថុមាននាទីកាន់តែទូលំទូលាយឡើងហើយនៅបាត់ដំបង ។ គេចាយលុយដែលជាប្រាក់សុទ្ធ បោះនៅប្រទេសសៀម ឬចូលមកពីប្រទេសកម្ពុជា ។ ខេត្តបាត់ដំបងដែលជាដែនស្តេចត្រាញ់មួយនោះ ក៏មានបោះពុម្ពប្រាក់ចាយដោយខ្លួនឯងដែរ ។ ភ្នាក់ងារបោះប្រាក់របស់លោកម្ចាស់ គឺដំបូងលោក រត្នសារ តែក្រោយមកគឺ **ចឹក ជុយ** ។ អ្នកស្រុកបាត់ដំបងតែងចំអន់អ្នកណាដែលគ្មានប្រាក់ចាយថាឲ្យទៅយកពី ចឹក ជុយ ។ ពាក្យចំអន់នេះមានតៗរហូតមកដល់ពេលក្រោយទៀត ពីព្រោះ ចឹក ជុយ គាត់ជាអ្នកបោះប្រាក់ ។ ផ្ទះបោះប្រាក់នេះតាំងនៅត្រង់មុខវត្តដំរីសខាងមាត់ស្ទឹង ។ ជាងដែលបោះប្រាក់នៅផ្ទះចឹក ជុយនេះ ទទួលប្រាក់ ២បាត ឬ១៦ ប៉ែក្នុង ១ថ្ងៃ ។

ប្រាក់ដែលបោះនៅបាត់ដំបងពេលនោះ គឺប្រាក់ប៉ែ ។ ប្រាក់ប៉ែមានពីរយ៉ាងគឺ

- ប្រាក់កឹង ដែលមានពណ៌ស មានរូបចាបម្ខាង ហើយម្ខាងទៀតរលីង

www.budinst.gov.kh www.elibraryofcambodia.org

- ប្រាក់គ្រុឌ ដែលមានពណ៌សដែរ ម្ខាងមានរូបគ្រុឌឈរ មើលពីចំហៀង ហើយម្ខាងទៀត មានបោះពុម្ពអក្សរខ្មែរច្បាស់ៗ ថា **ព្រះតំបង** ។

ឯការបោះពុម្ពអក្សរខ្មែរថា **ព្រះតំបង** លើប្រាក់យ៉ាងនេះ ក៏មានន័យថា ខេត្តបាត់ដំបងពេលនោះ ទោះបីនៅក្រោមអំណាចត្រួតត្រារបស់សៀមក៏ដោយ ក៏ខេត្តបាត់ដំបងនៅជាខ្មែរ ហើយម្យ៉ាងទៀត ប្រាកដជាខ្មែរបាត់ដំបងពេលនោះមិននិយមសៀមប៉ុន្មានទេ ។ ឮថាសៀមមិនពេញចិត្ត ហើយមានបំណងហាមឃាត់មិនឲ្យចាយប្រាក់នេះមួយពេល តែក្រោយមក មានការសំរុះសំរួលគ្នាវិញ ។

ប្រាក់កឹង ជាប្រាក់ចាស់ បោះពុម្ពយូរមកហើយ តែមានតំលៃស្មើនឹងប្រាក់គ្រុឌគឺ**មួយប៉ៃ** ។ តទៅនេះ យើងត្រូវប្រៀបធៀបប្រាក់ដែលគេចាយនៅខេត្តបាត់ដំបងនៅសម័យនោះ ។

ប្រាក់ដែលចូលមកពីប្រទេសកម្ពុជា ក៏អាចចាយបាននៅបាត់ដំបងដែរ គឺជាប្រាក់សុទ្ធ ឬទង់ដែង ឬសំណប៉ាហាំងទៅតាមតំលៃដូចជា

១ណែន មាន១៦រៀល, ១រៀល មាន១០កាក់

ប្រាក់ដែលចូលមកពីខាងសៀម មានច្រើនយ៉ាង ជាប្រាក់សុទ្ធ

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំង ទី ១៥



ប្រាក់ប៉ែ (ម.ត)



ប្រាក់ប៉ែដែលបោះចាយនៅបាត់ដំបង
សម័យលោកម្ចាស់ (ត.ឈ)

www.budinst.gov.kh www.elibraryofcambodia.org

ឬទង់ដែងទៅតាមតំលៃ ដូចជា :

៥០បៀ ស្មើនឹង ១ ឡុត, ២ ឡុត ស្មើ ១ អាត់

២ អាត់ ស្មើនឹង ១ ផៃ, ២ ផៃ ស្មើ ១ ហ្វៀង

២ ហ្វៀង ស្មើនឹង ១ ស្លឹង ឬ ស្មើនិង ១ប៉ៃ ប្រាក់បាត់ដំបង

៤ ស្លឹងស្មើនឹង ១ បាត ឬ ១ដួង ឬ ស្មើងនឹង ៦ កាក់ប្រាក់ មកពីប្រទេសខ្មែរ

៤ បាត ស្មើនឹង ១ តំលឹង

២០ តំលឹង ស្មើនឹង ១ជញ្ជីង ។

ប្រាក់ទាំងនេះសុទ្ធតែជាលោហធាតុមានទំងន់ ។ ហេតុនេះហើយបានជាមានពាក្យថា **«អ្នកមានទលរំត»** គឺមានប្រាក់ច្រើនដាក់លើផ្ទះ ដួលកាលត្រូវទល់រតផ្ទះ កុំឲ្យបាក់ដោយសារទំងន់ប្រាក់

ដើម្បីងាយយល់តំលៃប្រាក់នៅសម័យនោះ យើងត្រូវពិចារណាតំលៃទំនិញខ្លះ ដូចជា

- ១រៀល អាចទិញបាន ខៀន ១ ឬបានដែកឈូស ១ ឬបាន កន្ត្រៃកាត់ស្លា ១
- ១ តំលឹង អាចទិញបានមាន់ ១ ឬបានត្រីរស់ធំ១
- ១ កាក់ អាចទិញបានសាច់ជ្រូក ១ នាឡិ
- ឈើគូស ២ ប្រអប់ ថ្លៃ ៣ ស្លឹង

www.budinst.gov.kh www.elibraryofcambodia.org

- នំបញ្ចុក ២ ចង្វាយថ្លៃ ១ ស្លឹង
- បបរ ១ចានធំ ថ្លៃ ៤ ស្លឹង
- ស្រូវ ១០ ថាំង ថ្លៃពី ៣ ទៅ ៥រៀល
- ព្រះវិហារវត្តកណ្ដឹងស្លាបនារស់ប្រាក់ ១០០ណែន ។

## របៀបធ្វើប្រាក់ប៉ែ

ឯកសារបានផ្ដល់បន្ថែមមកថា ចិកដុយមានបច្ចេកទេសម្យ៉ាង សំរាប់ធ្វើប្រាក់ប៉ែ ។ គាត់យកសំណប៉ាហាំង តាមទំងន់ត្រូវការ លាយបរិមាណប្រាក់ខ្លះ ដាក់ក្នុងឆ្នាំងដីម្យ៉ាង ហៅថា បាវ រួចដាំលើភ្លើងឲ្យរលាយចូលគ្នា ។

គាត់រៀបផើងមួយ ដាក់ទឹកពាក់កណ្ដាល ហើយមានបណ្ដែតដើមចេកមួយកំណាត់ក្នុងនោះ ។ គាត់ចាក់ទឹកសំណប៉ាហាំង ដែលក្ដៅរលាយ ទៅលើដើមចេក ។ សំណក៏ខ្ចាតជាកំទេចល្អិត ទៅក្នុងទឹក ។ គាត់ស្រង់កំទេចសំណប៉ាហាំងនោះ សំដិលឲ្យស្ងួត ។

គាត់យកពុម្ពដី ប៉ុនដុំអិដ្ឋ មានរន្ធតូចៗប៉ុនកូនដៃជាច្រើន រួចគាត់ថ្លឹងកំទេចសំណប៉ាហាំងនោះ ចាក់ចូលទៅក្នុងរន្ធនៃពុម្ព ។ រួចស្រេចហើយគាត់យកពុម្ពនេះទៅដុតម្ដងទៀត ។ គាត់ដកយកពុម្ពមកដាក់ឲ្យត្រជាក់ ដកយកសំណប៉ាហាំងដែលកកជាដុំ មានទំងន់ស្មើៗគ្នា យកទៅច្របាច់ដោយពុម្ពម្យ៉ាង ឲ្យកើតរាងជា

www.budinst.gov.kh www.elibraryofcambodia.org

ប្រាក់កាក់ មានរូបគ្រុឌម្ខាង និងមានអក្សរខ្មែរ ថាព្រះតំបងម្ខាង ។

ពេលបោះពុម្ពរួច ចិកជុយតែងយកប្រាក់ប៉ែទៅហាលនៅលើកន្ទេល មុខផ្ទះគាត់ដូចគេហាលស្រូវ ។

## ច- ពាណិជ្ជកម្ម

ទោះបីមានការប្រើរូបិយវត្ថុច្រើនក៏ដោយ ក៏ប្រជាកសិករដែលរស់នៅតាមជនបទនិយមតែដូរផលិតផលរបស់ខ្លួន និងផលិតផលប្រើប្រាស់ដែលខ្លួនត្រូវការ ។ ពួកឈ្មួញ ដោយឃើញការលំបាកសព្វបែបសព្វយ៉ាង ក៏ឆ្លៀតកេងប្រវញ្ច័យកចំណេញយ៉ាងកប់ក្តោង ។ នៅពេលចម្រូត គេសង្កេតឃើញមានឈ្មួញជាច្រើនដើរពីកន្លែងមួយទៅកន្លែងមួយ ដោយមានទាសករវែកកញ្ជេរធំៗដែលដាក់ សំពត់អាវ ផ្តិល ចានក្បាន និងគ្រឿងប្រើប្រាស់ផ្សេងៗយកទៅដូរស្រូវ ដែលច្រូតហើយឬដែលកំពុងច្រូត ។

អ្នកខ្លះឆ្ងល់ថា ហេតុអ្វីបានជាកសិករនិយមតែដូរដូចនេះ ។ ម្តេចក៏មិនទិញតែម្តង វាបានចំណេញជាង ។ យើងត្រូវដឹងថាស្ថានភាពភូមិសាស្ត្រតម្រូវយ៉ាងនេះ ព្រោះនៅពេលចម្រូត ទឹកទន្លេសាបត្រូវស្រកដែលនាំឲ្យមានការលំបាកខាងគមនាគមន៍ ដែលជាហេតុនាំឲ្យទំនិញឡើងថ្លៃមួយរយៈពេល ។ កសិករដែលខ្វះមុខខ្វះក្រោយមិនអាចផ្គត់ផ្គង់ខ្លួនឯងបានដោយងាយទេ ។ ហេតុនេះ

www.budinst.gov.kh www.elibraryofcambodia.org

ហើយ បានជាចាំបាច់ត្រូវតែដូរស្រូវដែលខ្លួនច្រូតកាត់ហើយថ្មីៗ នោះទៅឲ្យពាណិជ្ជករ ។ ពាណិជ្ជករ គេស្តុកស្រូវនោះទុក ព្រោះគេមានលទ្ធភាពខាងហិរញ្ញវត្ថុច្រើនជាង ។ រហូតដល់រដូវវស្សា ដែលជារដូវងាយស្រួលខាងនាវាចរណ៍ក្នុងបឹងទន្លេសាប ទើបគេបញ្ចេញស្រូវនោះយកទៅលក់ឯព្រៃនគរ ។ សូមបញ្ជាក់ទៀតថា គេដឹកនាំស្រូវពីបាត់ដំបងទៅលក់ឯព្រៃនគរ ដែលសម័យនោះជាផ្សារស្រូវអង្ករសំខាន់នៅអាស៊ីអាគ្នេយ៍ ។ គេមិនដែលនាំស្រូវទៅលក់ឯបាងកកទេ ព្រោះដឹកស្រូវតាមផ្លូវគោកត្រូវចាយប្រាក់កាសនិងពេលវេលាច្រើនណាស់ ។ គេដឹកស្រូវទៅលក់ ឯព្រៃនគរ ដោយទូកថ្ងៃឬទូកប៉ុកចាយធំៗ ។

គេដឹកទំនិញពីបាត់ដំបងទៅលក់ឯបាងកកដែរ គឺ ត្រីឆ្អើរ ប្រហុក ផ្អក ។ល។ គេដឹកត្រីឆ្អើរ ប្រហុក ផ្អក ទៅបាងកក ដោយក្បួនរទេះ មានប្រហែល១០រទេះ ក្នុងមួយជើងៗ ។

ចំពោះទំនិញនាំចូលវិញ គេទិញចានក្បាន កែវ សំពត់អាវ គ្រឿងសំអាង ស្បែកជើង ប្រេងកាត ។ បើគេចង់បានផលិតផលអង់គ្លេស ឬអាឡឺម៉ង់ គេត្រូវទិញពីប្រទេសសៀម ។ តែបើគេចង់បានផលិតផលបារាំងគេត្រូវទិញពីខាងភ្នំពេញ ។ ពួកអភិជននៅបាត់ដំបងនិយមស្រានិងគ្រឿងសំអាងមកពីប្រទេសបារាំង តែវាស្ត្រ

www.budinst.gov.kh www.elibraryofcambodia.org

ប្រជានិយមគ្រឿងដែក និងអាវុធមកពីអាឡឺម៉ង់ ឬអង់គ្លេស ។

ដោយហេតុថា ខេត្តបាត់ដំបងនៅពេលនោះ ជាខេត្តចំណុះសៀម ពាណិជ្ជកម្មជាមួយប្រទេសសៀមប្រព្រឹត្តទៅដោយសេរី តែមានការរឹតត្បិតបន្តិចជាមួយប្រទេសខ្មែរយើង ។ ទំនិញចេញចូលប្រទេសសៀមឥតមានបង់ពន្ធដារអ្វីទេ ។ តែទំនិញចេញចូលជាមួយប្រទេសកម្ពុជាត្រូវមានបង់ពន្ធគយជាដាច់ខាត ។ ចៅតំបន់បាក់ព្រាមានភារៈហូតពន្ធលើទំនិញចេញឬនាំចូល ដោយយកពន្ធជាលុយជាកាក់ ជួនកាលគេយកជារបស់ ។ ភ្នាក់ងារគយមានអំណាចសំរេចប្រាក់ពន្ធបានតាមទំនើងចិត្ត ។ នៅសម័យនោះ ក៏មានអំពើពុករលួយមិនអន់ប៉ុន្មានដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

## ទីតាំងពុំសិល្បៈ

ចាស់ៗតែងអួតសរសើរនិងរំលឹកការសប្បាយ នៅសម័យលោកម្ចាស់ ។ តាមពិត នៅសម័យនោះប្រហែលជាសប្បាយមែន។ តែការសប្បាយនៅពេលនោះ មិនមែនសប្បាយដោសារការប្រកបវិជ្ជាជីវៈបានលូតលាស់ចំរើនទេ គឺសប្បាយខាងធ្វើបុណ្យទាន ខាងដើរលេងកំសាន្តមើលល្ខោនរបាំ រាំច្រៀង ។

ក្រោយពីការច្រូតកាត់ភ្ជួរ គេឈប់ខ្វល់ខ្វាយក្នុងការងារទៀតហើយគេនាំគ្នាដើរលេងពីភូមិមួយទៅភូមិមួយ សាកសួរញាតិមិត្ត ឬណាត់គ្នាធ្វើបុណ្យទាន ឬលេងល្បែងប្រជាប្រិយ៍ផ្សេងៗ ។ រដូវរំហើយ គឺជារដូវសប្បាយ ជារដូវចូលឆ្នាំតែម្តង ។

ការសប្បាយហួសហេតុបៀបនេះមានបុព្វហេតុច្រើនយ៉ាង ។ ការសប្បាយនឹងធ្វើបុណ្យទានបណ្តាលមកពីមានជំនឿមុតមាំ ខាងសាសនានេះម្យ៉ាង តែការសប្បាយដែលនាំឲ្យមានរបាំរាំច្រៀង និងល្បែងប្រជាប្រិយ៍ផ្សេងៗ បណ្តាលមកពីសភាពអាប់អួរ អស់សង្ឃឹមក្នុងការរស់នៅ ដោយសារការជិះជាន់សង្កត់សង្កិននៃវណ្ណៈសក្តិភូមិ និងវណ្ណៈគហបតីនេះម្យ៉ាង តែម្យ៉ាងទៀត ដោយ

www.budinst.gov.kh www.elibraryofcambodia.org

សារនៅពេលនោះ ខ្វះមធ្យោបាយកំសាន្តទាន់សម័យ ដូចជាភាព-យន្ត វិទ្យុ ទូរទស្សន៍ ថាសចំរៀង ។ល។

នៅសម័យលោកម្ចាស់ សិល្បៈមានការលូតលាស់ណាស់ ។ ចាស់ៗសរសើរល្ខោនលោកម្ចាស់មិនដាច់ពីមាត់ ។ របាំនិងល្បែងប្រជាប្រិយ៍ ក៏ មានច្រើនបែបយ៉ាងសំរាប់បំពេញចំណង់ចំណូលចិត្តប្រជារាស្ត្រគ្រប់មជ្ឈដ្ឋាន ។ ចំណែកឯពិធីបុណ្យវិញ មានបុណ្យខាងសាសនា បុណ្យផ្លូវការរបស់លោកម្ចាស់និងពិធីបុណ្យរបស់ប្រជារាស្ត្រសាមញ្ញនៅតាមជនបទ ។

ចំពោះបុណ្យខាងពុទ្ធសាសនា ដែលមានជាទំនៀមទំលាប់រហូតដល់សព្វថ្ងៃនោះ យើងមិនបាច់លើកយកមកធ្វើអត្ថាធិប្បាយនៅពេលនេះទៀតទេ ។ យើងយកតែបុណ្យខ្លះៗដែលមានលក្ខណៈប្លែកពីសព្វថ្ងៃ ។

## ក- ពិធីបុណ្យ

### *១- បុណ្យចូលឆ្នាំ*

គេប្រារព្ធពិធីបុណ្យចូលឆ្នាំនៅខែចែត្រ គឺនៅពេលដែលប្រជាកសិករទំនេរ ផុតពីការងារស្រែចំការ គឺជាពិធីបុណ្យប្រជាប្រិយ៍ដ៏អ៊ឹកអធឹកជាងគេ ហើយដែលមានរយៈពេលច្រើនថ្ងៃ ។ នៅវត្តអារាម មានពិធីចំរើនពុទ្ធមន្តជ័យមង្គល ពិធីពូនភ្នំខ្សាច់ និង

www.budinst.gov.kh www.elibraryofcambodia.org

ពិធីស្រង់ព្រះ ។ គេនាំគ្នាយកទឹកទៅជុះលាងព្រះពុទ្ធរូប រួចហើយលាបគ្រឿងក្រអូបផ្សេងៗ ។ អ្នកមានសទ្ធាច្រើន នាំគ្នាវែកទឹកដាក់ពាងក្នុងវត្តប្រគេនព្រះសង្ឃ ដើម្បីជាកុសលរបស់គេទៅអនាគតជាតិ ។

រាល់ពេលចូលឆ្នាំម្តងៗ គេនាំគ្នាទៅលេងកំសាន្តនៅឯវត្តសំរោងក្នុង ព្រោះនៅទីនោះមានប្រាសាទបុរាណ មានទីធ្លាធំទូលាយមានដើមឈើម្លប់ទ្រឈឹងទ្រឈៃ ។ អ្នកស្រុកនាំគ្នាលេងកំសាន្តច្រើនកកកុញជាងសព្វថ្ងៃទៅទៀត ។ ក្រៅពីវត្តសំរោងក្នុង គេទៅលេងកំសាន្តនៅវត្តឯកភ្នំខ្លះដែរ តែមិនច្រើនគ្នាទេ ។ សម័យនោះគេមិនដែលទៅលេងភ្នំសំពៅទាល់តែសោះ ហើយពេលនោះក៏គ្មានផ្លូវទៅទៀតផង ។

នៅវត្តសំរោង មានលេងល្បែងប្រជាប្រិយ៍ផ្សេងៗ ដូចជាលេងអង្គុញ ចោលឈូង ទាញព្រ័ត្រ ទាត់សីដក់ ។ ល្បែងសីដក់ជាកីឡានិងជាសិល្បៈដ៏ល្បី មានក្បាច់និងស្នៀតគួរឲ្យស្ញប់ស្ញែង ។ ក្រៅពីល្បែងទាំងនេះ មានល្បែងប្របកៃ ។ ស្រីប្រុសជាក្រុមៗនាំគ្នាច្រៀងឆ្លងឆ្លើយដោយឥតមានប្រកែកប្រកាន់អ្វីឡើយ ។

នៅតាមផ្លូវ គេនិយមធ្វើបុណ្យដាក់ទានដល់អ្នកដំណើរទៅមកនៅពេលចូលឆ្នាំ ។ គេធ្វើនំបញ្ចុក ឬបបរចែកឲ្យអ្នកដើរ ទៅ

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំង ទី ១៦

វត្តសំរោងក្នុង : ទីប្រជុំពេលចូលឆ្នាំ នៅសម័យលោកម្ចាស់





មកបរិភោគដោយឥតចេញសោហ៊ុយអ្វីឡើយ ។ ចំណីមួយមុខទៀត ដែលគេនិយមធ្វើដើម្បីដាក់ទាននោះ គឺគ្រាប់ជី ។ គេត្រាំគ្រាប់ជីទាំងពាងៗ ដាក់តាមផ្លូវឲ្យអ្នកដើរកំសាន្តបរិភោគតាមត្រូវការ ។ អ្នកដើរត្រូវតែទទួលទានរបស់គេជាដាច់ខាត ទោះ តិចក្តីច្រើនក្តី ។ អ្នកដើរលេងកំសាន្តមិនសូវពិបាកត្រឡប់ទៅទីលំនៅដើម្បីបរិភោគបាយទេ ។

គឺនៅពេលចូលឆ្នាំនេះហើយ ដែលគេដោះលែងទាសករដែលជាខ្ញុំកញ្ជះគេ ឲ្យបានទទួលការសប្បាយ ដោយចែកលុយឲ្យបន្តិចបន្តួចសំរាប់ចាយវាយ ។

## ២- *បុណ្យចេញវស្សា*

ថ្ងៃ ១៤ កើតខែអស្សុជ ជាថ្ងៃចេញវស្សា ។ មានពិធីតាមរបៀបពុទ្ធសាសនា នៅវត្តអារាម ។ តែនៅវេលាយប់ថ្ងៃពេញបូណ៌មីនេះ អ្នកស្រុកតាមដងស្ទឹងសង្កែ តែងប្រារព្ធធ្វើពិធីមួយដែលជាប្រពៃណី ។ គេនាំគ្នាធ្វើប្រទីបបណ្តែតភ្លឺព្រោងព្រាតនៅតាមដងស្ទឹង ។ ប្រទីបនេះ គឺជាទៀនធូបដែលគេដោតជាក្បាច់ក្បូរលើដើមចេកដែលភ្ជាប់គ្នា ។ ប្រទីបមានពីរយ៉ាង គឺប្រទីបធំដែលមានក្បាច់រចនាជារូបរាងផ្សេងៗ ហើយនិងប្រទីបរាយ ដែលជាស្រទបចេកខ្ចីមានដោតទៀនតែមួយ ។ នៅពេលនោះ គ្រប់គ្រួសារនិង

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំង ទី ១៧



វត្តឯកភ្នំ (ន.៣)

www.budinst.gov.kh www.elibraryofcambodia.org

វត្តអារាមនៅតាមដងស្ទឹង តែងធ្វើប្រទីបតូច ឬធំមួយមិនដែលខាន ទេ ។ ពិធីលយប្រទីបនេះ មានគោលបំណងខមាទោសព្រះគង្គា ដោយគេបានជ្រុលជ្រួសប្រព្រឹត្តអំពើមិនគប្បីផ្សេងៗ មានជុះនោម ដាក់ទឹកជាដើម ។

ព្រឹកស្អែកឡើង គឺថ្ងៃ ១រោច គេនាំគ្នាចុះទូកទៅកំសាន្ត នៅ តំបន់ប្រាសាទវត្តឯកភ្នំ ដែលកាលដើមមានធ្លាទឹកយ៉ាងធំទូលាយ ដែលសព្វថ្ងៃរលុបបាត់អស់ទៅហើយ ។ ធ្លាទឹកនេះ គេហៅថា រហាល ។ គេណាត់គ្នាប្រណាំងទូកយ៉ាងគឹកកងនៅត្រង់រហាល នេះ ។ ការប្រណាំងទូកនេះធ្វើដោយស្ម័គ្រចិត្តរៀងៗខ្លួន ពុំមែនជា ការរៀបចំជាផ្លូវការទេ ។ ការប្រណាំងនេះទៀតក៏ឥតមានចែក រង្វាន់ ឬ ភ្នាល់ដាក់លុយកាក់អ្វីដែរ ។ ទូកណាដែលមិនរួម ប្រណាំងនិងគេ ក៏នាំគ្នាចែវអុំទៅកំសាន្តនៅតំបន់លិចទឹកនៅជិត ខាង បេះផ្កាស្មោ ឬដកព្រលិតយ៉ាងសប្បាយ ។ ដំណើរកំសាន្តតាម ទូក នៅពេលចេញវស្សានេះ ប្រព្រឹត្តទៅពីរបីថ្ងៃជាប់ៗគ្នា ។

ចាប់ពីថ្ងៃចេញវស្សានេះទៅ រហូតដល់ថ្ងៃពេញបូណ៌មី ខែ កត្តិក គេនាំគ្នាបង្ហូតគោមនៅគ្រប់ផ្ទះ នៅពេលយប់ ។ គេធ្វើ គោមក្រដាស ឬក៏យកចង្កៀងអំពូងចងបង្ហូតនៅចុងបង្គោលឫស្សី យ៉ាងខ្ពស់ ។ គឺនៅក្នុងរយៈពេលមួយខែដែលគេបង្ហូតគោមនេះ

www.budinst.gov.kh www.elibraryofcambodia.org

ហើយ ដែលគេប្រារព្ធធ្វើបុណ្យកឋិនទាន ។

## ២- ពិធីមង្គលការ

ខ្មែរអ្នកបាត់ដំបង សម័យនោះ ប្រកាន់ទំនៀមទំលាប់ ក្នុងពិធីស្ដីដណ្ដឹងរៀបការកូនប្រុសស្រី ប្លែកពីអ្នកនៅភូមិភាគខាងកើត ។

នៅពេលណា អ្នកផ្លូវចៅមហាចូលស្ដីដណ្ដឹងគូស្រករ ឲ្យកូនប្រុសបានហើយនោះ កូនប្រុសត្រូវតែទៅនៅបំរើគ្រួសារខាងស្រីអស់ពេលយ៉ាងហោចណាស់ក៏មួយរដូវធ្វើស្រែដែរ ដើម្បីឲ្យគេពិនិត្យ ពីការងារ និង គំនិតមារយាទ របស់ខ្លួន ។ បន្ថែមលើខាន់ស្លា តាមកិច្ចព្រមព្រៀង គ្រួសារខាងប្រុសត្រូវសង់ផ្ទះមួយខ្នងសំរាប់គ្រួសារថ្មីរស់នៅ ក្រោយរៀបការ ។

នៅពេលទៅបំរើគ្រួសារខាងស្រី សាម៉ីខ្លួនខាងប្រុសត្រូវប្រកាន់ឥរិយាបថស្លូតបូត ស្ដាប់បង្គាប់ គួរសមសុភាពរាបសារ និងឧស្សាហ៍ធ្វើការ ។ ភាគច្រើនត្រូវគ្រួសារខាងស្រីធ្វើបាប ឬប្រើត្រឡប់ត្រឡិនប្រៀបបាននិងខ្ញុំកញ្ជះគេ ។ មានលក្ខខណ្ឌ ជាច្រើនដែលមិនសូវសមហេតុផល អនុញ្ញាតិឲ្យគ្រួសារខាងស្រី ផ្ដាច់កិច្ចព្រមព្រៀងឲ្យខកខានបានរៀបការយ៉ាងងាយ ។

ចំណែកឯពិធីមង្គលការពិតប្រាកដដែលគេហៅថា "រៀបការតាមរបៀបសៀម "ច្រើនតែប្រារព្ធទៅដោយសង្ខេបត្រឹមតែមួយ

www.budinst.gov.kh www.elibraryofcambodia.org

រសៀល ជាទូទៅ គឺ

ម៉ោង ២ រសៀល ព្រះសង្ឃចំរើនពុទ្ធមន្តសិរីមង្គល

ម៉ោង ៣ ចូលដល់ពិធីរៀបសំពះផ្ទឹម សែនព្រែនកាត់ខាន់ស្លា

ម៉ោង ៤ ពិធីជប់លៀងភ្ញៀវ ជាកិច្ចបង្ហើយដោយសង្ខេប ។

## *៣- បុណ្យផ្លូវការ*

បុណ្យផ្លូវការមានពីរយ៉ាងគឺ **បុណ្យស៊ីយិត ឬសៃយិត ហើយនិង បុណ្យ ឆ្នឹម ឬឆះឡឹម** ។ នៅពេលចូលឆ្នាំ នាម៉ឺនមុខមន្ត្រីទាំងអស់នៅក្នុងខេត្តត្រូវទៅធ្វើពិធីសច្ចាប្រណិធាន ផឹកទឹកសំបថនៅវត្តសង្កែ ។ គេហៅពិធីបុណ្យនេះថា បុណ្យសៃយិត ឬបុណ្យផឹកទឹក ។ គេយកដាវលំពែង កាំភ្លើង ក្ងរទឹកឲ្យនាម៉ឺនមុខមន្ត្រីគ្រប់រូបផឹក ដោយសច្ចាថាស្មោះត្រង់នឹងលោកម្ចាស់ និងស្មោះត្រង់ចំពោះព្រះចៅសៀម ។

ក្នុងពិធីនេះ នាម៉ឺនគ្រប់រូប ទាំងតូចទាំងធំ ទាំងលោកម្ចាស់សុទ្ធតែស្លៀកពាក់ឯកសណ្ឋានពេញយស ពាក់សក្តិ ពាក់មេដាយ ហើយមានស្ពាយដាវនៅចង្កេះ ។ សិស្សានុសិស្សក៏ត្រូវចូលរួមក្នុងពិធីនេះដោយមានឯកសណ្ឋានស្បែកជើងស្រោមជើងដែរ ។

នៅពេលបញ្ចប់ពិធីបុណ្យសៃយិតនេះ គេបាញ់កាំភ្លើងធំច្រើនណាត់ជាកិត្តិយស ។

www.budinst.gov.kh www.elibraryofcambodia.org

ឯបុណ្យឆ្លីម ឬឆៈឡឹមជាបុណ្យខួបថ្ងៃកំណើតព្រះចៅសៀម ។ គេប្រារព្ធពិធីបុណ្យឆ្លីម ដោយនិមន្តព្រះសង្ឃមកចំរើនពុទ្ធមន្ត នៅវិមានលោកម្ចាស់ ដែលគេហៅថា តឹកពងក្រពើ ។ បន្ទាប់មក មានប្រគុំផ្សព្វផ្សាយតន្ត្រី និងសំដែងល្ខោនរបាំនៅក្នុងកំផែងជូនសាធារណជនទស្សនា ដោយសេរី ។

នៅក្នុងកំផែង នាម៉ឺនធំៗសុទ្ធតែរៀបចំរោងតាំងគ្រឿងក្បាច់រចនានិងវត្ថុត្រកាលផ្សេងៗ ដូចជាពិធីតាំងតុក្នុងរាជវាំងភ្នំពេញដែរ។

## ៤- បុណ្យក្នុងគ្រួសារលោកម្ចាស់និងអភិជន

បុណ្យក្នុងគ្រួសារអ្នកធំ ដែលចាំបាច់ជាងគេ គឺបុណ្យកោរសក់ និងបុណ្យបំបួសនាគ ។

នៅសម័យមុន កូនក្មេងតែងតែកោរសក់ទុកជុក ។ គេកោរសក់ជុំវិញហើយទុកជុកកណ្តាលក្បាល ។ គេបួងសក់នេះដោយមានដាក់ស្នៀតសក់ ។ អ្នកធំ ឬអ្នកមានប្រើស្នៀតសក់អំពីមាស ហើយជួនកាលមានដាំពេជ្រ ។ កាលណាក្មេងអាយុបាន ១២ ឬ ១៣ឆ្នាំ គេត្រូវកោរជុកនេះចោល ។ ការកោរសក់នេះ ជាពិធីមួយមានសារៈសំខាន់ប្រហាក់ប្រហែលនិងពិធីមង្គលការដែរ ។

នៅក្នុងកំផែង ពិធីកោរសក់នេះមានភាពអ៊ឹកអធឹកដូចបុណ្យ

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំង ទី ១៨



# ពិធីកោរសក់



(ម.ម)

www.budinst.gov.kh www.elibraryofcambodia.org

ផ្លូវការមួយដែរ ។ គេកេណ្ឌរាស្ត្រប្រជាឲ្យផ្តល់ឈើ ឬ ស្បូវ មក ធ្វើរោងបុណ្យ ។ គេនិមន្តព្រះសង្ឃមកចំរើនព្រះបរិត្ត និង ប្រគេន ចង្ហាន់ព្រះសង្ឃ ។ តែរឿងដែលចំឡែកនោះ គឺគេធ្វើបុស្សបុក យ៉ាងខ្ពស់ និមន្តព្រះគ្រូសម្តេចចៅទៅស្រោចទឹក រួចទើបមាន បុរោហិតកោរសក់ឲ្យកូននោះ ។ ពេលជាមួយនេះ គេប្រគុំភ្លេងយ៉ាងគឹកកង ហើយមានសំដែងរឿងរាមកេរ្តិ៍បីយប់បីថ្ងៃ ។

ពិធីបំបួសនាគ មានលក្ខណៈប្រហាក់ប្រហែលសព្វថ្ងៃដែរ ។ តែលោកយាយអ៊ុំ នៅភូមិវត្តកណ្តឹង បានរំលឹកទស្សនីយភាពមួយដ៏ចាប់ចិត្ត គឺពិធីដង្ហែនាគកូនលោកម្ចាស់ ។ គេរៀបចំក្បួនដង្ហែជាពីរក្រុមដាច់ពីគ្នា ។ ក្រុមនីមួយៗសុទ្ធតែមានវង់ភ្លេងរបស់ខ្លួន ។ ក្រុមទីមួយដែលមានដង្ហែនាគនោះ មានតួល្ខោនប្រហែលហាសិបនាក់ តែងជាពលព្រះរាម ជិះសេះទេស ។ ក្រុមទី២ មានតួល្ខោនប្រមាណហាសិបនាក់ដែរតែងតួជាពលរាពណ៍ ។ ក្រុមទីមួយ ជាក្រុមធំចេញដំណើរពីក្នុងកំផែងទៅត្បូងតាមដងស្ទឹង ដល់ក្បែរវត្តសំពៅឆ្លងទឹកទៅត្រើយម្ខាង ហើយបត់ទៅជើងសំដៅទៅវត្តសង្កែ។ ក្រុមទីមួយនេះមានអ្នកនាគ ញាតិមិត្តអ្នកនាគ នាម៉ឺនមុខមន្ត្រី និងវង់ភ្លេងច្រើនវង់ ។ ក្រុមទីពីរមានដូរ្យតន្ត្រីកំដរដែរ តែមានគ្នាតិច គឺមានតែពលរាពណ៍ជិះក្របីស្នែងនប់ ។ ក្រុមទីពីរចេញដំណើរ

www.budinst.gov.kh www.elibraryofcambodia.org

ពីកំផែងទៅជើងដល់ត្រង់មុខវត្តកណ្ដាល ក៏ឆ្លងស្ពឹងទៅត្រើយខាងកើត ហើយដើរសំដៅទៅវត្តសង្កែដែរ ។ នៅពេលដែលក្បួនទាំងពីរក្រុមជួបគ្នានៅមុខវត្តសង្កែ ពលព្រះរាមចុះពីសេះទេស ពលរាពណ៍ក៏ចុះពីក្របីស្នែងនប់ ហើយក៏ច្បាំងគ្នាយ៉ាងកោលាហលក្រោមសំលេងដូរ្យដន្ត្រីដ៏កងរំពង ។ ឆាកប្រយុទ្ធនេះរំលឹកកាលដែលព្រះសាមណគោតមចេញទៅសាងផ្នួស ហើយត្រូវជំនះទ័ពមារាដែលតាមជ្រែក ។ ក្រោយពីច្បាំងឈ្នះពលរាពណ៍ហើយ ពលព្រះរាមក៏តាមដង្ហែនាគចូលទៅក្នុងវត្ត ប្រទក្សិណហើយចូលទៅក្នុងព្រះវិហារ ។

### ៤- *ពិធីបុណ្យខ្មោច*

អ្នកស្រុកបាត់ដំបង ជំនាន់នោះ មានទំលាប់ម្យ៉ាងក្នុងការធ្វើបុណ្យខ្មោច ។ បើមានមនុស្សស្លាប់ គេធ្វើបុណ្យតែបន្តិចបន្តួច ក៏យកខ្មោចនោះទៅកប់មួយអន្លើសិន ។ គេមិនធ្វើបុណ្យធំដុំទេ ព្រោះគេយល់ថាគ្រួសារកំពុងមានទុក្ខហើយមានលុយកាក់តិចតួច។ ចាប់ពីពេលនោះមក គ្រួសារសពត្រូវខិតខំរកលុយកាក់បំរុងធ្វើបុណ្យខ្មោចនោះ នៅពេលណាមួយឲ្យបានអធិកអធម ។ ក៏ប៉ុន្តែតាមធម្មតាមានតែពួកអភិជនទេ ដែលអាចធ្វើបុណ្យខ្មោចគ្រួសារគេបានអធិកអធមសប្បាយ ។ អ្នកក្រធ្វើបុណ្យខ្មោចយ៉ាងស្ដួច

www.budinst.gov.kh www.elibraryofcambodia.org

ស្តើងដោយវិធីសង្ខេប ក៏យកទៅកប់ឬដុតទៅ ។ អ្នកមានធន ធានតិចតួចច្រើនរួមគ្នាជាសមាគម ធ្វើបុណ្យខ្មោចគ្រួសារខ្លួន ។

អ្នកក្រុងបាត់ដំបងនិយមយកកន្លែងមួយ នៅខាងអាគ្នេយ៍ កំផែងត្រង់មាត់ស្ទឹងក្បែររោងអារឈើ ហូ គុង ហាន់ សព្វថ្ងៃដើម្បី ធ្វើបុណ្យខ្មោច ។ គេនិយមគាស់ខ្មោចដែលកប់យកមកធ្វើបុណ្យ នៅរវាងខែផល្គុណ ចេត្រនិងពិសាខ ដែលជាពេលដែលអ្នកផង ទំនេរផុតពីការស្រែចំការ ហើយជារដូវល្អគ្មានភ្លៀង ។ បើកាល ណា គេធ្វើបុណ្យខ្មោចដែលគាស់ពីដីមកយ៉ាងនេះ គេនិយមឲ្យមាន ល្បែងប្រជាប្រិយ៍ល្ខោនរបាំ ដូរ្យតន្ត្រី អុជកាំជ្រួចភ្ញីទៀន ហើយ ច្រើនមានប្រកួតកីឡាប្រដាល់ទៀតផង ។ តែបើគេធ្វើបុណ្យខ្មោច ដែលទើបនឹងស្លាប់ភ្លាម ៗ ដែលគេហៅ "ខ្មោចស្រស់ "នោះគេត្រូវ សំរួមចិត្តសំរួមអាត្មាជាការកាន់ទុក្ខ មិនដែលឲ្យមានការសប្បាយ ល្បែងរបាំរាំច្រៀងទេ ។ គេដំកល់សពច្រើនយប់ច្រើនថ្ងៃ នៅក្នុង រោងបុណ្យ រួចទើបគេដង្ហែសពកាត់តាមទីក្រុងហើយយកទៅ ដំកល់ក្នុង "ភ្នំយោង "ដើម្បីបូជា ។ មានជួនកាល គេដង្ហែខ្មោច ចេញពីរោងបុណ្យនៅពេលយប់ទៅដំកល់នៅវត្តណាមួយ រួចទើប ហែមកកាន់កន្លែងបុណ្យវិញនៅថ្ងៃបន្ទាប់ ។ ការដង្ហែពេលយប់ នេះ អ្នកហែត្រូវកាន់ចន្លុះ ឬគោម ។ គេហៅរបៀបហែនេះថា

www.budinst.gov.kh www.elibraryofcambodia.org

«លួចសព» ។

គេច្រើនសាងមេរុខ្ពស់ស្កឹមស្កៃ សំរាប់បូជាសពលោកចៅអធិការវត្ត ឬសម្តេចចៅ បូជាពិសេស សពលោកម្ចាស់ ។ គេដាក់សពលោកម្ចាស់ ឬមន្ត្រីសង្ឃទីរាជគណៈក្នុងកោដ្ឋដែលមានសណ្ឋានផ្សេងៗ ទៅតាមកំរិតឋានន្តរសក្តិ ។ គេនិយមធ្វើរូបទេវតាអំពីចំបើងបិតក្រដាសយ៉ាងប្រិមប្រិយ៍ ឲ្យកាន់ភ្លើងហើយគេបង្ហូតពីទីខ្ពស់ណាមួយក្បែរនោះមកដុតសព ។ គេច្រើនបូជាសពនៅពេលយប់ ទើបឃើញជាទស្សនីយភាពមួយដ៏រំភើប គឺឃើញទេវតាហាក់ដូចជាចុះមកពីស្ថានសួគ៌ យកភ្លើងមកបូជាសពនោះនៅពេលដែលគេអុជកាំជ្រួចភ្ញីទៀនយ៉ាងទ្រហឹងអ៊ឹងអាប់ ។

លោកតា លិប ស៊ុត នៅវត្តកណ្តឹងនិងលោកតា ញ៉ឹក ហួត នៅកំពង់ឆ្លង បានទៅមើលពិធីបុណ្យបូជាសពលោកម្ចាស់កថាថន ញ៉ុញ នៅរវាងឆ្នាំ ១៨៩៤ ។ គេដាក់សពលោកម្ចាស់ ញ៉ុញ ក្នុងកោដ្ឋ ដំកល់ក្នុងមេរុយ៉ាងស្កឹមស្កៃ ដែលគេស្ថាបនានៅខាងត្បូងវត្តកំផែងត្រង់មុខក្លោងទ្វារចូលពីខាងត្បូង ។ ព្រះសង្ឃគ្រប់វត្តត្រូវគេកេណ្ឌឲ្យមកធ្វើរោងបុណ្យ ក្នុងមួយវត្តរោងមួយ ។ រោងនិមួយៗ សុទ្ធតែមានគ្រឿងតាំងជាទីទាក់ទាញមហាជន ។ គេមានលេងភ្លេងរបាំ រាំច្រៀងរបៀបខ្មែរគ្រប់បែបយ៉ាង ថែមទាំងមាន ល្ខោន

www.budinst.gov.kh www.elibraryofcambodia.org

កូឡា និងអាពេលាវទៀតផង ។ នៅពេលយប់ គេមានអុជកាំជ្រួច ភ្លីទៀនគ្រប់បែបយ៉ាង ហើយថែមទាំងមានបាញ់កាំភ្លើងធំទៀតផង។

(ក្នុងការបាញ់កាំភ្លើងធំនេះ មានគ្រោះថ្នាក់ខាងច្នៃកទេស បណ្ដាលឲ្យស្លាប់អ្នកបាញ់ម្នាក់ ។ )

រាស្ត្រប្រជាដែលចូលទៅមើល ពិធីបុណ្យនេះត្រូវគេបញ្ញត្តិយ៉ាងតឹងរ៉ឹង ឲ្យយកក្រមាក្រវាត់ចង្កេះពីក្រៅអាវ ។ (នេះប្រហែលជាវិធានការខាងសុជីវធម៌ មិនមែនវិធានការខាងសន្តិសុខទេ ព្រោះនៅពេលបុណ្យតាំងតុនៅក្នុងវាំងភ្នំពេញ ក៏មិនឲ្យពាក់ស្បែកជើងឈើ ឬដាក់អាវក្រៅខោចូលដែរ ។ សូមបញ្ជាក់ថា ការក្រវាត់ចង្កេះនេះជាសុជីវធម៌ចាំបាច់ នៅពេលនោះ ។ កូនប្រសារជួបឪពុកក្មេក អ្នកតូចជួបអ្នកធំ ត្រូវតែយកកន្សែងក្រវាត់ចង្កេះ ។ បើពុំនោះទេ គេថាយើងព្រហើន ឥតពូជអំបូរ ។ ឪពុកក្មេកខ្លះយកលេសត្រង់កូនប្រសារនិយាយជាមួយមិនក្រវាត់ចង្កេះនេះ ដើម្បីផ្ដាច់កូនក្រមុំអស់ច្រើនគ្នាហើយ ។ រាស្ត្រប្រជានៅសម័យនោះត្រូវតែក្រវាត់ចង្កេះគ្រប់គ្នា ទើបគេអនុញ្ញាតិឲ្យចូលក្នុងបរិវេណពិធីបុណ្យ ។ លោកតាញ៉ុក ហួត ទោះបីគាត់ទើបមានអាយុតែប្រហែល ១០ ឆ្នាំក៏ដោយ ក៏គាត់ត្រូវតែក្រវាត់ចង្កេះនឹងគេដែរ ។)

នៅបញ្ចប់បុណ្យខ្មោចលោកម្ចាស់ព្រះគោដិនេះ មានពិធី

www.budinst.gov.kh www.elibraryofcambodia.org

បោះទាន ។ គេមានឆ្នាកដែលគេបង្កប់ក្នុង ផ្លែល្វា ឬផ្លែចេកខ្ចី ហើយបោះពីផ្កាយព្រឹកមក ។ រង្វាន់ដែលធំជាងគេត្រូវបានដំរី ។ នៅពេលបោះទាន រង្វាន់ធំបានទៅយាយចាស់កំសត់ម្នាក់ ។ យាយចាស់នោះទ្រហោរយំនៅពេលដែលគេនាំដំរីយកមកឲ្យគាត់ ។ គាត់មិនយកទេ តែគេឲ្យគាត់ជិះដំរីទាំងបង្ខំពីទីបុណ្យរហូតដល់ផ្ទះ ។ គេសរសើរព្រេងសំណាងគាត់ រួចគេក៏សុំលោះយកដំរីនោះមកវិញ ។ យើងកុំឆ្ងល់ ប្រាក់ដែលគេលោះគាត់នោះ មិនស្មើនិងតំលៃដំរីពិតប្រាកដទេ ។

## ខ ល្បែងប្រជាប្រិយ៍

### ១- *ល្បែងប្រណាំងទូក*

គេរៀបចំប្រណាំងទូកនៅមុខកំផែង នៅពេលបុណ្យចូលវស្សា ថ្ងៃ១ រោច ខែអាសាធ ។ ទូកប្រណាំងត្រូវចេញដំណើរពីមុខភាសុីស្រាប្រណាំងប្រជែងគ្នាទៅចាប់ទង់ជ័យនៅមុខវត្តសង្កែ ។ រាស្ត្រប្រជាឈរអង្គុយមើលត្រៀបត្រា នៅត្រើយទាំងសងខាងនៃស្ទឹងសង្កែ ។ លោកម្ចាស់ និង បរិពារ ព្រមទាំងនាម៉ឺនមុខមន្ត្រីអង្គុយមើលសុទ្ធតែភ្នាល់គ្នាដាក់លុយដាក់កាក់ ប្រកាន់ទូកមួយៗ ។ អ្នកតូចភ្នាល់តាមអ្នកតូច អ្នកធំភ្នាល់តាមអ្នកធំ ។ លោកម្ចាស់ក៏មានភ្នាល់ចាញ់ឈ្នះសន្ធឹកសន្ធាប់ដែរ ។ ទូកដែលឈ្នះត្រូវបានទទួល

www.budinst.gov.kh www.elibraryofcambodia.org

រង្វាន់ពីគណៈកម្មការរៀបចំពិធី ថែមរង្វាន់ក្រៅដែលអ្នកភ្នាល់ឈ្នះឲ្យទៀត ។

ទូកប្រណាំងដែលល្បីឈ្មោះជាងគេ នៅខេត្តបាត់ដំបង នៅពេលនោះគឺ

- ***ទូកចែវ ឬទូកម្ចង***

ទូកស្ទាំង របស់វត្តសំរោង

ទូកស្រីខ្មៅ របស់វត្តកណ្ដឹង

ទូកសព្រហ្មមាស របស់វត្តកណ្ដឹង

ទូកខ្នុរ របស់វត្តលៀប

- ***ទូកអុំ ឬទូកង***

ទូកច្រវាព្រើម របស់កណ្ដឹង

ទូករថណាម របស់វត្តសំពៅ ។ល។

ទូកប្រណាំងនីមួយៗមានអ្នកអុំ ឬ អ្នកចែវ យ៉ាងតិច ២០ នាក់ ។ ទូកប្រណាំងនីមួយៗសុទ្ធតែមានខ្មោចព្រាយបិសាចកាន់ ។ គេត្រូវតែគោរព ហើយប្រកាន់យ៉ាងតឹងរ៉ឹង ។ ក្រោយពីពេលប្រណាំង គេត្រូវយកទូកនោះមកតំកល់ទុកនៅទីមួយសមគួរ ដូចជាក្រោមដើមពោធិ ឬដាក់ក្នុងរោង ។ ពេលមុនយកទៅប្រណាំងត្រូវប្រារព្ធពិធីបួងសួងដោយមានសំណែន និងប្រគុំភ្លេងពិណពាទ្យ ឬ

www.budinst.gov.kh www.elibraryofcambodia.org

ភ្លេងសារិកាកែវ ទៅតាមទំលាប់ ឬចំណង់របស់ព្រាយបិសាចដែលកាន់ទូកនោះ ។ ទូក*សព្រហ្មមាស* របស់វត្តកណ្តឹងមានមហិទ្ធិរិទ្ធិណាស់ ។ នៅពេលបួងសួងមុនចុះទឹកទៅប្រណាំង ស្ត្រីមានផ្ទៃពោះដើរកាត់មុខត្រូវរលូតកូន ។ លោកយាយអ៊ុំបានប្រាប់ថា គេត្រូវបួងសួងបីយប់ បីថ្ងៃ ទើបគេរំកិលទូកសព្រហ្មមាសនេះ លើកំណល់មូលឲ្យរអិលលើសំពត់កំរាលពណ៌ស ទៅកាន់ស្ទឹងក្រោមស្នូរនៃភ្លេងពិណពាទ្យ ហើយមាននារីព្រហ្មចារីយ៍ពីរនាក់ស្លៀកពាក់តាមប្រពៃណី ដង្ហែទៅផង ។ តែបើរៀបចំពិធីមិនគ្រប់កិច្ចទេនោះ ទោះបីខំរុញយ៉ាងណាក៏ទូកនេះមិនទៅមុខដែរ ។ តាមពត៌មានខ្លះ ថាទូកសព្រហ្មមាសនេះសព្វថ្ងៃនៅឯវត្តឈើខ្មៅ តាមដងស្ទឹងសង្កែនៅមាត់បឹងទន្លេសាបឯណោះ គេធ្វើរោងយ៉ាងវែងមានជញ្ជាំងបាំងល្វសសំណាញ់ដាក់ទូកនេះ ។ ទូកប្រណាំងសឹងតែទាំងអស់មានតំណមសំខាន់មួយ៉ាង គឺគេមិនឲ្យប៉ះក្បាលទូក ឬជាន់ក្បាលទូក ។ ទោះបីដោយចេតនាឬអចេតនា អ្នកណាជាន់ក្បាលទូកប្រាកដជាត្រូវឆ្កួត ។ ទូកឈ្មោះ*រថណាម* របស់វត្តសំពៅមិនអនុញ្ញាតឲ្យមនុស្សពីរ បីនាក់ជិះលេងទេ ។ លោកតា ហ៊ុន ជា អាចារ្យវត្តគរបានមានប្រសាសន៍ថា បើត្រូវការអុំទូករថណាមនេះ គេត្រូវចុះឲ្យគ្រប់ចំនួយគ្រប់ខ្ទង់ ទើបអុំទៅមុខបាន បើមិនដូចនោះទេ

www.budinst.gov.kh www.elibraryofcambodia.org

ទូកនេះនឹងវិលត្រឡប់ត្រឡិន ធ្វើឲ្យអ្នកអុំធ្លាក់ក្នុងទឹកមិនខាន ។ គាត់បានប្រាប់ទៀតថា ទូកវត្តតាមិមមួយមិនចាំឈ្មោះ អណ្ដែតច្រាសទឹកពីវត្តតាមិមរហូតដល់វត្តខ្មែង ។

## ២- ល្បែងប្រណាំងសេះ :

គេប្រណាំងសេះ នៅខែមាឃ ដែលប្រជាកសិកររួចកិច្ចការរបស់ខ្លួនហើយជាពេលដែលផុតរដូវភ្លៀង ។ គេប្រណាំងដោយមានដើមទីនៅត្រង់វាលស្មៅមួយនៅខាងក្រោយវត្តសំពៅ ។ សេះទាំងអស់ត្រូវបរសំដៅក្លោងទ្វារខាងត្បូងនៃកំផែងខ្ពស់ រួចទៅចាប់ទង់ជ័យយកឈ្នះចាញ់នៅខាងក្រោយកំផែងកែវ ។ តែនៅពេលមួយ លោកតា ឌុក មៀន នៅភូមិវត្តបាឡាត់ បានតាមឪពុកគាត់ដែលមានទីជាហ្លួងពិភក្តិចិន្តា ទៅមើលការប្រណាំង កាលគាត់មានអាយុ ១២ឆ្នាំ ។ គាត់បានឃើញសេះប្រណាំងមកពីខាងត្បូងហើយមកចាប់ទង់ជ័យនៅខាងក្រោយកំផែងខ្ពស់ គឺខាងក្រោយគុកសព្វថ្ងៃ ក៏ប៉ុន្តែក្រោយដែលអ្នកជិះចាប់ទង់ជ័យបានហើយ សេះបានបង្ហួសឆ្ងាយទៅទៀត ។ សេះប្រណាំងជាច្រើន មកពីគ្រប់ទិសទី តាំងពីមោង កោះក្រឡ មង្គលបុរី ចូលមករួមប្រណាំង ។ គេចូលមើលការប្រណាំងដោយឥតបង់ថ្លៃទេ ។ សេះដែលឈ្នះត្រូវបានរង្វាន់ អ្នកមើលក៏ភ្នាល់គ្នាតាមធនធានរៀងខ្លួន ដូចនៅ

www.budinst.gov.kh www.elibraryofcambodia.org

ពេលប្រណាំងទូកដែរ ។ យើងមិនបានដឹងអំពីបទបញ្ហា និងឈ្មោះសេះល្បីៗ នៅពេលនោះទេ ។

យើងឃើញថាល្បែងប្រណាំងទូកក្តី ប្រណាំងសេះក្តីត្រូវរៀបចំឡើងសំរាប់តែពួកអភិជនភ្នាល់គ្នាដាក់លុយកាក់ ។

## ៣- *កីឡាប្រដាល់*

កីឡាប្រដាល់តែងប្រព្រឹត្តទៅនៅរដូវប្រាំង នៅតាមវត្តអារាមដែលមានពិធីបុណ្យ ជាពិសេសនៅពេលបុណ្យខ្មោច ។ គេច្រើនប្រកួតប្រដាល់ធំនៅវត្តសង្កែនិងនៅវត្តកំផែង ។ លោកតា ប៉ិល យ៉ត នៅភូមិវត្តកណ្តឹង បានប្រាប់ថា នៅពេលនោះ ការប្រកួតមានលក្ខណៈសាហាវណាស់ គេប្រកួតរហូតដល់មានស្លាប់រស់ ។ ពេលប្រកួត គេយកឃ្លៀសសំរាប់ដាក់ខ្មោចមកបំរុងទុកជាស្រេច ក្រែងមានគូប្រយុទ្ធណាស្លាប់ ។ តែអ្នកឈ្នះត្រូវបានរង្វាន់ពីគណៈកម្មការ ។

លោកតា ប៉ិល យ៉ត បានបន្ថែមទៀតថា អ្នកប្រដាល់មិនពាក់ស្រោមដៃ ដូចសព្វថ្ងៃទេ តែផ្ទុយទៅវិញនៅពេលខ្លះគេពាក់*សំបកខ្ចៅ* នៅចុងកណ្តាប់ដៃទៀតផងដើម្បីឲ្យគូប្រយុទ្ធឆាប់របួស ។ បើតាមលោកតា ប៉ិល យ៉ត ដដែល អ្នកប្រដាល់ដែលល្បីឈ្មោះ ជាងគេនៅសម័យលោកម្ចាស់ គឺ :

www.budinst.gov.kh www.elibraryofcambodia.org

- គុល នៅភូមិវត្តកណ្ដឹង
- ម៉ោល ប្រហែលនៅក្បែរវត្តពិភិទ្ធ
- តក់ នៅភូមិកំពង់សីមា
- ល្អុត នៅតំបន់ផ្សារស្វាយប៉ោ

កីឡាករដែលល្បីឈ្មោះខាងប្រដាល់នៅពេលនោះសុទ្ធតែបានទៅប្រកួតនៅឯស្រុកសៀម ប្រកបដោយជោគជ័យទៀតផង ។

## ៤- ល្បែងប្រជល់មាន់

នៅសម័យលោកម្ចាស់ ល្បែងប្រជល់មាន់ជាល្បែងប្រជាប្រិយដែលគេជល់មាន់ជាសាធារណៈដោយឥតមានច្បាប់ហាមឃាត់ទេ ទោះបីគេភ្នាល់គ្នាដាក់លុយ ដាក់កាក់ក៏ដោយ ។ លោកម្ចាស់កថាថន ឈុំ ចូលចិត្តប្រជល់មាន់ណាស់ ។ នៅក្នុងកំផែងមានសៃវៀនប្រជល់មាន់ពីរ មួយសំរាប់អ្នកមាន មួយទៀតសំរាប់រាស្ត្រប្រជាតូចតាច ។ អ្នកមានភ្នាល់គ្នាដាក់លុយទាំងថង់ ៗ ឯរាស្ត្រប្រជាហ៊ានភ្នាល់ដាក់តែពី ៤ កាក់ទៅ ១រៀលប៉ុណ្ណោះ ។ នេះតាមពត៌មានរបស់លោកតា ប៊ិល ·យ៉ត ។ សៃវៀនប្រជល់មាន់របស់លោកម្ចាស់ ស្ថិតនៅត្រង់ដើមស្វាយធំបីដើម ខាងជើងព្រះវិហារវត្តកំផែងសព្វថ្ងៃ ។ ប្អូនលោកម្ចាស់ឈ្មោះព្រះកញ្ចួន ជាអ្នកមានពូជមាន់ជល់ល្អៗ ជាងគេ នៅបាត់ដំបងសម័យនោះ ។

www.budinst.gov.kh www.elibraryofcambodia.org

## ៥- ល្បែងប្រណាំងទូកលើគោក

ការប្រណាំងទូកលើគោកជាល្បែងម្យ៉ាង ដែលយុវជនបាត់ដំបងសម័យនោះនិយមចូលចិត្តណាស់ ។ ពេលប្រណាំងម្តងៗមានទស្សនិកជនស្កាត់មកពីទីឆ្ងាយៗមកមើលយ៉ាងមីរដេរដាស ។ ទូកនេះមិនមែនជាទូកធម្មតាទេ គឺជាដែបស្សីតូចប៉ុនមេដៃ ដែលគេរោលភ្លើងពត់ឲ្យត្រង់ហើយមានក្បាលអើតបន្តិច ។ គេចងខ្សែមួយសរសៃនៅខាងចុង ។ បើកាលណាគេកញ្ឆក់ខ្សែនោះយ៉ាងខ្លាំងទៅ ទូកនោះក៏បោះពួយយ៉ាងលឿនដូចព្រួញទៅមុខ ។ ទូកដែលគេធ្វើបានល្អ អាចរត់បានលឿនរហូតដល់ជិត ២០០ម៉ែត្រ ។ ទូកដែលរត់លឿន ពឹងផ្អែកលើទូកនោះផង ហើយពឹងលើអ្នកដែលពួយទូកនោះផងដែរ ។ ទូកណាដែលរត់បានឆ្ងាយជាងគេ ត្រូវចាត់ទុកជាឈ្នះ តែការប្រណាំងនេះឥតមានភ្នាល់ជាលុយជាកាក់ទេ ។

## ៦- ល្បែងទាត់សីដក់

ល្បែងទាត់សីដក់ ជាកីឡាម្យ៉ាងដែលគេនិយមបំផុតមិនថាតែនៅបាត់ដំបងទេ គឺនៅពេញប្រទេសកម្ពុជា ។ សីដក់ត្រូវបានគេត្បាញអំពីបន្ទះផ្តៅឲ្យទៅជារាងមូលអាចលោតនៅពេលគេទាត់វា ។

នៅពេលទំនេរ យុវជននិយមប្រមូលគ្នាមកទាត់សីដក់ណាស់ ពីព្រោះជាល្បែងដែលទាមទារឧបករណ៍ និងទីន្លែងងាយរកបាន ។

www.budinst.gov.kh www.elibraryofcambodia.org

ប៉ុន្តែនៅសម័យនោះ មិនដែលមានការប្រកួតកីឡាប្រភេទនេះទេ ទោះបីមានកីឡាករមួយចំនួនបានបញ្ចេញថ្វីដៃដ៏គួរឲ្យចាប់ចិត្ត ។

### ៧- ពិធីប្រជល់រាង

យើងអាចចាត់ទុកពិធីនេះថាជាបុណ្យក៏បាន ថាជាល្បែងក៏បាន គេធ្វើពិធីប្រជល់រាងនេះ នៅពេលរាំងស្ងួតមិនមានភ្លៀង ។ គេប្រ ជល់រាងនេះនៅក្នុងកំផែង នៅត្រង់ដើមពោធិមួយដើមដែលនៅមុខបន្ទាយផ្នែកសឹករងសព្វថ្ងៃ ។ នៅក្រោមដើមពោធិនេះមាន អ្នកតាមួយឈ្មោះ *អ្នកតាឡាក់មឿង* ដែលសព្វថ្ងៃ បានផ្លាស់ទីលំនៅមកនៅសាលាដំបូងហើយ ។

នៅពេលប្រជល់រាង គេធ្វើរូបទីងមោងអំពីឫស្សីបិតក្រដាសហើយអាចលើកដៃលើកជើងបានតាមខ្សែដែលគេញាក់ ។ គេនាំដំរីលោកម្ចាស់ឈ្មោះ អាមាស អាប្រាក់ឲ្យចូលមក ។ នៅពេលឃើញទីងមោងលើកដៃលើកជើង អាមាស អាប្រាក់ ក៏បញ្ចេញសំឡេងកាចដាក់ហើយស្ទុះបោលទៅព្រេចច្រើនលើកច្រើនសារ លុះត្រាតែខ្ទេចទីងមោងនោះអស់ ។ នៅពេលប្រជល់រាងម្តងៗ មានរាស្ត្រប្រជាទៅមើលពិធីនេះយ៉ាងកុះករ ។ គេធ្វើពិធីប្រជល់រាងនេះដើម្បីសុំទឹកភ្លៀង ។

www.budinst.gov.kh www.elibraryofcambodia.org

## ៨- ពិធីបង្ហើរខ្លែង

ពិធីបង្ហើរខ្លែង ជាទំនៀមទំលាប់មួយរបស់ខ្មែរ ។ ចាប់ពីខែមិគ្គសិរទៅ អ្នកស្រុកជំនាន់ដើមនាំគ្នាបង្ហើរខ្លែងសឹងតែគ្រប់គ្នា ។ គេធ្វើខ្លែងធំៗអំពីឫស្សីបិទក្រដាស ឬ សំពត់ ។ ខ្លែងខ្លះមានចំកាងស្លាបដល់ទៅជាង ២ម៉ែត្រ ។ ខ្លែងធម្មតាហៅថា*ខ្លែងក្ពួង* *ខ្លែងឯក* ជាខ្លែងដែលដាក់ឯកនៅខាងមុខ ។ ឯកមានរាងដូចជាដងធ្នូ ដាក់អណ្តាតស្លឹកត្នោតឲ្យបន្លឺសំលេងនៅពេលត្រូវនិងខ្យល់បក់ ។ ខ្លែងឯកបន្លឺសំលេងឆ្លើយឆ្លងគ្នាយ៉ាងរងុំពេញអាកាស ។ លោកតាគង់ ភាក់ ដន្ត្រីករម្នាក់នៅក្បែរវត្តសូរភីបានប្រាប់ថា នៅសម័យលោកម្ចាស់ មានព្រះសង្ឃមួយអង្គព្រះនាម តូច មានកំណើតនៅបឹងឆ្មោរ គង់នៅវត្តសូរភី ប៉ុនប្រសប់ខាងធ្វើខ្លែងឯកណាស់ ។ លោកបង្ហើរខ្លែងសឹងតែវាស់ព្រឹកវាស់ល្ងាច ទោះបីលោកគ្រូចៅអធិការស្តីបន្ទោសយ៉ាងណាក៏ដោយ ។

ក្នុងការបង្ហើរខ្លែងនេះ គេប្រយ័ត្នបំផុតមិនឲ្យខ្លែងដាច់ខ្សែធ្លាក់លើដំបូលផ្ទះអ្នកដទៃឡើយ ។ គេថាកាលណាមានខ្លែងដាច់ធ្លាក់លើដំបូលផ្ទះអ្នកណា ចង្រៃអពមង្គលនឹងមានដល់គ្រួសារនោះ ។ អ្នកធ្វើឲ្យខ្លែងដាច់ធ្លាក់លើដំបូលផ្ទះគេ ត្រូវនិមន្តព្រះសង្ឃទៅសូត្រមន្តរំដោះគ្រោះឲ្យគេ ។

www.budinst.gov.kh www.elibraryofcambodia.org

# គ- ក្រុមសិល្បៈ

## ១- ក្រុមល្ខោនលោកម្ចាស់

លោកម្ចាស់មានល្ខោនពីរក្រុម គឺក្រុមល្ខោនប្រុស និងក្រុមល្ខោនស្រី ។ លោកឥន្ទនិម្មិត និងលោកទេពវិចិត្រ មានភារៈត្រួតត្រាក្រុមល្ខោនទាំងពីរនេះ ។

### - ក្រុមល្ខោនប្រុស (ល្ខោនខោល)

ល្ខោនប្រុសជាវង់ល្ខោនមួយយ៉ាងធំមានសិល្បករជាង ១០០ នាក់ ។ ល្ខោនប្រុសនេះ មានទីស្នាក់ការនិងកន្លែងហាត់រាំនៅខាងត្បូងផ្សារលើសព្វថ្ងៃ ។ ល្ខោននេះមានតួសុទ្ធតែប្រុសទាំងអស់ ទោះត្រូវដើរតួនាងសេតាក៏ដោយ ។ ល្ខោននេះជាល្ខោនបិទមុខ តួយក្ស ហនុមាន ស្វា សុទ្ធតែមានពាក់មុខដែលធ្វើអំពីខ្មុកប្រ័ក្ស ប្រកបដោយក្បាច់យ៉ាងប្រណិត ។

អ្នកសំដែងតួត្រូវធ្វើកាយវិការទៅតាមចង្វាក់ភ្លេង បញ្ចេញក្បាច់ក្បូរទៅតាមទំនុកដែលពោលពីខាងក្នុង ។ នៅពេលនោះ គេច្រៀងជាភាសារសៀមសឹងតែទាំងអស់ ។ គេពោលជាសៀមក៏មាន ជាខ្មែរក៏មាន ។ ការប្រើភាសាសៀមជាការនិយមរបស់អភិជនសម័យនោះ ។ តួសំដែងសំខាន់មាន ពុទ្រា ដើរតួព្រះរាម ម៉ន ដើរតួព្រះល្មក្សណ៍ ទូត ដើរតួរាពណ៍ ពេជ ដើរតួហនុមាន ។ល។

www.budinst.gov.kh www.elibraryofcambodia.org

ឯត្កកដែលល្បីឈ្មោះគឺ ដោរ និង ក្រង់ ។ នេះជាសេចក្តីរាយការណ៍របស់លោកតា គង់ ភាក់ ។ ក្នុងវង់ល្ខោនប្រុសនេះ មានឈ្មោះ គិម ជាអ្នកដើរតួនាងសេតា ។ លោកយាយអ៊ុំ នៅភូមិវត្តកណ្តឹងបានដំណាលថា លោកម្ចាស់ពេញចិត្តនិងនាយគិមនេះណាស់ព្រោះគាត់មានទំរង់មុខ រាងរៅ និងដៃជើងល្អដូចស្រីដែលល្អផុតលេខ ។ លោកម្ចាស់ដាក់បញ្ញត្តិថា បើអ្នកណាម្នាក់ធ្វើឲ្យបាក់ម្រាមដៃរបស់នាយគិមមួយ ត្រូវពិន័យជាប្រាក់ ១០០តំលឹង ។ មានតែឈ្មោះ គិមម្នាក់នេះគត់ ដែលលោកម្ចាស់អនុញ្ញាតិឲ្យចូលរាំជាមួយក្រុមល្ខោនស្រី ដែលតួសំខាន់ៗសុទ្ធតែជាប្រពន្ធលោកម្ចាស់ ។

នៅពេលសំដែងក្នុងកំផែង គេមានភ្លេងពិណពាទ្យពីរវង់ប្រគុំកំដរ ។ វង់មួយសំរាប់ប្រគុំនៅពេលដែលពួកក្រុមរាពណ៍ចេញ វង់មួយទៀតសំរាប់ពួកក្រុមព្រះរាម ។

នៅក្នុងរោងល្ខោន ដែលមានបណ្តោយដល់ទៅ ៩ ល្វែង ក្រៅពីសិល្បករនិងជន្រ្តីករ នៅមានអ្នកបច្ចេកទេសមួយចំនួនទៀតមានភារៈចាត់ចែងរៀបចំឆាក ។ នៅពេលសំដែង ត្រូវរឿងហោះហើរដើរលើអាកាស គេបង្ហូតខ្សែឲ្យតួល្ខោនអណ្តែតត្រសែតឡើងធ្វើឲ្យអ្នកមើលស្រម័យថានៅស្ថានសួគ៌ពិតមែន ។ នៅពេលដែលត្រូវរឿងនាងសេតាដើរកាត់ភ្លើងសំដែងស្វាមីភ័ក្តិ បង្ហាញព្រះរាម

www.budinst.gov.kh www.elibraryofcambodia.org

នោះ គេបង្កាត់ភ្លើងសន្ទោសន្ទៅមែនទែន ហើយឲ្យតួនាង សេតា ដើរកាត់មែនទែន ។ លុះទៅដល់ក្នុង ទើបគេឲ្យគ្រូស្ដោះព្រួសឲ្យបាត់រលាកភ្លាម ។ គ្រូដែលពូកែខាងក្រុងសិរិទ្ធិនេះ ត្រូវគេនិមន្តមកប្រចាំទុកជាមុនស្រេច ។ សូមបញ្ជាក់ថា នៅពេលនោះ គ្មានអគ្គិសនីឬចង្កៀងម៉ាំងសុងទេ ។ គេដុតគោមរយ៉ាឲ្យភ្លឺព្រោងព្រាតពេញរោងរបាំ ។ គោមរយ៉ាមានសល់នៅក្នុងព្រះវិហារវត្តសង្កែសព្វថ្ងៃ ។

## ២- ល្ខោនស្រី

ល្ខោនស្រីមានតួតិចជាងល្ខោនប្រុសទេ ។ នៅក្នុងក្រុមល្ខោនស្រីនេះ គេមិនឲ្យមានតួប្រុសចូលលាយឡំទេ ទោះពេលហាត់រាំក្ដី ពេលសំដែងជាសាធារណៈក្ដី ។ លោកម្ចាស់អនុញ្ញាតិឲ្យតួប្រុសតែម្នាក់គត់ចូលរាំជាមួយស្រីៗ គឺតួនាយគិម ដែលមាននិយាយរួចមកហើយក្នុងក្រុមល្ខោនប្រុស ។ ក្រុមល្ខោនស្រីនេះត្រូវបានគេជ្រើសរើសឡើងនៅពេលដែលលោកកថាថន ឈុំ ឡើងកាន់អំណាចដំបូង ។ គេជ្រើសរើសសិល្បការិនីក្នុងចំណោមនារីដែលមានរូបស្អាតៗ ដែលមានអាយុ ១៣ ឬ ១៤ឆ្នាំ ។ សិល្បការិនីភាគច្រើនជាជាតិខ្មែរ តែមានមួយភាគជាចិន ឬយួន មិនឮគេនិយាយថាមានសៀមទេ ។

www.budinst.gov.kh www.elibraryofcambodia.org



ក្រុមល្ខោនលោកម្ចាស់ (ជ.ឡ)



www.budinst.gov.kh www.elibraryofcambodia.org

តាមពត៌មានថា នៅពេលដែលគេជ្រើសរើសតួល្ខោនស្រីនេះ មានឪពុកម្តាយជាច្រើនដែលមានកូនស្រីរូបស្អាត បានលាក់បំពួនកូនស្រីរបស់ខ្លួនមិនឲ្យគេឃើញ ។ ឪពុកម្តាយខ្លះត្រូវមានទុក្ខទោសដោយសារតែលាក់កូនស្រី ឬ ប្រកែកមិនឲ្យកូនស្រីទៅរាំល្ខោន ។ នេះមិនមែនបានន័យថា អ្នកស្រុកបាត់ដំបងពេលនោះមិនស្រឡាញ់សិល្បៈទេ តែការទៅធ្វើជាសិល្បការិនីរបស់លោកម្ចាស់នាំឲ្យបាត់បង់អស់នូវសេរីភាពដែលមានតិចតួចស្រាប់នោះតែម្តង ។ សិល្បការិនីត្រូវរស់នៅក្នុងកំផែងកែវ ក្រោមបទបញ្ញានិងការត្រួតពិនិត្យយ៉ាងតឹងរ៉ឹង ។ សិល្បការិនីត្រូវហាមឃាត់ដាច់ខាតមិនឲ្យទាក់ទងអ្នកនៅក្រៅកំផែង ។ បើសិល្បការិនីណាមួយទាក់ទងស្នេហាលួចលាក់ជាមួយបុរសណាម្នាក់ ត្រូវមានទោសដល់ប្រហារជីវិតជាមួយនឹងគូប្រុសដែលខ្លួនទាក់ទង ។ លោកម្ចាស់ហាមដាច់ខាតមិនឲ្យសិល្បការិនីមានប្តីសីទេ ។ សិល្បការិនីជាឧបរណ៍សំរាប់បំរើការសប្បាយត្រេកត្រអាលគ្រប់បែបយ៉ាង ហើយដាច់មុខរបស់លោកម្ចាស់ ។ សិល្បការិនីណាដែលមានរូបសម្បត្តិល្អត្រូវលោកម្ចាស់ជ្រើសតាំងជាប្រពន្ធចុងដូចអ្នកល្មាយ កូនលោកស្រីពិភក្តនៅមុខកំផែង ជាតួឯកក្នុងក្រុមល្ខោនស្រី ហើយជាប្រពន្ធចុងទីមួយដែលលោកម្ចាស់ស្រឡាញ់ដាច់គេ ហើយផ្កាប់ជាមាស

www.budinst.gov.kh www.elibraryofcambodia.org

ពេជ្រកែវកងច្រើនជាងគេ ។. សិល្បការិនីថ្នាក់មធ្យម ត្រូវតាំងជាប្រពន្ធចុងប្រភេទទី ២ មានចែកផ្ទះសំបែងល្មមរស់នៅបានស្រួល ដូចជាអ្នកវ៉ាន អ្នកយុត អ្នកវ៉ែន អ្នកម៉ន ។ល។ សិល្បការិនីជាប្រពន្ធចុងប្រភេទទី២ នេះមានចំនួនប្រហែល ៣០ ។ សិល្បការិនីដែលមានរូបសម្បត្តិអន់បន្តិច ត្រូវគេចាត់ទុកជាស្រីបំរើកិច្ចការផ្សេងៗ តាមគេត្រូវការនៅក្នុងវិមានលោកម្ចាស់ ។ លោកយាយអ៊ុំបានប្រាប់ថា ស្ត្រីរបាំប្រភេទទី៣នេះត្រូវបរិភោគបាយរួមគ្នាដោយមានអ្នកបំរើរៀបចំឲ្យ តែមិនមានម្ហូបអាហារល្អគាប់ប្រសើរទេ គឺគេចែកបាយមួយចានសម្លមួយចានម្នាក់ ។ ពេលបាយខ្លះមានតែទឹកគ្រឿងមួយចាននិងត្រកួនមួយបាច់ ។ ហេតុនេះ ឪពុកម្តាយត្រូវតែរកម្ហូបបន្ថែមពីក្រៅ ដែលជាការរំខានដល់គ្រួសារពន់ពេក ។ ប្រពន្ធចុងប្រភេទទីមួយនិងទីពីរ មានផ្ទះដាច់ដោយឡែក ហើយមានស្ត្រីបំរើឆ្វេងស្តាំទៀតផង ។ តែសិល្បការិនីធម្មតាមិនមានប្រាក់ខែទេ ។

កាលដើម ល្ខោនស្រីនេះសំដែងតែរឿងរាមកេរ្តិ៍ដូចក្រុមល្ខោនប្រុសៗដែរ ។ នាងញ៉ឹងនិងនាងញ៉ីវប៊ិនប្រសប់ខាងដើរតួហនុមាន និងអង្គទ ។ នាងទាំងពីរនេះ មានទេពកោសល្យពិសេសគួរឲ្យស្ញប់ស្ញែង អាចហក់លោតពីដើមឈើមួយទៅដើមឈើមួយ

www.budinst.gov.kh www.elibraryofcambodia.org

អាចឡើងដើមស្លាបានដោយយកជើងទៅមុន ។ កាយវិការនេះ សូម្បីតែប្រុសៗក៏ពិបាកធ្វើដូច ។ នាងញ៉ឹង នាងញ៉ីវនេះជាកូនឃួន មានរូបសម្បត្តិដ៏ស្រស់មានអាយុ ១៣ និង ១៤ឆ្នាំ ។ ឪពុកមាន ទោសត្រូវដាក់ច្រវាក់ តែត្រូវបានរួចខ្លួនវិញ ដោយសុខចិត្តប្រគល់ កូនឲ្យចូលរាំក្នុងក្រុមល្ខោនលោកម្ចាស់ ។

លោកយាយអ៊ូច នៅភូមិស្វាយឆ្អេះ បានប្រាប់ទៀតថា នៅ ពេលក្រោយមក មានគ្រូសៀមឈ្មោះ ម៉ម ងៀម បានចូលមក បង្ហាត់ក្រុមល្ខោនស្រីនេះ ។ ចាប់ពីពេលនោះមក ក្រុមល្ខោនស្រី នេះសំដែងរឿងរាមកេរ្តិផង ហើយមានសំដែងរឿងប្លែកៗ ថែម ទៀត ដូចជារឿងអៃណាវបុស្បា រឿងព្រះលក្សិណវង្ស រឿផ្សាណាយ ម៉ាក់ចឹង រឿងព្រះអភ័យ ។ល។ ក្នុងការសំដែងរឿងព្រះអភ័យនេះ សិល្បការិនីស្លៀកពាក់បែបទំនើប បែបអឺរ៉ុប ដូចជាស្លៀកខោមាន ឆ្នូតនៅត្រង់ហៅប៉ៅទាំងសងខាង ។ ឯដន្ត្រីវិញ ក៏មានដន្ត្រីសម័យ ទំនើបបែបអឺរ៉ុបមកប្រគុំកំដរផងដែរ ។ គឺនៅពេលនេះហើយ ដែលមានជំរៀតចូលនៃសិល្បៈអឺរ៉ុប ។

ក្រុមល្ខោនស្រីសំដែងតែនៅក្នុងកំផែងទេ មិនដែលទៅ សំដែងនៅក្រៅវាំលឡើយ ។ ឯក្រុមល្ខោនប្រុស តែកាលណាផុត ពេលសំដែងនៅក្នុងកំផែងហើយ គេបំបែកគ្នាជាក្រុមតូចៗ ទៅ

www.budinst.gov.kh www.elibraryofcambodia.org

សំដែងនៅតាមវត្តអារាមដែលមានពិធីបុណ្យ ដើម្បីយកសោហ៊ុយចិញ្ចឹមជីវិត ។ លោកម្ចាស់ជួយផ្គត់ផ្គង់តែសម្ភារៈនិងឲ្យសោហ៊ុយខ្លះនៅពេលសំដែងប៉ុណ្ណោះ ។ ក្រៅពីនេះ ក្រុមល្ខោនត្រូវប្រកបរបរផ្សេងៗទៀតដើម្បីចិញ្ចឹមជីវិត ។

### ៣ វង់ភ្លេងពិណពាទ្យ

នៅតាមភូមិស្រុក និងនៅតាមវត្តអារាម តែងមានវង់ភ្លេងពិណពាទ្យសំរាប់ប្រគុំកំដរពិធីបុណ្យផ្សេងៗ ដូចជាបុណ្យកឋិនភ្ជុំបិណ្ឌ ទេសនាមហាជាតិជាដើម ។ តែវង់ភ្លេងនៅតាមភូមិនិងតាមវត្តអារាម ជាវង់ភ្លេងប្រជាប្រិយ៍ប្រគុំដោយសិល្បករមិនសូវល្បីឈ្មោះទេ ។ តែកាលណាមានបុណ្យធំ គេត្រូវជួលវង់ភ្លេងដែលល្បី ៗ ទើបមានកិត្តិយសដល់ម្ចាស់បុណ្យ ។

វង់ភ្លេងដែលល្បីឈ្មោះនោះគឺ វង់ភ្លេងលោកម្ចាស់នេះតែម្តង ។ លោកតា គង់ ភាក់ ជាដន្ត្រីករម្នាក់ នៅក្បែរវត្តសូរភីបានប្រាប់ថាវង់ភ្លេងលោកម្ចាស់ធំណាស់មានអ្នកភ្លេងដល់ទៅ១៣នាក់ ។ ឯឧបករណ៍ដែលប្រគុំនោះគឺ ស្គរធំ៤ សំភោ១ គងក្រោល១ គងតូច១ ស្រឡៃណក១ ស្រឡៃណៃ១ រនាតដែក១ រនាតរត់១ រនាតថាំង១ រនាតថោង១ ឈឹងតូច១ ឈឹងធំ១ ។ លោកម្ចាស់

www.budinst.gov.kh www.elibraryofcambodia.org

មិនបើកប្រាក់ខែឲ្យដន្ត្រីករទេ តែឲ្យប្រាក់៥បាតដល់អ្នកភ្លេងម្នាក់ ៗ ក្នុងពេលមានបុណ្យទានក្នុងកំផែងម្ដងៗ ។ ក្រៅពីពេលប្រគុំ អ្នកភ្លេងអាចបំបែកគ្នា ជាក្រុមតូចៗទៅប្រគុំតាមបុណ្យទាន ដោយយកឈ្នួល ៥បាតក្នុង១បុណ្យងាំនម្ដង ។

តាមធម្មតា វង់ភ្លេងពិណពាទ្យនេះ អាចក្រឡៃផ្លាស់បរិក្ខារ ជាវង់ភ្លេងខ្មែរបុរាណក៏បាន ជាវងភ្លេងមហោរីក៏បាន ជាវង់ភ្លេងខ្លងខែកក៏បាន ។ លោកតា គង់ភាក់បានប្រាប់ទៀតថា លោកម្ចាស់មានស្គរខ្លងខែកពីរ ធ្វើពីក្រញូង តែពួមិនសូវពិរោះទេ ។ វង់ភ្លេងលោកម្ចាស់នេះ មានលោកភិរម្យតោ នៅក្បៀវត្តលៀប ជាអ្នកដឹកនាំ ។ ឪពុកលោកតា គង់ ភាក់ នេះក៏ជាដន្ត្រីករម្នាក់ក្នុងវង់ភ្លេងលោកម្ចាស់នេះដែរ ។

ក្រៅពីនេះ មានវង់ភ្លេងមួយទៀតរបស់លោកបាឡាត់ ដែលមាន តា សុច នៅភូមិវត្តសំពៅជាអ្នកដឹកនាំ ។

## ៤- ក្រុមល្ខោនប្រជារាស្ត្រ

នៅសម័យនោះ គេមិនទាន់ឃើញមានល្ខោនបាសាក់ទេ ។ នៅតាមជនបទមានក្រុមល្ខោនបិទមុខ សំដែងតែរឿងរាមកេរ្តិ៍តែអាចផ្លាស់បរិក្ខារសំដែងជាយីកេវិញក៏បាន ។ ល្ខោនបិទមុខមិនដែលនិយាយទេ ។ គេកាច់កាយវិការទៅ តាមចង្វាក់ភ្លេង ដោយ

www.budinst.gov.kh www.elibraryofcambodia.org

មានចំរៀងនិងព៌នោលផង ។ៈ បើគេត្រូវការរឿងផ្សេង ក្រៅពីរាមកេរ្តិ៍ តួសំដែងត្រូវច្រៀងខ្លួនឯង ហើយនិយាយឆ្លងឆ្លើយគ្នា ។ តែលក្ខណៈល្ខោននៅបាត់ដំបងពេលនោះមិនដូចល្ខោនបាសាក់ទេ។

ក្រុមល្ខោនដែលល្បីឈ្មោះនៅពេលនោះគឺ :

- ក្រុមល្ខោនតា សំ នៅពាមឯក
- ក្រុមល្ខោនលោកចក្រី នៅភូមិអូរខ្ចាយ
- ក្រុមល្ខោនតាភោកនិងតាទូត នៅភូមិច្រាបក្រសាំង (ពីរក្រុមរួមគ្នា)
- ក្រុមល្ខោន តាឡឹកយាយកែនៅភូមិខ្វិតសង្កាត់ព្រែកខ្ពប។

## ៤- យីកេ

យីកេនៅពេលនោះ មិនដូចយីកេសព្វថ្ងៃទេ ។ គេមិនដែលឃើញមានក្រុមយីកេមួយដាច់ដោយឡែកទេ មានតែយីកេផងល្ខោនផង ។ ក្រុមតែមួយអាចលេងយីកេក៏បាន ទៅតាមសេចក្តីត្រូវការរបស់ម្ចាស់បុណ្យដែលគេជួល ។ តួយីកេ នៅពេលនោះមិននិយាយទេ គ្រាន់តែធ្វើកាយវិការរាំរែកទៅតាមចង្វាក់ភ្លេងចំរៀងនិងពំនោល ។ គេច្រៀងជាពួកដូចសព្វថ្ងៃដែរ ។

មានតែនៅភូមិ ខ្វិត ក្បែរវត្តក្តាំងងារមួយទេ ដែលមាន

www.budinst.gov.kh www.elibraryofcambodia.org

វង់យីកេដាច់មុខ មិនលេងល្ខោន គឺវង់យីកេ តាតុង ។

៦- អ្នកច្រៀងចាប៉ី

អ្នកច្រៀងចាប៉ីដែលល្បីឈ្មោះជាងគេ នៅបាត់ដំបង នៅសម័យលោកម្ចាស់ គឺតា យូ នៅភូមិចែងក្ដារ ។ តាយូនេះមានផ្ទះមួយនៅក្បែរវត្តកណ្ដាល ។ នៅពេលក្រោយដែលលោកម្ចាស់ទៅបស្ចឹមបាត់ហើយនោះ អ្នកស្រុកបាត់ដំបងបានសុំឲ្យ តា យូ នេះច្រៀងឆ្លងឆ្លើយ ជាមួយភិរម្យ ង៉ុយ ដែលមកពីភ្នំពេញញឹកញាប់ ។ អ្នកបាត់ដំបងវាយតំលៃថា តាយូមិនអន់ជាងភិរម្យង៉ុយប៉ុន្មានទេ ។ ក្រៅពីតា យូ មានអ្នកច្រៀងចាប៉ីល្បីទៀតដូចជាឈ្មោះ អុន នៅភូមិដាក់សរសរ ឈ្មោះសិរិទ្ធិ នៅតាប៉ុន ។ មានស្ត្រីម្នាក់ដែរខាងចំរៀងចាប៉ី នៅសម័យនោះ គឺឈ្មោះនាង ចននៅភូមិអូរខ្ចាយ តែខាងចននេះ មិនដេញចាប៉ីខ្លួនឯងទេ មានអ្នកដេញចាប៉ីម្នាក់ប្រគុំកំដរ ។

៧- អ្នកសូត

លោកគ្រូ ស៊ុំ នៅវត្តសូរភី ជាអ្នកសូតល្បីឈ្មោះ នៅបាត់ដបងនៅសម័យលោកម្ចាស់ ។

www.budinst.gov.kh www.elibraryofcambodia.org

### ៨- ក្រុមចំរៀងប្រប់កៃ

នៅមុនឆ្នាំ ១៩០៧ ខេត្តបាត់ដំបងមិនដែលមានអាយ៉ៃទេ ។ គេឃើញមានតែក្រុមចំរៀងប្រប់កៃ ។ ក្រុមប្រប់កៃខ្លះ ជាក្រុមវិជ្ជាជីវៈដើរច្រៀងយកលុយនៅពេលមានបុណ្យទាន ដូចល្ខោនដែរ ។ ប្រប់កៃគឺជាចំរៀងឆ្លងឆ្លើយគ្នា ដោយមានការទះដៃបន្ទរ គេមិនដែលប្រគុំភ្លេងកំដរប្រប់កៃទេ ។ ក្រុមចំរៀងប្រប់កៃមានច្រើនក្រុម តែក្រុមដែលល្បីជាងគេ គឺក្រុមអាចារ្យសោម នៅភូមិកំពង់អំពិល និងក្រុមនាងទូចនាងដែង នៅចំការសំរោង ។

បណ្ណាល័យ ពុទ្ធសាសនបណ្ឌិត LIBRARY BUDDHIST INSTITUTE

### ៩- អាពេ

ច្រើនតែជនជាតិលាវទេដែលជាអ្នកច្រៀងអាពេ ។ គេច្រៀងឆ្លងឆ្លើយគ្នា ដោយមានផ្លុំគែននិងទះស្គរយីកេកំដរ ។ នៅពេលមានបុណ្យធំ នៅក្នុងកំផែង គេតែងឃើញលាវមកច្រៀងអាពេនៅប៉មខាងអាគ្នេយ៍នៃកំផែងខ្ពស់ ។

### ១០- យីកេ៉

យីកេ៉ជាក្រុមល្ខោនកំប្លែង ស្លៀកពាក់រយីករយាកឲ្យគេសើច ដូចជាស្លៀកការុង ពាក់បាវ ពាក់ភួម ឬពាក់សំបុកចាបធ្វើជាមកុដ ។ តាមធម្មតា ក្រុមល្ខោនរាមកេ្តរិក៏មានផ្លាស់សំលៀកបំពាក់

www.budinst.gov.kh www.elibraryofcambodia.org

លេងជា យីកេ ដែរ ដើម្បីកំដររបរិយាកាសម្តងៗ ។ ចាស់ៗនិងអ្នករបទម្បមិនចូលចិត្តយីកេនេះទេ ។ យីកេ ជាពាក្យសៀម មានន័យថា *អាចម៍ស្រវឹង* ។ កាលដើម យីកេសំដែងរឿងរាមកេរ្តិ៍ ដូចល្ខោនធម្មតា ដោយមានភ្លេងពិណពាទ្យកំដរផង តែក្រោយមកយីកេ ច្រើនសំដែងរឿងខ្លីៗ ដោយគ្រាន់តែមានវាយស្គរអារក្ស ឬវាយបោតកំដរ ។

## ១១- ល្ខឹង

ល្ខឹង ជាក្រុមល្ខោនសំដែងរឿងរាមកេរ្តិ៍ដែរ តែអ្នកសំដែងឥតមានតុបតែងកាយទេ គឺស្លៀកពាក់ធម្មតា ឬ ឥតទាំងមានពាក់អាវផង ។

## ១២- ណាំងស្បែក

គឺជាផ្ទាំងធំៗឆ្លាក់ជារូបតាមរឿងរាមកេរ្តិ៍ ប្រកបដោយក្បាច់យ៉ាងប្រណិត ។ លោកម្ចាស់មានស្បែកប្រហែល ១៣០ផ្ទាំង ។ តែនៅពេលដែលលោកម្ចាស់ទៅបស្ថិមនោះគេបានយកស្បែកនោះទៅទុកលើពិតាននៃព្រះវិហារវត្តដំរីសជាមួយនឹងមុខល្ខោនជាច្រើន ។

គេសំដែងណាំងស្បែក ដោយឲ្យសិល្បករកាន់ផ្ទាំងស្បែកធ្វើកាយវិការ តាមចង្វាក់ភ្លេងពិណពាទ្យ ដែលប្រគុំនៅក្បែរនោះ ។ គេដុតភ្លើងនៅម្ខាងឲ្យចាំងស្រមោលទៅលើផ្ទាំងសំពត់ស ដែល

www.budinst.gov.kh www.elibraryofcambodia.org

ចងនៅខាងមុខ ។

ណាំងស្បែកនេះ មិនលើកដៃ យោលជើង ដូចអាយ៉ងដែលកើតមាននៅសម័យក្រោយទេ ។

### ១៣- នីវ

នៅផ្សារស្វាយប៉ោ នៅក្នុងរោងល្បែងហួយ មានការសំដែងនីវ ដែលជាអាយ៉ងចិន ។ គេលេង នីវ នៅពេលថ្ងៃដោយឥតមានផ្ទាំងសំពត់សទេ ។ គេពាក់រូបអាយ៉ងនៅចុងម្រាមដៃ ហើយញាក់ឲ្យកើតជាកាយវិការតាមភ្លេង និងចំរៀងចិន ។ នីវច្រើនសំដែងរឿងសាមកុក ។ គេចូលមើលនីវដោយឥតបង់ថ្លៃទេ ព្រោះគេលេងនីវដើម្បីទាក់ទាញមហាជនឲ្យចូលទៅលេងល្បែងហួយ

### ១៤- ភ្លេងហិប

នៅឆ្នាំ ១៩០៧ នៅតាមផ្ទះអ្នកមាន ឬ អ្នកធំ គេឃើញមានឧបករណ៍ម្យ៉ាងសំរាប់កំសាន្ត គឺភ្លេងហិប ។ ភ្លេងហិប ជាម៉ាស៊ីនចាក់ថាសចំរៀងរវៃដោយដៃ ។ នៅពេលនោះ គេប្រើថាសចំរៀងមានរាងមូលដូចបំពង់ឫស្សី មិនមែនមូលសំប៉ែតទេ ។ ថាសទាំងអស់មានច្រៀងតែសៀម មិនមានច្រៀងខ្មែរទេ ។

ក្រៅពីអ្នកធំនិងអ្នកមាន មានតែលោកគ្រូចាបនៅវត្តលៀបមួយអង្គទេ ដែលមានភ្លេងហិបនេះ ។ អ្នកស្រុកនាំគ្នាទៅមើលនិង

www.budinst.gov.kh www.elibraryofcambodia.org

ស្តាប់ភ្លេងហិបនៅកុដិលោកគ្រូចាបសឹងតែរាល់ថ្ងៃ ។ លោកតា ឥន្ទ សន្ទរ៍ នៅភូមិផ្សាធំនិងលោកតា ឌុក មៀន នៅវត្តបាឡាត់បាន បញ្ជាក់ប្រាប់ទៀតថា លោកគ្រូចាបនេះមានទេពកោសល្យពិសេស ខាងគ្រឿងយន្តផ្សេងៗ ។ លោកមាននិស្ស័យខាងបច្ចេកទេស ទំនើបណាស់ ។ លោកជាជាងឈើ ជាងដែក ។ តែនៅពេលនោះ នៅខេត្តបាត់ដំបងទាំងមូល មានតែលោកគ្រូចាបមួយអង្គនេះទេ ដែលចេះជួសជុលនាឡិកា ។ លោកចេះធ្វើប្រដាប់ប្រើប្រាស់តាម សម័យទំនើប ឬ ធ្វើល្បែងលេងពិសេស ដូចជាដាក់ម៉ាស៊ីនឲ្យ ហិបស្លាចេះដើរទៅកាន់ភ្ញៀវដែលមកថ្វាយបង្គំលោក ។ គឺលោកគ្រូ ចាបនេះហើយដែលជាអ្នកចាត់ចែងក្បាច់រចនាផ្សេងៗ សំរាប់លំអ ឆាកល្ខោនលោកម្ចាស់ មានការរចនាឲ្យល្ខោនហោះហើរដើរលើអា កាសជាដើម ។ ក៏គឺលោកគ្រូចាបនេះដែរដែលជាអ្នករចនាធ្វើ ទីង មោងសំរាប់ប្រផល់វាង នៅក្នុងកំផែង នៅពេលវាំងស្ងួត ។ល។

## ឃ- កាំជ្រួច

នៅសម័យដើម គេនិយមអុជកាំជ្រួចភ្ញីទៀននៅពេលមាន បុណ្យទានផ្សេងៗជាពិសេសពេលបុណ្យខ្មោច ។ នៅក្នុងស្រុក មាន ជាងធ្វើកាំជ្រួចសំរាប់កំសាន្តនៅពេលបុណ្យ ។ នៅពេលទេសនា

www.budinst.gov.kh www.elibraryofcambodia.org

មហាវេស្សន្តរជាតក គេនិយមផុតផាវនៅពេលដែលលោកទេសន៍ចប់ម្តងៗ ដើម្បីឲ្យពុទ្ធសាសនិកចាប់អារម្មណ៍ពីទិដ្ឋភាពផ្សេងៗ នៅព្រៃហិមពាន្ត ។ នៅពេលបុណ្យខ្លះមានបង្ហោះគោមទៀតផង ។

កាំជ្រួចមានច្រើនសណ្ឋាន ទៅតាមការរចនារបស់ជាងអ្នកធ្វើ ។ គេមិនសូវទិញកាំជ្រួចមកពីបរទេសទេ គេប្រើរូបធាតុដើមធ្វើរំសេវដើម្បីធ្វើកាំជ្រួច ។

គេធ្វើរំសេវ ដោយយកក្រាម លាយស្ពាន់ធម៌និងធ្យូងឈើដែលស្រាលៗ ដូចជាដើមត្រប់ ដើមគរ យកមកកូរឆាវលាយគ្នាក្នុងខ្ទះធ្លោតយ៉ាងធំ ឲ្យគោក ។ គេយកវត្ថុទាំងនេះទៅហាលថ្ងៃឲ្យស្ងួតរួចទើបយកមកបុកឲ្យផង់ដូចម្សៅ ហើយហាលថ្ងៃទុក ។ សូមបញ្ជាក់ថា ក្នុងការធ្វើកាំជ្រួច គេត្រូវបន្ថយកំលាំងរំសេវដោយយកជ័រចុង មកបុកឲ្យហ្មត់លាយជាមួយ ។

គេយករំសេវនេះទៅច្រកក្នុងបំពង់ឫស្សីធំប៉ុនមេជើង ហើយបុកឲ្យណែន ។ គេយកបំពង់សេវនេះដាក់គន្ទុយថ្លឹងឲ្យល្អ ទើបយកទៅដាក់បញ្ឈរ ហើយផុតឲ្យវាហោះទៅលើអាកាស បង្កើតជាទស្សនីយភាពដ៏ល្អ ។ គេអុជកាំជ្រួចដោយប្រើឈ្នួន ។ គេធ្វើឈ្នួនដោយយកអំបោះឆៅទៅលាបបាយម៉ាន ហើយជ្រលក់រំសេវ ។ គេហាលថ្ងៃអំបោះដែលប្រឡាក់រំសេវនេះឲ្យស្ងួត ហើយយក ក្រដាស់

www.budinst.gov.kh www.elibraryofcambodia.org

ស្តើងមករុំ ។ គេដុតចុងម្ខាងនៃឈ្នួន ឲ្យភ្លើងឆេះដេញតៗ ទៅរហូតដល់កាំជ្រួច ទើបកាំជ្រួចនោះស្ទុះទៅ លើដោយសារ កំលាំងធាក់នៃរំសេវដែលឆេះ ។ គេត្រូវប្រយ័ត្ន ថ្លឹងកាំជ្រួចឲ្យបានទៀងទាត់ បើពុំនោះទេ កាំជ្រួចមិនហោះទៅលើទេ អាចធាប់ធ្លាក់មកវិញ ឬរត់តែផ្តេសផ្តាសដេញគេដេញឯង ។

គេអាចមិនដាក់កន្ទុយកាំជ្រួច ហើយក្រខ្សែជាឧបរណ៍កំសាន្តផ្សេងៗដូចជា :

- *ផ្សោត* : គេដុតកាំជ្រួចដែលឥតមានកន្ទុយ ហើយបោះទៅក្នុងទឹកស្ទឹង ឲ្យវាលោតចុះលោតឡើង ដោយកំលាំងធាក់នៃរំសេវ ដូចផ្សោតដែលមុជទឹក ។

- *កណ្តុរ* : គឺជាកាំជ្រួចឥតកន្ទុយពីរ ផ្ទុយគ្នា ។ គេយកកាំជ្រួចទាំងពីរនេះទៅចងនឹងខ្សែលួសមួយ ដែលគេចងសន្ទឹងភ្ជាប់និងបង្គោលពីរដោយមានរ៉ក កាំជ្រួចដែលគេដុតឲ្យឆេះក៏រត់លើខ្សែរលួសនេះទៅវិញទៅមក ។

-*រន្ទា* : គឺជាកាំជ្រួចឥតកន្ទុយជាច្រើន ដាក់ក្នុងបំពង់ឫស្សីតំរៀបជាជួរហើយភ្ជាប់គ្នាដោយឈ្នួន ។ គេអុជតែម្តង កាំជ្រួចក៏ឆេះបន្តគ្នាម្តងមួយៗហោះទៅលើអាកាសប្រសេចប្រសាច ។

- *គុហា* : គឺជាកាំជ្រួចដែលចងជាប់និងបង្គោល ។ កាលណា

www.budinst.gov.kh www.elibraryofcambodia.org

គេដុត គុហាក៏ឆេះបញ្ចេញផ្កាភ្លើងព្រោងព្រាតទៅលើ ។

- *កង្ហារ* : គេបោះក្ដារមួយបន្ទះលើបង្គោលមួយ ដោយទុកឲ្យក្ដារនោះវិលបានតាមចិត្ត ។ គេចងកាំជ្រួចពីរឬបីនៅចុងនីមួយៗដោយដាក់ឲ្យបញ្ច្រាសគ្នា ហើយចងភ្ជាប់គ្នាដោយឈ្នួន ។ កាលណាគេដុត កាំជ្រួចនេះក៏ឆេះធាក់បញ្ច្រាស់គ្នាធ្វើឲ្យក្ដារនោះវិលយ៉ាងញាប់ ។ ឯផ្កាភ្លើងដែលបញ្ចេញក៏កើតជារង្វង់មូល អស់មួយរយៈពេល ។

- *ភ្ញី* : គេច្រកវំសេវក្នុងបំពង់ក្រដាសប៉ុនម្រាមដៃ ហើយបុកឲ្យណែន ។ គេយកបំពង់វំសេវនេះទៅចងនៅចុងបន្ទះឫស្សីជាច្រើន ដែលគេចងចំកាងដូចអង្រុតបញ្ច្រាស់ទៅលើភ្ជាប់នឹងបង្គោលឫស្សី ។ គេចងភ្ញីនេះឲ្យមានច្រើនថ្នាក់ ។ កាលណាគេដុតបំពង់វំសេវឆេះក៏វាត់ហើយយោលឡើងគ្រវីគ្រវាត់ ដូចទងផ្កាត្រូវខ្យល់បក់ ។

- *ដំរី* : គេយកដើមឫស្សីមានច្រើនថ្នាំងមកពុះមិនឲ្យបែកទេ ។ គេច្រកវំសេវទៅក្នុងបំពង់ឫស្សីនោះ ។ កាលណាគេដុតឈ្នួនវំសេវដែលឆេះក៏ធាក់ចេញមកក្រៅបន្លឺសំលេងដូចដំរីស្រែក។

- *ភាន៊ិ* : គេយកគ្រាប់សំរោងមកចោះយកសាច់ចេញ ។ គេ

www.budinst.gov.kh www.elibraryofcambodia.org

ច្រកវិសេវទៅក្នុងគ្រាប់នោះវិញ ។ គេដាក់គ្រាប់សំរោងមានវិសេវទៅក្នុងបំពង់ឫស្សីផ្ការដាក់លើបង្គោលមួយ ។ គេដាក់វិសេវបន្តិចក្នុងបំពង់នោះ ហើយតឈ្នួនទំលាក់មកក្រោម ។ កាលណាគេដុតគ្រាប់សំរោងនោះក៏លោតព្រោងព្រាតមកក្រោមរត់ឆ្វេចឆ្វាច ដូចតាឱបែកសំបុកហើយដេញអ្នកមើលប្រសេចប្រសាច ។

- *គោមហោះ* គោមហោះមិនមែនជាកាំជ្រួចទេ គឺជាគោមធំៗធ្វើអំពីបន្ទះឫស្សីបិទក្រដាស ។ គេដុតសំពត់ជ្រលក់ជ័រទឹកដែលបន្តោងនៅក្នុងនោះ ។ កាលណាសំពត់ឆេះល្អហើយ គោមនោះក៏ហោះឡើងទៅលើ ។ បើកាលណាមានអុជកាំជ្រួច គេតែងឃើញមានដុតគោមហោះនេះជានិច្ច ។

អ្នកធ្វើកាំជ្រួចដែលល្បីឈ្មោះ នៅបាត់ដំបងនៅរវាងឆ្នាំ ១៩០៧ គឺតា ស្វ នៅសាលាតាអន ជាងអុល នៅភូមិសោមនស្ស និង លោកគ្រូ រស់ ចៅអធិការវត្តកណ្តឹង ។ តែជាងខ្មែរ នៅពេលនោះមិនចេះធ្វើវិសេវឲ្យឆេះមានពណ៌ទេ ។ គេមិនសូវចេះធ្វើផាវទេ ។ គេទិញផាវមកពីបរទេស ។

នៅក្រោយសម័យលោកម្ចាស់ រដ្ឋការបារាំងបានហាមប្រាមមិនឲ្យធ្វើវិសេវ ដែលជាហេតុនាំឲ្យសាបរលាបល្បែងអុជ កាំជ្រួចកំសាន្តនៅពេលមានបុណ្យង៉ានផ្សេងៗ ។

www.budinst.gov.kh www.elibraryofcambodia.org

# ជីវភាពចម្រុងចម្រើន

## ១- ការរីកចំរើនខាងអក្សរសាស្ត្រ

នៅមុនឆ្នាំ ១៩០៧ ថ្វីត្បិតតែខេត្តបាត់ដំបងស្ថិតនៅក្រោមអំណាចសៀម តែអ្នកបាត់ដំបងបានរក្សាភាសានិងអក្សរសាស្ត្រជាតិខ្មែរឲ្យបានគង់វង់ថ្កុំថ្កើងជានិច្ច ។ នៅតាមវត្តអារាមគេរៀនភាសាខ្មែរ ព្រះសង្ឃសំដែងធម៌ទេសនាជាខ្មែរ ។ល។ មិនតែប៉ុណ្ណោះ គេនិយមកំណាព្យកាព្យឃ្លោងជាខ្មែរ ។ ហេតុនេះហើយដែលនាំឲ្យខេត្តបាត់ដំបងនៅសម័យនោះមានកវីម្នាក់ដ៏ឆ្នើម មានកិត្តិសព្ទរន្ទឺខ្ចរខ្ចាយ ហើយមានប្រជាប្រិយភាពយ៉ាងខ្លាំងក្នុងចំណោមអ្នកបាត់ដំបង ។ កវីនោះឈ្មោះ ឥន្ទ ដែលលោកម្ចាស់តាំងឲ្យមានទីជា *ឃុនវិចិត្រវោហារ* ហើយក្រោយមកតំលើងទីជា *ហ្លួងវិចិត្រវោហារ* ។

លោកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ មានកំណើតនៅរកាកោង ស្រុកមុខកំពូល ក្នុងឆ្នាំ ១៨៥៩ ។ នៅអាយុ ១៩ឆ្នាំ លោកបានមករស់នៅស្រុកបាត់ដំបង ដោយស្នាក់នៅរៀនសូត្រជាមួយព្រះគ្រូអាចារ្យ សុខ នៅវត្តកែវ លុះអាយុ២០ឆ្នាំ លោកបួសជាភិក្ខុហើយឆ្នាំបន្ទាប់មកលោកក៏ទៅបន្តការសិក្សានៅក្រុងបាងកកបាន៧ឆ្នាំទើប

www.budinst.gov.kh www.elibraryofcambodia.org

វិលត្រឡប់មកស្រុកបាត់ដំបងវិញ ។ លោកគង់នៅវត្តកណ្តាល បាន ១០ឆ្នាំ ទើបលាចាកសិក្ខាបទ មានគ្រួសារនៅភូមិផ្សាធំ ។ លោកមានថ្វីដៃយ៉ាងខ្លាំងខាងកំណាព្យ ដោយបានតែង និងបានប្រែបាលីជាសំរាយមានឈ្មោះ ៤៤មុខ ។ លោក កថាថន ឈុំ បានតែងតាំងជាហ្លួងវិចិត្រវោហារ ជាទីប្រឹក្សាកិច្ចការផ្សេងៗ ។

ក្រោយដែលលោកកថាថន ឈុំ ចាកចោលស្រុកបាត់ដំបងទៅរស់ឯបស្ចិមបុរី លោកបានទៅធ្វើការនៅភ្នំពេញអស់ពេលដប់ឆ្នាំ គឺពីឆ្នាំ ១៩១៤ ដល់ឆ្នាំ១៩២៤ ដោយមានទីជាឧកញ៉ាសុត្តន្តប្រីជា។ លុះអាយុបាន៦៤ឆ្នាំ លោកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ បានវិលមកបាត់ដំបងវិញ ។ លោកមានជំងឺ ហើយធ្វើមរណកាលនៅឆ្នាំនោះ គឺឆ្នាំ ១៩២៤ ។

ស្នាដៃរបស់លោកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ មានច្រើនណាស់ ដូចជា*គតិលោក* ១០ខ្សែ *និរាសនគរវត្ត រឿងអំបែងបែក បឋមសម្ពោធ លោកនីតិបករណ៍ សុភាសិតច្បាប់ស្រី ក្បួនមេកាព្យ* ។ល។ ភាគខ្លះនៃសៀវភៅគតិលោក និង សៀវភៅរឿងចំប៉ាំងតាកែ ជាកញ្ចក់ឆ្លុះជីវភាពនៅសម័យនោះ ។ ស្នាដៃទាំងពីរនេះ មានប្រយោជន៍ណាស់សំរាប់ការស្រាវជ្រាវ ខាងប្រវត្តិសាស្ត្រនិងសង្គមនៅបាត់ដំបងក្នុងសម័យមួយដែលគេហៅថា សម័យលោកម្ចាស់ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅចុងសតវត្សទី១៩ និងនៅដើមសតវត្សទី២០ ប្រជារាស្ត្រនៅបាត់ដំបងស្គាល់លោកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ នេះណាស់ ។ គ្រប់គ្នាហៅគាត់ថាអាចារ្យឥន្ទ ។ អ្នកបាត់ដំបងទាំងអស់សុទ្ធតែសរសើរស្នាដៃនិងសំនួនវោហាររបស់គាត់គ្រប់គ្នា ។ នៅពេលដែលខ្មែរយើងមិនទាន់មានសៀវភៅបោះពុម្ព អ្នកបាត់ដំបងនាំគ្នាខ្ចីសៀវភៅ ដែលជាស្នាដៃរបស់គាត់យកមកចំលងទុកចែកគ្នាអានបន្តពីមួយទៅមួយ ហើយមានអ្នកខ្លះទន្ទេញកំណាព្យគាត់ទាំងទំព័រៗចាំរត់មាត់ ។

លោកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ ជាកិត្តិយសធំណាស់សំរាប់ខេត្តបាត់ដំបងនៅសម័យ ដែលខេត្តនេះនៅក្រោមអំណាចសៀមអស់ពេលជាងមួយសតវត្ស ។ គាត់ជាភស្តុតាងបញ្ជាក់ថាសៀមអាចជ្រៀតជ្រែកបានតែក្នុងវិស័យរដ្ឋបាលប៉ុណ្ណោះ តែមិនអាចជ្រៀតជ្រែកចូលក្នុងផ្នត់គំនិតខ្មែរនៅបាត់ដំបងដែលជាខ្មែរនោះទេ ។

ក្នុងវិស័យអក្សរសាស្ត្រនេះទៀត ព្រះវិន័យធរអនុគណ ស្រីពេជ វត្តបាឡាត់បានមានថេរដីការបន្ថែមថា ចាស់ៗបាននិយាយតៗថានៅសម័យនោះ មានតាហោរម្នាក់ឈ្មោះ ឈឹម ដែលជាអ្នកភូមិផងរបងជាមួយ និងជាមិត្តស្និទ្ធស្នាលរបស់លោកឧកញ៉ាសុត្តន្តប្រីជាឥន្ទ ក៏មានសំនួនវោហារខាងកាព្យឃ្លោងម្នាក់ដែរ ។ តាឈឹម

www.budinst.gov.kh www.elibraryofcambodia.org

នេះតែងប្រឹក្សាចោទឆ្លើយជាមួយលោកសុត្តន្តប្រីជា ឥន្ទ ញឹកញាប់ ។ គេថាលោកតាឈឹមនេះបាននិពន្ធរឿងមួយឈ្មោះ រឿង *នាងឆន្ទា* ដែលប្រែមកពីគម្ពីរសៀមហើយចងជាបទព្រហ្មគីតិ ជាភាសាខ្មែរ ។ រឿងនាងឆន្ទានេះនិទានពីស្រីឆ្នាស់ម្នាក់មានប្ដីជាពោធិសត្វ ។ ក៏ប៉ុន្តែលោកតា ឥន្ទ សុន្ទរ៍ ដែលជាកូនរបស់លោកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ បានឆ្លើយថាគាត់ស្គាល់លោកតាឈឹមនេះហើយនិងធ្លាប់បានឃើញសាស្ត្រារឿងនាងឆន្ទានេះដែរតែគាត់មិនបានដឹងទេ ថាលោកតាឈឹមតែងកំណាព្យរឿងនាងឆន្ទានេះ ។

ក្រៅពីនេះ ព្រះគ្រូសាសនភិរ័ត កែ ម៉ូ វត្តស្វាយភីបានមានថេរដិការដែរថា នៅមុនលោកឧកញ៉ាសុត្តន្តប្រីជាឥន្ទនេះច្រើនឆ្នាំទៅទៀត នៅវត្តស្វាយភី មានព្រះសង្ឃមួយអង្គព្រះនាមកុយ ។ អ្នកស្រុកតែងហៅលោកគ្រូ កុយ ថាលោកគ្រូឃឹត ព្រោះលោកនិមន្តទៅណាមិនស្ងួវទាន់ពេលវេលាដូចគេទេ ។ លោកគ្រូឃឹត ពូកែខាងកំណាព្យកាព្យឃ្លោងណាស់ ។ គ្រាន់តែក្រឡេកឃើញពពិចនៅចុងឫស្សីលោកក៏តែងជាកំណាព្យសូត្រប្រាប់គេឯងក្នុងពេលនោះភ្លាម ។ តែគួរឲ្យស្ដាយ គេមិនមានសល់ឯកសារសរសេរ ដែលជាស្នាដៃលោកគ្រូឃឹតនេះទេ ។ ក៏ប៉ុន្តែកូនសិស្សកូនគណ នៅវត្តស្វាយភីបានទន្ទេញចាំមាត់កំណាព្យខ្លីៗរបស់លោកគ្រូឃឹតនេះច្រើនគ្នា ។ ព្រះ

www.budinst.gov.kh www.elibraryofcambodia.org



ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ(ឥ:ស)



សម្តេចចៅ ហាស ថោង វត្តសួរភិ (ក.ម)

www.budinst.gov.kh www.elibraryofcambodia.org

គ្រូសាសនភីរីត កែ ម៉ូ ក៏បានសូត្រកំណាព្យវត្តខ្លះរបស់ លោកគ្រូ យីតនេះតែវត្តដែលសំខាន់ជាងគេពិពណ៌នាអំពីវត្តទាំងប៉ុន្មានដែល មាននៅសម័យនោះ ។ វត្តកំណាព្យនេះនឹងមានចុះនៅខាងផ្នែក ដែលនិយាយអំពីពុទ្ធសាសនា ។

យើងគួររំលឹកទៀតដែរថា លោក *តង់ដារ* ដែលជាបេសក សង្ឃកាតូលិក ដែលមកតាំងនៅបាត់ដំបងពីឆ្នាំ ១៩០១ ដល់ ១៩០៤ ក៏បានយកចិត្តទុកដាក់និងអក្សរសាស្ត្រខ្មែរណាស់ដែរ ។ លោកបានទៅប្រឹក្សារៀនសូត្រជាមួយលោកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ ហើយបានចងក្រងវចនានុក្រមខ្មែរ-បារាំងមួយឈ្មោះថា *វចនានុក្រមតង់ដារ* ដែលជាស្នាដៃដ៏សំខាន់មួយពិបាករកជាទីបំផុត ។ ដូច្នេះ លោកសុត្តន្តប្រីជា ឥន្ទ ក៏បានចូលរួមក្នុងការចងក្រង វចនានុក្រមតង់ដារនេះដែរ ។

## ២- *ការសិក្សាអប់រំ*

នៅសម័យលោកម្ចាស់ ខ្មែរនាំគ្នារៀនអក្សរនិងភាសាជាតិ នៅតាមវត្តអារាមនានា ។ ព្រះសង្ឃដែលស្រឡាញ់អក្សរនិងភាសា ជាតិបានខិតខំបង្រៀនកូនចៅ ដោយយកចិត្តទុកដាក់និងឥតយក កំរៃជាគុណប្រយោជន៍ផ្ទាល់ខ្លួនឡើយ ។ នៅតាមវត្តខ្លះ ឬតាម ផ្ទះគ្រូអាចារ្យខ្លះមានបង្រៀនរហូតដល់គម្ពីរព្រះត្រៃបិដក ។

www.budinst.gov.kh www.elibraryofcambodia.org

នៅតាមវត្តអារាម កូនសិស្សក្មេង រៀនធម៌អាថ៌ខាងព្រះពុទ្ធ-សាសនាផង រៀនអក្សរខ្មែរផង ។ ព្រះសង្ឃបង្រៀនដោយឥតកម្មវិធីអ្វីទេ សិស្សណាមកដល់មុន បង្រៀនមុន សិស្សណាចូលក្រោយ បង្រៀនតាមក្រោយ ។ កូនសិស្សសរសេរលើក្តារមួយបន្ទះវែងហៅថាក្តារឈ្នួន លុះត្រាតែចេះបំបែក ផ្ទើផើង ប្រកបរួចទើបអានសាស្ត្រា ។ មុនដំបូង លោកគ្រូឲ្យអានសាស្ត្រាដែលតែងជាកំណាព្យ ដែលគេហៅថា*សាស្ត្រល្បែង* រួចទើបអានសាស្ត្រាសំរាយដែលប្រែមកពីគម្ពីរផ្សេងៗ ដែលគេហៅថា *សាស្ត្រាទេសន៍* ។ នៅពេលនេះ គេចាត់ទុកសិស្សថា ចេះដឹងគួរសមត្រូវបួសរៀនគម្ពីរព្រះត្រៃបិដក ។ បើកាលណារៀនចប់ហើយ សិស្សដែលធម្មតាជាព្រះសង្ឃអាចទៅបន្តការសិក្សានៅបាងកកបាន ។

ក្នុងការរៀនគម្ពីរព្រះត្រៃបិដកនេះ សាមណសិស្សរៀនតពីគ្រូដោយផ្ទាល់ ដោយអង្គុយបត់ជើងផ្ទាល់រនាបទល់មុខគ្រូ ដោយគ្មានតុកៅអីទេ ។ គេប្រើជើងអាធារសំរាប់តំកល់គម្ពីរ ។

នៅពេលចុងក្រោយ គេឃើញរាជការសៀមចូលមកបើកសាលារៀនបង្រៀនភាសាសៀមនៅបាត់ដំបង ប្រហែលក្នុងបំណងធ្វើឲ្យខ្មែរបាត់ដំបងក្លាយជាសៀម ផុតពីសិទ្ធិការពាររបស់ក្រុងប៉ារីសបារាំង ។

www.budinst.gov.kh www.elibraryofcambodia.org

លោកតា ហ៊ិន ជា អាចារ្យវត្តគរ បានសិក្សាអក្សរសៀម នៅវត្តពិភិទ្ធ ហើយបានទៅបន្តការសិក្សានៅប្រទេសសៀមនាក្រុងបាងកក ។ គាត់បានទៅសំណាក់នៅផ្ទះលោកម្ចាស់ ដែលសាងទុកឯបាងកក នៅតំបន់មួយហៅ យ៉ុតសេ ។ គាត់បានត្រឡប់មកស្រុកវិញ នៅឆ្នាំ ១៩០៧ដោយមិនទាន់ទាំងបានចូលរៀនផង ព្រោះស្រុកត្រូវភាន់ប្រែដោយខេត្តបាត់ដំបងបានមកខ្មែរ ។ គាត់បារម្ភក្រែងឪពុកម្ដាយរងទុក្ខវេទនាដោយបារាំងធ្វើបាបព្រោះតែគាត់នៅស្រុកសៀម ។ គាត់ធ្វើដំណើរត្រឡប់មកបាត់ដំបងវិញជាមួយមិត្តភក្តិ តាមកប៉ាល់កាត់ឈូងសមុទ្រសៀមមកដល់ព្រៃនគរ ហើយឡើងតាមទន្លេមេគង្គ ទន្លេសាបរហូតដល់បាត់ដំបង ។ លោកតា ហ៊ិន ជា បានផ្តល់ពត៌មានច្បាស់លាស់អំពីការសិក្សាក្នុងសាលារាជការសម័យលោកម្ចាស់ ។

រដ្ឋាភិបាលសៀមបានឧបត្ថម្ភខេត្តបាត់ដំបងឲ្យមានសាលារៀនបីកន្លែង គឺនៅវត្តពិភិទ្ធ១ នៅវត្តសង្កែ ១ នៅវត្តកំផែង១ ។ ក្នុងសាលារៀននីមួយៗមានសិស្សប្រមាណជាង ៥០នាក់ ដែលក្នុងនោះមានសិស្សស្រីប្រហែល១ភាគបីដែរ ។ សាលារៀននីមួយៗចែកជា ៣ថ្នាក់តាមលំដាប់ពីទាបទៅខ្ពស់ហៅ ថ្នាក់ទី១ ថ្នាក់ទី២ ថ្នាក់ទី៣ ។

www.budinst.gov.kh www.elibraryofcambodia.org

- សាលារៀននៅវត្តពិភិទ្ធ តាំងនៅត្រង់សាលាឧបោសថសព្វថ្ងៃដែលគេគ្រាន់តែកែបន្តិចបន្តួច ។ សាលារៀននេះមានឈ្មោះថា រោងរៀនកថាថនធរណិន្ទ្រ មានគ្រូតែម្នាក់ទេ ជាជាតិសៀម ដំបូងឈ្មោះ គ្រូខិម ក្រោយមកគ្រូខិមត្រូវផ្លាស់ចេញ ។ លោកគ្រូ កែវ មកជំនួស ។

- សាលារៀននៅវត្តសង្កែ មានឈ្មោះថា រោងរៀនឥន្ទ្រាធិបតី មានខ្មែរម្នាក់ដែលចេះសៀមច្បាស់លាស់ឈ្មោះលោកគ្រូ ស៊ុំ ជាអ្នកបង្រៀន ។

- សាលារៀននៅវត្តកំផែងមានឈ្មោះថា រោងរៀនអភ័យភេរី ។ តែក្រោយមក គេលើកសាលារៀននេះទៅតាំងនៅវត្តសំពៅវិញដោយមិនដឹងហេតុប្រាកដ ។ ដើមឡើយ មានព្រះសង្ឃខ្មែរមួយអង្គ ដែលចេះសៀមច្បាស់ ព្រះនាមលោកគ្រូ ចេត ជាអ្នកបង្រៀន ។ តែក្រោយមក លោកគ្រូចេតលាចាកសិក្ខាបទទៅ គ្រូសៀមឈ្មោះ គ្រូអន មកបង្រៀនតទៅទៀត ។

ដោយសាលារៀននីមួយៗមានគ្រូតែម្នាក់ ហើយគ្រូត្រូវបង្រៀនបីថ្នាក់នោះ លោកគ្រូត្រូវដាក់វេនឲ្យសិស្សថ្នាក់ខ្ពស់ទៅជួយបង្រៀនសិស្សដែលទើបនឹងចូលរៀន ។ គេរៀនតែអក្សរសាស្ត្រនិងលេខចំណោទប៉ុណ្ណោះ គេមិនរៀនវិទ្យាសាស្ត្រទេ ។ មុន

www.budinst.gov.kh www.elibraryofcambodia.org

នឹងចាប់ផ្ដើមរៀន សិស្សត្រូវសូត្រធម៌ថ្វាយបង្គំព្រះសិន ។ គេក៏មានហាត់កាយសិក្សា តំរៀបជួរមុនពេលចូលថ្នាក់ ។ លោកតាហ៊ិនជាបានប្រាប់ទៀតថា នៅពេលនោះ គេអប់រំសិស្សឲ្យមានសុជីវធម៌ល្អណាស់ សិស្សមិនដែលហៅគ្នាអា-ម៉ឹងទេ ហើយចេះគោរពចាស់ទុំ ។

រាល់ៗឆ្នាំ មានព្រះសង្ឃមួយអង្គ មានឋានៈជា *ចៅឃុនឧត្តរថានុរក្ស* មកពីបាងកក មកត្រួតមើលការសិក្សា នៅបាត់ដំបង ហើយចាត់ចែងប្រឡងផ្សេងៗ ។ លុះរៀនចប់សាលានៅបាត់ដំបងហើយ គេចេញសញ្ញាប័ត្រឲ្យដោយមានសិទ្ធិទៅបន្តការសិក្សារនៅបាងកក ។ សិស្សណារៀនចប់ថ្នាក់បឋមសិក្សាមុនអាយុ ១៥ឆ្នាំអាចទៅបន្តការសិក្សានៅបរទេស ជាពិសេសនៅទ្វីបអឺរ៉ុប ។ ក្នុងការបង្រៀននេះលោកគ្រូម្នាក់បានទទួលបៀវត្សពីរាជការ គឺពីលោកម្ចាស់ ជាប្រាក់ជាង ២០បាតក្នុងមួយខែ ។ រាជការឧបត្ថម្ភសិស្សជាសម្ភារៈតិចតួចដូចជា ដីស សៀវភៅមើលជាដើម ។ នៅពេលនោះសៀវភៅមើលមួយថ្លៃ ៤កាក់ ឯសៀវភៅសរសេរមួយថ្លៃ១កាក់ ។ ដើម្បីងាយយល់តំលៃប្រាក់ខែលោកគ្រូនិងសម្ភារៈសិស្សនៅពេលនោះ សូមបញ្ជាក់ថា ២០ បាតអាចទិញបានមាន់ ៨០ ហើយមួយកាក់អាចទិញបានសាច់ជ្រូក១នាឡិ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅពេលមានបុណ្យផ្លូវការម្តងៗ គេកេណ្ឌសិស្សឲ្យទៅសូត្របទរបៀបសូត្រ ដែលមានប្រគុំភ្លេងពិណពាទ្យកំដរ ។ ក្នុងចំណោមបទដែលសូត្រនោះមានបទមួយសំខាន់ជាងគេ គឺបទសាន់សឺនផ្រះបារមី ជាបទសរសើរព្រះបារមីព្រះចៅសៀម ។ បទសាន់សឺនផ្រះបារមីនេះមានសូត្ររហូតដល់សព្វថ្ងៃ នៅប្រទេសសៀម ។ ក្នុងការទៅសូត្របទនេះ សិស្សត្រូវមានឯកសណ្ឋានសំពត់ចងក្បិន អាវកត្រង់ ស្បែកជើងស្រោមជើង ។ សិស្សទិញឯកសណ្ឋាននេះខ្លួនឯង ។

លោកតា ញ៉ី ហួត នៅកំពង់ឆ្លង បានឆ្លើយថា គាត់មិនបានទៅរៀននឹងគេទេ ព្រោះឪពុកម្តាយគាត់ក្រ គ្មានលុយទិញស្បែកជើងស្រោមជើង ហើយគាត់ក៏មិនចង់រៀនអក្សរសៀមផង ។

### ៣- សាសនា

### *ក- ព្រះពុទ្ធសាសនា*

វចនានុក្រម ឡឺពើទីឡារូស ឆ្នាំ១៩៦៩ ត្រង់ទំព័រ ១១៦៥បានឲ្យកិត្តិយសខេត្តបាត់ដំបងថាជា "*មជ្ឈមណ្ឌលព្រះពុទ្ធសាសនា* "។ ពិតមែនហើយ ក្រុងបាត់ដំបងត្រូវតែមានកិត្តិយសជាមជ្ឈមណ្ឌលព្រះពុទ្ធសាសនាមែន ព្រោះក្រុងបាត់ដំបងមានវត្តអារាមច្រើនដែលជាកេរ្តិ៍ដំណែលតាំងពីបុរាណមក ។ វត្តអារាមខ្លះមានតំលៃណាស់

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងវិស័យសិល្បៈដូចជាវត្តកណ្ដឹង វត្តសង្កែ វត្តដំរីស វត្តពោធិវាល វត្តពិភិទ្ធ វត្តក្ដុល ។ល។ កិត្តិយសក្រុងបាត់ដំបងដែលថាជាមជ្ឈមណ្ឌលពុទ្ធសាសនានេះ គឺជាកេរ្ដិ៍ដំណែលតាំងពីបុរាណមក ព្រោះវត្តអារាមទាំងប៉ុន្មាន ដែលយើងឃើញសព្វថ្ងៃនេះសុទ្ធតែមានកំណើតតាំងពីមុនលោកម្ចាស់កថា ឈុំ សឹងតែទាំងអស់ ។ ព្រះឧត្តមព្រឹទ្ធាចារ្យ អ៊ុំ .សុខ វត្តតាមិមបានមានថេរដិការថា តាំងពីលោកដឹងក្ដីឡើងកាលណា លោកមិនដែលឃើញគេកសាងវត្តថ្មីទេ ។ លក្ខណៈប្លែកពីសម័យនោះមកសម័យនេះ គឺវត្តខ្លះធ្លាប់ថ្កុំថ្កើង ដូចជាវត្តកណ្ដាល វត្តសង្កែ វត្តដំរីស ឯវត្តខ្លះទៀត មានលក្ខណៈមិនទាន់សមរម្យ ។ ឯវត្តដែលកើតមុនគេ នៅបាត់ដំបងប្រហែលជា *វត្តកំពង់អំពិលនិងវត្តកណ្ដឹង* ។

ព្រះគ្រូសាសនភិរត កែ ម៉ូ វត្តសូរភីបានរំលឹកពីសំនួនវោហារកាព្យឃ្លោងរបស់លោកគ្រូ ឃីត ដែលជាអតីតចៅអធិការវត្តសូរភីតាំងពីយូរ មុនលោកឧញ៉ាសុត្តន្តប្រីជា ឥន្ទ ទៅទៀតស្ដីពីវត្តនានា ដែលមាននៅតាមដងស្ទឹងសង្កែជំនាន់លោក ។ បើយកតាមកំណាព្យនេះ យើងនឹងអាចវែកញែកឃើញវត្តថ្មីនិងវត្តចាស់ ដែលមាននៅសម័យនោះ ។ តែទោះជាថាវត្តនោះទើបកសាងថ្មីក៏មិនមែនថ្មីនៅជំនាន់ក្រោយលោកម្ចាស់ដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯកំណាព្យរបស់លោកគ្រូឃ្មុំត មានដូតទៅ ÷

*«សតិតាំងដើម*

*ឯវត្តកំពង់ អំពិលហើយត្រង់ តំរង់វត្តខ្វែង តាមិមតាអាត់ កណ្ដឹងហើយវត្ត សំពៅកំផែង ដំរីសលែង វត្តកណ្ដាលឯង សែទៅសែមក [1]។ ឯវត្តពិភិទ្ធ ទន្ទឹមគ្នាពិត ទៀបនិងវត្តពោធិ រីឯវត្តលៀប ទៀបនិងវត្តសុ បុរមនោ វត្តបាឡាត់ផង ឯវត្តនរា ចុះតាមគង្គា ដល់វត្តគុលឆ្លង ត្រឡប់ទៅកោះ កកែងកកោង ដល់វត្តសំរោង វត្តព្នៅវត្តកែវ ។»* ព្រះគ្រូសាសនភិវ័ត កែម្ង៉ បានមានថេរដិការថែមទៀតថា កំណាព្យនេះ នៅខ្វះវត្តពីរ គឺវត្តឯកភ្នំ និងវត្តមួយទៀតនៅតាមដងស្ទឹងសង្កែទៅក្រោម គឺវត្តស្ដីសំបួរមាស ។

បើស្ដាប់តាមកំណាព្យនេះ យើងឃើញថា នៅសម័យលោកគ្រូឃីត នៅតាមដងស្ទឹងសង្កែ មានវត្តប្រហែលតែ ២០ប៉ុណ្ណោះ គឺវត្តកំពង់អំពិល វត្តខ្វែង វត្តតាមិម វត្តកណ្ដឹង វត្តសំពៅ វត្តកំផែង វត្តដំរីស វត្តកណ្ដាល វត្តសង្កែ វត្តពិភិទ្ធ វត្តពោធិ វត្តលៀប វត្តសូរភី វត្តរំដួល វត្តបាឡាត់ វត្តនរា វត្តគុល វត្តសំរោង វត្តព្នៅ

---

[1]បើតាមព្រះគ្រូសាសនាភិវ័ត កែម្ង៉ ថា ពាក្យសែទៅសែមក បានសេចក្ដីថា វត្តសង្កែ ពាក្យថា វត្តសូរ គឺវត្តសូរភី ពាក្យថាបរមនោ គឺវត្តរំដួល ។

www.budinst.gov.kh www.elibraryofcambodia.org



វត្តសង្កែ (អ.ត)



វត្តគគ្គល (គ.ច)

www.budinst.gov.kh www.elibraryofcambodia.org

វត្តកែវ ថែមវត្តឯកភ្នំ និងវត្តស្ពឺសំបូរមាស ។ លោកតា ហ៊ិន ជាអាចារ្យវត្តគរ បានប្រាប់ថា វត្តគរមានកំណើតយូរយារហើយមុនវត្តសំពៅទៅទៀត តែយើងមិនឃើញឈ្មោះវត្តគរក្នុងកំណាព្យខាងលើនេះទេ ដោយមិនដឹងហេតុអ្វី ។

ព្រះវិហារបុរាណដែលនៅសល់ពីសម័យលោកម្ចាស់ មកដល់សព្វថ្ងៃមាន ព្រះវិហារវត្តកណ្ដឹង វត្តសង្កែនិង វត្តដំរីស ។ វត្តកណ្ដឹងមានព្រះវិហារពីរ ព្រះវិហារខាងជើងស្លាបនាយូរយារហើយ ឯព្រះវិហារខាងត្បូង ស្លាបនាដោយលោកស្រីអ៊ីង ប្រពន្ធធំរបស់លោកម្ចាស់ ។

វត្តសង្កែជាវត្តធំជាងគេ ជាវត្តរបស់សម្ដេចចៅ គឺវត្តព្រះមេគណ ជាវត្តដែលលោកម្ចាស់ទៅធ្វើបុណ្យ ជាពិសេសបុណ្យសែឃិតដែលជាបុណ្យផ្លូវការ ។

លោកម្ចាស់បានចាត់ឲ្យសាងព្រះវិហារវត្តដំរីស បុន្មានឆ្នាំមុនដែលលោកទៅបស្ចិម ។

វត្តគុលជាវត្តបុរាណ មានកំណើតនៅសម័យនោះដែរ ។ កាលដើមឡើយ វត្តនេះជាទីតាំងបន្ទាយរបស់ចៅពញា បឌិន ។ តែក្រោយមក គេបានឧទ្ទិសដីនេះថ្វាយព្រះពុទ្ធសាសនា ដើម្បីសាងវត្តអារាមមួយដាក់ឈ្មោះថា *"វត្តប្រាបប្រាមបច្ចាមិត្រ"* ។ គេសង្កេត

www.budinst.gov.kh www.elibraryofcambodia.org

ឃើញ មាននៅសល់ចេតិយ ខាងក្រោយព្រះវិហារ ក្នុងលក្ខណៈ រចនាបថទចំខ្មែរ ប្លែកខុសពីវត្តនានា នៅក្នុងខេត្ត ។

ក្នុងសម័យលោកម្ចាស់ វត្តអារាមទាំងប៉ុន្មានត្រូវដាក់នៅក្រោមបង្គាប់ព្រះសង្ឃមួយអង្គទីជារាជាគណៈ ដែលរាស្ត្រសាមញ្ញហៅថា "*សម្តេចចៅ*"។ បន្ទាប់ពីសម្តេចចៅ មិនមានអនុគណដូចសព្វថ្ងៃទេ គឺមានតែព្រះឧបជ្ឈាយ៍ ។ សម្តេចចៅ និងព្រះឧបជ្ឈាយ៍ ក៏មិនមាននាទីដូចមេគណ និងអនុគណសព្វថ្ងៃដែរ ព្រោះពេលនោះ មិនសូវមានការចាត់ចែងខាងរដ្ឋបាល ។ សម្តេចចៅ ដែលជាមេគណ គង់នៅវត្តសង្កែមានព្រះនាម *ទៀង* ។ លោកមានជំងឺចាងស្បែកទើបពុទ្ធសាសនិកជនហៅថា *សម្តេចចៅចាង* ។ ក្រោយមកទៀតឋានៈសម្តេចចៅ ត្រូវបានទៅព្រះគ្រូព្រះនាម ហាស ថោង គង់នៅវត្តសូរភី ។ រីឯព្រះឧបជ្ឈាយ៍វិញមាននៅវត្តសំពៅនិងវត្តកែវ ។ ព្រះគ្រូឧបជ្ឈាយ៍ដែលគង់នៅវត្តសំពៅមានព្រះនាម យស ។ នៅវត្តកែវ ដំបូងព្រះឧបជ្ឈាយ៍ មានព្រះនាម គង់ តែក្រោយដែលលោកសុគតទៅនោះ លោកកថាថន ឃុំបានបញ្ញត្តិឲ្យពុទ្ធសាសនិកជនទាំងអស់ហៅថា "*លោកគ្រូព្រះគោដ្ឋ*"។ នៅវត្តកែវដដែល ព្រះគ្រូមួយអង្គទៀតព្រះនាម ណិប ក៏ឡើងទទួលទីជាព្រះឧបជ្ឈាយ៍បន្តពីលោកគ្រូព្រះគោដ្ឋទៀត ។

www.budinst.gov.kh www.elibraryofcambodia.org





វត្តកណ្ដឹង (អ.ត)

www.budinst.gov.kh www.elibraryofcambodia.org

នៅពេលសុគត សពសម្តេចចៅនិងព្រះឧបជ្ឈាយ៍ត្រូវគេតំកល់ក្នុងកោដ្ឋធ្វើបុណ្យទក្ខិណានុប្បទាន ។

សូមបញ្ជាក់ថា នៅក្រោយឆ្នាំ ១៩០៧ ដែលសៀមប្រគល់ខេត្តបាត់ដំបងមកឲ្យខ្មែរវិញនោះ រាជការភ្នំពេញបានតែងតាំងសម្តេចចៅព្រះនាម ថោង ជាព្រះធម្មចរិយាព្រិទ្ធ ឯព្រះឧបជ្ឈាយ៍ព្រះនាម ណិប ជាព្រះគ្រូធម្មានុសិទ្ធិសាទរ ។

យើងមិនបាច់ធ្វើអត្ថាធិប្បាយអំពីព្រះពុទ្ធសាសនានេះ ឲ្យវែងទេព្រោះមិនសូវខុសពីសព្វថ្ងៃប៉ុន្មាន ។ យើងលើកយកតែលក្ខណៈដែលប្លែកមកកត់ទុកជាចំណាំទៅពេលក្រោយ ។

លោកម្ចាស់តែងបរិច្ចាគទ្រព្យសម្បត្តិ ប្រគេនជាបៀវត្សសំរាប់ព្រះសង្ឃគ្រប់វត្តទាំងអស់ក្នុងខេត្ត ។ ព្រះឧត្តមព្រឹទ្ធាចារ្យ អ៊ុំ សុខវត្តតាមិម កាលលោកនៅជាសាមណេរ លោកធ្លាប់ចូលក្នុងកំផែងជាមួយលោកគ្រូលោក ទៅបើកបៀវវត្ស ដែល លោកម្ចាស់ប្រគេនដល់វត្តនីមួយៗ តែលោកមិនចាំទេថា ប្រាក់ដែលគេប្រគេនទៅវត្តនីមួយៗនោះប៉ុន្មាន ។ ព្រះឧត្តមព្រឹទ្ធាចារ្យមានថេរដីការថែមទៀតថា នៅសម័យដើម គេមិនដែលធ្វើបុណ្យផ្កាប្រាក់ទេ ។ ឯបុណ្យដទៃទៀតមានដូចសព្វថ្ងៃតែមានទំលាប់ខ្លះដែលសព្វថ្ងៃគេបោះបង់ចោល ។ ព្រះសង្ឃជំនាន់ដើម មុនឆាន់ ត្រូវលើកព្រះហស្ត

www.budinst.gov.kh www.elibraryofcambodia.org

ប្រណាម្យហើយសូត្រធម៌សិន ។ តែសព្វថ្ងៃ លោកសង្ឃឈប់លើក ព្រះហស្តសំពះ សូត្រធម៌ទៀតហើយ ព្រោះមានពាក្យគេរិះគន់ ។

លក្ខណៈខុសប្លែកមួយទៀតគឺសាមណេរ ។ សាមណេរមិន មានចីពរទេ មានតែស្បង់ អង្ស័គ និងសំពត់ពានាពណ៌លឿង ។ គេមិនបំបួសលោកនេននៅក្នុងវិហារទេ គេបំបួសតែតាមកុដិ ។ ពេលបិណ្ឌបាត ភិក្ខុមានយោគសំរាប់ស្ពាយបាត ឯលោកនេនកាន់ បាតផ្ទាល់ដៃ ដូចព្រះសង្ឃខាងគណៈធម្មយុត្តិសព្វថ្ងៃ ។ លោកនេន មិនឆាន់នៅពេលជាមួយលោកភិក្ខុទេ តែយកចង្ហាន់ដែលសល់ពី លោកភិក្ខុមកឆាន់ ។ លោកនេនឆាន់រួមថាសជាមួយក្មេងៗដែល ជាកូនសិស្សលោក តែមានបញ្ញត្តិមួយ ឲ្យលោកនេនឆាន់បីម៉ាត់ មុនកូនសិស្ស ។

សូមបញ្ជាក់ទៀតថា នៅសម័យនោះមិនទាន់មានពុទ្ធសាសនា ខាងគណៈធម្មយុត្តិនៅឡើយទេ ។

## ខ- សាសនាកាតូលិក

គ្រិស្តសាសនាបានចូលមកតាំងនៅបាត់ដំបងតាំងពីឆ្នាំ ១៧៩០ គឺតាំងពីមុនពេលដែលចៅហ្វាបែន មកធ្វើស្តេចត្រាញ់នៅបាត់ដំបង ទៅទៀត ដោយមានលោកសង្ឃកាតុលិកនាម សង់ អា សេស៊ិយ

www.budinst.gov.kh www.elibraryofcambodia.org

មកតាំងនៅត្រង់ភូមិថ្មលប្រាំបីជុំ ។

លោកតាឥន្ទ សុន្ទរ៍ នៅភូមិជ្វាធំ បានប្រាប់ថា "ដំបូងមានតែជនជាតិយួនទេ ដែលចុះចូលនឹងសាសនាគ្រិស្តនេះ ។ តែក្រោយមកមានជនជាតិខ្មែរបានចុះចូលដែរ ភាគច្រើនជាអ្នកទីទាល់ក្រ ជាពិសេសពួកទាសករ ។ អ្នកផ្សាយសាសនាបានប្រើកម្មវិធីសង្គ្រោះជនក្រីក្រលំបាកវេទនា ក្មេងកំព្រា និងមនុស្សចាស់ជរាពិការ ដោយចាយលុយច្រើនណាស់ ដើម្បីលោះទាសករណាដែលមាន បំណងចុះចូលសាសនាគ្រិស្តឲ្យមានសេរីភាព ដើម្បីទិញដីស្រែជាច្រើនចែកដល់អ្នកចុះចូលថ្មីប្រកបរបរចិញ្ចឹមជីវិត ។ លោកតា ឥន្ទ សុន្ទរ៍ បានប្រាប់ទៀតថា វិហារកាតូលិកសព្វថ្ងៃនេះស្ថាបនាមុនឆ្នាំ ១៩០៧ ឆ្ងាយណាស់ ។ អ្នកស្រុកហៅ ព្រះសង្ឃកាតូលិកថា ប៉ាទ្រី ។ ប៉ាទ្រី ដែលគាត់ស្គាល់គឺលោក ប៉ែណា តង់ដារ និង សាំបែរ ។ គាត់ស្គាល់ប៉ាទ្រី ឈ្មោះ តង់ដារ ច្បាស់ជាងគេ ព្រោះប៉ាទ្រីតង់ដារ នេះមកសិក្សាអក្សរខ្មែរជាមួយឪពុកគាត់ គឺ លោកឧកញ៉ាសុតន្ត ប្រីជា ឥន្ទ ។"

សៀវភៅ *អ៊ីសតួរដឺឡាមីស្យ៊ុង អូ កាំបូដ* របស់ព្រះសង្ឃកាតូលិកឈ្មោះ វ៉ាំងសង់ រ៉ុលឡាំង បោះផ្សាយនៅពេលបុណ្យប៉ាក ១៩៦៨មានចែងអំពីប្រវត្តិនិងសកម្មភាពរបស់គ្រិស្តសាសនានៅបាត់

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំង ទី ២៣



វិហារកាតូលិក ស្ថាបនានៅចុងសតវត្សទី ១៩ (អ.គ)

www.budinst.gov.kh www.elibraryofcambodia.org

ដំបង (ត្រង់ទំព័រ ១៩) ដូចតទៅ ៖

"លោកកឌីយេ បានមកដល់បាត់ដំបងនៅឆ្នាំ ១៨៤៩ ហើយរស់នៅទីនោះ ២ ឬ ៣ឆ្នាំ ។ លោកប៊ូយើរ៍បានចូលមកដល់ទៀតនៅឆ្នាំ ១៨៥២ ។ លោកស៊ីលវែស បានមករស់នៅទីនេះ ១២ឆ្នាំពីឆ្នាំ១៨៥៤ ដល់ ១៨៦៦ ។ ចាប់ពីឆ្នាំ ១៨៦៦ ព្រះវិហារគ្រិស្តសាសនាមិនមានព្រះសង្ឃគង់នៅទេ តែរាល់ឆ្នាំ លោកកឌីយេបេសកសង្ឃនៅបាណាមបានមកធ្វើទស្សកិច្ចរហូតដល់ឆ្នាំ ១៨៧៤ ។ ចាប់ពីពេលនោះរហូតដល់ឆ្នាំ១៨៨៤ មានបេសកសង្ឃនៅសុមបៀនឈ្មោះលោក មីស្នែរ មកធ្វើទស្សនកិច្ចរាល់ឆ្នាំ ។ ចាប់ពីឆ្នាំ១៨៨៤ទើបមានព្រះសង្ឃគង់នៅជាប់លាប់ ដូចជាលោកស្ទូរីប៊ីរ (១៨៨៤-១៨៩១) លោក ប៉ែរ៉ា (១៨៩២-១៩០១) លោកតង់ដារ (១៩០១-១៩០៤) លោកប៉ែណា (១៩០៤-១៩០៦) លោក ស៊ុ (១៩០៦-១៩០៧) លោកសាំប៉ែរ (១៩០៧ ...)។ គ្រិស្តសាសនាមានសាសនិកជន ៤១៣នាក់ជាអ្នកស្រុកអាយ និង៥០នាក់ជាជនជាតិអឺរ៉ុប ។ ចាប់ពីឆ្នាំ ១៩០៤ គ្រិស្តសាសនាបានបើកមន្ទីរពេទ្យតូចមួយនិងមន្ទីររក្សាក្មេងកំព្រាមួយទៀត ដោយមានដូនជីបារាំងពីរនាក់ និងដូនជីអ្នកស្រុកអាយ ៤នាក់ ជាអ្នកកាន់កាប់ ។"

តាមប្រភពដដែល គ្រិស្តសាសនាបានទៅតាំងនៅខ្សាច់ពោយ

www.budinst.gov.kh www.elibraryofcambodia.org

មួយកន្លែងទៀតនៅឆ្នាំ ១៨៨២ ដោយមានលោក មីស្ទែរ ជាអ្នកផ្តើមគំនិត ។

### គ- *សាសនាអ៊ីស្លាម*

សាសនាអ៊ីស្លាមបានចូលមកតាំងនៅខេត្តបាត់ដំបង រវាងមួយសតវត្សហើយៗមានមជ្ឈមណ្ឌលនៅភូមិផ្ទាធំ និងភូមិនរា នៅតាមដងស្ទឹងសង្កែ ទៅខាងក្រោមទីប្រជុំជន ។ គឺជា*សាសនាអ៊ីស្លាមនិកាយសាហ៊ីអ៊ី* ។

ព្រះហាកិម ឈាស់ហាជ្យី សុខៃឡម៉ាន់ បានប្រាប់ថាតាំងពីសម័យលោកម្ចាស់ម្ង៉ែះ សាសនាអ៊ីស្លាមមានវត្តពីរ គឺវត្តដារារាមនៅភូមិផ្ទាធំនិងវត្តនុប្បរតនបូទុមបូចន្ទ្រនៅភូមិនរា ។ តាំងពីដើមមក វត្តអ៊ីស្លាមទាំងពីរនេះប្រកាន់ធម៌មិនដូចគ្នាទេ ។ វត្តនៅភូមិផ្ទាធំប្រកាន់ធម៌ចាស់ ឯវត្តនៅភូមិនរាប្រកាន់ធម៌ថ្មី គឺធម៌ប្រែជាភាសាខ្មែរ ។

វត្តនីមួយៗ មានហាកិម ជាចៅអធិការ ។ នៅរវាងឆ្នាំ ១៩០០ វត្តនុប្បរតនបូទុមបូចន្ទ្រ មានហាកិមឈ្មោះ *តុកាឡីអាប់នុលឡស់* ។ ឯវត្តដារារាម មាន*តុប៊ី ហៅតាប៊ី* ជាហាកិម ។ តាំងពីសម័យនោះ ខ្មែរអ៊ីស្លាមនៅភូមិផ្ទាធំ មានវង់ភ្លេងមួយវង់ដែលមានស្គរយីកេច្រើនដែលគេហៅថា *រាំបាណា* ។ ឯក្រុមខាងភូមិនរា

www.budinst.gov.kh www.elibraryofcambodia.org

គេមិនពេញចិត្តវង់ភ្លេងទេ ។

ព្រះហាកិម លាស់ហាជ្ស៊ី សុខ្ស៊ែម៉ាន់ បានប្រាប់ទៀតថាលោកម្ចាស់រាប់អានខ្មែរអ៊ីស្លាមជាបងប្អូន ឥតមានធ្វើបាបសង្កត់សង្កិនអ្វីទេ ។ លោកម្ចាស់ពេញចិត្តខ្មែរអ៊ីស្លាមណាស់ ព្រោះខ្មែរអ៊ីស្លាមពូកែខាងអាគមគាថា កាប់មិនមុតបាញ់មិនឆេះ ។ លោកម្ចាស់ទុកខ្មែរអ៊ីស្លាមថាជាទ័ពក្លាហាន ជាពិសេសនៅពេលចំបាំងតាកែ ។

www.budinst.gov.kh www.elibraryofcambodia.org

# ឈោក់ឆ្មាស់

ចាប់តាំងពីរជ្ជកាលស្តេចសៀមទី៤មក ពួកអភិជនសុទ្ធតែបានដាក់នាមត្រកូល ។ ពួកកូនចៅ ចៅហ្វ៊ាបែន បានសន្មតនាមត្រកូលខ្លួនថា "*អភ័យវង្ស*" ដើម្បីរំលឹកគោរម្យងារ "អភ័យធិបេស" ដែលព្រះចៅសៀមតែងតាំងឲ្យគ្រួសារគេធ្វើស្តេចត្រាញ់ អស់ច្រើនឆ្នាំ និងច្រើនតំណ នៅបាត់ដំបង ។ ពិតមែនតែស្តេចត្រាញ់ពីរចុងក្រោយមានងារថា "កថាថន" ក៏នៅពេលក្រោយឆ្នាំ ១៩០៧ លោកឈុំ ដែលទៅនៅបស្ចិមហើយនោះ ក៏ត្រូវបានស្តេចសៀមតែងតាំងជា "*ចៅពញាអភ័យភូបេស* "អានតាមសៀមថា "ចៅផ្រះយ៉ាអផៃភូបេត"។ ក្រោយឆ្នាំ ១៩០៧ គ្រួសារ "អភ័យវង្ស"ស៊ើងតែទាំងអស់បានទៅរស់នៅស្រុកសៀម ហើយខ្លះបានទទួលតំណែងខ្ពស់ក្នុងរាជការសៀមរហូតដល់ថ្នាក់រដ្ឋមន្ត្រីផង ។

គ្រួសារអភ័យវង្សនេះជាខ្មែរសុទ្ធសាធ និយាយខ្មែរច្បាស់លាស់និងចេះអក្សរខ្មែរ ។ ចៅហ្វ៊ាបែនដែលជាបុព្វការីនៃត្រកូលអភ័យវង្សនោះ ជាខ្មែរម្នាក់មានកំណើតនៅខេត្តទ្រាំងគឺខេត្តតាកែវសព្វថ្ងៃ ។ កាលក្រោយឆ្នាំ ១៩០៧ ភ្លាមៗ គេមិនសូវឃើញពួក

www.budinst.gov.kh www.elibraryofcambodia.org

អភ័យវង្សរៀបការនិងជនជាតិសៀមទេ ។ លោកម្ចាស់ក៏មានប្រពន្ធជាខ្មែរទាំងអស់ដែរ លើកលែងតែអ្នកវ៉តមួយ ។ ពួកអភ័យវង្សមានសេសសល់នៅបាត់ដំបងខ្លះដែរតែមិននិយមដាក់ឈ្មោះត្រកូលទេព្រោះខ្លាចមានផលវិបាកខាងនយោបាយព្រោះខ្មែរយើងគ្រប់គ្នាតែងចាត់ទុកចៅហ្វាបែនថាជាជនក្បត់ ។

នៅបាត់ដំបង គេតែងហៅស្តេចត្រាញ់ដែលជាកូនចៅចៅហ្វាបែនថា **លោកម្ចាស់** ។ នៅពេលចុងក្រោយ លោកម្ចាស់មានពីរ គេហៅលោកម្ចាស់កថាថន ញ៉ុញ ថា *លោកម្ចាស់ព្រះកោដ្ឋ* ព្រោះនៅពេលអនិច្ចកម្ម គេដាក់សពលោកម្ចាស់នេះក្នុងកោដ្ឋ តាមព្រះរាជានុញ្ញាតិនៃព្រះចៅសៀម ។ ឯលោក ឈុំ ដែលបន្តអំណាចមកទៀត គេហៅថា *លោកម្ចាស់បស្ចិម* ព្រោះចាប់ពីឆ្នាំ ១៩០៧ គាត់បានទៅរស់នៅឯបស្ចិមបុរី នាប្រទេសសៀម ។

ដោយការស្រាវជ្រាវនេះ ពឹងផ្អែកលើឯកសារនិយាយភាគច្រើននោះយើងមិនអាចដឹងបានអំពីជីវប្រវត្តិរបស់ស្តេចត្រាញ់ទាំងអស់នៃត្រកូលអភ័យវង្សទេ ។ យើងអាចដឹងបានខ្លះតែរឿងលោកកថាថន ឈុំ ដែលជាស្តេចត្រាញ់ចុងក្រោយ ។

លោក ឈុំ កើតឆ្នាំរកានព្ស័ក ព.ស. ២៣៩៣ គ.ស. ១៨៤៩ នៅបាត់ដំបង ។ គាត់ជាកូនលោកកថាថន ញ៉ុញ និង

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំង ទី ២៨



លោកម្ចាស់កថាថន ឈុំ (ម.ក)

www.budinst.gov.kh www.elibraryofcambodia.org

លោកជំទាវធិម ។ គាត់មានបងប្អូនបង្កើត ឪពុកជាមួយម្តាយជាមួយចំនួនប្រាំនាក់ ។ តែដោយលោក ញ៉ុញ ជាឪពុកគាត់មានប្រពន្ធច្រើនដែរ គាត់នៅមានបងប្អូនច្រើនទៀតដែលមាន ម្តាយផ្សេងគ្នា តែលោក ឈុំ ជាកូនធំព្រោះជាកូនលោកជំទាវដែលជាប្រពន្ធធំ ។ បងប្អូនទាំង ៥នាក់របស់លោកម្ចាស់ គឺ :

- អ្នកម្ចាស់ ឃ្លិប ហៅថាម្ចាស់ ម៉ុំ "ស្រី"
- អ្នកម្ចាស់ យ៉ែម "ស្រី"
- អ្នកចៅហ្វាយ អេស "ស្រី"
- លោក ឈុំ "ប្រុស"
- លោកនាយ សំប៊ុន "ស្រី"

លោកម្ចាស់ ឈុំ ធ្លាប់បួសរៀននៅបាត់ដំបង ដោយមានព្រះគ្រូចៅអធិការវត្តបាឡាត់ ព្រះនាម ដុំ ជាព្រះឧបជ្ឈាយ៍ ។ លោកម្ចាស់ចូលចិត្តរៀនខាងប្រដាល់ គុនដាវ គុនដំបង និងរៀនមន្តវិជ្ជាការ ជាពិសេសរៀនមន្តអាគមកាប់មិនមុតបាញ់មិនឆេះ ជាមួយលោកគ្រូវត្តស្ទឹង ដែលពូកែល្បី ។ ក្រោយពីរស់នៅបាងកកអស់ពេលច្រើនឆ្នាំ លោកម្ចាស់ឈុំធ្លាប់បានធ្វើដំណើរទៅដល់ភ្នំពេញ ព្រៃនគរ សិង្ហបុរី រហូតដល់សេរីលង្កា ។

តាមពត៌មានខ្លះថា កាលលោកនៅពីក្មេង លោកធ្លាប់ទៅនៅ

www.budinst.gov.kh www.elibraryofcambodia.org

បំរើជាមហាតលិកស្តេចសៀម ។ ស្តេចសៀមបានដាក់ទណ្ឌកម្មគាត់ដោយវាយច្រើនរំពាត់ ព្រោះតែគាត់បានសាសងស្នេហាខុសច្បាប់ជាមួយអស់អ្នករស់នាងនៅក្នុងវាំង ។

តាំងពីមិនទាន់បានឡើងកាន់អំណាចជាស្តេចត្រាញ់ លោកឃុំនេះមានឈ្មោះល្បីខាងលេងសើចសប្បាយនិងស្រីញី ហើយនិងខាងកាប់សំលាប់មនុស្សឥតពិចារណា ។

នៅពេលដែលលោកញ៉ុញចូលក្នុងវ័យចាស់ជរា អ្នកម្ចាស់ឃ្លិប ដែលជាកូនស្រីច្បង ចាត់ចែងកិច្ចការទាំងអស់ជំនួសឪពុក ។ គឺអ្នកម្ចាស់ឃ្លិបនេះហើយ ដែលនាំសួយសារអាករផ្សេងៗទៅថ្វាយស្តេចសៀមរាល់ឆ្នាំ ។

លោកយាយ អុំ បានប្រាប់ថា ម្តាយមីងគាត់ឈ្មោះ យាយកែម ធ្លាប់បានជូនដំណើរអ្នកម្ចាស់ ឃ្លិប នេះទៅស្រុកសៀម យកមាសពេជ្រទៅថ្វាយស្តេចសៀម ដោយធ្វើដំណើរកាត់តាមភ្នំពេញព្រៃនគរ ហើយឆ្លងកាត់ឈូងសមុទ្រសៀម ។ នៅពេលធ្វើដំណើរអ្នកម្ចាស់ ឃ្លិប មានបាវស្រី៣នាក់ដើរតាម គឺម្នាក់កាន់ឆ័ត្រ ម្នាក់កាន់ហិបស្លា និងម្នាក់ទៀតចាំកាន់ស្បែកជើង នៅពេលអ្នកម្ចាស់ឡើងលើប្រាសាទ ។ បាវស្រីរង់ចាំអ្នកម្ចាស់នៅខាងក្រៅ ។ នៅពេលដែលថ្វាយបង្គំលាស្តេចសៀមមកវិញ ស្តេចសៀមបានប្រទាន

www.budinst.gov.kh www.elibraryofcambodia.org

សំពត់អាវជាច្រើន ។ គឺអ្នកម្ចាស់ ឃ្លិប នេះហើយដែលនាំម៉ូត សំលៀកបំពាក់ផ្សេងៗ មកផ្សាយនៅបាត់ដំបង ។

ព្រះចៅសៀមពេញចិត្តនឹងអ្នកម្ចាស់ ឃ្លិបនេះណាស់ ហើយមានបំណងលើកប្ដីម្ចាស់ឃ្លិប ដែលជាជាតិសៀមមានឈ្មោះ *អេម សិង្ហសេនីយ* ដែលត្រូវជាកូនលោកចៅឃុនបឌិន ឲ្យឡើងកាន់អំណាចជាស្ដេចត្រាញ់ នៅក្រោយដែលលោកកថាថន ញ៉ុញ ធ្វើមរណកាលទៅ ។

លោកឈុំ ដឹងស្ថានការណ៍បែបនេះទាន់ ក៏ចាត់ឲ្យគេកាប់សំលាប់ប្ដីម្ចាស់ ឃ្លិប ដែលជាបងថ្លៃនោះចោលទៅ ។ ព្រះចៅសៀមទាល់ព្រះតំរិះក៏លើកលោក ឈុំ នេះឲ្យឡើងជាស្ដេចត្រាញ់ក្រោយពេលដែលលោកញ៉ុញចូលមរណភាព នៅរវាងឆ្នាំ១៨៩៤ [1] ដោយដាក់គោរម្យងារថា : "*ចៅពញាគទាធរ ធរណិន្ទ្រ រាមនរិន្ទ ឥន្ទ្រាធិបតី អភ័យភេរី ពាហុ* "។ ពាក្យថា គាទាធរ នេះអានតាមសៀមថា កថាថន ប្រែថា អ្នកទ្រទ្រង់ដំបង ។

---

[1] ប្រហែលជាដោយសារទំនាស់ក្នុងការកាប់សំលាប់ប្ដីអ្នកម្ចាស់ ឃ្លិបនេះហើយបានជាអ្នកម្ចាស់ ឃ្លិប មិនតាមលោកម្ចាស់ទៅបស្ចិមទេ ។ កូនប្រុសអ្នកម្ចាស់ឃ្លិបដែលមានឪពុកជាសៀម សុខចិត្តរស់នៅបាត់ដំបងហើយត្រូវបានព្រះបាទស៊ីសុវត្ថិ តែងតាំងជា ឧកញ៉ាអធិបតីសេនា ។

www.budinst.gov.kh www.elibraryofcambodia.org

ក្រោយដែលឡើងកាន់អំណាចនៅអាយុជាង ៣០ឆ្នាំ លោកម្ចាស់ បានចាត់ឲ្យជ្រើសរើសក្រមុំរូបស្អាតៗមកធ្វើជាស្រីរបាំនៅក្នុងកំផែងកែវ ។

នៅក្រោយដែលគាត់ឡើងកាន់អំណាច គាត់បានបំភ្លេចចោលប្រពន្ធដើមឈ្មោះ អ្នកសក់ ហើយគាត់ទទួលយកអ្នក អ៊ុង ឲ្យឡើងជាប្រពន្ធធំជាលោកជំទាវ ។ បន្ទាប់មក លោកម្ចាស់ក៏តាំងលោកម៉ៅជាឪពុកលោកស្រីអ៊ុងនេះ ឲ្យឡើងឋានៈជា *ព្រះយ៉ា ព្រះឃ្លាំង* ។ លោកព្រះឃ្លាំង បានរិះរកស្នេហ៍អាគមយ៉ាងច្រើនមកដាក់ឲ្យលោកម្ចាស់ស្រឡាញ់តែកូនស្រីគាត់ម្នាក់ ។ តែមិនយូរប៉ុន្មានស្រីរបាំដែលមានរូបស្អាតៗបានក្លាយជាប្រពន្ធចុងគាត់សឹងតែទាំងអស់ ដូចជាអ្នករ៉េត អ្នកល្ហាយ អ្នកម៉ន អ្នកវ៉ាន អ្នកវ៉ែន ។ល។ ប្រពន្ធចុងដែលលោកម្ចាស់ស្រឡាញ់ជាងគេគឺ អ្នកល្ហាយ ដែលជាកូនលោកស្រីពិភក្ត ដែលមានរូបសម្បត្តិលើសស្រីទាំងពួងនៅបាត់ដំបងក្នុងពេលនោះ ។

លោកម្ចាស់ប្រមូលប្រាក់ពន្ធដារទាំងអំបាលម៉ាណ ទុកជាប្រយោជន៍ផ្ទាល់ខ្លួន ទិញមាសទាំងនាឡិៗ ចែកឲ្យស្រីរបាំដែលជាប្រពន្ធចុងគាត់ ។ ពេលចេញសំដែង តួល្ខោនដែលជាប្រពន្ធចុងសុទ្ធតែពាក់មាសសុទ្ធមិនមែនពាក់មាសក្រឡែទេ ថែមទាំងពេជ្រ

www.budinst.gov.kh www.elibraryofcambodia.org

យ៉ាងចិញ្ចាចចិញ្ចែង ។

លោកម្ចាស់ជាមនុស្សកោងកាច កាប់សំលាប់មនុស្សឥតត្រាប្រណីនិងឥតពិចារណា ។ អ្នកបាត់ដំបងកោតញញើតថ្វីដែគាត់គ្រប់គ្នា ។ ក្រៅពីកាប់សំលាប់បងថ្លៃដែលជាប្ដីម្ចាស់ ឃ្លិប គាត់បានកាប់សំលាប់មនុស្សអស់ច្រើនណាស់ ។ អ្នកខ្លះត្រូវស្លាប់ដោយមានទោស តែអ្នកខ្លះត្រូវស្លាប់ដោយសារតែធ្វើឲ្យខូចប្រយោជន៍គាត់ ។ គាត់បានសំលាប់ឃុនគង់ដែលជាប្អូនគាត់ ឪពុកជាមួយតែម្ដាយផ្សេង ព្រោះតែ ឃុនគង់ នេះទៅស្រឡាញ់ស្រីរបាំដែលជាប្រពន្ធចុងគាត់ ។ កាលដែលលោកម្ចាស់សំលាប់ឃុនគង់នេះលោកគ្រូចៅអធិការវត្តសំពៅមានកិត្តិស័ព្ទខ្លាំងណាស់ ហើយឡើងល្បីព្រះនាមថា លោកគ្រូព្រះឱស្ឋទិព្វ ព្រោះលោកបានទាយថា ឃុនគង់ ត្រូវស្លាប់ដោយអាវុធ ។ នៅពេល ឃុនគង់ មានទោសលោកបាននិមន្តទៅសុំលោកម្ចាស់ប្រណីទោស ។ លោកម្ចាស់ ក៏ព្រមតាមដោយសុខចិត្តនីរទេស ឃុនគង់ ទៅនៅភ្នំពេញ ។ ឃុនគង់បានរួចខ្លួនហើយ តែមិនដាច់អាល័យ ក៏លួចរត់មកបាត់ដំបងវិញ ហើយគេក៏ចាប់ឃុនគង់សំលាប់ចោលទៅ ។

ក្រៅពីនេះ លោកម្ចាស់បានសំលាប់ព្រះភិនិត្យសម្បត្តិ អ៊ុយ នៅពេលគាត់កំពុងបរិភោគបាយថ្ងៃត្រង់ជាមួយគ្រួសារ ព្រោះតែ

www.budinst.gov.kh www.elibraryofcambodia.org

គាត់បានរាប់អានកុងស៊ុលបារាំង ។ លោកយាយ អ៊ិច ជាប្រពន្ធព្រះ ភិនិត្យសម្បត្តិបានប្រទេចផ្ដាសារលោកម្ចាស់យ៉ាងខ្លាំង ។ គាត់ជេរ លោកម្ចាស់ជាសាធារណៈ ឲ្យលោកម្ចាស់ស្លាប់តែដោយគ្រាប់កាំ ភ្លើង ឬឲ្យប្រាសចោលស្រុកកុំឲ្យគាត់ឃើញស្រមោល ។

លោកម្ចាស់ចូលចិត្តបរបាញ់សត្វណាស់ ។ នៅពេលទំនេរ គាត់កេណ្ឌរាស្ត្រប្រជាឲ្យរកជិនិះនិងស្បៀងផ្ទាល់ខ្លួន ទៅជួយដេញ សត្វគាត់ ។ រាស្ត្រប្រជាក្តៅក្រហាយនឹងកំណែនទៅដេញសត្វនេះ ណាស់ ព្រោះម្យ៉ាងត្រូវខាតពេលវេលា ខាតការងារ ខាតស្បៀង អាហារ ព្រោះម្យ៉ាងទៀតខ្លួនជាអ្នកកាន់ព្រះពុទ្ធសាសនា ខ្លាចកម្ម ពៀរវេរា នាំឲ្យព្រាត់ប្រាស់ប្រពន្ធកូន ។ រាស្ត្រប្រជាបានចូលទៅទាម ទារតវ៉ាលោកម្ចាស់សុំមិនទៅបរបាញ់សត្វទេ ។ តែផ្ទុយទៅវិញ ម្នាក់ៗដែលទៅតវ៉ានេះត្រូវលោកម្ចាស់វាយម្នាក់មួយដំបងៗ ហើយ ឲ្យត្រឡប់មកផ្ទះវិញ ចាំថ្ងៃក្រោយហៅឲ្យទៅដេញសត្វទៀត ។ ក្នុង កំណែនដេញសត្វនេះ អ្នកមានទ្រព្យសម្បត្តិអាចជួលគេឲ្យទៅជំនួស បាន ឬឲ្យគេខ្ចីគោក្របី ។ តែអ្នកខ្លះអាណិតសត្វពាហណៈខ្លួន ក៏ចេះ តែប្តូរទៅដោយខ្លួនឯង ។ គេកេណ្ឌឲ្យរាស្ត្រម្នាក់ៗទៅដេញសត្វ មួយសប្តាហ៍ក្នុងមួយឆ្នាំ ។ នៅពេលបាញ់សត្វបាន គេចែកសាច់ឲ្យ ខ្លះដែរ គឺម្នាក់បានសាច់ ១នាឡិ ។

www.budinst.gov.kh www.elibraryofcambodia.org

លោកម្ចាស់ច្រើនទៅបរបាញ់សត្វ នៅតំបន់ចន្លោះអូរស្រឡៅ និងភ្នំធិបតី ។ គាត់បានសាងផ្ទះមួយ ដែលគេហៅថាទំនៀប នៅក្បាលក្របី ខាងកើតកំពង់ព្រះ សំរាប់សំរាកនៅពេលបាញ់សត្វ ។ ជួនកាល លោកម្ចាស់តែងបោះជំរុំនៅអូរស្រឡៅ ហើយឆ្អើរសាច់នៅទីនោះ ទើបមានឈ្មោះថា ចែងចង្អើរ ព្រោះគេធ្វើចង្អើរនៅក្រោមដើមចែង ។ លោកម្ចាស់មានទំនៀបមួយទៀតនៅភាសហួសពាមឯកបន្តិចទៅសំរាប់កំសាន្តនៅពេលទឹកជន់លិចវាល ឬ ជាទីសំណាក់នៅពេលបរបាញ់សត្វនៅរដូវប្រាំង ។

លោកម្ចាស់មិនសូវបាញ់ត្រង់ប៉ុន្មានទេ គាត់មានព្រានច្រើននាក់សំរាប់ជួយបាញ់សត្វ ។ ព្រានដែលសំខាន់ជាងគេ គឺព្រានជំនិតដែលជាឪពុកមា លោកតា ប៉ិល យ៉ត ។ លោកតា ប៉ិល យ៉ត បានប្រាប់ថាគេដេញសត្វតាមរបៀបច្រើនយ៉ាង ។ ជួលកាលគេនាំគ្នាដើររកសត្វបាញ់តែម្តង ជួនកាលគេឲ្យរាស្ត្រប្រជាជិះក្របីកៀងសត្វពីទីឆ្ងាយៗ ឲ្យរត់ទៅរកព្រានដែលពួនចាំបាញ់នៅទីណាត់មួយ ជួនកាលគេដេញសត្វឲ្យបោលទៅ រកក្រោលចំហមួយដែលគេធ្វើបំរុងទុក ។ លុះសត្វចូលក្នុងក្រោលអស់ ទើបគេបិទទ្វារ ។ គេហៅរបៀបនេះថា*ដេញសត្វបញ្ចូលស៊ឹង* ។ គេចាប់សត្វពីស៊ឹង យកទៅដាក់ក្នុងទ្រុង ឯក្នុងកំផែង កាប់ស៊ីម្តងមួយៗ ។ តែជួនកាល

www.budinst.gov.kh www.elibraryofcambodia.org

គេដេញសត្វដោយសេះ ។ នាម៉ឺនដែលមានសេះ ជិះសេះ តំរៀបគ្នាជាខ្សែ ដោយម្នាក់ៗមានកាន់ឆ្នោងដែលមានចងសំពត់ក្រហមនៅចុងខ្សែតី ។ គេដេញសត្វរហូតដល់សត្វអស់កំលាំងហត់ហេវហើយដួល ទើបគេវាយសំលាប់ ឬលើកទាំងរស់ដាក់រទេះត្រឡប់មកវិញ ។

លោកតា រស់ ប៊ុត បានប្រាប់ថា លោកម្ចាស់ត្រូវការឲ្យគេគក់ច្រុបាច់រាល់ពេលសំរាន្ត ទោះបីគាត់សំរាន្តលក់ឬមិនលក់ក៏ដោយ ។ នៅក្នុងកំផែង គាត់ដាក់វេនឲ្យស្រីចូលគក់ច្របាច់គាត់ បីនាក់ក្នុងមួយយប់ ប៉ុន្តែនៅពេលទៅបាញ់សត្វ គាត់មិនឲ្យស្រីៗទៅជាមួយទេ នាំឆ្អែងបាញ់សត្វមិនបាន ។ ហេតុនេះ នៅពេលសំរាន្ត គេកេណ្ឌឲ្យមានក្មេងប្រុសជំទង់ៗចូលទៅគក់ច្របាច់ ។ គេត្រូវគក់មួយយប់ទើសភ្លឺ ឥតសំរាកទេទោះពេលលោកម្ចាស់សំរាន្តលក់ក៏ដោយមិនលក់ក៏ដោយ ។ អ្នកណាខ្ជិលមុខតែត្រូវឆ្នោងហើយ ។ កាលនៅពីតូចលោកតា រស់ ប៊ុត នៅភូមិស្វាយឆ្អេះ ធ្លាប់បានចូលទៅគក់ច្របាច់បំរើលោកម្ចាស់ដែរ ។

លោកតា រស់ ប៊ុត នេះធ្លាប់មានរឿងជាមួយលោកម្ចាស់នៅពេលលោកម្ចាស់កំពុងបរិភោគបាយ ឯទំនៀបក្បាលក្របីលោកម្ចាស់សួររកជីកំប៉ុង តែគ្មានអ្នកណាដឹងទេ ។ លោកតា ប៊ុត

www.budinst.gov.kh www.elibraryofcambodia.org

ក្លាបានឆ្លើយភ្លាមថា "ខ្ញុំប្របាទឃើញមាននៅកំពង់ព្រះ "។ លោកម្ចាស់ក៏ប្រើឲ្យទៅរកភ្លាម ។ ដោយខ្លាច គាត់ត្រូវរត់ទៅរកតាមបញ្ហារអស់ច្រើនគីឡូម៉ែត្រ ។ គាត់ទៅដល់ទំនៀបវិញប្រហែលពីរម៉ោងក្រោយលោកម្ចាស់ពិសារបាយរួច ។ នៅពេលទៅដល់មិត្តភក្តិប្រាប់ថា "ថ្ងៃក្រោយឯងកុំឆោត បើលោកម្ចាស់សួររកអ្វីយើងឆ្លើយថា មិនដឹង ស្រណុកខ្លួនជាង "។

លោកតា ញ៉ឹក ហួត នៅកំពង់ឆ្លង បានឲ្យការណ៍ម្យ៉ាងទៀតថាលោកម្ចាស់មិនត្រូវគ្នានឹងកុងស៊ុលបារាំងទេ ។ កុងស៊ុលបារាំងតែងប្ដឹងស្ដេចសៀមទូលទាស់អំពីលោកម្ចាស់ ។ តែលោកម្ចាស់ប៉ិនប្រសប់ខាងផ្គាប់ផ្គុនព្រះចៅសៀមណាស់ ។ ព្រះចៅសៀមហៅលោកម្ចាស់ទៅសាកសួររឿងហេតុផ្សេងៗ តាមដែលបារាំងប្ដឹងនោះ ។ ព្រះចៅសៀមក៏ប្រសប់ខាងការពារកូនចៅណាស់ដែរ ។ រាល់ពេលដែលលោកម្ចាស់ចូលទៅគាល់ ព្រះចៅសៀមតែងបំពាក់មេដាយថែមឲ្យលោកម្ចាស់ទៀត ដើម្បីបញ្ឈឺចិត្តកុងស៊ុលបារាំង ។ នៅពេលដែលលោកម្ចាស់ត្រឡប់ពីបាងកកវិញ នាម៉ឺនមុខមន្ត្រីនៅបាត់ដំបងលើកកិត្តិយសលោកម្ចាស់ដោយធ្វើក្លោងទ្វារជាស៊ុំផ្កា នៅមុខវត្តដំរីសចាំទទួលលោកម្ចាស់ ។ ចាប់ពីក្លោងទ្វារស៊ុំផ្កានេះមករហូតដល់ក្នុងកំផែង គេយកសំពត់សមកធ្វើជាដំបូលទទួល

www.budinst.gov.kh www.elibraryofcambodia.org

ជាកិត្តយសដល់លោកម្ចាស់ដែលបានមេដាយថ្មី ។

នៅឆ្នាំ ១៩០៤ លោកម្ចាស់បានជួលជាងអ៊ីតាលីឲ្យស្ថាបនាវិមានថ្មីមួយ ដែលជាសណ្ឋាគារខេត្តសព្វថ្ងៃ តែលោកម្ចាស់មិនបានរស់នៅក្នុងវិមាននេះទេ ព្រោះត្រូវនិរាសទៅនៅឯបស្ចិម ។

នៅរវាងឆ្នាំ១៩០៦ មានប្រផ្នូលមិនល្អច្រើនចំពោះលោកម្ចាស់ ។ មានសត្វត្មាតធំមួយហើរមកបុកប៉ះវិមានលោកម្ចាស់ រហូតដល់បាក់កស្លាប់ ។ នៅពេលកោរសក់កូន លោកម្ចាស់បានចាត់ឲ្យគេសំដែងល្ខោនរាមកេរ្តិ៍តាំងពីដើមរហូតដល់ចប់ ទាំងយប់ទាំងថ្ងៃ ។ ក្បួនបុរាណគេមិនដែលសំដែងរឿងរាមកេរ្តិ៍ដល់ចប់ទេ ព្រោះមានទំនាយថាត្រូវព្រាត់ប្រាសស្រុកនិងប្រពន្ធកូន ។ នេះលោកម្ចាស់ឲ្យគេសំដែងល្ខោនរហូតដល់រាពណ៍ស្លាប់ ដែលគេហៅថា *រាពណ៍ផ្កាំមៀង* ។ លោកអុងប៉ាង តឹក ប្រាប់ថាលោកម្ចាស់បានឡើងលើឆាកខ្លួនឯង សំដែងក្រមុំចក្រម៉ើមជាមួយស្រីរបាំ ដែលជាប្រពន្ធចុងឲ្យរាស្ត្រប្រជាមើល ។

នៅខែមីនា ១៩០៧ សៀមបានសុខចិត្តចុះសន្ធិសញ្ញា ប្រគល់ខេត្តបាត់ដំបងមកឲ្យខ្មែរវិញ ។ បារាំងបានសុំឲ្យលោកម្ចាស់នៅធ្វើជាចៅហ្វាយខេត្តតទៅទៀត តែគាត់មិនសុខចិត្ត ក៏ដឹកប្រពន្ធកូននិងទ្រព្យសម្បត្តិ មាសពេជ្រច្រើនរយរទេះយកទៅស្រុកសៀម

www.budinst.gov.kh www.elibraryofcambodia.org

ចែកកូនចៅដេកស៊ីចាយសប្បាយរហូតដល់សព្វថ្ងៃ ។

លោកតា ឌុកមៀន នៅភូមិបាឡាត់ បានឈរមើលក្បួនដំណើរចេញទៅបស្ចិមនៃលោកម្ចាស់ ដែលមានរទេះគោ រទេះក្របីនិងសេះ ដ៏វីរាប់រយ ។ រាស្ត្រប្រជាខ្លះដែលឆោតល្ងង់ ទៅតាមលោកម្ចាស់ច្រើនគ្នា ។ លោកម្ចាស់មិនបានទំនុកបំរុងអ្នកអស់នោះទេ ។ អ្នកអស់នោះត្រូវធ្លាក់ក្ររហេមរហាម ទើបត្រឡប់មកស្រុកវិញ ។

លោកម្ចាស់បានលក់ផ្ទះសំបែងទាំងអស់នៅបាត់ដំបង ឲ្យទៅបារាំង ជាពិសេសសណ្ឋាគារខេត្ត ដែលលោកម្ចាស់មិនទាន់បានឡើងនៅផងនោះ ។ លោកម្ចាស់បានទៅសាងផ្ទះមួយទៀតនៅបស្ចិមមានលំនាំដូចសណ្ឋាគារខេត្តបាត់ដំបងដែរ ។

ប្រហែលដប់ឆ្នាំក្រោយមក លោកម្ចាស់ក៏មានជំងឺទឹកនោមផ្អែម រហូតដល់ទទួលអនិច្ចកម្មនៅរវាងឆ្នាំ ១៩២០ នៅឯបស្ចិមបុរីនាស្រុកសៀមទៅ ។ កូនចៅជាច្រើនក៏រស់នៅស្រុកសៀមរហូតដល់សព្វថ្ងៃ ។

www.budinst.gov.kh www.elibraryofcambodia.org

# កំផែង

នៅក្រោយពេលដែលចៅពញាអភ័យធិបេស រស់ ទទួលអនិច្ចកម្មទៅនោះ ព្រះចៅសៀមហាក់ដូចជាឈប់ចង់ឲ្យគ្រួសារចៅហ្វាបែនកាន់អំណាចនៅបាត់ដំបងទៀតហើយ ។

ព្រះចៅសៀមបានតាំងព្រះអង្គអិម ដែលជាក្សត្រខ្មែរភៀសខ្លួនទៅស្រុកសៀម ឲ្យមកកាន់កាប់ខេត្តបាត់ដំបង ។

ព្រះចៅសៀមបានចាត់ចៅពញាបឌិន ឲ្យមកសាងកំផែងបន្ទាយមួយនៅបាត់ដំបង ។ តាមឯកសារខ្លះថា ព្រះអង្គអិមបានសាងបន្ទាយមួយរួចហើយ តែបន្ទាយនោះជាបន្ទាយធ្វើអំពីឈើច្រុះក្ការ ហើយលិចទឹកនៅរដូវវស្សា ។ ទើបនៅឆ្នាំ ១៨៣៧ ចៅពញាបឌិន បានមកស្ថាបនាបន្ទាយមួយទៀត ដែលនៅខាងលើទឹក ផុតពីទឹកជំនន់ ។ បន្ទាយថ្មីនេះមានកំផែងអិដ្ឋបូកបាយអរយ៉ាងមាំព័ទ្ធជុំវិញ ។ អ្នកស្រុកហៅបន្ទាយនេះថា *"កំផែង"* តាមពាក្យសៀមដែលថា កំពែង ។ កំផែងនេះមានពីរជាន់ គឺកំផែងខ្ពស់និងកំផែងកែវ ។

www.budinst.gov.kh www.elibraryofcambodia.org

### ក- កំផែងខ្ពស់

គឺជាបន្ទាយប្រាការមួយយ៉ាងខ្ពស់និងយ៉ាងមាំ ធ្វើអំពីអិដ្ឋបូកបាយអរ មានរាងចតុកោណកែង ។ ឯកសារជាច្រើននិយាយផ្សេងៗគ្នាពីវិមាត្រនៃកំផែងខ្ពស់នេះ តែឯកសាររបស់ព្រះគ្រូសិរីសត្ថាកែវ សាងមានភាពសមជាងគេ ហើយចែងថា កំផែងនេះមានបណ្តោយ ១៨សិន ១ទឹង ១២សិន កំពស់ ៤ហត្ថ កំរាស់ ២ហត្ថ១ចំអាម [1] ។

កំផែងខ្ពស់នេះមានព្រំដែនខាងជើងទល់ផ្លូវចន្លោះ ប្រៃសណីយ៍ និងរោងចក្រអគ្គិសនី

- ខាងកើតទល់ផ្លូវលេខ ១
- ខាងត្បូងដល់ត្រង់រោងអារឈើ ហូ តុង ហាន់
- ខាងលិចស្របតាមខាងក្រោយវត្តកំផែងសព្វថ្ងៃទៅជើង

មើលពីខាងក្រៅ កំផែងខ្ពស់នេះជាជញ្ជាំងខ្ពស់ចោត តែពីខាងក្នុង គេពូនដីឲ្យមានរាងទេរផ្ទប់និងជញ្ជាំងសំរាប់ឲ្យអ្នកការពារបន្ទាយឡើងមកទប់ទល់និងគូសត្រូវបានដោយងាយ ។ នៅលើដីទេរនេះ គេដាំសុទ្ធតែដើមចំប៉ាក្រហម ។ កំផែងមានក្លោងទ្វារ៦ គឺ

---

[1] រង្វាស់បូរាណ : ១សិនមាន២០ព្យាម ។ ១ព្យាម ៤ហត្ថ ។ ១ហត្ថមាន២ចំអាម ។ ដូចនេះ១សិនត្រូវជា៤០ម៉ែត្រ ។

www.budinst.gov.kh www.elibraryofcambodia.org

ខាងកើតមានទ្វារពីរ ខាងលិចមានទ្វារពីរ ខាងជើង និងខាងត្បូង មានក្លោងទ្វារមួយៗ ។ កំផែងនេះមានប៉មបួនដែលគ្រាន់តែជាទីខ្ពស់ស្មើកំផែងដែរ តែញោចចេញមកក្រៅបន្តិច នៅតាមមុំ និងនៅចំកណ្ដាលខាងកើតនិងកណ្ដាលខាងលិច ។ ប៉ម ជាកន្លែងដាក់កាំភ្លើងធំ ។ នៅប៉មកណ្ដាលខាងកើត មានដងទង់យ៉ាងខ្ពស់ បង្ហូតទង់ពណ៌ក្រហមមានរូបដំរីសនៅកណ្ដាល គឺជា ទង់ជាតិសៀមនៅពេលនោះ ។

បែរមករកស្ទឹង នៅខាងកើត កំផែងមានក្លោងទ្វារពីរ មួយនៅត្រង់ចន្លោះសាលាខេត្តនិងសាលាស្រុកសង្កែសព្វថ្ងៃ មួយទៀតនៅត្រង់មុខវត្តកំផែង ។ បើគេចូលត្រង់តាមក្លោងទ្វារទាំងពីរនេះទៅក្នុង គេនឹងឃើញកាំភ្លើងធំតំកល់លើកង់ ដែលអាចរុញចុះរុញឡើងបាន ដាក់នៅក្នុងរោងមួយ ។ គឺកាំភ្លើងធំទាំងពីរនេះហើយដែលគេយកមកដាក់តាំងនៅមុខសណ្ឋាគារខេត្តសព្វថ្ងៃ ។

(អ្នកខ្លះយល់ច្រឡំថា កាំភ្លើងធំជាកាំភ្លើងស៊ីម៉ង់តាំងឲ្យល្អមើល ។ តាមពិត កាំភ្លើងធំនេះត្រូវគេនាំមកពីប្រទេសអង់គ្លេសមកបាត់ដំបង តាំងពីរវាងឆ្នាំ ១៨៣៧ ។ គឺអាវុធធុនធ្ងន់មានប្រសិទ្ធភាពខ្លាំងក្លា ។ គេបាញ់កាំភ្លើងធំនេះដោយច្រករំសេវតាមមាត់ ។ គេយកភ្លើងដុតរន្ធហេវ ដែលនៅខាងក្រោយ រំសេវក៏ផ្ទុះឡើង

www.budinst.gov.kh www.elibraryofcambodia.org



ក្លោងទ្វារកំផែង (ន.៣)



ចេតិយ៍ព្រះអរហន្តធាតុ

ស្ថាបនានៅឆ្នាំ ១៨៤០ (ພ.ស)

www.budinst.gov.kh www.elibraryofcambodia.org

ព្រួសដុំដែកទាំងមូលៗទៅលើគូសត្រូវ ។ កាំភ្លើងធំមិនមែនមានតែពីរទេ គឺមានប្រហែលជាង១០០ទៀត ដាក់ប្រចាំការនៅតាមប៉មនានាខ្លះ ដាក់នៅក្នុងឃ្លាំងខ្លះ ។ លោកតា ម៉ិល អឿ បានប្រាប់ថា កាលជំនាន់បារាំង គេតែងបាញ់កាំភ្លើងធំនេះរាល់ព្រឹក នៅពេលគោរពទង់ជាតិ តែក្រោយដែលមានគ្រោះថ្នាក់បច្ចេកទេសបណ្តាលឲ្យស្លាប់អ្នកបាញ់ម្នាក់មក គេក៏ឈប់ឲ្យបាញ់កាំភ្លើងធំនេះទៅ ។ ម្យ៉ាងទៀត នៅពេលនោះ បារាំងបានជញ្ជូនកាំភ្លើងធំទាំងនេះជាច្រើនទៅស្រុកវាទុកជាកេរ្តិ៍ដំណែលបុរាណ ។ មួយចំណែកទៀត គេបានយកកាំភ្លើងធំជាច្រើនយកទៅធ្វើជាបូសបាតស្ពានដែកសព្វថ្ងៃ )។

នៅខាងក្នុងកំផែងខ្ពស់ ត្រង់បរិវេណសណ្ឋាគារខេត្តសព្វថ្ងៃ មានកំផែងឥដ្ឋមួយជាន់ទៀតហ៊ុំព័ទ្ធលំនៅលោកម្ចាស់ ហៅថា កំផែងកែវ ។ នៅខាងជើងកំផែងកែវ មានផ្ទះថ្ម ផ្ទះឈើធំៗជាច្រើន ដែលជាលំនៅបងប្អូនលោកម្ចាស់ មានអ្នកម្ចាស់ ឃ្លីបជាអាទិ ។ នៅខាងលិចកំផែងកែវ មានឃ្លាំងកាំភ្លើងនិងគ្រាប់រំសេវ ឃ្លាំងស្រូវនិងរទេះសាលី ។ នៅខាងត្បូងកំផែងកែវ មានផ្ទះអ្នកស្រុករកេតរកូត មានផ្ទះស្មៀនត្រាជាអាទិ ។ ហួសទៅត្បូងបន្តិចទៀត គឺវត្តកំផែង ។ វត្តកំផែងនេះស្ថាបនាដោយលោក

www.budinst.gov.kh www.elibraryofcambodia.org

ស្រីធិម ដែលជាលោកជំទាវលោកម្ចាស់កថាថន ញ៉ុញ ហើយត្រូវជាម្ដាយលោកម្ចាស់ឈុំ នេះតែម្ដង ។ ដោយហេតុនេះហើយ បានជាវត្តកំផែងនេះមានឈ្មោះថា *វត្តទេពធិមរាជនិវេសន៍* ។ វត្តកំផែង កាលដើមតាំងនៅត្រង់ទក្ខិណៈសាលាសព្វថ្ងៃ មានព្រះវិហារប្រកបដោយក្បូរក្បាច់យ៉ាងប្រណិត មាននាគព័ទ្ធសសរតាំងពីដីដល់ដំបូល ។ នៅខាងជើងព្រះវិហារ មានចេតិយ៍ដ៏មានកំពូលស្រួចត្រដែត គឺជាចេតិយ៍ព្រះអរហន្តធាតុ ស្ថាបនាតាំងពីពេលធ្វើកំផែងនៅរវាងឆ្នាំ១៨៣៧ម្ល៉េះ ។

នៅត្រង់វត្តកំផែងសព្វថ្ងៃ មានក្រោលដំរីលោកម្ចាស់ដែលមាន តាវ៉ាន់ ជាទ្រមាក់ មើលការខុសត្រូវ ។ លោកតា លិម ស៊ុត បានប្រាប់ថា លោកម្ចាស់មានដំរីចំនួន៧បុស ដែលក្នុង១បុសមាន ៨ដំរី ។ ដំរីលោកម្ចាស់មានឈ្មោះ អាចៀបធំ អាចៀបតូច អាមាស អាប្រាក់ អាដួន អាម្ចុល មីក្រពុំ មីប្រហុក ។ មីក្រពុំដើរនឹងថ្កល់ អ្នកជិះអាចកាន់កែវមានទឹកពេញមិនកំពុបទេ ។ ដំរីឈ្មោះមីប្រហុក តែងដើររុករើផ្ទះអ្នកស្រុក ផ្ទះទាបៗឬផ្ទះស្លឹក លូករកប្រហុកស៊ី ។ ម្យ៉ាងទៀត លោកម្ចាស់ក៏មានសេះល្អៗច្រើនដែរ ហើយច្រើនជាសេះទេសធំៗ ។ សេះដែលល្បីជាងគេឈ្មោះ អានារី ដែលជាសេះមង្គល ដែលមានមនុស្សពីរនាក់មើលឲ្យទឹកឲ្យស្មៅ ។ នៅពេលទៅ

www.budinst.gov.kh www.elibraryofcambodia.org



ភាគមួយនៃកំផែងដែលរសល់ដល់សព្វថ្ងៃ (គ.ច)



កាំភ្លើងធំការពារកំផែង (ឧ.ណ)

www.budinst.gov.kh www.elibraryofcambodia.org

ណាមកណា លោកម្ចាស់ចូលចិត្តជិះសេះញីឈ្មោះមីស្រកា ។

នៅក្បែរក្រោលដំរី មានដើមស្វាយបីដើមធំៗ ប៉ុនកង់រទេះ ដែលនៅក្រោមនោះមានសៃរៀនប្រជល់មាន់របស់លោកម្ចាស់ ។ នៅខាងជើងនោះបន្តិច មានវាលស្រឡះ ជាស្រែសំរាប់ស្រីរបាំក្នុងកំផែងកែវចេញមកធ្វើស្រែ បំពេញកិច្ចនៅរដូវវស្សា ។

## ១- *កំផែងកែវ*

កំផែងកែវជាបរិវេណសំរាប់តែលោកម្ចាស់ លោកជំទាវ លោកស្រី ម៉ម ឃុន អស់អ្នកអស់នាង ស្រីរបាំ ស្រីបំរើ ។ កំផែងកែវមានទីតាំងនិងទំហំប្រហាក់ប្រហែលបរិវេណសណ្ឋាគារខេត្តសព្វថ្ងៃ ។ កំផែងកែវនៅឃ្លាតពីកំផែងខ្ពស់ខាងកើតប្រហែល៣០ម៉ែត្រ នៅចន្លោះនោះ មានសាលាកាត់ក្តី ដែលគេហៅថា *សានក្លាង* ។ កំផែងកែវមានទ្វារចេញមកខាងកើតពីរ ។ បើគេចូលតាមទ្វារខាងត្បូង គេនឹងឃើញអាគារធំមួយ ដែលគេហៅថា "*តឹកពងក្រពើ*" ជាលំនៅលោកម្ចាស់ លោកជំទាវអ៊ុង និងកូនស្រីពីរនាក់ ។ នៅខាងត្បូងតឹកពងក្រពើនេះ មានអាគារមួយទៀតដែលទើបនឹងសង់ថ្មីមិនទាន់ហើយនៅឡើយផង គឺសណ្ឋាគារខេត្តសព្វថ្ងៃនេះ ដែលលោកម្ចាស់បានជួលជាងអ៊ីតាលីឲ្យមកស្ថាបនា នៅរវាងឆ្នាំ១៩០៤ ។ បើគេចូលតាមក្លោងទ្វារខាងជើង គេឃើញមានផ្ទះ

www.budinst.gov.kh www.elibraryofcambodia.org

ថ្នាប៦ ជ្រុងដែលគេហៅថា *តឹកជប៉ុន* ជាផ្ទះសំរាប់ទទួលភ្ញៀវ ។ នៅចន្លោះតឹកពងក្រពើ និងតឹកជប៉ុន មានសួនច្បារព័ទ្ធជុំវិញអាគារមួយដែលហៅថា*អហ៊ិត ឬ ធិរ៉ាការ* ដែលជាកន្លែងធ្វើការរបស់លោកម្ចាស់ ។ (អហ៊ិត នេះជាពាក្យអង់គ្លេសថា office អានតាមលំនាំសៀម) ។ នៅខាងក្រោយមានរោងល្ខោនយ៉ាងធំសំរាប់សំដែងជូនសាធារណជននៅពេលមានបុណ្យទាន ។ នៅក្បែររោងល្ខោនមានអាគារពីរជាន់ទទឹងថ្ងៃយ៉ាងវែង ចែកជាសង្កាត់ៗសំរាប់ប្រពន្ធលោកម្ចាស់។ ក្រៅពីនេះ មានក្រោលសេះទ្រុងជ្រូកព្រៃ ទ្រុងប្រើស ទ្រុងក្ដាន់ ហើយនិងផ្ទះរកេតរកូតសំរាប់ស្រីរបាំស្រីបំរើ ។ ក្ដាន់ ប្រើស និងជ្រូកព្រៃទាំងនេះបំរុងសំរាប់កាប់បរិភោគនៅពេលដែលមិនបានទៅបរបាញ់សត្វ ។

## *គ- ជីវភាពនៅក្នុងកំផែងកែវ*

នៅក្នុងកំផែងកែវ គ្មានមនុស្សប្រុសរស់នៅទេ ក្រៅពីលោកម្ចាស់ ។ កូនប្រុសលោកម្ចាស់សុទ្ធតែមានផ្ទះនៅក្រៅ ។ ស្រីរូបស្អាតៗជាងមួយរយនាក់ត្រូវគេយកមកបង្ខាំងទុកបំរើកាមតណ្ហាលោកម្ចាស់ ។ ស្រីដែលរូបស្អាតៗជាងគេ ត្រូវលោកម្ចាស់រើសតាំងជាប្រពន្ធចុង ហៅថាម៉ម ឬហៅថាអ្នក ដូចជាអ្នកវ៉ាន អ្នកអែបអ្នកល្ម៉ាយ ។ល។ លោកម្ចាស់មានប្រពន្ធចុងប្រភេទនេះជាង ៣០ ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រពន្ធចុងប្រភេទនេះសុទ្ធតែមានបាវបំរើឆ្វេងស្តាំ មានផ្ទះមួយល្វែង ម្នាក់ៗ មានមាសពេជ្រពាក់ស្នេកស្កះ ។

នៅក្នុងកំផែងកែវ ស្រីៗមានសំលៀកបំពាក់ម្យ៉ាងប្លែកពីអ្នកនៅក្រៅកំផែង ។ គេស្លៀកសំពត់ចងក្បិន ហើយបង់កសំពត់ស្តើង ទន់ទំលាក់ចុះមកមុខ ។ គេមិនពាក់អាវទេ ទោះបីនៅផ្ទះ ឬទៅបំរើលោកម្ចាស់នៅឯតឹកពងក្រពើក៏ដោយ ។ លោកតាញ៉ឹក ហួត បានប្រាប់ថា កាលគាត់នៅពីតូច គាត់បានទៅតាមលោកគ្រូចៅអធិការវត្តសំពៅនិមន្តទៅឆាន់នៅផ្ទះលោកម្ចាស់ គាត់បានឃើញស្រីរូបស្អាតៗ ស្លៀកសំពត់ចងក្បិនក្រវាត់ខ្សែក្រវាត់ប្រាក់បង់កសំពត់ព្រៃទំលាក់មកមុខ ចេញមកបំរើ ។ ព្រះសង្ឃ ដែលនិមន្តទៅឆាន់នោះ មិនហ៊ានលួចមើលទេ ។

រាល់ថ្ងៃ ទាំងចៅហ្វាយទាំងបាវ សុទ្ធតែលែងខ្លួនទទេ ដើរចុះដើរឡើងឬសំរាកនៅតាមរានហាល ។ នេះជាពត៌មានរបស់លោកយាយអ៊ូច នៅភូមិស្វាយឆ្កេះ ដែលគាត់ឧស្សាហ៍ចេញចូលក្នុងកំផែង ព្រោះម្តាយគាត់ជាអតីតស្រីរបាំ ។ រឿងដែលអស្ចារ្យទៅទៀតគឺ រឿងដែលស្រីរបាំនិងស្រីបំរើទៅងូតទឹកនៅឯស្ទឹងរាល់ថ្ងៃនៅពេលរសៀល ។ នៅពេលចេញពីកំផែងកែវទៅនោះ ស្ត្រីទាំងហ្នឹងដើរដោយមាននាយភូឃុំបីបួននាក់ជូនដំណើរ ។ នៅពេល

www.budinst.gov.kh www.elibraryofcambodia.org

នោះ គេបិទចរាចរមួយពេល មិនឲ្យមនុស្សដើរកាត់ហ្លួងអស់អ្នកអស់នាងទេ ។ តែកាលណាបុរសណាម្នាក់ជ្រុលខ្លួនទៅសារសងសំដីជាមួយស្រីៗទាំងនោះ បុរសនោះមុខតែបានឈឺខ្លួនដោយគេចាប់យកទៅវាយរ៉ាវមិនខានឡើយ ។ គេមានធ្វើផែ ដែលជាផ្ទះបណ្តែតទឹកមួយនៅមុខវត្តសង្កែត្រើយខាងលិច សំរាប់ឲ្យអស់អ្នកអស់នាងចុះទៅងូតទឹក ។

ស្រីៗនៅក្នុងកំផែង ទោះបីជាស្រីបំរើក៏ដោយប្រពន្ធចុងក៏ដោយ មិនអាចមានសិទ្ធិទាក់ទងស្នេហាជាមួយបុរសណាមួយបានឡើយ ។ កាលណាជ្រុលជ្រួសមានកំហុសព្រោះរឿងស្នេហា មុខជាត្រូវទោសប្រហារជីវិតមិនខានឡើយដោយគេចោទថា "ពានវាំង"។ ឧទាហរណ៍ មានស្រាប់រួចមកហើយ គឺឃុន គង់ ជាប្អូនរបស់លោកម្ចាស់ដែលបានទៅទាក់ស្នេហាជាមួយស្រីរបាំ ។ លោកម្ចាស់បានឲ្យគេយក ឃុន គង់ ទៅសំលាប់ចោលដោយឥតត្រាប្រណី ។ នេះគ្រាន់តែប្អូនបង្កើតផង ។ ក៏ប៉ុន្តែ ស្រីទាំងនោះអាចសុំលោកម្ចាស់ចេញទៅនៅខាងក្រៅ ឈប់នៅក្នុងកំផែងបាន បើសិនជាគេយល់ព្រម ។

កំផែងកែវប្រៀបបាននិងគុក ដែលគេបង្ខាំងទុកស្រីៗឲ្យអស់សេរីភាពដែលសំពត់អាវ មាសពេជ្រ ប្រេងម្សៅមិនអាចទូរទាត់បាន

www.budinst.gov.kh www.elibraryofcambodia.org

ឡើយ ។ ឪពុកម្តាយជាច្រើនត្រូវរងទុក្ខទោសដោយសារលាក់កូនចៅមិនឲ្យទៅធ្វើជាស្រីរបាំក្នុងកំផែង ។ ឯជីវភាពប្រចាំថ្ងៃរបស់ស្រីទាំងនោះក៏មិនបានប្រសើរដែរ ។ រាល់ពេល គេឲ្យបរិភោគរួមគ្នាដោយមានចង្ក្រានរួម ។ ក្នុងមួយពេល គេចែកបាយមួយចាន ឲ្យបរិភោគ ជួនកាលមានទឹកគ្រឿងមួយចាននិងត្រកួនមួយបាច់ ។ ឪពុកម្តាយពិបាកចិត្តពេកក៏យកបាយពីផ្ទះឲ្យកូនរាល់ពេល ។ នេះមិននិយាយពីស្រីដែលមានថ្នាក់ជាប្រពន្ធចុង ជាម៉ែមនោះទេ ។

រាល់យប់ គេដាក់វេនឲ្យស្រីរបាំពីរបីនាក់ចូលទៅគក់ច្របាច់លោកម្ចាស់ ព្រោះលោកម្ចាស់ត្រូវការឲ្យគេគក់ច្របាច់រាល់យប់ហើយមួយយប់ទើសភ្លឺ ។ នៅពេលថ្ងៃ ស្រីរបាំហាត់រាំ ដោយមានគ្រូសៀមមកបង្ហាត់ ។ នៅពេលរៀនរាំ គ្រូបានដាក់ទណ្ឌកម្មមួលក្តិចកាច់ដៃ កាច់ជើង ឬ វាយនិងរំពាត់ផ្តៅ ។ នៅពេលសំដែងជាសាធារណៈ បើស្រីរបាំណាធ្វើកាយវិការខុសឆ្គងខ្លាំង មុខជាត្រូវរំពាត់ធ្ងន់ទៅទៀត ។

អ្នកត្រួតត្រាស្រីរបាំគឺ លោកភូវាំង ។ លោកភូវាំងមានផ្ទះដែលជាការិយាល័យផ្នែកសុរិយាដីសព្វថ្ងៃ គ្រាន់តែកែកុនបន្តិចបន្តួច ។ លោកភូវាំងមានភ្នាក់ងារច្រើនទៀតជួយមើលការខុសត្រូវគឺ ភូឃុំ ។ លោកភូវាំងជាអ្នកមើលត្រួតត្រាកិរិយាមារយាទស្រីទាំង

www.budinst.gov.kh www.elibraryofcambodia.org

អស់នៅក្នុងកំផែងកែវ ហើយគាត់មានអំណាចរហូតដល់វាយប្រពន្ធចុងលោកម្ចាស់ទៀតផង ។ ប្រពន្ធចុងលោកម្ចាស់ខ្លាចលោកភូវាំងដូចខ្លា ហើយសុទ្ធតែបានត្រូវរំពាត់លោកភូវាំងគ្រប់គ្នា លើកលែងតែលោកជំទាវអ៊ុងដែលជាប្រពន្ធធំ ។

*នេះហើយកំផែងកែវដែលជាស្ថានសួគ៌សំរាប់លោកម្ចាស់ ។*

www.budinst.gov.kh www.elibraryofcambodia.org

# ប្រពន្ធកូនលោកម្ចាស់

កាលមិនទាន់ឡើងកាន់អំណាច លោកម្ចាស់បានរៀបការជាមួយអ្នកសក់ ហើយមានកូនប្រុសមួយឈ្មោះ ឃុន ធិន ។ តែក្រោយមក លោកម៉ៅ នៅវត្តសូរភី បានយកកូនក្រមុំមួយឈ្មោះ អ៊ុង មកជូន ។ លោក ម៉ៅ បានរកអាគមគាថាស្នេហ៍យ៉ាងច្រើនដាក់លោកម្ចាស់ ។ លោកម្ចាស់ក៏តែងតាំងអ្នកស្រីអ៊ុងនេះ ជាលោកស្រី ជំទាវ ធំជាងប្រពន្ធដើមទៅទៀត ដែលគេហៅថា *លោកស្រីអ៊ុង* ។ លោកស្រីអ៊ុង ជាប្រពន្ធធំនេះមានកូនបួននាក់ គឺ*ឃុនឈឿម ឃុនលឿម ឃុនវីន និង ឃុនឈ្វង ហៅពុច* ។

នៅពេលឡើងកាន់អំណាចភ្លាម លោកម្ចាស់ក៏ចាត់ចែងរើសស្រីក្រមុំរូបស្អាតៗមកធ្វើជាស្រីរបាំ ដែលបានក្លាយម្តងមួយៗ ជាប្រពន្ធចុង ។ តាមច្បាប់ គេហៅប្រពន្ធចុងទាំងនេះថា *ម៉ម* តែរាស្ត្រខ្មែរទំលាប់តែតាមខ្លួន ហៅថា *អ្នក ៗ* ដូចជាអ្នកល្មាយ អ្នករ៉ត ។ល។ ប្រពន្ធចុងលោកម្ចាស់ មានច្រើនណាស់ប្រហែលជាង ៤០នាក់ ។ តែប្រពន្ធខ្លះមិនមានកូន បានសុំលាលោកម្ចាស់ចេញទៅនៅក្រៅកំផែង ហើយក៏មានគ្រួសារផ្សេងទៅ ។ ប្រពន្ធចុង

www.budinst.gov.kh www.elibraryofcambodia.org

ភាគច្រើនសុទ្ធតែមានកូនមួយៗ ។ តែខ្លះមិនមានកូនទេ ក៏សុខចិត្តនៅស្មោះត្រង់ជាមួយលោកម្ចាស់ រហូតដល់លោកម្ចាស់ទទួលមរណភាព ។

ដោយសារតែលោកម្ចាស់មានប្រពន្ធច្រើននេះហើយ បានជាលោកស្រី អ៊ុង កើតទុក្ខរីងរៃ ឈឺចាប់គ្មានលោះថ្ងៃណា ។ គាត់កើតជង្ងឺម្យ៉ាងគឺខ្លាច គាត់ខ្លាចសព្វខ្លាចគ្រប់ ខ្លាចជាងគេគឺសំលេងឆ្កែលូ ។ គេតែងចាត់ឲ្យវាយសំលាប់ឆ្កែទាំងអស់ ដែលលូឮដល់លោកស្រី ។ លោកព្រះឃ្លាំង ជាឪពុក បានរិះរកគ្រប់មធ្យោបាយដើម្បីព្យាបាលលោកស្រី និង បានបន់ស្រន់*ព្រះអង្គខ្មៅ* ដែលជាព្រះពុទ្ធរូបសក្តិសិទ្ធិនៅវត្តកណ្តឹង ដោយសុំសាងព្រះវិហារមួយថ្វាយបើកាលណាកូនស្រីបានធូរស្បើយ ។ លោកស្រីអ៊ុង បានធូរស្បើយបន្តិច គាត់ក៏ចាត់សាងព្រះវិហារមួយ នៅខាងត្បូងព្រះវិហារចាស់ដែលយើងឃើញសព្វថ្ងៃនេះ ។

គឺលោកស្រី អ៊ុង នេះហើយ ដែលជាអ្នកចាត់ចែងស្ថាបនាព្រះវិហារវត្តដំរីស សព្វថ្ងៃនេះ ។

តែលោកស្រីអ៊ុង មិនរស់បានយូរទេ អាការរោគប្រទាញគាត់ឲ្យទទួលមរណភាព នៅមុនពេលដែលលោកម្ចាស់ទៅបស្ចិមទៅទៀត ។ គេធ្វើបុណ្យសពលោកស្រីអ៊ុង យ៉ាងអ៊ឹកអធឹកនៅមុខវត្ត

www.budinst.gov.kh www.elibraryofcambodia.org

ដំរីស ។ លោកយាយណាមបានរាយឈ្មោះប្រពន្ធនិងកូនលោកម្ចាស់យ៉ាងច្បាស់លាស់ ដូចដែលមានចុះឈ្មោះក្នុងបញ្ជីខាងក្រោមនេះ តែក្នុងបញ្ជីនេះ មានតែឈ្មោះប្រពន្ធដែលមានកូន ឬដែលស្មោះត្រង់នឹងលោកម្ចាស់រហូតដល់ស្លាប់ មិនមានឈ្មោះប្រពន្ធដែលបានលាលោកម្ចាស់ ទៅមានប្ដីផ្សេងទេ ។

នៅពេលលោកម្ចាស់ទៅបស្ចឹម លោកម្ចាស់បានដឹកមាសពេជ្រទ្រព្យសម្បត្តិជាង១០០រទេះ ដែលលោកម្ចាស់ទារយកពីប្រជារាស្ត្រស្រុកបាត់ដំបង យកទៅទុកឯស្រុកសៀមជាសម្បត្តិផ្ទាល់ខ្លួន ។ នៅពេលមុនគាត់ទទួលមរណភាព គាត់បានចែកកេរ្តិ៍មរតកដល់កូនៗ ។

កូនទាំងបួនរបស់លោកស្រីអ៊ឹង មានផ្ទះសំបែងទ្រព្យសម្បត្តិរាប់មិនអស់ទេ ព្រោះគេជាកូនប្រពន្ធធំ ។ ឯឃុនធិន ជាកូនអ្នកសក់ ដែលស្លាប់នៅស្រែអន្ទាក់នោះ ក៏បានមរតកដែរ ហើយមរតកនេះបានធ្លាក់ទៅនាយជា ជាកូនស្រីរបស់គាត់ដែលមានផ្ទះនៅក្បែរវត្តពោធិក្នុង ។

បន្ទាប់ពីលោកស្រីអ៊ឹង គឺកូនអ្នកល្មោយទាំងបី ដែលបានទទួលប្រាក់ច្រើនជាងគេ គឺបាន ១សែនបាតក្នុងម្នាក់ៗ ។ ក្រៅពីនេះកូនដទៃទៀតបានពី ៣ទៅ ៨ម៉ឺនបាត ។ កូនខ្លះ ដូចជា ឃុនថែប ឃុន

www.budinst.gov.kh www.elibraryofcambodia.org

ខាប ឃុនឃួង ឃុនឆៀត ដែលទៅបន្តវិជ្ជានៅប្រទេសបារាំង ត្រូវកាត់ពីរម៉ឺនបាតចេញព្រោះមានចំណាយច្រើនកាលនៅរៀន ។ កូនស្រីបានមរតកតិចជាងគេ គឺបានតែបីម៉ឺនបាតទេ ។ តែឃុន ឈុបដែលឈ្លោះជាមួយម្តាយត្រូវលោកម្ចាស់កាត់កាល់ មិនចែកកេរ្តិ៍អាករឲ្យទេ ។

សូមបញ្ជាក់ថា ក្នុងចំណោមកូនលោកម្ចាស់ទាំងអស់ ឃុនឃួង (ឃួង អភ័យវង្ស) ដែលមានងារជាហ្លួងកោវិទនោះ មានចំណេះវិជ្ជានិងឋានៈខ្ពស់ជាងគេ ។ ហ្លួងកោវិទនេះជាអ្នកដឹកនាំបក្សប្រជាធិបតេយ្យជាមួយលោក សេនីយ៍ប្រាមោជ ធ្លាប់បានចូលរួមក្នុងរដ្ឋប្រហារឆ្នាំ ១៩៣២ រៀបចំឲ្យមានរដ្ឋធម្មនុញ្ញ នៅប្រទេសសៀម ហើយធ្លាប់បានឡើងឋានៈជារដ្ឋមន្ត្រីទី ១ នៅឆ្នាំ១៩៤៤-១៩៤៥ ។

www.budinst.gov.kh www.elibraryofcambodia.org

# បញ្ជីរាយនាមប្រពន្ធកូនលោកម្ចាស់កថាថន ឈុំ

| លរៀងប្រពន្ធ | នាមប្រពន្ធ | ចំនួនកូន | ឈ្មោះកូន | ភេទ | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| ១ | លោកស្រីអ៊ុង | ៤ | ឃុនឈឿម | ស្រី | |
| | | | ឃុនលឿម | ប្រុស | |
| | | | ឃុន រីន | ស្រី | |
| | | | ឃុនឈួង | ប្រុស | ហៅ ឃុន ពុច |
| ២ | អ្នក ល្មាយ | ៣ | ឃុន ឆះខ្សែម | ប្រុស | |
| | | | ឃុន កះសេម | ប្រុស | ហៅ ឃុន ហ៊ុង |
| | | | ឃុន ឆះអន | ស្រី | |
| ៣ | អ្នក សក់ | ១ | ឃុន ធិន | ប្រុស | ស្លាប់នៅស្រែអន្ទាក់ |
| ៤ | អ្នក ភិង | ១ | ឃុន ឆាយ | ប្រុស | |
| ៥ | អ្នក អែប | ១ | ឃុន ភ៊ីន | ប្រុស | ឆ្កួត ហើយស្លាប់នៅបាត់ដំបង |
| ៦ | អ្នក បួរ | ២ | ឃុន ថែប | ប្រុស | |
| | | | ឃុន ថវិន | ស្រី | ហៅ ឃុនប្រង់ |

www.budinst.gov.kh www.elibraryofcambodia.org

| | | | | | |
|---|---|---|---|---|---|
| ៧ | អ្នក ណាម | ៣ | ឃុន ភៀន | ស្រី | |
| | | | ឃុន សៈរឹង | ប្រុស | |
| | | | ឃុន ប៊ី | ប្រុស | |
| ៨ | អ្នក វ៉ាន | គ្មាន | | | |
| ៩ | អ្នក យុត | ១ | ឃុន ខាប | ប្រុស | |
| ១០ | អ្នក វ៉ត(សៀម | ១ | ឃុន ឃួង | ប្រុស | គឺ ហួងកោរិទ |
| ១១ | អ្នក យ៉ែម | ១ | ឃុន ប៉ោក | ស្រី | |
| ១២ | អ្នក លូន | ១ | ឃុន សាវ៉ាត | ប្រុស | ហៅឃុនប៉ោយ |
| ១៣ | អ្នក យឿន | ២ | ឃុន យួង | ប្រុស | |
| | | | ឃុន សា វ៉ុង | ប្រុស | ហៅ ឃុន កុយ |
| ១៤ | អ្នក ឆយ | ២ | ឃុន ឆវី | ស្រី | ហៅ ឃុន តាប់ |
| | | | ឃុន រួយ | ប្រុស | |
| ១៥ | អ្នក អ៊ុំ | ១ | ឃុនថែមស៊ុំ | ស្រី | ហៅ ឃុន ល្អង |
| ១៦ | អ្នក សន | ១ | ឃុន សៈណាង | ប្រុស | |
| ១៧ | អ្នក សង្វ៉ាន | ១ | ឃុន អុកឈើយ | ស្រី | |
| ១៨ | អ្នក វ៉ៃន | ១ | ឃុន សៈរិង | ស្រី | |
| ១៩ | អ្នកប៉ែន | គ្មាន | | | |
| ២០ | អ្នក គ្រីប | ១ | ឃុន ឈឿ | ស្រី | |

www.budinst.gov.kh www.elibraryofcambodia.org

| | | | | | |
|---|---|---|---|---|---|
| ២១ | អ្នក ម៉រ | ១ | ឃុន ឈុប | ស្រី | លោកម្ចាស់ កាត់កាល់ |
| ២២ | អ្នក វៀង | គ្មាន | | | |
| ២៣ | អ្នក វី | ១ | ឃុន ឆៀត | ប្រុស | ហៅឃុន មៅ |
| ២៤ | អ្នក គិមហោ | ១ | ឃុន នឿង | ស្រី | |

www.budinst.gov.kh www.elibraryofcambodia.org

# ដំណើរវិលមកប្រទេសខ្មែរវិញ នៃ ខេត្តបាត់ដំបង

*ឯកសារខាងក្រោមនេះ ដកស្រង់ចេញពីសៀវភៅ "បាត់ដំបងអេសុងប៉ាស់សេ "បោះផ្សាយជាភាសាបារាំងនៅឆ្នាំ ១៩៦៨ ដោយក្រសួងឃោសនាការខ្មែរ និងសៀវភៅឈ្មោះ "ឡាថៃឡង់ "និពន្ធ ដោយលោកភីសជេ បោះផ្សាយនៅក្រុងប៉ារីស ។ រីឯឯកសារជាក់ស្តែងក្នុងស្រុក ដូចជាតំណាងនៃកុងស៊ុលបារាំងនៅបាត់ដំបង ជាឯកសារនិយាយដែលទទួលពីលោកតា ឥន្ទសុន្ទរ៍ នៅភូមិផ្ទាធំ តាមដែលគាត់បានឃើញនិងបានដឹងនៅសម័យនោះ ។*

ចាប់តាំងពី ក្រោយការបាក់បែកបន្ទាយលង្វែកមក ប្រទេសខ្មែរបានថយរិទ្ធានុភាពយ៉ាងខ្លាំង ។ យួននិងសៀមគំរាមកំហែងខ្មែរជានិច្ច ។ នៅឆ្នាំ ១៧៩៤ ខេត្តបាត់ដំបងបានធ្លាក់ក្រោមការត្រួតត្រារបស់សៀម ។ ព្រះបាទអង្គដួងព្រួយបារម្ភនិងវាសនាប្រទេសខ្មែរ ក៏សុំពឹងជំនួយបារាំង ។ នៅឆ្នាំ ១៨៥៩ បារាំងបានចូលមកតាំងនៅព្រៃនគរ ហើយក្រោយមកទៀត ក៏ពង្រីកដែនអាណានិគម*កូសាំងស៊ីន លើទឹកដីកម្ពុជាក្រោម* ដែលជារបស់ខ្មែរ

www.budinst.gov.kh www.elibraryofcambodia.org

ដែលយួនកំពុងតែទន្ទ្រានយក ។

នៅឆ្នាំ ១៨៦៣ ព្រះបាទនរោត្តមបានដាក់ប្រទេសខ្មែរក្រោមអំណាចការពាររបស់បារាំង ដែលនាំឲ្យប្រទេសខ្មែរបានរួចផុតអំពីជំរៀតជំរែកសៀម និង យួន ។ នៅឆ្នាំ ១៨៦៧ ព្រះចៅសៀមសុខចិត្តទទួលស្គាល់អំណាចការពាររបស់បារាំង មកលើប្រទេសខ្មែរ តែសៀមនៅតែត្រួតត្រាខេត្តបាត់ដំបង សៀមរាប សេរី សោភ័ណ មូលព្រៃ និងទន្លេរពៅ ដដែល ។

នៅឆ្នាំ ១៨៨៣ មានអនុសញ្ញាបារាំង ខ្មែរមួយ ដាក់ប្រទេសខ្មែរក្រោមអាណាព្យាបាលរបស់បារាំង ។ ចាប់ពីពេលនោះមក ខ្មែរបានធ្លាក់ខ្លួនជាខ្ញុំកញ្ជះបារាំងពិតប្រាកដហើយ ។ បារាំងត្រូវសំរេចវាសនាខ្មែរជំនួសខ្មែរក្នុងឋានៈជាអាណាព្យាបាល ។

បារាំងមានបំណងចូលមកកាន់កាប់ខេត្តបាត់ដំបង និងសៀមរាបដោយកំលាំងទ័ព ។ ប៉ុន្តែនៅឆ្នាំ ១៨៨៦ មានឧប្បត្តិហេតុជាច្រើនរវាងបារាំងនិងសៀមនៅប្រទេសលាវ ។ បារាំងបានរុញច្រានសៀម ចេញពីភាគខាងលើនៃប្រទេសលាវ ហើយមានបំណងនឹងរំដោះ តំបន់ត្រើយខាងឆ្វេងនៃទន្លេមេគង្គដែល*ក្នុងនោះមានខេត្តទន្លេរពៅ របស់ខ្មែរ និងខេត្តចំប៉ាសក្តិ របស់លាវ ។*

នៅឆ្នាំ ១៨៩៣ កិច្ចចរចាររវាងលោក ប៉ារី ខាងបារាំងនិង

www.budinst.gov.kh www.elibraryofcambodia.org

អ្នកអង្គម្ចាស់ទេវវង្ស ខាងសៀម ត្រូវទទួលបរាជ័យ ។ បារាំងបានបញ្ជូននាវាចំបាំងពីរគ្រឿង ឲ្យវាយប្រយុទ្ធឡើងតាមទន្លេមេណាមចៅប្រះយ៉ាទៅចតនៅមុខបាងកក នៅថ្ងៃទី ៨ កក្កដា ១៨៩៣ ។ នៅថ្ងៃ ទី ២០ កក្កដា បារាំងបានផ្ញើឱសានវាទមួយទៅបង្ខំសៀម ។ ព្រះចៅសៀម*ចុឡាឡុងកន* ក៏យល់ព្រមតាមឱសានវាទរបស់បារាំងនៅថ្ងៃ ២៩ ខែឆ្នាំដដែល ។ សៀមសុខចិត្តចុះសន្ធិសញ្ញាជាមួយបារាំងនៅថ្ងៃទី ៣ខែតុលា ១៨៩៣ ដោយសុខចិត្តដកថយពីដែនដីទាំងអស់ ដែលនៅត្រើយខាងឆ្វេងនៃទន្លេមេគង្គ ។

បារាំងបញ្ជូនកងទ័ពឲ្យទៅកាន់កាប់ខេត្តសៀម ឈ្មោះ ចន្ទបុរី ដើម្បីបង្ខំសៀមឲ្យគោរពសន្ធិសញ្ញានេះ ។ តែបារាំងមិនបានទាមទារឲ្យសៀមប្រគល់ខេត្តបាត់ដំបងនិងសៀមរាបមកឲ្យខ្មែរវិញទេ ពេលនោះ ។ តែមាត្រា៣នៃសន្ធិសញ្ញានេះ បារាំងបង្ខំសៀមមិនឲ្យដាក់ទ័ពនៅតំបន់មួយដែលមានទទឹង ២៥គ ម ស្របតាមត្រើយខាងស្តាំនៃទន្លេមេគង្គ ព្រមទាំងនៅបាត់ដំបងនិងសៀមរាបទៀត ។ ដូចនេះសៀមគ្មានអំណាចតាំងទ័ព ឬសង់បន្ទាយនៅខេត្តទាំងពីរនេះទេ គឺនៅពេលនេះហើយដែលរាជការសៀមផ្តើមពង្រឹងអំណាចប៉ូលីសដើម្បីត្រួតត្រាតំបន់គ្មានកងទ័ពនៅតាមបណ្តោយផងទន្លេមេគង្គ ។

ទំនាស់មួយបានកើតឡើងក្នុងការអនុវត្តន៍មាត្រា ៤នៃសន្ធិ

www.budinst.gov.kh www.elibraryofcambodia.org

សញ្ញាឆ្នាំ១៨៩៣នេះ ដែលចែង *អំពីសិទ្ធិរបស់បារាំងក្នុងការការពារជនជាតិខ្មែរ យួន លាវ ដែលរស់នៅក្នុងដែនសៀម ។ បារាំងត្រូវការពារជនជាតិទាំងនេះតាមផ្លូវច្បាប់ កុំឲ្យមានការជិះជាន់ពីអាជ្ញាធរសៀម* ។ មាត្រា ៤នេះ ធ្វើឲ្យសៀមបាត់បង់អធិបតេយ្យផ្ទៃក្នុងយ៉ាងខ្លាំង ។ សៀមបានរិះរកគ្រប់មធ្យោបាយ ដើម្បីបំផ្លាញមាត្រា៤នេះ ដោយប្រើគ្រប់វិធីបង្ខិតបង្ខំជនជាតិខ្មែរ ដែលរស់នៅក្រោមអំណាចគេ ឲ្យប្រកាសខ្លួនជាសៀម ។ នៅឆ្នាំ ១៨៩៦ បារាំងបានបញ្ជូនស្នងការម្នាក់ឲ្យមកតាំងនៅបាត់ដំបង ក្នុងបំណងការពារសិទ្ធិរស់នៅនៃជនជាតិខ្មែរ លាវ និងយួន ។

នៅឆ្នាំ ១៨៩៧ ព្រះចៅសៀម ចុឡាឡុងកន បានយាងទៅធ្វើទស្សនកិច្ចនៅប្រទេសនានានៅទ្វីបអឺរ៉ុប មានប្រទេសរុស្ស៊ី ប្រទេសអាឡឺម៉ង់ ប្រទេសអង់គ្លេស ប្រទេសបារាំង ។ នៅក្រុងប៉ារីស ព្រះចៅចុឡាឡុងកន បានចូលទៅជួបប្រធានាធិបតីបារាំងឈ្មោះ *ភេលិច ផូរ* ស្នើសុំឲ្យបារាំងលុបចោលមាត្រា៤ នៃសន្ធិសញ្ញាឆ្នាំ ១៨៩៣នេះចេញ ។ ប្រធាននាធិបតីបារាំង *ភេលិច ផូរ* សុខចិត្តលុបមាត្រា ៤ នេះចោល បើសិនជាសៀមសុខចិត្តប្រគល់ខេត្តបាត់ដំបង សៀមរាប និងចន្ទបុរី មកឲ្យបារាំង ។

នៅឆ្នាំ ១៩០២ បារាំងបានចុះសន្ធិសញ្ញាជាមួយសៀម លុប

www.budinst.gov.kh www.elibraryofcambodia.org

ចោលសិទ្ធិការពារជនជាតិខ្មែរ យួន. លាវ ដែលមានចែងក្នុងមាត្រា ៤ នៃសន្ធិសញ្ញាឆ្នាំ ១៨៩៣ ដោយគ្រាន់តែដូរយកខេត្តមូលព្រៃនិងទន្លេរពៅ ដែលមានទំហំប្រហែល ២០.០០០គ.ម២ មកវិញ ។ តែសន្ធិសញ្ញាថ្មីនេះត្រូវមតិបារាំងរិះគន់យ៉ាងខ្លាំង ហើយក៏ខានឲ្យសច្ចាប័នទៅវិញ ។

នៅឆ្នាំ ១៩០៤ បារាំងបានបង្ខំសៀមឲ្យចុះសន្ធិសញ្ញាប្រគល់ខេត្តមូលព្រៃនិងទន្លេរពៅ មកឲ្យខ្មែរ ។ សន្ធិសញ្ញានេះ មានមាត្រាសំងាត់មួយទៀត ដែលសៀមត្រូវប្រគល់អំណាចប៉ូលីស ខេត្តបាត់ដំបង សៀមរាប និងសេរីសោភ័ណមកឲ្យបារាំង ។ ចាប់ពីពេលនោះមក គេឃើញមាននាយទាហានបារាំងចូលមកចាត់ចែងបង្ហាត់ទាហាននៅបាត់ដំបង ។ ជាមួយគ្នានោះ បារាំងសុំឲ្យសៀមប្រគល់សិទ្ធិឲ្យបារាំងស្ថាបនារួមគ្នាជាមួយសៀម នូវផ្លូវរថភ្លើងមួយពីបាត់ដំបងទៅភ្នំពេញ ។

នៅឆ្នាំ ១៩០៦ នាយករដ្ឋន្ត្រីបារាំងឈ្មោះ *ភ្លឺម៉ង់ស្វ* បានសុំបើកធ្វើការចរចារម្តងទៀតជាមួយសៀម ។ ការចរចារនេះប្រព្រឹត្តទៅដោយឥតមានការលំបាកអ្វីឡើយ ។ ការចរចារនេះ ត្រូវបញ្ចប់ដោយមានសន្ធិសញ្ញាមួយនៅថ្ងៃ **២៣ មីនា ១៩០៧** ។

តាមមាត្រា១នៃសន្ធិសញ្ញានេះ សៀមត្រូវប្រគល់ខេត្ត

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំង ទី ២៧



ព្រះបាទស៊ីសុវត្ថិ (ន.ណ)

www.budinst.gov.kh www.elibraryofcambodia.org

**បាត់ដំបង សៀមរាប និង . សិរីសោភ័ណមកឲ្យបារាំង** ហើយបារាំងក៏ប្រគល់ឲ្យសៀមវិញ នូវដែនដី**ដានសាយនិងក្រាត ព្រមទាំងកោះនានានៅខាងត្បូងជ្រោយឡែមលិងរហូតដល់ កោះគុត** ។ ការប្ដូរដែនដីត្រូវធ្វើ ២០ថ្ងៃក្រោយ ដែលសន្ធិសញ្ញា នេះត្រូវធ្វើសច្ចាប័ន ។

អគ្គទេសាភិបាលបារាំងនៅឥណ្ឌូចិន បានប្រគល់ខេត្តបាត់ ដំបង សៀមរាបនិង សិរីសោភ័ណថ្វាយព្រះមហាក្សត្រខ្មែរព្រះបាទ ស៊ីសុវត្ថិ ។

ខេត្តបាត់ដំបង ដែលធ្លាក់ក្រោមអំណាចសៀម ដោយសារតែ អំពើលោភលន់របស់ចៅហ្វាបែនពីឆ្នាំ ១៧៩៤ នោះត្រូវបានវិល មកកាន់មាតុភូមិខ្មែរវិញ *ក្នុងរាជ្យព្រះមហាក្សត្រខ្មែរព្រះបាទ ស៊ីសុវត្ថិ និង ក្នុងរាជ្យព្រះចៅសៀមព្រះរាមាទី៥ ចុឡាឡុងកន* ។

**ឆ្នាំ ១៩០៧ ជាឆ្នាំប្រវត្តិសាស្ត្ររបស់ខេត្តបាត់ដំបង ដែលបានរួចខ្លួនពីអំណាចត្រួតត្រារបស់សៀម អស់មួយ សតវត្ស** ។

www.budinst.gov.kh www.elibraryofcambodia.org

# ឯកសារបន្ថែម

*អំពី កុងស៊ុល បារាំង*

លោកតា ឥន្ទ សុន្ទរី បានផ្តល់ពត៌មានបន្ថែមអំពីកុងស៊ុលបារាំងដូចតទៅ :

«បារាំងបានមកតាំងស្ថានកុងស៊ុលរបស់ខ្លួន នៅត្រង់មន្ទីរពេទ្យស៊ីវិលសព្វថ្ងៃនេះ ។ នៅខាងមុខស្ថានកុងស៊ុល មានដងទង់មួយយ៉ាងខ្ពស់នៅមាត់ស្ទឹង បង្ហូតទង់បីពណ៌របស់ប្រទេសបារាំង ។ កុងស៊ុលបារាំងមានផ្លាស់ប្តូរញឹកញាប់ ។ តែមានកុងស៊ុលម្នាក់ក្នុងចំណោមនោះ ឈ្មោះ ប្រ៊ីក ។»

នៅភ្នំពេញ មានស្លាបនាអនុស្សាវរីយ៍មួយនៅវត្តភ្នំ ដើម្បីរំលឹកពេលដែលខេត្តបាត់ដំបង សៀមរាប និងសិរីសោភ័ណ បានវិលមកមាតុភូមិខ្មែរវិញ កាលពី ខែមីនា ១៩០៧ ។ នៅទីនោះមានចារឹករូបនិងឈ្មោះ កុងស៊ុលបារាំងម្នាក់នៅបាត់ដំបង គឺលោក ដូរូសូ ដឺ គុលសង់ ដែលបានធ្វើមរណភាពនៅបាត់ដំបងនៅឆ្នាំ ១៩០៣ ។

«កុងស៊ុលបារាំងត្រូវមានភារៈ ការពារសិទ្ធិជនជាតិខ្មែរ លាវ យួន ដែលនៅក្រោមអំណាចសៀម ។ កុងស៊ុលបារាំងបានទាមទារឲ្យដោះលែងទាសករដែលជាជនជាតិខ្មែរ ដោយត្រូវគិតឈ្នួល

www.budinst.gov.kh www.elibraryofcambodia.org

ជាប្រាក់៤រៀលក្នុងមួយឆ្នាំ ឬមានជូនកាលកុងស៊ុលបារាំងនេះចេញប្រាក់លោះទាសករឲ្យរួចខ្លួនតែម្តង ។ មានជនជាតិខ្មែរជាច្រើនដែលជាទាសករត្រូវគេធ្វើបាបបានរត់មកពឹងកុងស៊ុលឲ្យជួយខ្លួន ។ អ្នកដែលប្រគល់ខ្លួនឲ្យបារាំងការពារ សុទ្ធតែមានប័ណ្ណសំគាល់ខ្លួនហើយឈប់បង់ពន្ធដារឲ្យលោកម្ចាស់ទៀតហើយ ។

លោកម្ចាស់មិនសប្បាយចិត្តនិងតំណាំងស្ថានកុងស៊ុលបារាំងនេះទេព្រោះរាជការសៀមត្រូវបាត់បង់អធិបតេយ្យភាពយ៉ាងខ្លាំង ។ លោកម្ចាស់បានប្រើល្បិចផ្សេងៗ បង្ខំខ្មែរនៅបាត់ដំបងឲ្យប្រកាសខ្លួនជាសៀម ។ សៀមខំបើកសាលារៀនដើម្បីឲ្យខ្មែរចេះនិយាយសៀមឲ្យបានច្រើនគ្នា ។ លោកម្ចាស់បានហាមប្រាមរាស្ត្រប្រជាមិនឲ្យទាក់ទងរាប់អានកុងស៊ុលបារាំង ។ លោកម្ចាស់បានចាត់ឲ្យគេសម្លាប់ព្រះភិនិត្យសម្បត្តិ អ៊ុយ ដែលចចេសទាក់ទងរាប់អានកុងស៊ុលបារាំង ។ លោកយាយ អ៊ុច ដែលជាភរិយារបស់ព្រះភិនិត្យសម្បត្តិ អ៊ុយនេះ បានសាងធម្មមន្ទីរមួយនៅវត្តពោធិវាលដែលជាបណ្ណាល័យនិងជា ទីស្នាក់ការសមាគមអ្នកស្រាវជ្រាវឯកសារ ខេត្តបាតដំបង។

*អំពីនាយទាហានបារាំង*

តាមសន្ធិសញ្ញាបារាំង សៀមចុះថ្ងៃទី១៣ កុម្ភៈ ១៩០៤ សៀម

www.budinst.gov.kh www.elibraryofcambodia.org

បានប្រគល់ខេត្តម្លូព្រៃ និងខេត្តទន្លេរពៅមកឲ្យខ្មែរ ។ តាមសន្ធិសញ្ញានេះមានមាត្រាសំងាត់មួយ ដែលសៀមសុខចិត្តប្រគល់អំណាចប៉ូលីស នៅបាត់ដំបង សៀមរាប និងសិរីសោភ័ណ ឲ្យមកនាយទាហានបារាំង ។

ចាប់តាំងពីពេលនោះមក អ្នកស្រុកបាត់ដំបងបានឃើញបារាំងចូលមកបង្ហាត់ទាហាននៅបាត់ដំបង ។ ទីបញ្ជាការរបស់នាយទាហានបារាំង នៅពេលនោះ តាំងនៅខាងមុខសាលាសង្កាត់ស្វាយប៉ោ គឺខាងកើតវត្តកំផែងសព្វថ្ងៃនេះ ។

លោកតា ឥន្ទ សុន្ទរី បានប្រាប់ថា នាយទាហានបារាំងមានគ្នា ៥នាក់ហើយមេធំឈ្មោះ *ប៉ុងសូ* ។ នៅពេលមកដល់ដំបូង នាយទាហានបារាំងទាំងនេះ ចាប់ផ្ដើមជ្រើសរើសខ្មែរឲ្យធ្វើទាហាន ។ ទាហានដែលជ្រើសរើសទាំងអស់មានចំនួនប្រហែល ១០០នាក់ គឺទាហានសេះ ៦០នាក់ ទាហានថ្មើរជើងប្រហែល ៤០នាក់ ។ ទាហានទាំងអស់សុទ្ធតែជាជាតិខ្មែរ មានកំណើតនៅបាត់ដំបង ។ លោកម្ចាស់ មិនសប្បាយចិត្តនិងវត្តមាននៃនាយទាហានបារាំងនេះទេព្រោះម្យ៉ាងលោកម្ចាស់ ត្រូវបាត់បង់អធិបតេយ្យភាព ហើយម្យ៉ាងទៀត លោកម្ចាស់ត្រូវមានភារកិច្ចចញ្ចឹមប្រាក់ខែនាយទាហាននិងពលទាហាននេះទៀត ។ នាយទាហានបារាំងត្រូវបានប្រាក់ខែ ១០០

www.budinst.gov.kh www.elibraryofcambodia.org

បាតក្នុងមួយខែ ។ ឯទាហានខ្មែរ បើជាកាប៉ូរ៉ាល់ ត្រូវបាន ៩រៀល ក្នុង ១ ខែ បើជាកូនទាហានត្រូវបាន ៧រៀលក្នុង ១ខែ ។

ឆ្នាំ ១៩០៧ ខេត្តបាត់ដំបង សៀមរាបនិងសេរីសោភ័ណ ត្រូវបានរួចពីការត្រួតត្រារបស់សៀម តែវិលចូលមកមាតុភូមិខ្មែរដែលជាអាណាព្យាបាលរបស់បារាំង ។

www.budinst.gov.kh www.elibraryofcambodia.org

# ក្រោយលោកម្ចាស់នៅបស្ទិម

តាមសន្ធិសញ្ញាថ្ងៃទី ២៣ មីនា ១៩០៧ សៀមត្រូវប្រគល់ខេត្តបាត់ដំបង សៀមរាបនិង សិរីសោភ័ណមកឲ្យខ្មែរវិញ ។-ការប្រគល់ខេត្តទាំងនេះត្រូវធ្វើ ២១ ថ្ងៃក្រោយដែលសន្ធិសញ្ញានេះបានទទួលសច្ចាប័ន ។ គេមានធ្វើពិធីប្រគល់ជាផ្លូវការនៅក្នុងកំផែងបាត់ដំបងនេះ ដោយមានមន្ត្រីបារាំងមកទទួល ។ បារាំងបានសុំឲ្យលោកម្ចាស់នៅធ្វើជាស្ដេចត្រាញ់បន្តនៅបាត់ដំបង សៀមរាប និងសិរីសោភ័ណ ទៅទៀតដែរ តែលោកម្ចាស់មិនព្រម ។ គាត់ក៏រៀបចំជញ្ជូនទ្រព្យសម្បត្តិជាងមួយរយរទេះគោ ដឹកប្រពន្ធកូនទៅរស់ឯបស្ចឹមបុរី ។ គាត់ត្រូវលក់ផ្ទះសំបែងទាំងអស់នៅបាត់ដំបងមានសណ្ឋាគារខេត្តសព្វថ្ងៃនេះជាដើមឲ្យបារាំង ។

ទៅដល់បស្ទិម គាត់បានសាងវិមានមួយទៀត មានប្លង់ដូចសណ្ឋាគារខេត្តបាត់ដំបងដែរតែដោយសារស្ថាបនាក្រោយ ក៏មានក្បាច់ក្បូរសមល្អជាង ។

អគ្គទេសាភិបាលបារាំងបានចេញក្រិត្យប្រគល់ខេត្ត បាត់ដំបង សៀមរាប និងសិរីសោភ័ណ មកថ្វាយព្រះមហាក្សត្រខ្មែរ "អារេតេ

www.budinst.gov.kh www.elibraryofcambodia.org

ចុះថ្ងៃទី ២២ ធ្នូ ១៩០៧ ។

ក្រោយដែលលោកម្ចាស់ទៅបស្ចិមនោះ ទាហាននិងមន្ត្រីបារាំងខ្មែរ បានចូលមកកាន់កាប់ត្រួតត្រាខេត្តនេះ ។ នៅបាត់ដំបងមិនមានឧប្បត្តិហេតុកើតឡើងទេ តែនៅមង្គលបុរីមានប្រជារាស្ត្រមួយពួក បានងើបបះបោរតតាំងជាមួយបារាំងយ៉ាងខ្លាំង ។ ពួកគេបានចូលកាន់កាប់ប្រៃសណីយ៍ទូរលេខ ទូរស័ព្ទ វាយកំទេចអាគាររដ្ឋបាល ទប់ទល់និងទ័ពបារាំង ។ គេមិនស្គាល់ឈ្មោះអ្នកដឹកនាំពិតប្រាកដនៃការបះបោរនេះទេ ។ ការវាយប្រយុទ្ធគ្នាក៏កើតនៅត្រង់ប្រឡាយហ្លួង បណ្តាលឲ្យមានស្លាប់អ្នកស្រុកខ្លះ និងព្រះសង្ឃពីរអង្គនៅវត្តពោធិហ្លួង ។ អ្នកស្រុកមានតែអាវុធបុរាណគឺ កាំភ្លើងថ្ម ដាវលំពែងមិនអាចទប់ទល់នឹងទ័ពបារាំងដែលប្រដាប់ដោយអាវុធទំនើបបញ្ជាដោយ*វរសេនីយឯកកាំពីស្រ្តុង* នោះទេ ។ ការបះបោរក៏សាបរលាបទៅ ។

តែនៅពេលនោះដែរ ក៏មានការបះបោរកើតនៅតំបន់ភ្នំក្រវាញ ដឹកនាំដោយ *វិរសេសញ៉ូវ និង គ្រូញូវ* ។ បារាំងបានលើកទ័ពដោយមានអាវុធទំនើប មានសេះអូសកាំភ្លើងធំទៅវាយកំទេចការបះបោរនោះ ។

តើប្រជារាស្ត្របះបោរដោយសារស្រឡាញ់លោកម្ចាស់ ឬ ក៏

www.budinst.gov.kh www.elibraryofcambodia.org

ដោយសារមិនចង់ធ្វើជាអាណានិគមបារាំង ?

ដើម្បីបន្ធូរទឹកចិត្តអ្នកស្រុកបាត់ដំបង រដ្ឋការបារាំងបានតាំងលោក*អេម អរុណ* ដែលជាកូនអ្នកម្ចាស់ឃ្លំបនិងជាក្មួយលោកម្ចាស់ឲ្យធ្វើជាចៅហ្វាយខេត្តបាត់ដំបង អស់មួយរយៈពេល ដោយមាន*រេស៊ីដង់បារាំង* ម្នាក់នៅអមត្រួតពិនិត្យ ។ តែក្រោយមក បារាំងបានលើកលោកអរុណឲ្យឡើងឋានៈជា*អាំងស្ប៉ិចទ័រ* ឲ្យត្រួតត្រាកិច្ចការទាំងអស់ រួចគេតាំងចៅហ្វាយខេត្តមួយថ្មីឡើង ។ ព្រះបាទស៊ីសុវត្ថិបានតាំងលោក អរុណឲ្យមានឋានៈជាឧកញ៉ាអធិបតីសេនា។

អ្នកបាត់ដំបងស្រឡាញ់លោក អរុណ នេះណាស់ គេហៅថា *លោកចៅហ្វាយចាស់ ឬលោកចៅហ្វាយអធិបតី* ។

ជាមួយគ្នានេះ *លោកសក្តិបីអ៊ុំ* បានចូលមកកាន់កាប់កិច្ចការនៅបាត់ដំបង ។ គឺលោកសក្តិបី អ៊ុំ នេះហើយដែលជាអ្នកបើកផ្លូវនានាក្នុងខេត្តបាត់ដំបង ។

លោកសក្តិបី អ៊ុំ ជាមនុស្សអង់អាចហើយកាចណាស់ ។ គាត់ធ្លាប់រៀនសាលាចំបាំងនៅប្រទេសបារាំង ។ មានតែគាត់ម្នាក់នេះទេដែលហ៊ានវាយបារាំង ដោយឥតមានទោស ។ គាត់វាយទាត់ធាក់មនុស្ស ទាំងខ្មែរទាំងបារាំង ។ នៅបាត់ដំបង គាត់បានធ្វើភូមិមួយយ៉ាងធំ នៅក្បែរវត្តកំពង់សីមា ដែលសព្វថ្ងៃគេហៅថាភូមិសក្តិបី ។

www.budinst.gov.kh www.elibraryofcambodia.org

ក្រោយដែលលោកម្ចាស់ទៅបស្ចិម បានប៉ុន្មានខែ ព្រះបាទស៊ីសុវត្ថិបានយាងមកធ្វើទស្សនកិច្ចនៅបាត់ដំបង ។ ព្រះអង្គសំណាក់នៅវត្តសង្កែ ដោយចាត់ឲ្យមានសំដែងល្ខោនព្រះរាជទ្រព្យជូនសាធារណជនទស្សនាជាច្រើនថ្ងៃ ។ បន្ទាប់មក ព្រះបាទស៊ីសុវត្ថិក៏យាងទៅទស្សនាមង្គលបុរី សិរីសោភ័ណ និង សៀមរាបទៀត ។

នៅរវាងឆ្នាំ ១៩១០ រដ្ឋការបារាំងបានចាត់ចែងរៀបចំទីក្រុងដោយរុះរើកំផែងចោលអស់មួយភាគធំ ហើយទុកតែបន្តិចសំរាប់ធ្វើជញ្ជាំងខាងជើងនៃបន្ទីរឃុំឃាំង ។ គេបានចាត់ចែងធ្វើផ្លូវនានាក្នុងក្រុង ។ គេស្ថាបនាផ្សារអំពីដែកត្រង់ផ្សារស្វាយប៉ោដែលក្រោយមក គេយកមកសង់ជាផ្សារលើសព្វថ្ងៃនេះ ។ វត្តកំផែងត្រូវផ្លាស់កន្លែងថយទៅខាងលិច ត្រង់ទីកន្លែងសព្វថ្ងៃ ។ គេដេញផ្ទះដែលនៅមុខកំផែង និង មាត់ស្ទឹងឲ្យទៅតាំងនៅទីផ្សេង ។

ខេត្តបាត់ដំបងបានទទួលការប្រែប្រួលយ៉ាងខ្លាំងទាំងរដ្ឋបាលទាំងសេដ្ឋកិច្ចនៅពេលដែលបារាំងចូលមកកាន់កាប់ ។

www.budinst.gov.kh www.elibraryofcambodia.org

# ឯកសារពិគ្រោះ

**ឯកសារជាភាសាខ្មែរ .-**

- ឯកសារមហាបុរសខ្មែរ របស់លោក អេង សុត
- គតិលោក និពន្ធដោយឧកញ៉ាសុត្តន្តប្រីជា ឥន្ទ
- ចំបាំងតាកែនៅភ្នំក្រវាញ និពន្ធដោយឧញ៉ាសុត្តន្តប្រីជា ឥន្ទ
- ប្រជុំរឿងព្រេងខ្មែរ ភាគ ៦ របស់ពុទ្ធសាសនបណ្ឌិត្យ

**ឯកសារជាភាសារបារាំង .-**

1886 Brien, J.
"Apercu sur la province de Battambang," *Excursions et reconnaissances*, XI (Reproduced as "Notice sur la province de Battambang," La revue indochinoise, Hanoi: Imp. d'Extrême-Orient, 1906).

1968 Cambodian Ministry of Information
*Battambang et son passe.*

1962 Coedès, Georges
*Les peuples de la péninsule Indochinoise*. Paris: Dunod

Dam, Chhoeun
*Essai sur les recherches archéologiques de la province de Battambang.*

1880 Delaporte, L.
*Voyage au Cambodge. L'Architecture Khmère.*

www.budinst.gov.kh www.elibraryofcambodia.org

Paris: Librairie Ch. Delagrave.

1961 Delvert, Jean
*Le paysan cambodgien*. Le Monde d'Outre-Mer, Passé et Présent, Premier Série, Etudes, No. X. Paris: Mouton.

1 Fisher,
La Thailande. Paris.

1872 Garnier, F.
"Chronique royale du Cambodge," *Journal Asiatique*, octobre-décembre 1871 and août-septembre 1872.

1873 Garnier, F.
*Voyage d'exploration en Indochine*, 2 vols. Paris.

1957 Giteau, Madeleine
*Histoire du Cambodge*. Paris: Didier.

1961 Meunier, Achille D.
*Histoire du Cambodge*. Paris.

1872 Mouhot, Henri
*Voyage dans les Royaumes du Siam, du Cambodge, du Laos*. Paris: Hachette.

1898 Pavie, A.
*Mission Pavie, Indochine (1879-1895)*, 2 vols. Paris.

www.budinst.gov.kh www.elibraryofcambodia.org

ឯកសារភាសាសៀម.-

- ប្រវត្តិចៅពញាបតិន្ទ្រតេជា

- ប្រជុំចុតហ្មាយ ទាក់ទងថៃនិងយួន ក្នុងរជ្ជកាលទី ៣

ឯកសារនិយាយ .-

១- ព្រះឧត្តមប្រាជ្ញាចារ្យ អ៊ុំ សុខ វត្តតាម៉ិម កើតឆ្នាំ ១៨៩១ ព្រះជន្ម ១៧ វស្សា នៅឆ្នាំ ១៩០៧ ។

២- លោកយាយ ឈីន កើតឆ្នាំ ១៨៨១ នៅភូមិទួលតាឯក អាយុ២៧ឆ្នាំ នៅឆ្នាំ១៩០៧ ។ គាត់ជាប្អូនជីដូនមួយលោកម្ចាស់ ។

៣- លោក លិម ស៊ុត នៅភូមិវត្តកណ្ដឹង កើតឆ្នាំ ១៨៨៤ អាយុ២៤ឆ្នាំ នៅឆ្នាំ ១៩០៧ធ្លាប់តាមលោកម្ចាស់ទៅបស្ចិម ។

៤- លោក ដុស ដែង កើតនៅឆ្នាំ ១៨៨៤ នៅភូមិវត្តគរ អាយុ ២៤ឆ្នាំ នៅឆ្នាំ១៩០៧ ។ គាត់ជាក្មួយលោកស្រីអ៊ីង ប្រពន្ធធំលោកម្ចាស់ ។

៥- លោក ហ៊ុន ជា កើតឆ្នាំ ១៨៨៦ អាចារ្យវត្តគរ អាយុ ២១ឆ្នាំ នៅឆ្នាំ ១៩០៧ ។ គាត់ធ្លាប់បានរៀនសៀមនៅសាលា វត្តពិភិទ្ធហើយបានទៅនៅបាងកកដោយសំណាក់នៅផ្ទះលោក ម្ចាស់នៅសង្កាត់មួយឈ្មោះ យ៉ុតសេ តាំងពីឆ្នាំ ១៩០៦ ។

៦- លោក ញ៉ឹក ហួត កើតឆ្នាំ ១៨៨៦ នៅកំពង់ឆ្លង សង្កាត់ ឈើទាល អាយុ ២២ឆ្នាំ នៅឆ្នាំ១៩០៧ ។

www.budinst.gov.kh www.elibraryofcambodia.org

៧- លោកយាយ អុំ កើតឆ្នាំ ១៨៨៧ នៅភូមិវត្តកណ្ដឹង អាយុ២១ ឆ្នាំ នៅឆ្នាំ ១៩០៧ ។ ឪពុកធំគាត់មានងារជា ឃុន សានក្តីកិច្ចនៅសម័យលោកម្ចាស់ ។

៨- លោក សួន សាន កើតឆ្នាំ ១៨៨៧ នៅក្បែរវត្តក្តាំងងារអាយុ ២១ ឆ្នាំ នៅឆ្នាំ ១៩០៧ ។

៩- លោក រស់ ប៊ុត កើតឆ្នាំ ១៨៨៨ នៅភូមិស្វាយឆ្កេះ សង្កាត់វត្តគរ អាយុ ២០ឆ្នាំ នៅឆ្នាំ ១៩០៧ ។ គាត់ធ្លាប់បាន បំរើ គក់ច្រចាច់លោកម្ចាស់នៅពេល បរបាញ់សត្វ ។

១០- លោក ណិប ចាន់ កើតឆ្នាំ ១៨៩០ ប្រធានគណៈកម្មការវត្តគរ អាយុ ១៨ឆ្នាំ នៅឆ្នាំ ១៩០៧ ។

១១- លោក អរុណ រ៉ុក កើតឆ្នាំ ១៨៩០នៅសង្កាត់ស្វាយប៉ោ អាយុ ១៨ឆ្នាំ នៅឆ្នាំ១៩០៧ ។ គាត់ជាចៅរបស់អ្នកម្ចាស់ឃ្លិប ។

១២- លោកយាយ ម៉ៅ យុត កើតឆ្នាំ ១៨៩០ នៅភូមិនរា អាយុ ១៨ឆ្នាំ នៅឆ្នាំ១៩០៧ ។ គាត់ជាក្មួយលោកស្រីអ៊ឹង ប្រពន្ធធំលោកម្ចាស់ ។

១៣- លោកយាយ បឿ កើតឆ្នាំ ១៨៩១ នៅភូមិពាមឯក អាយុ ១៩ឆ្នាំ នៅឆ្នាំ ១៩០៧ ។

១៤- ព្រះហាកិម ហាជ្បី សុខៃម៉ាន់ កើតឆ្នាំ ១៨៩០នៅ ភូមិនរា ជាសង្ឃរាជអ៊ិស្លាមតាំងពីសម័យលោកម្ចាស់ ។

១៥- លោក ប៊ុល យ៉ត កើតនៅឆ្នាំ ១៨៩២ នៅភូមិវត្តកណ្ដឹងអាយុ ១៦

www.budinst.gov.kh www.elibraryofcambodia.org

ឆ្នាំនៅឆ្នាំ ១៩០៧ ។ ឪពុកមាគាត់ជាព្រានដៃស្តាំរបស់លោកម្ចាស់

ហៅព្រានជំនិត ។

១៦- លោក គង់ ភាក់ កើតឆ្នាំ ១៨៩២ នៅភូមិត្បាល់គិន ក្បែរវត្តសួរភី ។

ឪពុកគាត់ជាអ្នកភ្លេង ក្នុងវង់ភ្លេងលោកម្ចាស់ ។ ខ្លួនគាត់ក៏ជាអ្នកភ្លេងដែរ ។

១៧- លោក ឥន្ទ សុន្ទរ៍ កើតឆ្នាំ ១៩៨៣ នៅភូមិថ្នាធំ អាយុ ១៤ឆ្នាំ នៅឆ្នាំ

១៩០៧ ។ ឪពុកគាត់មានទីជាហ្លួងវិចិត្រវោហារជាទីប្រឹក្សារបសលោកម្ចាស់

ដែលថ្ងៃក្រោយមកឡើងឋានៈជាឧកញ៉ាសុត្តន្តប្រីជា ឥន្ទ នៅពេលខេត្ត

បាត់ដំបង បានមកខ្មែរ ។

១៨- លោកយាយ ចាន់ អ៊ូច កើតឆ្នាំ ១៨៩២ នៅភូមិស្វាយឆ្កេះ អាយុ

១៤ឆ្នាំនៅឆ្នាំ ១៩០៧ ។ ម្តាយគាត់ ជាអតីតស្រីរបាំ ។

១៩- លោក ឌុក មៀន កើតឆ្នាំ ១៨៩៤ នៅភូមិវត្តបាឡាត់ អាយុ ១៣ឆ្នាំ

នៅឆ្នាំ១៩០៧ ។ ឪពុកគាត់មានងារជា ហ្លួងពិភក្តិចិន្តានៅសម័យលោកម្ចាស់ ។

២០- លោក ម៉ិល អឿ កើតឆ្នាំ ១៨៩៤ នៅភូមិវត្តកណ្តឹង អាយុ ១៣ឆ្នាំ នៅឆ្នាំ

១៩០៧ ។ បងគាត់ជាស្រីរបាំ ក្នុងកំផែងកែវ

២១- លោក អ៊ាប អេងតឹក កើតឆ្នាំ ១៨៩៤ នៅមុខស្ពានកុមារអាយុ ១៣ឆ្នាំ

នៅឆ្នាំ ១៩០៧ ។

**អ្នកជួយផ្តល់ឯកសារ .-**

- ព្រះវនរ័ត ប៊ុណ្យ សម្ភាជ មេគណខេត្តបាត់ដំបង

www.budinst.gov.kh www.elibraryofcambodia.org

- ព្រះគ្រូសិរីសត្ថា កែវ សាង អនុគណស្រុកបាត់ដំបង
- ព្រះគ្រូវិន័យធរអនុគណស្រុកសង្កែ ព្រះនាម ស្រី ពេជ វត្តបាឡាត់
- ព្រះគ្រូសាសនភិរត កែ ម៉ូ វត្តស្វាយភី
- ព្រះគ្រូចៅអធិការវត្តកំពង់សីមា ព្រះនាម ម៉ៀន ចៀច
- ព្រះគ្រូចៅអធិការវត្តសង្កែ ព្រះនាម មិន ប៊ិន
- លោក សោម សំអ៊ិន វិទ្យាល័យ អ៊ាប យុត
- លោក កុល យឿត វិទ្យាល័យ នេត យ៉ង់
- លោក ហង់ សុទ្ធិរិទ្ធ វិទ្យាល័យ បាត់ដំបង
- លោក ម៉ៅ វិន ការិយាល័យភូមិភាគទេសចរណ៍បាត់ដំបង
- លោក ហ៊ុន ស៊ុផាន វិទ្យាល័យ នេត យ៉ង់
- ឃុន អរុណ ជឿយ សិង្ហសេនីយ៍ វត្តកំផែង
- ឃុន អរុណ ថវិន សិង្ហសេនីយ៍ ផ្លូវលេខ ២កន្លះ
- លោក ម៉ូវ កាក់ ភូមិកំពង់សីមា
- លោក គង់ ឆាត ភូមិកំពង់សីមា
- លោក ញ៉ុញ ឡឹត នៅមង្គលបុរី
- លោក យ៉េង យ៉េន ភូមិខ្ពិត ក្បែរវត្តកាំងងារ
- អ្នកស្រី យ៉ង បូ នាមដើម កុយរ៉ា ស៊ុ ភូមិវត្តសំពៅ
- លោកឡូរ ងៃ នាយការិយាល័យភូមិភាគទេសចរណ៍ ប៉ៃលិន

www.budinst.gov.kh www.elibraryofcambodia.org

- លោក ម៉ៅ ខាន់ ផ្លូវឡាអេ
- លោក ប៉ក់ ស៊ីវីវឌ្ឍ វិទ្យាល័យស្វាយប៉ោ
- លោក តូច ឈឿង ភូមិស្វាយឆ្អេះ សង្កាត់វត្តគរ
- លោក ហុង ឃុត ភូមិស្វាយឆ្អេះ សង្កាត់វត្តគរ
- លោក ដើក វ៉ាន់ នៅបង្គួលបុរី
- លោក ពាញ សាវី នៅបង្គលបុរី
- លោក ញ៉ុក ជីង នៅបង្គលបុរី
- លោក សេម ឃុត នៅបង្គលបុរី
- លោក ដែង ឈ្មោង នៅបង្គលបុរី
- លោក កែវ ស៊ៀប នៅបង្គលបុរី
- លោក ឈាង ប៊ុត នៅបង្គលបុរី
- លោក ផាច យ៉ាន ចៅសង្កាត់ឬស្សីក្រោក ស្រុកបង្គលបុរី
- លោក វិន វ៉ាន់ឌី នៅបង្គលបុរី អតីតតំណាងរាស្ត្រ
- ឧបាសិកា ចំរើន ណម វត្តខ្ទមតាឯក
- ឧបាសិកា ឈុត ម៉្លិច ភូមិស្វាយឆ្អេះ
- កញ្ញា ប៊ុក ក្រអូប ភូមិវត្តសួរភី
- អ្នកស្រី កែវ លៀប ភូមិស្វាយឆ្អេះ
- អ្នកស្រី សក់ សន្ទឹង នាមដើម ប៉ក់អឿប នៅផ្សារលើ

www.budinst.gov.kh www.elibraryofcambodia.org

- លោក យ៉ុក សូផា វិទ្យាល័យ នេតយ៉ង់
- លោក ឌុក មៀនសូភុន វិទ្យាល័យ នេតយ៉ង់
- លោក ប៉ក់ ស៊ីរីវឌ្ឍ វិទ្យាល័យ នេតយ៉ង់
- លោក ម៉ែន ភីន វិទ្យាល័យ នេតយ៉ង់
- លោក ហុក ងីន វិទ្យាល័យ នេតយ៉ង់
- លោក លោត លោនហ៊ីរ វិទ្យាល័យ បាត់ដំបង
- លោក ឌី សាវើណា វិទ្យាល័យ អ៊ាប ឃុត
- លោក ង៉ែត សុន វិទ្យាល័យ បាត់ដំបង
- លោក គាន គិមលៀង វិទ្យាល័យ នេតយ៉ង់
- លោក អ៊ិត ហៀបងន់ វិទ្យាល័យ នេតយ៉ង់
- លោក អ៊ួងហ៊ិម វិទ្យាល័យ អ៊ាប ឃុត
- លោក បាយ សំអាត វិទ្យាល័យ អ៊ាប ឃុត
- លោក ស៊ាង ជិនឡាក់ វិទ្យាល័យ មោងឫស្សី
- លោក ថ្វី ឈាងហួត វិទ្យាល័យ នេតយ៉ង

## អ្នកផ្តល់រូបភាព

ក. ម. = ព្រះគ្រូ កែ ម៉ូ វត្តសូរភី

គ. ហ. = លោក គាន គិមលៀង

គ. ច. = លោក គ្រី ចំរើន

www.budinst.gov.kh www.elibraryofcambodia.org

ឃ.ស = លោក ឃឹម សុគីន

ជ. ឡ. = បណ្ឌិត ជូ នី ខ្សែដង់រ៉ូដ

ញ. ឡ = លោក ញ៉ុញ ឡឺត

ន. ណ. = ឯកឧត្តម នុត ណារ៉ាង

ត. ឈ. = លោក តូច ឈឿង

ម. ត. = ឯកឧត្តម មីសែល ត្រាណេ

ម. ម. = ព្រះគ្រូ មៀន មៀច វត្តកំពង់សីមា

ម. ក. = លោក ម៉ូរ៉ា កាក់

អ. គ = លោក អ៊ុំ គង់ (កែសំរួលដោយលោក

យិន សំអែល និង កញ្ញា ជា ផល្លីណា)

អ. ជ. = ឃុន អរុណ ជឿយ សិង្ហសេនីយ

អ. ស. = លោក អ៊ិន ស៊ីយ៉ុន្ដា

ឥ. ស. = លោក ឥន្ទ សុន្ទរ៍

តូច ឈឿង

www.budinst.gov.kh www.elibraryofcambodia.org

# មាតិការឿង

១ ចៅហ្វាបែន..................................................................
២ មួយសតវត្សក្រោមអំណាចគ្រួសារចៅហ៊្វាបែន.................
៣ ចំបាំងតាកែ នៅតំបន់ភ្នំក្រវាញ......................................
៤ ទឹកដីនិងមនុស្សនៅមុនឆ្នាំ ១៩០៧..................................
៥ របបគ្រប់គ្រង.................................................................
៦ ជីវភាពសេដ្ឋកិច្ច ..........................................................
៧ ជីវភាពសិល្បៈ...............................................................
៨ ជីវភាពវប្បធម៌..............................................................
៩ លោកម្ចាស់...................................................................
១០ កំផែង និងជីវភាពក្នុងកំផែង.......................................
១១ ប្រពន្ធកូនលោកម្ចាស់.................................................
១២ ដំណើរវិលមកកាន់ប្រទេសខ្មែរវិញ................................
១៣ ក្រោយលោកម្ចាស់ទៅបស្ចិម.........................................
១៤ ឯកសារពិគ្រោះ.........................................................

www.budinst.gov.kh www.elibraryofcambodia.org

អ្នករៀបចំទំព័រ
កញ្ញា វ៉ីង សុគន្ធនីកា

បោះពុម្ពលើកទី ២
រក្សាសិទ្ធិគ្រប់យ៉ាង
c Cedoreck, Phnom Penh.1994

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org



## បាត់ដំបងសម័យលោកម្ចាស់

ជាប្រវត្តិសាស្ត្រសង្គមនៃខេត្តបាត់ដំបងដែលនៅក្រោមអំណាចសៀម

អស់មួយសតវត្ស (១៧៩៥-១៩០៧)

ក្របខាងមុខ : លោកម្ចាស់កថាថន ឈុំ (ឆ.ណ)

និងវិមានរបស់លោកស្ថាបនានៅឆ្នាំ ១៩០៥ (ត.ល)

ក្របខាងក្រោយ : អនុស្សាវរីយ៍នៃការវិលត្រឡប់នៃខេត្តបាត់ដំបង សៀមរាប

និងសេរីសោភ័ណ មកប្រទេសកម្ពុជាវិញ នៅឆ្នាំ ១៩០៧ (ឆ.ណ

www.budinst.gov.kh www.elibraryofcam...

៧០០០៦